# កម្រងអត្ថបទនីតិវិធី
# បំពេញបែបបទបញ្ចេញទំនិញពីគយ



ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
ខែតុលា ឆ្នាំ២០១៥

# កម្រងអត្ថបទនីតិវិធី
# បំពេញបែបបទបញ្ចេញទំនិញពីគយ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

ខែតុលា ឆ្នាំ២០១៥

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

លេខ : ៧៩០ អគរ

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥

## លិខិតបង្គាប់ការ

## អគ្គនាយក
## អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគយ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងសារាចរលេខ ០០១ សរ.សហវ.គរ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការគ្រប់គ្រងមន្ត្រីរាជការគយនិងរដ្ឋាករ
- យោងប្រកាសលេខ ៣៨៩ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពមូលដ្ឋាន នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- យោងតម្រូវការ និងការងារចាំបាច់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា



អាសយដ្ឋាន: លេខ ៦-៨ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ / ទូរសារ: (៨៥៥-២៣) ២១៤ ០៦៥ / ៧២៥ ១៨៧ / ២១២ ៤៥៧ / E-mail: info-pru@customs.gov.kh

# **បទ្ចាប់**

**ប្រការ ១.-**

បង្កើតក្រុមការងារចងក្រងសៀវភៅនីតិវិធីបញ្ចេញទំនិញ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១. | លោក **ផាំ អេងវ៉េង** | អនុប្រធាននាយកដ្ឋានរបបគយ | ប្រធាន |
| ២. | លោក **សុខ សុវិទ្យា** | អនុប្រធាននាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ | អនុប្រធាន |
| ៣. | លោក **អ៊ុក គីមសៀ** | ប្រធានការិយាល័យគយនិងរដ្ឋាករ ប្រចាំតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ | សមាជិក |
| ៤. | លោក **ឈុន ទឿន** | ប្រធានការិយាល័យរដ្ឋបាលនិងគ្រប់គ្រង នៃសាខាគយនិងរដ្ឋាករ អាកាសយានដ្ឋានអន្តរជាតិ | សមាជិក |
| ៥. | លោក **ម៉ុក ហួត** | ប្រធានការិយាល័យរដ្ឋបាលនិងគ្រប់គ្រង នៃសាខាគយនិងរដ្ឋាករនាំចេញ | សមាជិក |
| ៦. | លោក **នន សុខុម** | អនុប្រធានសាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិភ្នំពេញ | សមាជិក |
| ៧. | លោក **យឹម សំអន** | ប្រធានការិយាល័យគយនិងរដ្ឋាករ បាវិត | សមាជិក |
| ៨. | លោក **អ៊ុន ហេម៉ាលីន** | អនុប្រធានការិយាល័យគ្រប់គ្រងវិនិយោគកាត់ដេរ នៃនាយកដ្ឋានរបបគយ | សមាជិក |
| ៩. | លោកស្រី **ម៉ុន្នី សុជាតា** | អនុប្រធានការិយាល័យរដ្ឋបាលនិងគ្រប់គ្រងនៃសាខាគយនិងរដ្ឋាករប្រៃសណីយ៍ | សមាជិក |
| ១០. | លោក **លីវ បូរ៉ាន់** | អនុប្រធានការិយាល័យរដ្ឋបាលនិងគ្រប់គ្រង នៃសាខាគយនិងរដ្ឋាករ កំពង់ផែអន្តរជាតិក្រុងព្រះសីហនុ | សមាជិក |
| ១១. | លោកស្រី **អ៊ុកចាន់សុគន្ធា** | ភ្នាក់ងារ នៃនាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ | សមាជិក |
| ១២. | លោក **ឈាយសុផាន់ណារិទ្ធ** | ភ្នាក់ងារ នៃសាខាគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ | សមាជិក |

**ប្រការ ២.-**

ក្រុមការងារចងក្រងសៀវភៅនីតិវិធីបញ្ចេញទំនិញ មានតួនាទី និងភារកិច្ចដូចតទៅ ÷

- សម្របសម្រួល និងសហការជាមួយ លោក Hiroshi Suzuki អ្នកប្រឹក្សាយោបល់ឯករាជ្យ ក្នុងការប្រមូលនូវរាល់សេចក្តីណែនាំ និងបទប្បញ្ញត្តិច្បាប់ជាធរមាន ដើម្បីចងក្រងជាសៀវភៅនីតិវិធីបញ្ចេញទំនិញ។
- សម្របសម្រួល និងទំនាក់ទំនងជាមួយគ្រប់អង្គភាពគយ ជាមួយក្រសួង-ស្ថាប័នជំនាញ និងវិស័យឯកជនពាក់ព័ន្ធនឹងការងារចងក្រងសៀវភៅនីតិវិធីបញ្ចេញទំនិញ តាមការចាំបាច់។
- អនុវត្តភារកិច្ចផ្សេងទៀតតាមការចាត់តាំងដោយអគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

**ប្រការ ៣.-**

ប្រធានលេខាធិការដ្ឋាន ប្រធាននាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រង គ្រប់អង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ត្រូវមានភារកិច្ចអនុវត្តតាមលិខិតបង្គាប់ការនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**អគ្គនាយក**

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

<u>ចម្លងជូន</u> ÷

- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

បណ្ឌិត គុណ-ញឹម

# អារម្ភកថា

ច្បាប់ស្តីពីគយនិងបទប្បញ្ញត្តិទ្រទ្រង់ការអនុវត្តព្រមទាំងនិតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយជាធរមាននានាត្រូវបានកសាងឡើងជាបន្តបន្ទាប់ចាប់តាំងពីឆ្នាំ២០០៧ កន្លងមក ដោយអ្នកជំនាញការគយជាតិ និងអន្តរជាតិ ជាពិសេសគឺអ្នកជំនាញការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងអ្នកជំនាញការ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)។ ថ្វីត្បិតតែបទប្បញ្ញត្តិទាំងនោះត្រូវបានតាក់តែងឡើងក្នុងបរិបទសម្រាប់ប្រទេសកម្ពុជា ប៉ុន្តែបានរក្សាមូលដ្ឋានគ្រឹះដែលមានសង្គតភាពនឹងការអនុវត្តល្អជាអន្តរជាតិ ជាពិសេសអនុសញ្ញាអន្តរជាតិស្តីពីសាមញ្ញកម្មនិងសុខដុមនីយកម្មនីតិវិធីគយ ឬហៅកាត់ថាអនុសញ្ញាក្រុងក្យូតូដែលបានកែសម្រួល (Revised Kyoto Convention)។

គោលបំណងនៃកម្រងអត្ថបទនេះ មិនមែនជាការប្រមូលផ្តុំនៃច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការនាំចេញនាំចូលទាំងស្រុងនោះទេ ប៉ុន្តែជាសម្រង់អត្ថបទនៃផ្នែកសំខាន់ៗនៃច្បាប់និងបទប្បញ្ញត្តិទាំងនោះ ហើយត្រូវបានប្រែសម្រួលជាភាសាសាមញ្ញសម្រាប់អ្នកអានទូទៅ ដែលមិនមានជំនាញពាក់ព័ន្ធនឹងគយ។ ដូច្នេះ កម្រងអត្ថបទប្រភេទនេះអាចចាត់ទុកថាជាការបោះពុម្ពផ្សព្វផ្សាយលើកដំបូងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

ជាទូទៅ សាមញ្ញកម្មនីតិវិធីគយត្រូវបានគេទទួលស្គាល់ថាជាវិធានការមួយសម្រាប់កិច្ចសម្រួលពាណិជ្ជកម្មដែលជាគោលដៅរួមរបស់គយទូទាំងពិភពលោក។ តែទោះជាយ៉ាងណាក៏ដោយកម្មវិធីលើកកម្ពស់ការយល់ដឹងរបស់សាធារណជនប្រកបដោយប្រសិទ្ធភាពក៏ដើរតួនាទីយ៉ាងសំខាន់ផងដែរនៅក្នុងកិច្ចសម្រួលពាណិជ្ជកម្ម។ ការផ្សព្វផ្សាយឲ្យបានទូលំទូលាយនូវកម្រងអត្ថបទនេះ នឹងជួយឲ្យភាគីពាក់ព័ន្ធកាន់តែងាយយល់អំពីនីតិវិធីនានាសម្រាប់ការបំពេញបែបបទបញ្ចេញទំនិញពីគយ។

ខ្ញុំសង្ឃឹមថា កម្រងអត្ថបទនេះនឹងក្លាយជាឯកសារដ៏មានសារៈប្រយោជន៍សម្រាប់អ្នកអានគ្រប់មជ្ឈដ្ឋានរួមទាំងអ្នកសិក្សាស្រាវជ្រាវ អ្នកជំនាញគោលនយោបាយ និងជាពិសេសធុរជនដែលកំពុង ឬមានបំណងប្រកបធុរកិច្ចនៅកម្ពុជា។

**អគ្គនាយក**

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**



**បណ្ឌិត គុណ ញឹម**

# សេចក្តីអះអាងផ្នែកគតិយុត្តិ

សៀវភៅកម្រងអត្ថបទស្តីពីការបំពេញបែបបទបញ្ចេញទំនិញពីគយ (ហៅកាត់ថា "កម្រងអត្ថបទ") ត្រូវបានរៀបរៀងឡើងដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (ហៅកាត់ថា "អគរ") សហការជាមួយលោក Hiroshi Suzuki ប្រធានស្ថាប័នស្រាវជ្រាវពាណិជ្ជកម្មសម្រាប់កម្ពុជា (Business Research Institute for Cambodia - BRIC) ក្រោមគម្រោងជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍអាស៊ី (ADB) ស្តីពីការគាំទ្រកិច្ចសម្រួលពាណិជ្ជកម្មសម្រាប់ការអនុវត្តផែនការសហគមសេដ្ឋកិច្ចអាស៊ាន។ គោលបំណងសំខាន់នៃកម្រងអត្ថបទនេះ គឺដើម្បីផ្សព្វផ្សាយ បង្កើនការយល់ដឹង និងសម្រួលបន្ថែមទៀតដល់សាធារណជន ក្នុងការស្វែងយល់អំពីនីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយនៅកម្ពុជា។ ទោះជាយ៉ាងណា រាល់ខ្លឹមសារនានានៅក្នុងសៀវភៅកម្រងអត្ថបទនេះ គឺគ្រាន់តែជាការប្រមូលផ្តុំនិងបកស្រាយដោយសង្ខេបនូវបទប្បញ្ញត្តិច្បាប់ជាធរមាននានាពាក់ព័ន្ធនឹងនីតិវិធីនៃការបំពេញបែបបទបញ្ចេញទំនិញពីគយតែប៉ុណ្ណោះ និងមិនឆ្លុះបញ្ចាំងនូវទស្សនៈ ឬ គោលនយោបាយរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជាឡើយ។

ក្នុងន័យនេះ អគរ សូមបញ្ជាក់ថា កម្រងអត្ថបទនេះ នឹងពុំស្ថិតក្នុងក្របខណ្ឌនៃការធានាអះអាងផ្នែកគតិយុត្តិជាគោលដៅសម្រាប់ប្រើប្រាស់ក្នុងផ្លូវតុលាការឡើយ និងពុំមានកាតព្វកិច្ចផ្លូវច្បាប់ណាមួយពាក់ព័ន្ធនឹងកំហុសការបាត់បង់ខ្លឹមសារ ឬ ការបកស្រាយមិនត្រឹមត្រូវនានា ដែលកើតឡើងជាយថាហេតុក្នុងការរៀបចំកម្រងអត្ថបទនេះឡើយ។ ទន្ទឹមនេះ អគរ ក៏សូមរក្សាសិទ្ធិក្នុងការកែប្រែនានា ដូចជាការលុបចេញ ការបន្ថែម ឬ ការកែតម្រូវខ្លឹមសារ និងការធ្វើបច្ចុប្បន្នភាពដើម្បីឲ្យស្របតាមស្ថានភាពជាក់ស្តែងពីពេលមួយទៅពេលមួយ ដោយពុំមានការផ្តល់ហេតុផល ឬ ការជូនដំណឹងជាសាធារណៈជាមុនផងដែរ។

ចុងបញ្ចប់ ដើម្បីធានាការអនុវត្តឲ្យអនុលោមតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន អគរ ស្នើដល់សាធារណជនមេត្តាអានឯកសារគតិយុត្តិជាធរមានបន្ថែមទៀត ដូចមានយោងនៅគ្រប់ផ្នែកនៃកម្រងអត្ថបទនេះ មុនពេលអនុវត្តនីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយជាក់ស្តែង។

# សេចក្តីថ្លែងអំណរគុណ

កម្រងអត្ថបទនេះត្រូវបានចងក្រងឡើងដោយមានការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្រោមជំនួយបច្ចេកទេស (TA 8079) ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មសម្រាប់គាំទ្រផែនការអភិវឌ្ឍសហគមន៍សេដ្ឋកិច្ចអាស៊ាន (មហាអនុតំបន់ទន្លេមេគង្គ/ តំបន់អភិវឌ្ឍន៍ត្រីកោណ ប្រទេសឥណ្ឌូនេស៊ី- ម៉ាឡេស៊ី- ថៃ) ដែលត្រូវបានឧបត្ថម្ភថវិកាដោយរដ្ឋាភិបាលជប៉ុនតាមរយៈមូលនិធិជប៉ុនសម្រាប់កាត់បន្ថយភាពក្រីក្រ។

ទស្សនៈដែលបានលើកឡើងក្នុងកម្រងអត្ថបទនេះគឺជាទស្សនៈរបស់អ្នកនិពន្ធ និងមិនឆ្លុះបញ្ចាំងពីទស្សនៈ និងគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ឬ ក្រុមប្រឹក្សាភិបាលរបស់ធនាគារ ឬរាជរដ្ឋាភិបាលឡើយ។

# បញ្ជីអក្សរកាត់

| | |
|---|---|
| ក.អ.ក | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| គ.វ.ក | គណៈកម្មាធិការវិនិយោគកម្ពុជា |
| គលគ | គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ |
| គ.ជ.នា | គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍ |
| អគរ | អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា |
| តសព | តំបន់សេដ្ឋកិច្ចពិសេស |
| សហវ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |

# មាតិកា

លិខិតបង្គាប់ការ......ii
អារម្ភកថា......v
សេចក្ដីអះអាងផ្នែកគតិយុត្ត......vi
សេចក្ដីថ្លែងអំណរគុណ......vii
បញ្ជីអក្សរកាត់......viii
ផែនទីនៃព្រះរាជាណាចក្រកម្ពុជា......x
មាតិកា......xi
ជំពូក ១ ÷ ព័ត៌មានទូទៅ......១
១.១. រចនាសម្ព័ន្ធ និងតួនាទីរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា......១
១.១.១. ប្រវត្តិសង្ខេប......១
១.១.២. ទស្សនវិស័យ......៣
១.១.៣. បេសកកម្ម......៣
១.១.៤. រចនាសម្ព័ន្ធ......៣
១.១.៤.១. អង្គការលេខ......៣
១.១.៤.២. តួនាទី និងភារកិច្ច......៥
១.២. ខ្លឹមសារពាក់ព័ន្ធច្បាប់ស្ដីពីគយ......៩
១.២.១. បទប្បញ្ញត្តិទូទៅ......៩
១.២.១.១. គោលបំណង......៩
១.២.១.២. ដែនគយ និងវង់អំណាចគយ......៩
១.២.១.៣. វិធានការការពារផលិតករក្នុងស្រុក......១០
១.២.១.៤. ការជាប់អាយ៉ត ឬកម្រិតកំណត់......១០
១.២.២. ការនាំចូល......១១
១.២.៣. ការនាំចេញ......១១
១.២.៤. ចំណាត់ថ្នាក់តាមតារាង ដើមកំណើត និង តម្លៃគិតពន្ធ......១២
១.២.៥. ការលើកលែង ការលើកលែងជាភាគ និងការបង្វិលសងវិញនូវពន្ធ និងអាករ......១៤
១.២.៦. ប្រតិវេទន៍គយ......១៤
១.២.៧. សន្និធិគយបណ្ដោះអាសន្ន និងភណ្ឌាគារគយមានដែនកំណត់......១៤
១.៣. ពន្ធនិងអាករ......១៥
១.៣.១. ប្រព្រឹត្តកម្មធម្មតា......១៥
១.៣.២. ប្រព័ន្ធអនុគ្រោះពន្ធ......១៦

ជំពូក ២ ÷ នីតិវិធីគយ ........ ២១
២.១. នីតិវិធីទូទៅ ........ ២១
២.១.១. នីតិវិធីប្រតិវេទន៍គយ ........ ២១
២.១.១.១. នីតិវិធីប្រតិវេទន៍គយតាមប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ ........ ២២
២.១.១.២. បុគ្គលដែលមាននីតិសម្បទា ........ ២៤
២.១.១.៣. ឯកសារចាំបាច់ក្នុងការបំពេញប្រតិវេទន៍គយ ........ ២៤
២.១.១.៤. ភារកិច្ចនិងការទទួលខុសត្រូវរបស់ជើងសាគយ ឬប្រតិវេទករ ........ ២៥
២.១.២. ការនាំចូល ........ ២៦
២.១.២.១. ផ្លូវសមុទ្រ/ ផ្លូវទន្លេ ........ ២៦
២.១.២.២. ផ្លូវអាកាស ........ ២៨
២.១.២.៣. ផ្លូវគោក ........ ២៩
២.១.៣. ការនាំចេញ ........ ៣១
២.១.៣.១. ផ្លូវសមុទ្រ/ ផ្លូវទន្លេ ........ ៣១
២.១.៣.២. ផ្លូវអាកាស ........ ៣១
២.១.៣.៣. ផ្លូវគោក ........ ៣២
២.១.៤. ឆ្លងកាត់ ........ ៣២
២.១.៤.១. ឆ្លងកាត់ជាតិ ........ ៣២
២.១.៤.២. ឆ្លងកាត់អន្តរជាតិ ........ ៣៣
២.២. នីតិវិធីពិសេស ........ ៣៤
២.២.១. ធុរជនល្អបំផុត ........ ៣៤
២.២.១.១. កញ្ចប់លក្ខណៈវិនិច្ឆ័យ ........ ៣៤
២.២.១.២. កញ្ចប់ប្រព្រឹត្តកម្មលើកទឹកចិត្ត ........ ៣៥
២.២.១.៣. ការដាក់ពាក្យស្នើសុំជាសមាជិក ........ ៣៥
២.២.២. គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ល.គ) ........ ៣៦
២.២.២.១. ការលើកលែងពន្ធគយ និងអាករ ........ ៣៧
២.២.២.២. នីតិវិធីនាំចូលសម្រាប់ គ.ល.គ ........ ៣៨
២.២.២.៣. ការបំពេញបែបបទបញ្ចេញទំនិញនាំចេញនៅសាខាគយនិងរដ្ឋាករនាំចេញ ........ ៣៨
២.២.៣. តំបន់សេដ្ឋកិច្ចពិសេស (តសព) ........ ៤០
២.២.៣.១. ការលើកទឹកចិត្តពន្ធ និងអាករដល់អ្នកវិនិយោគក្នុងតំបន់ ........ ៤០
២.២.៣.២. នីតិវិធីនាំចូល ........ ៤១
២.២.៣.៣. នីតិវិធីនាំចេញ ........ ៤៣
២.២.៣.៤. ការលក់ទំនិញចូលទីផ្សារក្នុងស្រុក ........ ៤៥
២.២.៤. ការនាំចូលតាមរបបប្រវេសន៍កាលិក ........ ៤៥
២.២.៥. ភណ្ឌាគារគយមានដែនកំណត់ ........ ៤៧
២.២.៥.១. ប្រភេទភណ្ឌាគារគយមានដែនកំណត់ ........ ៤៧

២.២.៥.២. នីតិវិធីគ្រប់គ្រងទំនិញក្នុងភណ្ឌាគារគយមានដែនកំណត់................... ៤៧
២.២.៦. ទំនិញនាំចូលតាមរបបអាគារលក់ទំនិញរួចពន្ធ ............................................. ៤៨
២.២.៦.១. បែបបទនៃការនាំចូល........................................................................ ៤៨
២.២.៦.២. ការធ្វើចរាចរទំនិញរួចពន្ធ.................................................................. ៤៨
២.២.៦.៣. កាតព្វកិច្ចរបស់អាជីវករ................................................................... ៤៨
២.២.៧. ទំនិញដែលត្រូវលើកលែងពន្ធ និងអាករ...................................................... ៤៩
២.២.៧.១. ការកំណត់មុខទំនិញដែលត្រូវលើកលែងពន្ធ និងអាករ....................... ៤៩
២.២.៧.២. ការគ្រប់គ្រងទំនិញដែលបានលើកលែងពន្ធ និងអាករ........................ ៥០
២.២.៨. នីតិវិធីក្នុងការនាំចេញអង្ករ និងផលិតផលកសិកម្ម.......................................... ៥១
២.៣. នីតិវិធីមុនពេលបំពេញបែបបទបញ្ចេញទំនិញពីគយ.................................................. ៥២
២.៣.១. វិធានបញ្ជាក់ជាមុន ....................................................................................... ៥២
២.៣.១.១. និយមន័យ......................................................................................... ៥២
២.៣.១.២. បុគ្គលដែលមានសិទ្ធិស្នើសុំវិធានបញ្ជាក់ជាមុន(អ្នកស្នើសុំ)................. ៥៣
២.៣.១.៣. ការិយាល័យទទួលបន្ទុកវិធានបញ្ជាក់ជាមុន .................................. ៥៣
២.៣.១.៤. នីតិវិធីក្នុងការស្នើសុំវិធានបញ្ជាក់ជាមុន.......................................... ៥៣
២.៣.១.៥. ដំណើរការពាក្យស្នើសុំវិធានបញ្ជាក់ជាមុន........................................ ៥៣
២.៣.១.៦. សុពលភាពរបស់វិធានបញ្ជាក់ជាមុន ................................................ ៥៥
២.៣.១.៧. ការពិនិត្យឡើងវិញនូវវិធានបញ្ជាក់ជាមុន ........................................ ៥៥
២.៣.១.៨. ការផ្សព្វផ្សាយវិធានបញ្ជាក់ជាមុន.................................................... ៥៥
២.៣.២. ការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ.......................................................................... ៥៨
២.៣.២.១. និយមន័យតម្លៃគិតពន្ធគយ............................................................... ៥៨
២.៣.២.២. ការធ្វើវិមជ្ឈការការងារតម្លៃគិតពន្ធគយ .......................................... ៥៨
២.៣.២.៣. នីតិវិធីនៃការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ........................................... ៥៩
២.៣.៣. វិញ្ញាបនបត្រដើមកំណើតទំនិញ ...................................................................... ៦០
២.៣.៣.១. ការបង្ហាញវិញ្ញាបនបត្រដើមកំណើតទំនិញ.......................................... ៦០
២.៣.៣.២. ករណី វិញ្ញាបនបត្រដើមកំណើតទំនិញត្រូវបានច្រានចោល................. ៦០
២.៣.៣.៣. ទម្រង់នៃវិញ្ញាបនបត្រដើមកំណើតទំនិញ........................................... ៦០
២.៣.៣.៤. ការត្រួតពិនិត្យវិញ្ញាបនបត្រដើមកំណើតទំនិញ .............................. ៦០
២.៣.៤. ទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់ ................................................... ៦១
២.៣.៥. លិខិតអនុញ្ញាតគយ .................................................................................... ៦៣
២.៣.៥.១. ទំនិញជាកម្មវត្ថុនៃការស្នើសុំលិខិតអនុញ្ញាតគយ .............................. ៦៤
២.៣.៥.២. នីតិវិធីនៃការស្នើសុំលិខិតអនុញ្ញាតគយ ........................................... ៦៤
២.៤. នីតិវិធីផ្សេងៗ............................................................................................................ ៦៧
២.៤.១. កញ្ចប់បញ្ញើតាមប្រៃសណីយ៍.......................................................................... ៦៧
២.៤.១.១. សន្និធិគយបណ្ដោះអាសន្ន.................................................................. ៦៧
២.៤.១.២. ការបំពេញបែបបទគយ..................................................................... ៦៧

២.៤.១.៣. ការត្រួតពិនិត្យទំនិញ ........................................................ ៦៨
២.៤.២. ទំនិញឬ សម្ភារប្រើប្រាស់ផ្ទាល់ខ្លួនរបស់អ្នកដំណើរ ...................................... ៦៨
២.៤.៣. ទំនិញគ្មានលក្ខណៈពាណិជ្ជកម្ម ........................................................ ៦៩
២.៤.៤. ទំនិញតាមរូបភាពតូច ........................................................ ៦៩
២.៤.៥. ទំនិញតម្លៃទាប........................................................ ៧០
២.៤.៦. ការនាំចូល និងនាំចេញរូបិយប័ណ្ណបរទេស ........................................................ ៧១
២.៤.៦.១. ការនាំចូលរូបិយប័ណ្ណ........................................................ ៧១
២.៤.៦.២. ការនាំចេញរូបិយប័ណ្ណ........................................................ ៧១
២.៤.៦.៣. នីតិវិធីនាំចេញរូបិយប័ណ្ណ........................................................ ៧១
២.៤.៧. ការនាំចូលនិងនាំចេញសាកសព........................................................ ៧១
២.៤.៨. ការសម្រុះសម្រួលបទល្មើសគយ ........................................................ ៧២
២.៤.៨.១. សិទ្ធិរដ្ឋបាលគយក្នុងការសម្រុះសម្រួលបទល្មើសគយ........................ ៧២
២.៤.៨.២. នីតិវិធីសម្រុះសម្រួលបទល្មើសគយ........................................................ ៧២
២.៤.៨.៣. នីតិវិធីតវ៉ាប្រឆាំងកំណត់ហេតុគយ........................................................ ៧៣
ជំពូក ៣ ÷ នីតិវិធីផ្សេងទៀតអនុលោមតាមច្បាប់និងបទប្បញ្ញត្តិរបស់ក្រសួងពាក់ព័ន្ធ........................ ៧៤
៣.១. អាជ្ញាប័ណ្ណ លិខិតអនុញ្ញាតិ និងវិញ្ញាបនបត្រ........................................................ ៧៤
៣.២. វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ........................................................ ៧៦
៣.២.១. សេចក្តីផ្តើម........................................................ ៧៦
៣.២.២. ប្រទេសដែលតម្រូវឲ្យមានវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ........................ ៧៦
៣.២.៣. របៀបដាក់ពាក្យស្នើសុំ វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ ........................ ៧៧
៣.២.៤. កម្រៃសេវានៃការដាក់ពាក្យ ស្នើសុំវិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ................ ៨១
៣.២.៥. កាលវិភាគដំណើរការ ប្រព័ន្ធស្វ័យប្រវត្តិកម្ម........................................................ ៨១
៣.២.៦. ព័ត៌មានទំនាក់ទំនង........................................................ ៨២
៣.៣. វិញ្ញាបនបត្រអនាម័យ និងភូតគាមអនាម័យ........................................................ ៨២
៣.៣.១. និយមន័យ ........................................................ ៨២
៣.៣.២. គោលបំណង........................................................ ៨២
៣.៣.៣. កិច្ចការពារ........................................................ ៨៣
៣.៣.៤. ទំនិញដែលជាកម្មវត្ថុត្រូវត្រួតពិនិត្យភូតគាមអនាម័យ ........................................ ៨៣
៣.៣.៥. ដំណើរការស្នើសុំ វិញ្ញាបនបត្រអនាម័យ និងភូតគាមអនាម័យ........................ ៨៣
៣.៣.៦. កំណត់សម្គាល់........................................................ ៨៥
៣.៣.៧. ព័ត៌មានបន្ថែមសម្រាប់ការងារភូតគាមអនាម័យ........................................ ៨៥
ឧបសម្ព័ន្ធ ........................................................ ៨៦
ឧបសម្ព័ន្ធ ក. ច្បាប់ និងបទប្បញ្ញត្តិ ពាក់ព័ន្ធនឹងបែបបទបញ្ចេញទំនិញពីគយ................................ ៨៦
ឧបសម្ព័ន្ធ ខ. តារាងតម្លៃ........................................................ ៩១
ឧបសម្ព័ន្ធ គ. បញ្ជីទំនាក់ទំនងតាមក្រសួងពាក់ព័ន្ធ........................................................ ៩២
ឧបសម្ព័ន្ធ ឃ. យោង........................................................ ៩៥

# ជំពូក ១ ព័ត៌មានទូទៅ

## ១.១. រចនាសម្ព័ន្ធ និងតួនាទីរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

### ១.១.១. ប្រវត្តិសង្ខេប

អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ត្រូវបានបង្កើតឡើងក្នុងសម័យសង្គមរាស្ត្រនិយមដោយព្រះរាជក្រមលេខ ៦៦១ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៥១។ កិច្ចដំណើរការរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករត្រូវបានបញ្ឈប់ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ក្រោមរបបខ្មែរក្រហម។ អង្គភាពនេះចាប់ដំណើរការ ឡើងវិញ នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៧៩ ក្រោមឱវាទក្រសួងពាណិជ្ជកម្ម។ អង្គភាពនេះត្រូវបានផ្ទេរទៅនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអនុក្រឹត្យលេខ ០៦ អនក្រ ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ១៩៨៨។ ទីចាត់ការគយនិងរដ្ឋាករ ត្រូវបានតម្លើងជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (អគរ) តាមរយៈអនុក្រឹត្យលេខ ១៣៤ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨។ អគរ គឺជារដ្ឋបាលសាធារណៈ ស្ថិតក្រោម ឱវាទ ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។

ប្រធាន គយ និង រដ្ឋាករ ត្រូវបាន ជ្រើសតាំង ដោយរដ្ឋាភិបាលមានសមាសភាពដូចខាងក្រោម÷

| ល.រ | ឆ្នាំចូលកាន់តំណែង | នាមឈ្មោះ | កំណត់សម្គាល់ |
|---|---|---|---|
| ១. | ឆ្នាំ១៩៥២ | លោក អៀវ ស៊ីចូវ | និស្សិតពាណិជ្ជកម្មមកពីបារាំង |
| ២. | ឆ្នាំ១៩៥៤ | លោក កែវ ម៉ុងត្រី | និស្សិតពាណិជ្ជកម្មមកពីបារាំង |

| | | | |
|---|---|---|---|
| ៣. | ឆ្នាំ១៩៥៦ | លោក អ៊ុច សាំសែម | អធិការគយ-រដ្ឋាករ |
| ៤. | ឆ្នាំ១៩៥៨ | លោក កុច សាន | អធិការគយ-រដ្ឋាករ |
| ៥. | ឆ្នាំ១៩៦០ | លោក ញ៉ឹក នូ | មន្ត្រីរាជការ |
| ៦. | ឆ្នាំ១៩៦២ | លោក ជុំ យ៉ែម | មន្ត្រីរាជការ |
| ៧. | ឆ្នាំ១៩៦៣ | លោក ឈិន រ៉ែន | អធិការគយ-រដ្ឋាករ |
| ៨. | ឆ្នាំ១៩៦៤ | លោក ជុំ យ៉ែម | អធិការគយ-រដ្ឋាករ |
| ៩. | ឆ្នាំ១៩៦៦ | លោក ហ៊ូ ហុង | មន្ត្រីរាជការ |
| ១០. | ឆ្នាំ១៩៦៨ | លោក ជុំ យ៉ែម | អធិការគយ-រដ្ឋាករ |
| ១១. | ឆ្នាំ១៩៧០ | លោក សូ ខាំខូយ | អធិការគយ-រដ្ឋាករ |
| ១២. | ឆ្នាំ១៩៧២ | លោក ជុំ យ៉ែម | អធិការគយ-រដ្ឋាករ |
| ១៣. | ឆ្នាំ១៩៧៤ | លោក តិម សុន | នាយកកិច្ចការសាធារណៈ |
| ១៤. | ឆ្នាំ១៩៧៥ | លោក គង់ សារិន | អធិការគយ-រដ្ឋាករ |
| ១៥. | ឆ្នាំ១៩៧៩-១៩៩៧ | លោក ស ហួរ | នាយកទីចាត់ការគយនិងរដ្ឋាករ |
| ១៦. | ឆ្នាំ១៩៩៧ -១៩៩៨ | លោក អ៊ិន សារឿង | នាយកទីចាត់ការគយនិងរដ្ឋាករ |
| ១៧. | ឆ្នាំ១៩៩៨-២០១៤ | ឯកឧត្តមបណ្ឌិត ប៉ែន ស៊ីម៉ន | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកគយនិងរដ្ឋាករកម្ពុជា |
| ១៨. | ខែកញ្ញា ២០១៤-បច្ចុប្បន្ន | បច្ចុប្បន្ន ឯកឧត្តមបណ្ឌិត គុណ ញឹម | អគ្គនាយកនៃ អគរ |

អគរ បានក្លាយជាសមាជិកទី ១៥៥ នៃអង្គការគយពិភពលោក (World Customs Organization) នាថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០១។

## ១.១.២. ទស្សនវិស័យ

អគរ មានទស្សនវិស័យក្នុងការអភិវឌ្ឍខ្លួនឲ្យក្លាយជារដ្ឋបាលគយទំនើបមួយ ស្របតាមបមាណីយ និងឧត្តមានុវត្តន៍ជាអន្តរជាតិ ដោយមានការទទួលស្គាល់ពីថ្នាក់ជាតិនិងអន្តរជាតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាល និងកិច្ចប្រតិបត្តិការ ព្រមទាំងជាស្ថាប័នផ្តល់សេវាយ៉ាងមានប្រសិទ្ធភាពដល់សហគមន៍ធុរកិច្ចនិងភាគីពាក់ព័ន្ធ។

## ១.១.៣. បេសកកម្ម

បេសកកម្មរបស់ អគរ គឺ ដើម្បីជួយពន្លឿននិងសម្រួលដល់ការធ្វើធុរកិច្ចស្របច្បាប់ និងដំណើរឆ្លងកាត់របស់អ្នកទេសចរណ៍ ការប្រមូលនិងបង្កើនចំណូលថវិកាជាតិ ការធានាឲ្យមានការប្រកួតប្រជែងសេដ្ឋកិច្ចប្រកបដោយសមធម៌ ការធ្វើឲ្យប្រសើរឡើងនូវសុវត្ថិភាពសង្គមនិងសន្តិសុខជាតិ និងការធ្វើឲ្យមាននិរន្តភាពនៃការអភិវឌ្ឍនិងសម្រេចបានតាមគោលដៅកំណើនសេដ្ឋកិច្ចរបស់កម្ពុជា។ ក្នុងន័យនេះ គោលដៅយុទ្ធសាស្ត្រនិងផែនការសកម្មភាពត្រូវបង្កើតឡើងដើម្បីធ្វើឲ្យបេសកកម្មនេះទទួលបានជោគជ័យ។

## ១.១.៤. រចនាសម្ព័ន្ធ

### ១.១.៤.១. អង្គភាពលេខ

រចនាសម្ព័ន្ធនិងការគ្រប់គ្រងរបស់ អគរ បានផ្លាស់ប្តូរបន្ទាប់ពីបានដំឡើងពីនាយកដ្ឋានគយនិងរដ្ឋាករទៅជា អគរ ដើម្បីឆ្លើយតបតាមការអភិវឌ្ឍពាណិជ្ជកម្មអន្តរជាតិ និងបញ្ហាប្រឈមផ្សេងៗដែលរដ្ឋបាលគយបានជួបប្រទះ។ អង្គការលេខរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករនាពេលបច្ចុប្បន្នបានរៀបចំស្របតាមបេសកកម្ម តួនាទីរបស់អគ្គនាយកដ្ឋានដែលមានចែងនៅក្នុងអនុក្រឹត្យលេខ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ដែលត្រូវបានកែតម្រូវពីអនុក្រឹត្យលេខ ១៣៤ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ និងអនុក្រឹត្យលេខ ១៥២ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៨។


អង្គការលេខរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
Organizational Chart of the General Department of Customs and Excise of Cambodia
អគ្គនាយក
Director General
អគ្គនាយករង
Deputy Director General
នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រង
Department of Administration and Management
នាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ
Department of Planning, Technique and International Affairs
នាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ
Department of Legal Affairs, Audit and Public Relation
នាយកដ្ឋានបង្ការ និងបង្ក្រាបបទល្មើស
Department of Prevention and Suppression
នាយកដ្ឋានរដ្ឋាករ
Department of Excise
នាយកដ្ឋានរបបគយ
Department of Customs Regime
នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ
Department of Free Zones Management
លេខាធិការដ្ឋាន
Secretariat
អង្គភាពមូលដ្ឋាន
Local Units
យោង: អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣
Reference: Sub-decree of The Royal Government of Cambodia No. 488 Dated 16 October, 2013

រចនាសម្ព័ន្ធរដ្ឋបាល អគរ មាននាយកដ្ឋានក្រោមឱវាទចំនួនប្រាំពីរ និងលេខាធិការដ្ឋានមួយនៅថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋានមួយចំនួនដូចខាងក្រោម÷

### ១- អង្គភាពថ្នាក់កណ្តាល

- លេខាធិការដ្ឋាន
- នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រង
- នាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ
- នាយកដ្ឋានបង្ការ និងបង្ក្រាបបទល្មើស
- នាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ
- នាយកដ្ឋានរបបគយ
- នាយកដ្ឋានរដ្ឋាករ
- នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ

### ២- អង្គភាពមូលដ្ឋាន

- សាខាគយនិងរដ្ឋាករនាំចេញ
- សាខាគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ
- សាខាគយនិងរដ្ឋាករប្រៃសណីយ៍
- សាខាគយនិងរដ្ឋាករផែស្ងួត
- សាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិភ្នំពេញ
- សាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ
- សាខាគយនិងរដ្ឋាកររាជធានី-ខេត្ត

## ១.១.៤.២. តួនាទី និងភារកិច្ច

### លេខាធិការដ្ឋាន

- ស្រាវជ្រាវ ពិនិត្យ សិក្សា ធ្វើរបាយការណ៍ និងជូនយោបល់ជាប្រចាំលើរាល់ការងារចាំបាច់នានាជូនអគ្គនាយកនៃ អគរ
- រៀបចំ តាក់តែង ចងក្រង ថែរក្សានូវបណ្តាឯកសារនានាតាមការចាំបាច់របស់អគ្គនាយកនៃអគរ
- ត្រួតពិនិត្យបណ្តាឯកសារ សេចក្តីព្រាងសំណើសំណុំលិខិតផ្សេងៗ ឬកំណត់បង្ហាញមតិនានាមុននឹងបញ្ជូនទៅសុំការសម្រេចពីថ្នាក់ដឹកនាំនៃអគរ
- រៀបចំ គ្រប់គ្រងការងារសវនកម្មផ្ទៃក្នុងអង្គភាពគយនិងរដ្ឋាករ និងបំពេញបេសកកម្មផ្សេងទៀតតាមការកំណត់ជាក់ស្តែងរបស់អគ្គនាយកនៃអគរ ។

### នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រង

- រៀបចំ និងចាត់ចែងការងារគ្រប់គ្រងមន្ត្រីរាជការគយនិងរដ្ឋាករ ដែលរាប់បញ្ចូលទាំងការគ្រប់គ្រងស្ថិតិ អនុលោមភាព ការផ្លាស់ប្តូរ-ផ្ទេរភារកិច្ច និងឋានៈ ការលើកសរសើរ ឬ ដាក់វិន័យ និងការរៀបចំគោលនយោបាយពាក់ព័ន្ធនឹងក្របខ័ណ្ឌបៀវត្សរ៍ ប្រាក់កម្រៃ របបឧបត្ថម្ភ និងរបបសម្រាកលំហែផ្សេងៗ
- រៀបចំនិងចាត់ចែងការងារបណ្តុះបណ្តាលមន្ត្រីរាជការគយនិងរដ្ឋាករ ក៏ដូចជាមន្ត្រីរាជការនៃអង្គភាពពាក់ព័ន្ធផ្សេងទៀត ព្រមទាំងផ្នែកឯកជនផងដែរ ក្នុងករណីចាំបាច់
- គ្រប់គ្រងការទទួល ការបញ្ជូន និងការចែកចាយឯកសារផ្លូវការផ្សេងៗ
- ទទួលបន្ទុកការងាររដ្ឋបាលផ្សេងទៀត រាប់បញ្ចូលទាំងការកសាងរបាយការណ៍ ការវាយតំលៃប្រសិទ្ធភាពការងារ និងការចេញលិខិតឧទ្ទេសនាម ឬ លិខិតបញ្ជាបេសកកម្មផ្សេងៗ
- គ្រប់គ្រងស្ថិតិការប្រើប្រាស់អាវុធក្នុងអង្គភាព
- ទទួលខុសត្រូវ គ្រប់គ្រងការងាររបស់ អគរ ពាក់ព័ន្ធនឹងហិរញ្ញវត្ថុ គណនេយ្យ ការចូលរួមកសាង និងត្រួតពិនិត្យការអនុវត្តផែនការចំណូល-ចំណាយ ការទូទាត់នានា ការគ្រប់គ្រងតម្រូវការ ការទិញការបែងចែក និងការថែរក្សាសម្ភារ និងបរិក្ខារព្រមទាំងទ្រព្យសម្បត្តិផ្សេងៗរបស់ អគរ

- បំពេញបេសកកម្មផ្សេងទៀត តាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## នាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ

- លើកឡើងនូវគោលនយោបាយសមស្រប ពាក់ព័ន្ធនឹងនីតិវិធីនៃការប្រមូលពន្ធនិងអាករ ការកំណត់គោលដៅ ប្រមូលចំណូល និង ការកសាង នូវផែនការមេ និងផែនការសកម្មភាពរបស់អង្គភាពគយនិងរដ្ឋាករ
- គ្រប់គ្រងការកសាង ការស្រាវជ្រាវ និងចូលរួមតាមដានត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិ និងគោលនយោបាយទាំងឡាយ ដែលពាក់ព័ន្ធនឹងតារាងពន្ធគយ ការកំណត់តម្លៃគិតពន្ធគយ ឬអាករគយលើទំនិញនាំចេញ-នាំចូល ការវិវត្តនៃការកំណត់ដើមកំណើតទំនិញអោយបានទាន់ពេលវេលា និងស្របតាមការវិវត្តនៃសេដ្ឋកិច្ចជាតិ និងពាណិជ្ជកម្មអន្តរជាតិ ដោយរាប់បញ្ចូលទាំងការកែសម្រួលចំណាត់ថ្នាក់ទំនិញ ការវាយតម្លៃផលប៉ះពាល់ពីការសម្រួលនានា ការកសាងវិធីសាស្ត្រវិភាគ និងគ្រប់គ្រងមន្ទីរពិសោធន៍គយនានា
- កសាង និង គ្រប់គ្រង ការអនុវត្ត នូវ ផែនការអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានវិទ្យាគយ ជាពិសេសពាក់ព័ន្ធនឹងការធ្វើស្វ័យប្រវត្តិកម្មនីតិវិធីគយ ព្រមទាំងការគ្រប់គ្រងស្រង់ ប្រមូល និងរក្សាទិន្នន័យស្ថិតិនាំចេញ-នាំចូល ដោយរាប់បញ្ចូលទាំងការគ្រប់គ្រងការប្រើប្រាស់ និង ថែរក្សាប្រព័ន្ធទាំងនោះ
- ស្រាវជ្រាវ និងកែសម្រួលជាប្រចាំនូវបញ្ជីតម្លៃគិតពន្ធឬអាករគយសម្រាប់ពិចារណាលើទំនិញនាំចេញ-នាំចូល តម្លៃរូបិយប័ណ្ណ អត្រាប្តូរប្រាក់អោយបានសមស្របតាមភាពជាក់ស្តែងសម្រាប់ជាមូលដ្ឋានពិចារណានិងសម្រេចចិត្តក្នុងការអនុវត្តការងាររបស់អង្គភាពគយ និងរដ្ឋាករមូលដ្ឋាន
- បំពេញតួនាទីពិនិត្យ និងផ្តល់យោបល់លើការងារពាក់ព័ន្ធនឹងបច្ចេកទេសគយ ជាពិសេសលើការងារកំណត់តម្លៃគិតពន្ធគយ ដើមកំណើត និងចំណាត់ថ្នាក់ទំនិញ និងចូលរួមធ្វើសវនកម្មលើការងារខាងលើនេះ ព្រមទាំងការងារជម្រះបញ្ជីផ្សេងៗទៀត
- បំពេញតួនាទីជាមជ្ឈមណ្ឌលកិច្ចការអន្តរជាតិពាក់ព័ន្ធនឹងវិស័យគយជារួម
- សិក្សា និងវិភាគព័ត៌មានពាក់ព័ន្ធនឹងសេដ្ឋកិច្ច និង ពាណិជ្ជកម្មអន្តរជាតិ ដោយប្រៀបធៀបជាមួយនឹងទិន្នន័យរបស់រដ្ឋបាលគយនៃប្រទេសជាដៃគូពាណិជ្ជកម្មក្នុងតំបន់និងពិភពលោក
- សម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយអង្គការគយពិភពលោក រដ្ឋបាលគយផ្សេងទៀតនិងជាមួយអង្គការនានាដែលពាក់ព័ន្ធនឹងវិស័យគយ
- សម្របសម្រួល និង ចូលរួម សហការ ជាមួយ អង្គភាពពាក់ព័ន្ធនៃក្រសួង-ស្ថាប័នរាជរដ្ឋាភិបាលក្នុងក្របខ័ណ្ឌ សហប្រតិបត្តិការសេដ្ឋកិច្ច និង ពាណិជ្ជកម្មអន្តរជាតិ
- ចូលរួមឃ្លាំមើល និងវាយតម្លៃប្រសិទ្ធភាពនៃប្រតិបត្តិការគយ
- បំពេញបេសកកម្មផ្សេងទៀត តាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## នាយកដ្ឋានបង្ការ និងបង្ក្រាបបទល្មើស

- សហការកសាងគោលនយោបាយបម្រើអោយការស្រាវជ្រាវ និងបង្ក្រាបអំពើរត់ពន្ធ និងគេចពន្ធគ្រប់ប្រភេទ និងបទល្មើសផ្សេងទៀតទូទាំងដែនគយ
- ចាត់តាំងបណ្តាញស្រាវជ្រាវសម្ងាត់ និងកម្លាំងពិសេសសម្រាប់ទប់ស្កាត់ និងបង្ក្រាបរាល់អំពើល្មើសច្បាប់គយ និងអំពើល្មើសផ្សេងទៀត

- រក្សាទុកទំនិញ ដែលឃាត់ទុកបណ្តោះអាសន្ន រង់ចាំការសម្រេចវិនិច្ឆ័យជាស្ថាពរពីអង្គការមានសមត្ថកិច្ចនានា និងចាត់ចែងទំនិញទាំងនោះតាមមុខសញ្ញាដែលបានកំណត់

- ចាត់តាំងក្រុមប្រតិបត្តិការស្រាវជ្រាវ និងបង្ក្រាបអំពើរត់ពន្ធ ធ្វើសកម្មភាពតាមគោលដៅសំខាន់ៗ ចាំបាច់នៅទូទាំងប្រទេស តាមបទបញ្ជាផ្ទាល់របស់អគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

- ជាមជ្ឈមណ្ឌលសហប្រតិបត្តិការ និងគ្រប់គ្រងប្រមូល ចងក្រងរាល់ព័ត៌មានពាក់ព័ន្ធនឹងទំនិញ បុគ្គល មធ្យោបាយដឹកជញ្ជូន និងល្បិចល្មើសគ្រប់ប្រភេទពីបណ្តាប្រភពក្នុងប្រទេសនិងអន្តរជាតិ ព្រមទាំងធ្វើការវិភាគ និងវាយតម្លៃហានិភ័យលើព័ត៌មានទាំងនេះ សម្រាប់បម្រើអោយការងារបង្ក្រាបអំពើរត់ពន្ធ និងបទល្មើសផ្សេងទៀតរបស់ស្ថាប័នមានសមត្ថកិច្ច នៃព្រះរាជាណាចក្រកម្ពុជានិងសមភាគីបរទេសផងដែរ

- បំពេញបេសកកម្មផ្សេងទៀត តាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## នាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ

- សហការស្រាវជ្រាវ និងផ្តល់យោបល់ពាក់ព័ន្ធនឹងការកសាងបទប្បញ្ញត្តិគយនានា ព្រមទាំងបទប្បញ្ញត្តិផ្សេងទៀតដែលទាក់ទងទៅនឹងកិច្ចប្រតិបត្តិការគយ

- ទទួលបន្ទុកត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិគយនានា ព្រមទាំងបទប្បញ្ញត្តិផ្សេងទៀត ដែលទាក់ទងទៅនឹងកិច្ចប្រតិបត្តិការគយ និងការធ្វើវិសោធនកម្ម ឬ ការកែសម្រួលបទប្បញ្ញត្តិគយ

- ទទួលបន្ទុកពិនិត្យ និងចូលរួមពិនិត្យសំណើសុំបង្កើតភណ្ឌាគារគយមានដែនកំណត់តំបន់រួចពន្ធ សេវាកម្មជើងសាគយ និងបណ្តាអាជីវកម្មដ្ឋានប្រហាក់ប្រហែល និងចាត់ចែងគ្រប់គ្រងត្រួតពិនិត្យទីកន្លែង និងសេវាកម្មទាំងនេះ ដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់ និងកិច្ចសន្យាជាធរមាននានា

- សម្រុះសម្រួលបទល្មើសគយ និងវិវាទផ្សេងទៀត ដោយផ្តល់យោបល់សម្រាប់បម្រើអោយការវិនិច្ឆ័យរាល់អំពើល្មើសច្បាប់គយនានា ដាក់ជូនអគ្គនាយកនៃ អគរ ពិនិត្យនិងសម្រេចស្របតាមបញ្ញត្តិនៃច្បាប់ស្តីពីគយ

- ទទួលពិនិត្យ និងវាយតម្លៃនូវរាល់ការតវ៉ានានារបស់ផ្នែកឯកជននានា ក្នុងនាមជាអង្គភាពទំនាក់ទំនងសាធារណៈរបស់ អគរ ក្នុងគោលដៅរក្សាតុល្យភាពរវាងប្រសិទ្ធភាពនៃការអនុវត្តបទប្បញ្ញត្តិច្បាប់ជាធរមាន និងកិច្ចសម្រួលពាណិជ្ជកម្មអន្តរជាតិ

- កសាង និង ត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងហានិភ័យ ដើម្បីកំណត់មុខសញ្ញាដែលមានហានិភ័យខ្ពស់

- ប្រមូលវិភាគវាយតម្លៃនិងគ្រប់គ្រងព័ត៌មាន និងទិន្នន័យពីប្រភពនានាបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន និងប្រព័ន្ធគ្រប់គ្រងលក្ខណៈវិនិច្ឆ័យជ្រើសរើសហានិភ័យ

- តាមដានការអនុវត្តកិច្ចព្រមព្រៀងអន្តរស្ថាប័នជាមួយនឹងភ្នាក់ងាររាជរដ្ឋាភិបាលផ្សេងទៀត ដោយអនុលោមតាមគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ

- កសាងផែនការ និងចាត់ចែងធ្វើសវនកម្មលើអាជីវកម្មដ្ឋាន ដែលមានហានិភ័យខ្ពស់នានាតាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

- បំពេញបេសកកម្មផ្សេងទៀត តាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## នាយកដ្ឋានរបបគយ

- ចូលរួម រៀបចំ គោលនយោបាយ គ្រប់គ្រង សកម្មភាពវិនិយោគ និងសកម្មភាពនាំចេញ-នាំចូលទំនិញរបស់អង្គការ ស្ថានទូត ស្ថាប័នរដ្ឋ និងបុគ្គលផ្សេងៗទៀតតាមរបបគយអនុគ្រោះ
- ត្រួតពិនិត្យ និងគ្រប់គ្រងការចេញលិខិតអនុញ្ញាត នាំចេញ-នាំចូលទំនិញតាមរបបគយអនុគ្រោះនានា តាមការកំណត់របស់ អគយ ព្រមទាំងមានភារកិច្ចតាមដានត្រួតពិនិត្យ ការប្រើប្រាស់សម្ភារបរិក្ខារ និងទំនិញគ្រប់ប្រភេទដែលទទួលបានការអនុគ្រោះនានាតាមទិសដៅដែលបានកំណត់
- ចាត់ចែងត្រួតពិនិត្យជាក្រោយលើប្រតិវេទន៍ និងឯកសារភ្ជាប់ ហើយសរុបលទ្ធផលនិងលើកឡើងនូវវិធានការសមស្របក្នុងករណីចាំបាច់
- បំពេញបេសកកម្មផ្សេងទៀត តាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## នាយកដ្ឋានរដ្ឋាករ

- លើកឡើងនូវគោលនយោបាយពន្ធនិងអាករ ការគ្រប់គ្រងផលិតកម្ម ការនាំចេញ-នាំចូល ការធ្វើចរាចរចែកចាយ ឬការធ្វើសន្និធិផលិតផលតេលសិលា និងផលិតផលជាប់អាករពិសេសផ្សេងទៀត តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- កសាងនូវផែនការមេ និងផែនការសកម្មភាពសម្រាប់អភិវឌ្ឍវិស័យរដ្ឋាករ និងសម្រាប់កិច្ចសម្រួលពាណិជ្ជកម្មតាមរបបគយនីមួយៗរបស់អង្គភាពគយនិងរដ្ឋាករ
- គ្រប់គ្រង ត្រួតពិនិត្យបែបបទនាំចេញ-នាំចូលការប្រមូលពន្ធនិងអាករ ការចែកចាយ ការដឹកជញ្ជូន ចរាចរ សន្និធិផលិតផលតេលសិលានៅទូទាំងប្រទេស នៅតាមមណ្ឌលឃ្លាំង ឬ អាជីវកម្មដ្ឋានផ្សេងៗ
- គ្រប់គ្រងកិច្ចដំណើរការរបស់បណ្តាអាជីវកម្មដ្ឋានផលិតទំនិញជាប់អាករពិសេស ហាងលក់ទំនិញរួចពន្ធ ការធ្វើបែបបទភណ្ឌិកាប្រេសណីយ៍ តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំង ចូលរួម សហការ ជាមួយ សមត្ថកិច្ចពាក់ព័ន្ធ ស្រាវជ្រាវ និងបង្ក្រាបបទល្មើសគយពាក់ព័ន្ធនឹងប្រតិបត្តិការអាជីវកម្មទាំងនេះ
- បំពេញបេសកកម្មផ្សេងទៀត តាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ

- ចូលរួមរៀបចំគោលនយោបាយគ្រប់គ្រងកិច្ចដំណើរការតំបន់រួចពន្ធនានានៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសបណ្តាតំបន់សេដ្ឋកិច្ចពិសេសទាំងអស់ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ជាធរមាន ការអនុវត្តល្អបំផុតជាអន្តរជាតិ និងអនុសញ្ញាទីក្រុងក្យូតូស្តីពីការធ្វើអោយសាមញ្ញ និងស៊ីចង្វាក់នៃនីតិវិធីគយសំដៅធានាអោយបាននូវភាពរលូនរហ័សក្នុងការបំពេញបែបបទលើទំនិញចេញ និងចូលតំបន់ទាំងនេះ
- ចូលរួមពិនិត្យជាមួយគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា លើសំណើសុំអនុញ្ញាតនាំចូលឧបករណ៍ សម្ភារបរិក្ខារ និងទំនិញផ្សេងទៀត សម្រាប់ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធតំបន់សេដ្ឋកិច្ចពិសេសរបស់អ្នកអភិវឌ្ឍន៍តំបន់
- សម្របសម្រួលអោយមានការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចប្រចាំការជាអចិន្ត្រៃយ៍ ជាមួយរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ក្នុងការពិនិត្យនិងសម្រេចនៅនឹងកន្លែងនូវការលើកទឹកចិត្តលើការនាំចូលសម្ភារបរិក្ខារផលិតកម្ម សម្ភារសាងសង់ និងធាតុចូលផលិតកម្មផ្សេងទៀតរបស់អ្នកវិនិយោគក្នុងតំបន់

- គ្រប់គ្រង ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់អនុលោមភាពនៃការអនុវត្តភារកិច្ច និងកាតព្វកិច្ចរបស់អ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគ ក្នុងតំបន់សេដ្ឋកិច្ចពិសេស ក្នុងពេលសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងមូលដ្ឋានផលិតកម្ម និងក្នុងពេលធ្វើអាជីវកម្ម
- គ្រប់គ្រង និងដឹកនាំបញ្ជាតាមឋានានុក្រមដោយផ្ទាល់លើអង្គភាពគយនិងរដ្ឋាករមានសមត្ថកិច្ចប្រចាំការតាមតំបន់រួចពន្ធ ឬ តំបន់សេដ្ឋកិច្ចពិសេស
- បំពេញបេសកកម្មផ្សេងទៀត តាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# ១.២. ខ្លឹមសារពាក់ព័ន្ធច្បាប់ស្តីពីគយ

## ១.២.១. បទប្បញ្ញត្តិទូទៅ

### ១.២.១.១. គោលបំណង

គោលបំណងនៃច្បាប់នេះគឺ÷

- ផ្តល់សិទ្ធិគ្រប់គ្រង ត្រួតពិនិត្យ ប្រមូលពន្ធ និងកម្រៃផ្សេងៗលើទំនិញនាំចេញ ឬនាំចូល
- ផ្តល់សិទ្ធិដាក់បទប្បញ្ញត្តិលើការធ្វើចរាចរ ការធ្វើសន្និធិ និងការដឹកជញ្ជូនឆ្លងកាត់នៃទំនិញនាំចេញ ឬនាំចូល
- ជំរុញការបង្ការ និងបង្ក្រាបអំពើល្មើស និងអំពើរត់ពន្ធ
- ចូលរួមអនុវត្តគោលនយោបាយពាណិជ្ជកម្មអន្តរជាតិរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- ជំរុញនូវការអនុវត្តតាមស្តង់ដាអន្តរជាតិ និងការអនុវត្តល្អប្រសើរ ដែលពាក់ព័ន្ធទៅនឹងការត្រួតពិនិត្យគយនិងការសម្រួលពាណិជ្ជកម្ម។

ទីចាត់ការគយនិងរដ្ឋាករ ជាស្ថាប័នទទួលខុសត្រូវក្នុងការគ្រប់គ្រង និងការអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ។ ស្ថាប័ននេះស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (មាត្រា១)

### ១.២.១.២. ដែនគយ និងទង់អំណាចគយ

ដែនគយមាន ដែនដី ដែនទឹក ដែនអាកាស និងកោះនានានៃព្រះរាជាណាចក្រកម្ពុជា។ រាជរដ្ឋាភិបាលមានសិទ្ធិបង្កើតតំបន់រួចពន្ធនានា ដែលមិនស្ថិតនៅក្រោមការអនុវត្តទាំងស្រុង ឬភាគខ្លះនូវនីតិវិធីគយ។

ច្បាប់នេះត្រូវអនុវត្ត÷

- ដូចគ្នានៅក្នុងដែនគយទាំងមូល
- ស្មើភាពគ្នាដោយឥតយោគយល់ចំពោះបុគ្គលណាឡើយ
- ដោយពុំមានផ្តល់នូវអភ័យឯកសិទ្ធិ ឬរួចផុតពីការអនុវត្តនៃច្បាប់នេះចំពោះទំនិញនាំចេញ និងនាំចូលដោយក្នុងនាមរដ្ឋ (មាត្រា ៣)

ទំនិញនាំចេញ ឬនាំចូលទាំងអស់ គឺជាកម្មវត្ថុនៃការអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ។ ទំនិញទាំងឡាយដែលចូលមកក្នុង ឬចេញពីដែនគយ ត្រូវជាប់ពន្ធនាំចូល ឬនាំចេញ និងអាករ ដូចចែងក្នុងតារាងពន្ធគយ។ បែបបទស្តីពីការរៀបចំ និងការអនុវត្តតារាងពន្ធគយត្រូវចែងលំអិតក្នុងអនុក្រឹត្យ (មាត្រា ៥)។

**វង់អំណាចគយមានមណ្ឌលសមុទ្រនិងមណ្ឌលដីគោក÷**

ក. មណ្ឌលសមុទ្រមានព្រំដែនពីឆ្នេរទៅក្រៅចម្ងាយម្ភៃ (២០) គីឡូម៉ែត្រ។

ខ. មណ្ឌលដីគោកលាតសន្ធឹង:

- ពីឆ្នេរសមុទ្រចូលមកក្នុងចម្ងាយម្ភៃ(២០) គីឡូម៉ែត្រ ព្រមទាំងដីចម្ងាយម្ភៃ(២០) គីឡូម៉ែត្រពីមាត់ទន្លេ មាត់ស្ទឹង មាត់ព្រែក ដែលហូរចាក់ទៅសមុទ្រមកទល់នឹងការិយាល័យគយនៅដើមគេង្អស់គិតពីសមុទ្រមក និងរង្វង់ម្ភៃ (២០) គីឡូម៉ែត្រ ជុំវិញការិយាល័យគយនេះ។
- តាមព្រំដែនដីគោកមកខាងក្នុងចម្ងាយម្ភៃ (២០) គីឡូម៉ែត្រ។
- ដើម្បីឱ្យងាយស្រួលដល់ការបង្ក្រាបបទល្មើស រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចចេញប្រកាស÷

  ក. ពង្រីក ជម្រៅ មណ្ឌល ដីគោក រហូតដល់ហុកសិប (៦០) គីឡូម៉ែត្រសម្រាប់ទីកន្លែង និងរយៈពេលកំណត់មួយ។

  ខ. កំណត់វង់អំណាចគយរហូតដល់បី (៣) គីឡូម៉ែត្រ ជុំវិញការិយាល័យគយដែលមិនស្ថិតក្នុងវង់អំណាចដូចមានចែងខាងលើ។

### ១.២.១.៣. វិធានការការពារផលិតករក្នុងស្រុក

រាជរដ្ឋាភិបាលអាចកំណត់បានដោយអនុក្រឹត្យចាត់វិធានការចាំបាច់នានា រាប់បញ្ចូលទាំងការដំឡើងអត្រាពន្ធ ដើម្បីការពារផលិតករកម្ពុជា នៅពេលដែលផលិតករក្នុងស្រុកត្រូវទទួលរងគ្រោះដោយកំណើននៃការនាំចូល ឬ ដោយឧបត្ថម្ភធនដែលបានផ្តល់ដោយរដ្ឋាភិបាលនៃប្រទេសផ្សេងទៀត ចំពោះការនាំចូលផលិតផលរបស់ខ្លួនមកកម្ពុជា ឬដោយការលក់បង្ខូចថ្លៃទំនិញនៅលើទីផ្សារកម្ពុជា (មាត្រា ៧)។

### ១.២.១.៤. ការជាប់អាយ៉ត ឬកម្រិតកំណត់

រាជរដ្ឋាភិបាលអាចកំណត់បានដោយអនុក្រឹត្យនូវមុខទំនិញមួយចំនួនឱ្យជាប់អាយ៉ត ឬកម្រិតកំណត់ក្រោមល័ក្ខខ័ណ្ឌលើការនាំចេញ និងនាំចូលក្នុងគោលបំណងណាមួយដូចតទៅ (មាត្រា ៨)÷

- សន្តិសុខជាតិ
- សណ្តាប់ធ្នាប់សាធារណៈ និងតាមស្តង់ដានៃសុភាវធម៌ និងសីលធម៌
- ការការពារសុខភាព និងជីវិតមនុស្ស សត្វ ឬរុក្ខជាតិ
- ការការពារបេតិកភណ្ឌជាតិ ដែលមានតម្លៃខាងសិល្បៈ ប្រវត្តិសាស្ត្រ ឬ បុរាណវត្ថុវិទ្យា
- ការអភិរក្សធនធានធម្មជាតិ
- ការតម្រូវតាមបញ្ញត្តិនានានៃច្បាប់ណាមួយជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- ការបំពេញកាតព្វកិច្ចក្រោមធម្មនុញ្ញសហប្រជាជាតិ

ដើម្បីប្រយុទ្ធប្រឆាំងអំពើល្មើសនិងអំពើរត់ពន្ធ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់នូវមុខទំនិញមានវេទយិតភាព ឬទំនិញដែលជាប់ពន្ធខ្ពស់ជាទំនិញកំណត់ពិសេស សម្រាប់គោលបំណងនៃច្បាប់នេះ ហើយអាចកំណត់បន្ថែមលើការត្រួតពិនិត្យ និងការដាក់កម្រិតបានលើការដឹកជញ្ជូន ចរាចរ សន្និធិ និងការកាន់កាប់រក្សាទំនិញ។

## ១.២.២. ការនាំចូល

ទំនិញនាំចូលទាំងអស់ ត្រូវបានរាយការណ៍នៅការិយាល័យគយ ឬ ទីកន្លែងផ្សេងទៀត ទៅតាមការកំណត់របស់នាយកទីចាត់ការគយ និងរដ្ឋាករ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវចេញប្រកាសកំណត់ពេលវេលា របៀបរបប តម្រូវការឯកសារ កាលៈទេសៈ និងការលើកលែងនានាពាក់ព័ន្ធនឹងការរាយការណ៍ពីទំនិញនាំចូល (មាត្រា ១០)។

គ្មានជនណាម្នាក់អាចបើទំនិញចេញពីមធ្យោបាយដឹកជញ្ជូនពេលមកដល់កម្ពុជាបានទេ មុនពេលដែលទំនិញទាំងនេះត្រូវបានរាយការណ៍ដល់គយស្របតាមច្បាប់នេះ លើកលែងតែក្នុងករណីដែលសុវត្ថិភាពមធ្យោបាយដឹកជញ្ជូនទំនិញ ជននានាលើមធ្យោបាយដឹកជញ្ជូន ឬ គតិយុត្តជនផ្សេងទៀតត្រូវបានគំរាមកំហែងក្នុងល័ក្ខខ័ណ្ឌមានអាសន្ន ដូចចែងក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (មាត្រា ១២)។

រដ្ឋបាលគយអាចអនុញ្ញាតឲ្យទំនិញដូចមានចែងក្នុងមាត្រា ១០ នៃច្បាប់នេះ យកចេញពីកន្លែងបំពេញបែបបទបញ្ចេញទំនិញពីគយមុនពេលបង់ពន្ធ អាករ និងកម្រៃនានាបន្ទាប់ពីបានបំពេញទម្រង់ការគយរួច និង នៅក្រោមការត្រួតពិនិត្យគយក្នុងគោលបំណង៖

- ធ្វើសន្និធិគយបណ្ដោះអាសន្ន
- ធ្វើសន្និធិគយមានដែនកំណត់
- ដឹកជញ្ជូនបន្តក្នុងរង្វង់ ឬតាមដែនគយ ឆ្លោះទៅគម្យដ្ឋានតាមតម្រាយផ្លូវស្របច្បាប់ និងក្នុងរយៈពេលកំណត់ដោយគយរួមមាន ការឆ្លងកាត់ ការផ្ទេរមធ្យោបាយដឹកជញ្ជូន ឬ ការដឹកជញ្ជូនឆ្ពោះទៅកាន់ មកពី ឬ រវាងការិយាល័យ និង ភណ្ឌាគារគយនានា (មាត្រា ១៣)។

ទំនិញនាំចូលទាំងឡាយ អាចទទួលបានការអនុញ្ញាតដោយរដ្ឋបាលគយ ឲ្យយកចេញតាមរបបប្រវេសន៍កាលិក ប្រសិនបើក្នុងពេលនាំចូលអាចត្រូវបានបង្ហាញថាទំនិញទាំងនោះនឹងត្រូវនាំចេញទៅវិញ។ ទំនិញនាំចូលបណ្ដោះអាសន្ន ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យគយ រហូតដល់ពេលដែលល័ក្ខខ័ណ្ឌផ្សេងៗតាមរបបប្រវេសន៍កាលិកត្រូវបានបំពេញរួច (មាត្រា ១៥)។

## ១.២.៣. ការនាំចេញ

ទំនិញគ្រប់ប្រភេទដែលនាំចេញត្រូវរាយការណ៍នៅការិយាល័យគយនិងរដ្ឋាករ ឬ ទីកន្លែងណាមួយតាមការកំណត់របស់នាយកទីចាត់ការគយនិងរដ្ឋាករ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់ពេលវេលា របៀបរបប តម្រូវការឯកសារ កាលៈទេសៈ និងការលើកលែងមួយចំនួនពាក់ព័ន្ធនឹងការរាយការណ៍ ចរាចរ សន្និធិនិងការដឹកជញ្ជូនទំនិញទាំងឡាយដែលត្រូវនាំចេញ (មាត្រា ១៦)។

## ១.២.៤. ចំណាត់ថ្នាក់តាមតារាង ដើមកំណើត និង តម្លៃគិតពន្ធ

ចំណាត់ថ្នាក់តាមតារាង ដើមកំណើត និងតម្លៃគិតពន្ធគយនៃទំនិញនាំចូលដែលបានបញ្ជាក់នៅក្នុងប្រតិវេទន៍គយ ត្រូវបានប្រកាសស្របទៅតាមវិធានដូចខាងក្រោមនេះ (មាត្រា ១៨)៖

- បុគ្គល អ្នកនាំចូល ឬ ភ្នាក់ងាររបស់ខ្លួនដែលបំពេញប្រតិវេទន៍គយនៃទំនិញនាំចូលត្រូវតែប្រកាសអំពីចំណាត់ថ្នាក់តាមតារាងពន្ធ និងដើមកំណើតនៃទំនិញទាំងនោះដើម្បីធ្វើការគណនាពន្ធ និងអាករ។ រដ្ឋបាលគយត្រូវធ្វើការផ្ទៀងផ្ទាត់ចំណាត់ថ្នាក់តាមតារាង និងដើមកំណើតនៃទំនិញនាំចូល។
- បុគ្គល អ្នកនាំចូល ឬ ភ្នាក់ងាររបស់ខ្លួនត្រូវទទួលខុសត្រូវក្នុងការប្រកាសឱ្យបានត្រឹមត្រូវនូវតម្លៃគិតពន្ធគយ ដើម្បីបង់ប្រាក់ពន្ធ និងអាករ និងត្រូវលាតត្រដាងរាល់ព័ត៌មានទាំងអស់វិក្កយបត្រ និងឯកសារផ្សេងទៀត ដើម្បីឱ្យរដ្ឋបាលគយអាចផ្ទៀងផ្ទាត់ និងធ្វើការកំណត់ឱ្យបានត្រឹមត្រូវនូវតម្លៃគិតពន្ធគយនៃទំនិញនាំចូល។
- ក្នុងរយៈពេលបី (៣) ឆ្នាំ គិតចាប់ពីថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ បន្ទាប់ពីការធ្វើសវនកម្ម ការស៊ើបអង្កេត អធិការកិច្ច ឬការត្រួតពិនិត្យឡើងវិញនូវទំនិញនាំចូល រដ្ឋបាលគយអាចកំណត់ឡើងវិញនូវចំណាត់ថ្នាក់តាមតារាង ឬដើមកំណើត ដែលបានប្រកាសដោយចេញនូវប្រវេសន៍។
- នៅពេលដែលការធ្វើសវនកម្ម ការស៊ើបអង្កេត អធិការកិច្ច ឬ ការត្រួតពិនិត្យឡើងវិញ ត្រូវបានធ្វើឡើងនៅក្រោមមាត្រានេះ បានរកឃើញនូវសកម្មភាពខុសឆ្គងណាមួយនោះ ប្រវេសន៍ត្រូវបានចេញចំពោះតែទំនិញដែលស្ថិតនៅក្រោមការស៊ើបអង្កេត ក្នុងរយៈពេលមិនលើសពីដប់ (១០) ឆ្នាំគិតពីថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ។
- ពន្ធ និងអាករបន្ថែម កម្រៃផ្សេងទៀត និងការពិន័យទាំងអស់ ដែលជាប់ពីការចេញប្រវេសន៍នេះ ត្រូវតែបង់ជូនរដ្ឋបាលគយ។
- រាល់ការបង្វិលសងវិញណាមួយនូវពន្ធ អាករ កម្រៃ និងការពិន័យដែលបានបង់លើស ដោយបុគ្គលអ្នកនាំចូល ឬ ភ្នាក់ងាររបស់ខ្លួនដែលកើតឡើងពីការចេញប្រវេសន៍ត្រូវតែបង្វិលសងវិញដោយរដ្ឋបាលគយ។

សម្រាប់គោលបំណងនៃការនាំចេញ និងនាំចូលទំនិញទាំងឡាយត្រូវបានធ្វើចំណាត់ថ្នាក់ ហើយពន្ធ និងអាករត្រូវបានគណនាស្របតាមតារាងពន្ធគយ វៀរលែងតែត្រូវបានលើកលែងដោយច្បាប់នេះ ឬ ច្បាប់ផ្សេងទៀតជាធរមាននៃព្រះរាជាណាចក្រកម្ពុជា (មាត្រា ១៩)។

សម្រាប់ការនាំចូល ការប្រមូលពន្ធ និងអាករនានា ត្រូវអនុវត្តស្របតាមដើមកំណើតនៃទំនិញ។ ដើមកំណើតនៃផលិតផលធម្មជាតិនានាគឺជាប្រទេសដែលផលិតផលនោះត្រូវបានប្រមូល ឬ ទាញពីដី។ ទំនិញឧស្សាហផលដែលបានផលិតនៅក្នុងប្រទេសតែមួយ ដោយពុំមានការដាក់បញ្ចូលវត្ថុធាតុដើមពីប្រទេសដទៃ គឺមានដើមកំណើតពីប្រទេសដែលឧស្សាហផលនោះត្រូវបានផលិត។ ប្រទេសនាំចេញគឺជាប្រទេសដែលទំនិញត្រូវបានគេបញ្ជូនដោយត្រង់សំដៅមកដែនគយ (មាត្រា ២០)។

**តម្លៃគិតពន្ធគយលើទំនិញនាំចូល ត្រូវបានកំណត់ទៅតាមវិធានដូចខាងក្រោមនេះ (មាត្រា ២១) ÷**

ក. តម្លៃគិតពន្ធគយលើទំនិញនាំចូល គឺជាតម្លៃចម្លងការ មានន័យថាថ្លៃដែលបានទូទាត់ ឬ នឹងត្រូវទូទាត់ពិតប្រាកដ លើទំនិញដែលបានលក់សម្រាប់នាំចេញមកព្រះរាជាណាចក្រកម្ពុជា ស្របតាមបញ្ញត្តិនៃប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចមានកំណត់ក្នុងវាក្យខណ្ឌ ជ នៃមាត្រានេះ។

ខ. ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលពុំអាចត្រូវបានកំណត់ក្រោមបញ្ញត្តិ នៃវាក្យខណ្ឌ ក នៃមាត្រានេះ តម្លៃគិតពន្ធគយគឺជាតម្លៃចម្លងការនៃទំនិញដូចគ្នា។

គ. ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលពុំអាចត្រូវបានកំណត់ក្រោមបញ្ញត្តិ នៃវាក្យខណ្ឌ ក និងវាក្យខណ្ឌ ខ នៃមាត្រានេះ តម្លៃគិតពន្ធគយគឺជាតម្លៃចម្លងការនៃទំនិញប្រហាក់ប្រហែលគ្នា។

ឃ. ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលពុំអាចត្រូវបានកំណត់ក្រោមបញ្ញត្តិនៃវាក្យខណ្ឌ ក វាក្យខណ្ឌ ខ និងវាក្យខណ្ឌ គ នៃមាត្រានេះ តម្លៃគិតពន្ធគយត្រូវផ្អែកលើវិធីសាស្ត្រអនុមាន។

ង. ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលពុំអាចត្រូវបានកំណត់ក្រោមបញ្ញត្តិនៃវាក្យខណ្ឌ ក វាក្យខណ្ឌ ខ វាក្យខណ្ឌ គ និងវាក្យខណ្ឌ ឃ នៃមាត្រានេះ តម្លៃគិតពន្ធគយត្រូវផ្អែកលើវិធីសាស្ត្រគណនា។

ច. លំដាប់នៃការអនុវត្តនៃវាក្យខណ្ឌ ឃ និងវាក្យខណ្ឌ ង នៃមាត្រានេះអាចត្រូវត្រឡប់ចុះឡើង បានតាមសំណើរបស់អ្នកនាំចូល។

ឆ. ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលពុំអាចត្រូវបានកំណត់ក្រោមបញ្ញត្តិនៃវាក្យខណ្ឌ ក វាក្យខណ្ឌ ខ វាក្យខណ្ឌ គ វាក្យខណ្ឌ ឃ និងវាក្យខណ្ឌ ង នៃមាត្រានេះ តម្លៃគិតពន្ធគយត្រូវផ្អែកលើមូលដ្ឋានទិន្នន័យដែលមានស្រាប់ក្នុងដែនគយក្រោមល័ក្ខខ័ណ្ឌច្បាស់លាស់។

ជ. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ រដ្ឋមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ ត្រូវចេញប្រកាសកំណត់នូវរាល់បញ្ហាដែលពាក់ព័ន្ធនឹងការកំណត់តម្លៃគិតពន្ធគយ។

តម្លៃគិតពន្ធគយនៃទំនិញនាំចេញ គឺជាតម្លៃទំនិញនៅចំណុចនាំចេញ។ តម្លៃគិតពន្ធគយនេះនឹងត្រូវកំណត់ដោយបូកថ្លៃដឹកជញ្ជូនទំនិញរួមទាំងរាល់ចំណាយទាំងឡាយ ដែលត្រូវបង់សម្រាប់ប្រតិបត្តិការនាំចេញរហូតដល់ព្រំដែន លើកលែងអាករនាំចេញ អាករក្នុងប្រទេស និងបន្ទុកប្រហាក់ប្រហែលដែលអ្នកនាំចេញបានបង់និងមានបង្កាន់ដៃ (មាត្រា ២២)។

## ១.២.៥. ការលើកលែង ការលើកលែងជាភាគ និងការបង្វិលសងវិញនូវពន្ធ និងអាករ

ទំនិញដែលចូលក្នុងដែនគយសម្រាប់ឆ្លងកាត់ ឬ ផ្ទេរ មធ្យោបាយដឹកជញ្ជូន មិនត្រូវជាប់ពន្ធ និងអាករនាំចូលឡើយ (មាត្រា ២៥)។

ការលើកលែងពន្ធនិងអាករនាំចូលត្រូវអនុញ្ញាតផ្តល់ជូនចំពោះទំនិញបេសកកម្មការទូត ឬ បេសកកម្មកុងស៊ុលបរទេស អង្គការអន្តរជាតិ និងភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលផ្សេងទៀត និងក្រោមបញ្ញត្តិនៃច្បាប់ផ្សេងទៀតរបស់ព្រះរាជាណាចក្រកម្ពុជា (មាត្រា ២៦)។

ការលើកលែងជាភាគនៃពន្ធ អាករនាំចូលអាចនឹងផ្តល់ជូនចំពោះការនាំចូល ពូជដំណាំ និងពូជសត្វសម្រាប់កសិកម្ម ទំនិញនាំចូលបណ្តោះអាសន្ន និងទំនិញ និងសម្ភារដែលមានចែងក្នុងច្បាប់ផ្សេងទៀតរបស់ព្រះរាជាណាចក្រកម្ពុជា (មាត្រា ២៧)។

## ១.២.៦. ប្រតិវេទន៍គយ

រាល់ទំនិញនាំចូល ឬ នាំចេញ ទោះជាជាប់ពន្ធ និងអាករក្តី ឬ ត្រូវបានលើកលែងពន្ធ និងអាករ ទំនិញទាំងនោះត្រូវតែជាកម្មវត្ថុនៃការធ្វើប្រតិវេទន៍គយ (មាត្រា ២៩)។ រាល់ទំនិញនាំចូល ឬ នាំចេញត្រូវប្រកាសដោយម្ចាស់ទំនិញ ឬ ដោយបុគ្គលដែលបានទទួលការអនុញ្ញាតឱ្យបំពេញបែបបទគយក្នុងនាមម្ចាស់ទំនិញ (មាត្រា ៣១)

បុគ្គលណាដែលគ្មានវិជ្ជាជីវៈជាជើងសាគយ អាចបំពេញប្រតិវេទន៍គយបានសម្រាប់អាជីវកម្មខ្លួន (មាត្រា ៣៣)។

អ្នកនាំចូល ឬ ម្ចាស់ទំនិញត្រូវទទួលខុសត្រូវចំពោះពន្ធ និងអាករនាំចូល។ ក្នុងករណីដែលអ្នកនាំចូល ឬ ម្ចាស់ទំនិញមិនត្រូវបានរកឃើញ ភ្នាក់ងារជើងសាគយត្រូវទទួលខុសត្រូវចំពោះពន្ធ និងអាករនាំចូល (មាត្រា ៣៥)។

## ១.២.៧. សន្និធិគយបណ្តោះអាសន្ន និងឃ្លាំងគយមានដែនកំណត់

សន្និធិគយបណ្តោះអាសន្ន គឺសំដៅលើសន្និធិទំនិញដែលស្ថិតនៅក្រោមការត្រួតពិនិត្យគយ នៅកន្លែងដែលទទួលការអនុញ្ញាត ដើម្បីរង់ចាំការបំពេញបែបបទបញ្ចេញទំនិញពីគយ។ អាជ្ញាប័ណ្ណសម្រាប់ប្រតិបត្តិការទីកន្លែងសន្និធិគយបណ្តោះអាសន្ន ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (មាត្រា ៤៣)។

ភណ្ឌាគារគយមានដែនកំណត់គឺជាទីកន្លែងដែលទំនិញត្រូវបានដាក់ សម្រាប់រយៈពេលជាក់លាក់មួយស្ថិតនៅក្រោមការត្រួតពិនិត្យគយ ដោយមានបញ្ជាក់ពីពេលវេលាច្បាស់លាស់។ ការដាក់ទំនិញក្នុងភណ្ឌាគារគយមានដែនកំណត់ ត្រូវបានព្យួរការបង់ពន្ធ អាករ និងការដាក់កម្រិតកំណត់ដែលទំនិញទាំងនោះត្រូវជាប់។ ភណ្ឌាគារគយមានដែនកំណត់មានបីប្រភេទ÷

ក. ភណ្ឌាគារសាធារណៈ ដែលទទួលការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចធ្វើប្រតិបត្តិការដោយភ្នាក់ងាររបស់រាជរដ្ឋាភិបាល ឬ ដោយបុគ្គលណាមួយបាន។ ភណ្ឌាគារនេះត្រូវបានប្រើប្រាស់សម្រាប់ផ្តល់សេវាដល់បុគ្គលទាំងឡាយដែលមានសិទ្ធិធ្វើសន្និធិទំនិញ។

ខ. ភណ្ឌាគារឯកជន ត្រូវបានផ្តល់ការអនុញ្ញាត ដោយនាយកទីចាត់ការគយនិងរដ្ឋាករ ត្រូវបាន ប្រើប្រាស់ដោយឡែក ដោយបុគ្គលណាម្នាក់ សម្រាប់ធ្វើសន្និធិទំនិញ ដើម្បីការប្រើប្រាស់ ដោយឡែក រាប់បញ្ចូលទាំងប្រតិបត្តិករអគារលក់ ទំនិញរួចពន្ធ។

គ. ភណ្ឌាគារពិសេស គឺជាភណ្ឌាគារដែលទទួល បាន សិទ្ធិពី នាយកទីចាត់ការគយ និង រដ្ឋាករ សម្រាប់ថែរក្សាប្រភេទទំនិញគ្រោះថ្នាក់ប៉ះពាល់ ដល់គុណភាពទំនិញដ៏ទៃទៀត ឬ អាចត្រូវការ ទីកន្លែងពិសេសសម្រាប់រក្សាទំនិញទាំងនោះ។

អាជ្ញាប័ណ្ណសម្រាប់ភណ្ឌាគារគយមានដែនកំណត់ ត្រូវ កំណត់នូវល័ក្ខខ័ណ្ឌសម្រាប់ម្ចាស់កម្មសិទ្ធិ និងប្រតិបត្តិករ រាប់បញ្ចូលទាំងទីតាំង សំណង់ គម្រោងអគារ នីតិវិធី សម្រាប់ចាត់ចែង និងគ្រប់គ្រង (មាត្រា ៤៨)។

ទំនិញអាចរក្សាទុកក្នុងភណ្ឌាគារគយមានដែនកំណត់ រហូតដល់រយៈពេលពីរ (២) ឆ្នាំគិតពីថ្ងៃចុះបញ្ជិកា (មាត្រា ៤៦)។

ស្ថិតក្នុងកាលៈទេសៈជាក់ស្តែង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចអនុញ្ញាតឱ្យបង្កើតភណ្ឌាគារផលិតកម្ម មានដែនកំណត់ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គយ ក្នុងគោលបំណងកែច្នៃ និងផលិតទំនិញ។ ផលិតផល ដែលដាក់ចូលក្នុងភណ្ឌាគារផលិតកម្មមានដែនកំណត់ ត្រូវព្យួរពន្ធ និងអាករនាំចូល (មាត្រា ៤៩)។

ប្រតិបត្តិការកែច្នៃ ឬ ចំរាញ់គេលសិលាឆៅ ឬ បីទីម ខនិជ ដើម្បីទទួលបានផលិតផលគេលសិលា ត្រូវដាក់ ឱ្យស្ថិតនៅក្រោមរបបភណ្ឌាគារផលិតកម្មមានដែន កំណត់បាន (មាត្រា ៥០)។

# ១.៣. ពន្ធនិងអាករ

## ១.៣.១. ប្រព្រឹត្តកម្មធម្មតា

ពន្ធ និងអាករ ត្រូវប្រមូលលើទំនិញនាំចេញ នាំចូល មុនពេលបញ្ចេញទំនិញទាំងនេះពីគយ លើកលែងតែក្នុងករណី ពិសេស ដែលពន្ធ និងអាករត្រូវបានព្យួរ។

ប្រភេទពន្ធ និងអាករប្រមូលដោយគយមានដូចខាងក្រោម÷

| លរ. | ប្រភេទពន្ធនិងអាករ | អត្រាពន្ធ |
|---|---|---|
| **I.** នាំចូល | | |
| ១ | ពន្ធគយ | 0%; ៧%; ១៥%; ៣៥% |
| ២ | អាករពិសេស | 0%; ៤,៣៥%; ៥%; ១0%; ១៥%; ២៥%; ៣0%; ៤៥%; ៥0% |
| ៣ | អាករបន្ថែម | 0,0២$/លីត្រ លើប្រេងសាំង, 0,0៤$/លីត្រ ចំពោះប្រេងម៉ាស៊ូត |
| ៤ | អាករលើតម្លៃបន្ថែម | ១0% |
| **II.** នាំចេញ | | |
| ១ | អាករនាំចេញ | 0%, ៥%, ១0%, ១៥%, ២0%, ៥0% |

*ប្រភព÷ តារាងពន្ធគយឆ្នាំ២០១២ បោះពុម្ពលើកទី៣ ខែមករា ឆ្នាំ២០១៥*

## ១.៣.២. ប្រព័ន្ធអនុគ្រោះពន្ធ

| ក្របខ័ណ្ឌកិច្ចព្រមព្រៀង | កម្មវិធីអនុវត្តន៍ |
|---|---|
| **ពាណិជ្ជកម្មទំនិញអាស៊ាន (ATIGA)** | **ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**<br>• ព្រះរាជក្រមលេខ ០៨/០៩.០១៧ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៩<br>• ប្រកាសលេខ ២៨៨ សហវ ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ២០១១ ស្តីពីការអនុញ្ញាតឲ្យប្រើកម្មវិធីកាត់បន្ថយ ឬ លុបពន្ធនាំចូលរបស់កម្ពុជាក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន។<br><br>ប្រទេសកម្ពុជាត្រូវលុបពន្ធនាំចូលលើគ្រប់ផលិតផលទាំងអស់ត្រឹមឆ្នាំ២០១៥ ដោយមានភាពទន់ភ្លន់ដល់ឆ្នាំ២០១៨ តាមរយៈកម្មវិធីដូចខាងក្រោម ÷<br>– ៨០% នៃបន្ទាត់ពន្ធគយសរុបត្រូវបញ្ចុះមកនៅត្រឹម 0-៥% ត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩<br>– ពន្ធនាំចូលលើផលិតផល Information and Communication Technology-ICT ត្រូវបញ្ចុះមក0% ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១០<br>– ពន្ធនាំចូលលើផលិតផលកសិកម្មមិនទាន់កែច្នៃ នៅក្នុងបញ្ជីរវទយិត SL ត្រូវកាត់បន្ថយ ឬ លុបមក 0-៥% នៅឆ្នាំ២០១៧។<br>– ពន្ធនាំចូលលើផលិតផលកសិកម្មមិនទាន់កែច្នៃនៅក្នុងបញ្ជីរវទយិតខ្ពស់ HSL ត្រូវអនុវត្តតាមអត្រា MFN ជាធរមាន។<br>– ពន្ធនាំចូលលើផ្នែកសមាហរណកម្មអាទិភាព Priority Integration Sector-PIS ត្រូវលុបមក0% នៅឆ្នាំ២០១២។<br>– ពន្ធនាំចូលលើផ្នែកសមាហរណកម្មអាទិភាព Priority Integration Sector-PIS Negative List PIS-NL ត្រូវលុបមក0% នៅឆ្នាំ២០១៥។<br>– ព្រះរាជាណាចក្រកម្ពុជាអាចរក្សាទុកអត្រាពន្ធ ៥% ចំនួន ៧% នៃបន្ទាត់ពន្ធគយសរុប ឬ ស្មើនឹង ៦៦២ បន្ទាត់ពន្ធរហូតដល់ឆ្នាំ២០១៨។ |
| **កិច្ចសហប្រត្តិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងអាស៊ាន និងសាធារណរដ្ឋប្រជាមានិតចិន (ACFTA)** | **ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**<br>• ព្រះរាជក្រមលេខ ១២០៧/០៣៣ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧<br>• ប្រកាសលេខ ៦៤៥ សហវ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៨ ស្តីពីការអនុញ្ញាតឲ្យប្រើកម្មវិធីកិច្ចព្រមព្រៀងរបស់ព្រះរាជាណាចក្រកម្ពុជាស្តីពីកិច្ចសហប្រត្តិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងអាស៊ាន និងសាធារណរដ្ឋប្រជាមានិតចិន។<br><br><u>ផ្លូវធម្មតា</u><br>– ៥០% នៃបន្ទាត់ពន្ធគយសរុបត្រូវបន្ថយមក0-៥% ត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ និង |

| ក្របខ័ណ្ឌ<br>កិច្ចព្រមព្រៀង | កម្មវិធីអនុវត្តន៍ |
|---|---|
| | – បន្តលុបពន្ធគយរហូតត្រឹមថ្ងៃទី០១ ខែមករា ២០១៥ ដោយមានភាពទន់ភ្លន់ដល់ឆ្នាំ២០១៨។<br><br><u>បញ្ជីរវេទយិត</u><br>– ប្រទេសកម្ពុជាអាចរក្សាទុក ៥០០ បន្ទាត់ពន្ធគយក្នុងបញ្ជី SL ដោយបញ្ចុះមក 0-៥% មុនថ្ងៃទី០១ ខែមករា ឆ្នាំ២០២០<br><br><u>បញ្ជីរវេទយិតខ្ពស់</u><br>– ប្រទេសកម្ពុជាអាចរក្សាទុកមិនលើសពី ៤០%នៃបន្ទាត់ពន្ធសរុបក្នុងបញ្ជីរវេទយិតភាពខ្ពស់ |
| **កិច្ចសហប្រត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងអាស៊ាន និងសាធារណរដ្ឋកូរ៉េ (AKFTA)** | **ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**<br>• ព្រះរាជក្រមលេខ ១២០៧/០៣៤ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧<br>• ប្រកាសលេខ ៦១៣សហវ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៨ ស្តីពីការអនុញ្ញាតឲ្យប្រើកម្មវិធីកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងអាស៊ាននិងសាធារណរដ្ឋកូរ៉េ។<br><br><u>ផ្លូវធម្មតា</u><br>– ប្រទេសកម្ពុជាត្រូវកាត់បន្ថយយ៉ាងតិច៥០%នៃបន្ទាត់ពន្ធគយសរុប ដែលស្ថិតនៅក្នុងផ្លូវធម្មតាមក0-៥%មិនឲ្យយឺតជាងខែមករា ឆ្នាំ២០១៥ និង៩០%នៃបន្ទាត់ពន្ធត្រូវលុបឲ្យបានមុនខែមករា ឆ្នាំ២០១៧។ បន្ទាត់ពន្ធទាំងអស់ក្នុងបញ្ជី NT ត្រូវបញ្ចុះមក 0% ឲ្យបានមុនខែមករា ២០១៨ ដោយមានភាពទន់ភ្លន់ដល់ឆ្នាំ២០២០។<br><br><u>បញ្ជីរវេទយិត</u><br>– ប្រទេសកម្ពុជាត្រូវកាត់បន្ថយអត្រាពន្ធគយដែលស្ថិតនៅក្នុងបញ្ជីរវេទយិតដល់ ២0% មិនឲ្យយូរជាងថ្ងៃទី០១ ខែមករា ឆ្នាំ២០២០។ បន្ទាត់ពន្ធទាំងអស់ក្នុងបញ្ជី SL ត្រូវកាត់បន្ថយជាបន្តបន្ទាប់មក0-៥% មុនថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤។<br><br><u>បញ្ជីរវេទយិតខ្ពស់</u><br>– ប្រទេសកម្ពុជាត្រូវកាត់បន្ថយអត្រាពន្ធគយស្ថិតនៅក្នុងបញ្ជីរវេទយិតភាពខ្ពស់មិនលើស៥0% នៃបន្ទាត់ពន្ធសរុបឲ្យបានមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ |

<table>
<tr><th>ក្របខ័ណ្ឌ<br>កិច្ចព្រមព្រៀង</th><th>កម្មវិធីអនុវត្តន៍</th></tr>
<tr><td>ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងប្រទេសជាសមាជិកអាស៊ាននិងប្រទេសជប៉ុន (AJCEP)</td><td>ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ<br>• ព្រះរាជក្រមលេខ ១០០៩/០១៩ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩<br>• ប្រកាសលេខ ១៣៧៦ សហវ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការអនុញ្ញាតឲ្យប្រើប្រាស់កម្មវិធីកិច្ចព្រមព្រៀងស្តីពីភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងប្រទេសជាសមាជិកអាស៊ាននិងប្រទេសជប៉ុន តាមកម្មវិធីដូចខាងក្រោម។<br><br><u>ផ្លូវធម្មតាទី១</u><br>– អត្រាពន្ធគយស្ថិតក្នុងបញ្ជី NT1 ត្រូវបន្ថយមក 0% នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១០<br><br><u>ផ្លូវធម្មតាទី២</u><br>– ៤០%នៃបន្ទាត់ពន្ធគយត្រូវកាត់បន្ថយដល់៥% ត្រឹមឆ្នាំ២០២០ និង៩០%នៃបន្ទាត់ពន្ធគយត្រូវលុបត្រឹមឆ្នាំ២០២៣ ហើយ ១០០%នៃបន្ទាត់ពន្ធគយត្រូវលុបត្រឹមឆ្នាំ២០២៦។<br><br><u>បញ្ជីវេទយិតខ្ពស់ ឬ ប្រភេទ C</u><br>– ប្រទេសកម្ពុជាត្រូវដាក់៤%នៃបន្ទាត់ពន្ធគយក្នុងប្រភេទ C ឬ បញ្ជីវេទយិតខ្ពស់។<br><br><u>បញ្ជីវេទយិតឬ ប្រភេទ R</u><br>– ប្រទេសកម្ពុជាត្រូវដាក់៨%នៃបន្ទាត់ពន្ធគយក្នុងប្រភេទ R ឬ បញ្ជីវេទយិត។<br><br><u>បញ្ជីលើកលែង ឬ ប្រភេទ X</u><br>– ប្រទេសកម្ពុជាត្រូវដាក់៣%នៃបន្ទាត់ពន្ធក្នុងបញ្ជីលើកលែង។</td></tr>
<tr><td>តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវ៉ែលហ្សេឡង់ (AANZFTA)</td><td>ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ<br>• ព្រះរាជក្រមលេខ ១០១០/០១៦ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១០<br>• ប្រកាសលេខ ១១៩៩ សហវ.ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការអនុញ្ញាតឲ្យប្រើប្រាស់កម្មវិធីកាត់បន្ថយឬ លុបពន្ធនាំចូលរបស់ព្រះរាជាណាចក្រកម្ពុជាក្រោមកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវ៉ែលហ្សេឡង់។<br><br><u>ផ្លូវធម្មតាទី១ និងទី២</u><br>– ៨៨%នៃបន្ទាត់ពន្ធគយត្រូវកាត់បន្ថយនៅឆ្នាំ២០២១ សម្រាប់ផ្លូវធម្មតាទី១ និង២០២៤ សម្រាប់ផ្លូវធម្មតាទី២</td></tr>
</table>

| ក្របខ័ណ្ឌ<br>កិច្ចព្រមព្រៀង | កម្មវិធីអនុវត្តន៍ |
|---|---|
| | <u>បញ្ជីវេទយិត</u><br>– ៧%នៃបន្ទាត់ពន្ធគយសរុបត្រូវកាត់បន្ថយដល់ ៥% ក្នុងឆ្នាំ២០២៥។<br><u>បញ្ជីវេទយិតខ្ពស់</u><br>– ប្រទេសកម្ពុជាអាចដាក់ចំនួន ៣.៤៥%នៃបន្ទាត់ពន្ធគយសរុបក្នុងបញ្ជីវេទយិតខ្ពស់។<br><u>បញ្ជីលើកលែង</u><br>– ប្រទេសកម្ពុជាអាចដាក់ ១.៥០% នៃបន្ទាត់ពន្ធគយសរុបក្នុងបញ្ជីលើកលែងទូទៅ។ |
| **តំបន់ពាណិជ្ជកម្មសេរីរវាងប្រទេសសមាជិកអាស៊ាន និងប្រទេសឥណ្ឌា (AIFTA)** | **ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**<br>• ព្រះរាជក្រឹត្យលេខ ០២១១/០០៤ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១<br>• ប្រកាសលេខ ៣៨៩ សហវ.ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការអនុញ្ញាតឲ្យប្រើកម្មវិធីកាត់បន្ថយ ឬ លុបពន្ធនាំចូលរបស់ព្រះរាជាណាចក្រកម្ពុជា ក្រោមកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីរវាងប្រទេសសមាជិកអាស៊ាន និងប្រទេសឥណ្ឌា។<br><u>ផ្លូវធម្មតាទី១</u><br>– អត្រាពន្ធគយត្រូវកាត់បន្ថយ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១០<br><u>ផ្លូវធម្មតាទី២</u><br>– អត្រាពន្ធគយត្រូវកាត់បន្ថយ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩<br><u>បញ្ជីវេទយិត</u><br>– អត្រាពន្ធគយត្រូវកាត់បន្ថយ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩<br><u>ផលិតផលពិសេស</u><br>– ដូចជាៈ ប្រេងដូង កាហ្វេ តែខ្មៅ និងម្រេច ដែលត្រូវកាត់បន្ថយចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩ |

| ក្របខ័ណ្ឌកិច្ចព្រមព្រៀង | កម្មវិធីអនុវត្តន៍ |
|---|---|
| **ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ RCEP** | • ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់ (RCEP) គឺជាកិច្ចចរចាពាណិជ្ជកម្មសេរី (FTA) មួយដែលត្រូវបានបង្កើតឡើងក្នុងចំណោមប្រទេសទាំង១៦ ÷ មានសមាជិកអាស៊ានទាំង ១០ប្រទេស (ប្រ៊ុយណេ កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម) និង ប្រទេសទាំងប្រាំមួយទៀតដែលមានស្រាប់នូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយអាស៊ាន (FTAs) មានដូចជាប្រទេសអូស្ត្រាលី ចិន ឥណ្ឌា ជប៉ុន កូរ៉េ និងនូវែលសេឡង់។ ទាក់ទងជាមួយនឹង RCEP ទាំងប្រាំមួយ ប្រទេសដែលមិនមែនជាសមាជិកអាស៊ានទាំងនោះត្រូវបានគេស្គាល់ថាជាដៃគូពាណិជ្ជកម្មសេរីអាស៊ាន ( AFPs)។<br>• បន្ទាប់ពីដំណើរត្រៀមរៀបចំ បណ្ដាប្រទេសដែលបានចូលរួមបានចាប់ផ្ដើមកិច្ចចរចាជាផ្លូវការ នៅក្នុងខែឧសភា ឆ្នាំ២០១៣។ RCEP នឹងគ្របដណ្ដប់ការធ្វើពាណិជ្ជកម្មទំនិញ ពាណិជ្ជកម្មសេវាកម្ម ការវិនិយោគ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេស កម្មសិទ្ធិបញ្ញា ការប្រកួតប្រជែង ការដោះស្រាយវិវាទ/បញ្ហាផ្លូវច្បាប់ និងបញ្ហារបស់ស្ថាប័ន ព្រមទាំងបញ្ហាផ្សេងទៀតដើម្បីត្រូវបានបញ្ជាក់កំឡុងពេលនៃការចរចានេះ។ |

ជំពូក

# ២ នីតិវិធីគយ

## ២.១. នីតិវិធីទូទៅ

### ២.១.១. នីតិវិធីប្រតិវេទន៍គយ

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**

- ប្រកាសលេខ ១៤៤៧ សហវ.ប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីបញ្ញត្តិ និងនីតិវិធីប្រតិវេទន៍គយ
- សេចក្តីណែនាំលេខ ១៣០៨ អគរ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីនីតិវិធីលំអិត និងភារកិច្ចទទួលខុសត្រូវក្នុងដំណើរការប្រតិវេទន៍គយ

### ២.១.១.១. នីតិវិធីប្រតិវេទន៍គយតាមប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ

ការដាក់ប្រតិវេទន៍គយ (ឯកសាររដ្ឋបាលតែមួយ Single Administrative Document-SAD) តាម ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (Automated System for Customs Data -ASYCUDA) មានដំណើរការតាមគំនូសបំព្រួញដូចខាងក្រោម÷




ការដាក់ឲ្យដំណើរការប្រព័ន្ធ ASYCUDA ផ្តល់លទ្ធភាពឲ្យដាក់ប្រតិវេទន៍គយ និងឯកសារពាក់ព័ន្ធផ្សេងទៀតតាមមធ្យោបាយអេឡិចត្រូនិក។

នីតិវិធីទូទៅដែលអ្នកនាំចូល នាំចេញ និងអ្នកតំណាងត្រូវអនុវត្តតាម សម្រាប់ ការដាក់ ប្រតិវេទន៍ គយ តាមមធ្យោបាយអេឡិចត្រូនិក តាមនីតិវិធីដូចខាងក្រោម។

#### ១. ការរៀបចំ និងការបោះពុម្ពប្រតិវេទន៍គយ

ជើងសាគយ ឬ ប្រតិវេទករត្រូវបំពេញប្រតិវេទន៍គយដោយផ្ទាល់ទៅក្នុងប្រព័ន្ធ ASYCUDA។ ប្រព័ន្ធនេះនឹងឆែកពិនិត្យប្រតិវេទន៍ ផ្ទៀងផ្ទាត់ទៅនឹងឯកសារយោងដែលមាន នៅក្នុង ប្រព័ន្ធ និង ដំណើរការ ត្រួតពិនិត្យមួយចំនួន។ ប្រព័ន្ធនឹងអនុញ្ញាតឲ្យចុះបញ្ជិការួច អាចទុកជាមោឃៈបានបន្ទាប់ពីមានការអនុញ្ញាតពី អគរ ។ មានតែប្រតិវេទន៍ដែលចុះបញ្ជីការួចប៉ុណ្ណោះ ត្រូវបានចាត់ទុកជាឯកសារគតិយុត្ត។

បន្ទាប់ពីចុះបញ្ជិការួច ជើងសា ឬ ប្រតិវេទករត្រូវបោះពុម្ព និង ចុះហត្ថលេខា លើ ប្រតិវេទន៍ ចុះបញ្ជី ការួច ចំនួន ២ច្បាប់ ដាក់ជូនមន្ត្រីគយមានសមត្ថកិច្ច ដោយភ្ជាប់ជាមួយនូវឯកសារយោងទាំងអស់ដែលតម្រូវ។

ប្រព័ន្ធដំណើរការដោយស្វ័យប្រវត្តិ ជូនជាព័ត៌មានដល់ជើងសាគយ ឬ ប្រតិវេទករពីស្ថានភាពនៃដំណើរការប្រតិវេទន៍។

## ២. ការដាក់ប្រតិវេទន៍គយ

មន្ត្រីគយនៅផ្នែកទទួលឯកសារ ឆែកពិនិត្យមើលប្រតិវេទន៍គយចុះបញ្ជិការួចទម្រង់ជាក្រដាសនិងឯកសារយោងនានា ជាមួយទិន្នន័យក្នុងប្រព័ន្ធ ដើម្បីឲ្យប្រាកដថា ប្រតិវេទន៍គយត្រូវបានបំពេញត្រឹមត្រូវ បានបោះពុម្ពច្បាស់និងអាចអានបាន មានចុះហត្ថលេខាដោយជើងសាគយ ឬ ប្រតិវេទករ និងមានឯកសារភ្ជាប់ចាំបាច់នានាត្រូវដាក់ជាមួយនឹងប្រតិវេទន៍គយ។

មន្ត្រីគយអាចបដិសេធប្រតិវេទន៍ណាមួយដែលមិនស្របតាមតម្រូវការ នៃកថាខ័ណ្ឌទី១ខាងលើ។

## ៣. ច្រកដំណើរការប្រតិវេទន៍គយ

នៅពេលប្រតិវេទន៍គយត្រូវបានឆែកពិនិត្យគ្រប់គ្រាន់និងត្រឹមត្រូវ មន្ត្រីគយបញ្ជាប្រព័ន្ធឲ្យវាយតំលៃប្រតិវេទន៍គយ។ ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យគ្រប់គ្រងហានិភ័យប្រព័ន្ធនឹងកំណត់ច្រកដំណើរការប្រតិវេទន៍គយដូចខាងក្រោម÷

- **ច្រកក្រហមៈ** ប្រតិវេទន៍គយនឹងត្រូវបានធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ជាមួយឯកសារ ហើយទំនិញនឹងត្រូវធ្វើអធិការកិច្ចជារូបវ័ន្ត មុនពេលធ្វើការប្តូរច្រកប្រតិវេទន៍គយទៅ **ច្រកបៃតង** និងវាយតំលៃដោយមន្ត្រីគយ។
- **ច្រកលឿងៈ** ប្រតិវេទន៍គយនឹងត្រូវបានធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ជាមួយឯកសារ មុនពេលធ្វើការប្តូរច្រកប្រតិវេទន៍គយទៅ **ច្រកបៃតង** និងវាយតំលៃដោយមន្ត្រីគយ។
- **ច្រកបៃតងៈ** ប្រតិវេទន៍គយត្រូវបានវាយតំលៃដោយស្វ័យប្រវត្តិ ហើយចេញឯកសារបញ្ចេញទំនិញ។ប្រតិវេទន៍គយទម្រង់ជាក្រដាស អាចជាកម្មវត្ថុនៃការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញ។
- **ច្រកខៀវៈ** ប្រតិវេទន៍គយត្រូវផ្តល់ប្រព្រឹត្តកម្មដូចគ្នាទៅនឹងច្រកបៃតង ជាកម្មវត្ថុនៃការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញ ជាមួយហេតុផលជាក់លាក់។

ក្នុងករណីដែលប្រតិវេទន៍ត្រូវបានជ្រើសរើសឲ្យដំណើរការតាមច្រកក្រហម និងលឿង មន្ត្រីគយផ្ទៀងផ្ទាត់ លក្ខណៈវិនិច្ឆ័យជ្រើសរើសដែលបណ្តាលឲ្យប្រតិវេទន៍គយត្រូវបានជ្រើសរើសដាក់បញ្ចូលក្នុងច្រកនេះ។ ប្រព័ន្ធនឹងបង្ហាញពីតម្រូវការពិសេសដែលត្រូវឆែកពិនិត្យ ដូចជាការតម្រូវឲ្យមានអាជ្ញាប័ណ្ណនាំចូលឲ្យដកគំរូទំនិញ ប្រវត្តិនៃការគេចពន្ធ។ល។

## ៤. កន្លែងសាកសួរ

ប្រតិវេទន៍គយដែលត្រូវបានរកឃើញកំហុសឆ្គង ឬភាពមិនប្រក្រតីនានា នាពេលត្រួតពិនិត្យឯកសារ ឬពេលត្រួតពិនិត្យទំនិញជារូបវ័ន្ត ត្រូវបញ្ជូនទៅកន្លែងសាកសួរ។ ជើងសាគយ ឬ ប្រតិវេទករនឹងត្រូវជូនដំណឹងថាប្រតិវេទន៍គយបានបញ្ជូនទៅ “កន្លែងសាកសួរ” និងហេតុផលដែលនាំឲ្យមានការបញ្ជូនករណីនេះទៅ “កន្លែងសាកសួរ។

នៅពេលទទួលបានការជូនដំណឹង ជើងសាគយ ឬប្រតិវេទករ ត្រូវបង្ហាញខ្លួននៅ “កន្លែងសាកសួរ។ ការកែតម្រូវណាមួយលើប្រតិវេទន៍គយ នឹងត្រូវពិភាក្សារវាងមន្ត្រីគយផ្នែកសាកសួរ និងជើងសាគយ ឬ ប្រតិវេទករ។ ប្រសិនបើមិនមានការព្រមព្រៀង មន្ត្រីគយត្រូវរៀបចំរបាយការណ៍ ឬ កំណត់ហេតុបញ្ជូនទៅទីចាត់ការគយដើម្បីមានវិធានការបន្ត។

នៅពេលដែលសកម្មភាពខាងលើត្រូវបានបំពេញរួចនិងមានការព្រមព្រៀង មន្ត្រីគយត្រូវចុះហត្ថលេខាលើប្រតិវេទន៍ដែលកែតម្រូវរួច ហើយធ្វើបច្ចុប្បន្នភាពនូវឯកសារលទ្ធផលនៃការត្រួតពិនិត្យ តាមលទ្ធផលនៃដំណោះស្រាយនៅកន្លែងសាកសួរ ឬ តាមសេចក្តីសម្រេចរបស់ អគរ រួចប្តូរច្រកប្រតិវេទន៍ទៅច្រកបៃតង។

### ៥. ការស្កេនកុងតឺន័រ

ការស្កេនកុងតឺន័រ ត្រូវបានធ្វើឡើងដាច់ដោយឡែកពីដំណើរការប្រតិវេទន៍។

ប្រព័ន្ធ និងមានការប្រើប្រាស់នៅការិយាល័យស្កេនដែលអាចជួយមន្ត្រីផ្នែកស្កេន ធ្វើការប្រៀបធៀបទំនិញដែលបានប្រកាសលើប្រតិវេទន៍គយ ជាមួយនឹងអ្វីដែលបានឃើញនៅលើរូបភាពស្កេន ឬ ព័ត៌មានស្កេន។

ភាពមិនប្រក្រតីណាមួយបានរកឃើញ ត្រូវកត់ត្រាបញ្ចូលទៅក្នុងទម្រង់លទ្ធផលត្រួតពិនិត្យដោយគយ។

### ៦. ការជូនដំណឹងវាយតំលៃ

នៅពេលដែលប្រតិវេទន៍គយត្រូវបានវាយតម្លៃដោយប្រព័ន្ធ ការជូនដំណឹងវាយតម្លៃត្រូវបានបង្ហាញដែលមានរៀបរាប់ពីចំនួនប្រាក់ពន្ធគយ និងអាករត្រូវបង់។ ការជូនដំណឹងនេះ ត្រូវបានប្រើប្រាស់ជាឯកសារយោងដើម្បីបង់ពន្ធ អាករ និងកម្រៃនានា។

### ៧. គណនេយ្យ

ពន្ធ អាករ និងកម្រៃនានា ត្រូវបង់ស្របតាមបទប្បញ្ញត្តិជាធរមាន។ ប្រសិនបើត្រូវបង់នៅធនាគារជាតិនៃកម្ពុជា ឬ នៅស្ថាប័នហិរញ្ញវត្ថុដែលមានការអនុញ្ញាតផ្សេងទៀត សក្ខីប័ត្ររបស់ស្ថាប័នទាំងនេះត្រូវជូនដល់មន្ត្រីគយមានសមត្ថកិច្ច ហើយប្រព័ន្ធនឹងចេញនូវបង្កាន់ដៃគយ។

### ៨. ការអនុញ្ញាតឲ្យយកទំនិញចេញពីគយ

ក្រោយពីបង់ពន្ធ អាករ បន្ទុក និងកម្រៃនានា មន្ត្រីគយមានសមត្ថកិច្ច ចេញប័ណ្ណអនុញ្ញាតឲ្យយកទំនិញចេញ។ ប័ណ្ណនេះមានចែងលំអិតព័ត៌មានពីពន្ធ អាករ និងកម្រៃនានាដែលពាក់ព័ន្ធទៅនឹងប្រតិវេទន៍គយហើយត្រូវបានប្រើប្រាស់ដើម្បីអនុញ្ញាតឲ្យយកទំនិញចេញពីគយ។

### ៩. សវនកម្មក្រោយពេលបញ្ចេញទំនិញ

ប្រតិវេទន៍គយដែលត្រូវបានជ្រើសរើសតាមច្រកខៀវ និងច្រកបៃតង ត្រូវធ្វើសវនកម្មជាសំខាន់លើមូលដ្ឋានក្រោយពេលបញ្ចេញទំនិញពីគយ។

## ២.១.១.២. បុគ្គលដែលមាននីតិសម្បទា

- នីតិបុគ្គល ឬ ក្រុមហ៊ុនដែលមានវិញ្ញាប័នប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម
- ម្ចាស់ទំនិញ ឬ តំណាង
- ជើងសាគយដែលទទួលស្គាល់ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករ
- បុគ្គលរបស់ក្រុមហ៊ុនដែលទទួលបានសិទ្ធិស្របច្បាប់

## ២.១.១.៣. ឯកសារចាំបាច់ក្នុងការបំពេញប្រតិវេទន៍គយ

ឯកសារត្រូវភ្ជាប់ជាមួយប្រតិវេទន៍គយ រួមមាន÷

- វិក្កយបត្រ និងបញ្ជីវេចខ្ចប់
- ឯកសារដឹកជញ្ជូន

ក្នុងករណីតម្រូវចាំបាច់

- និវេទន៍ប័ណ្ណ
- អាជ្ញាប័ណ្ណ
- លិខិតអនុញ្ញាត
- វិញ្ញាបនបត្រដើមកំណើតទំនិញ
- វិញ្ញាបនបត្រធានារ៉ាប់រង និង
- ឯកសារពាក់ព័ន្ធផ្សេងទៀត

## ២.១.១.៤. ភារកិច្ចនិងការទទួលខុសត្រូវរបស់ជើងសាគយ ឬប្រតិវេទករ

- បញ្ចូលទិន្នន័យប្រតិវេទន៍គយ រួមទាំងប័ណ្ណកំណត់តម្លៃរហូតដល់ចុះបញ្ជិកា
- នៅពេលការបញ្ចូលទិន្នន័យបានបញ្ចប់ ផ្ទៃកពិនិត្យជាមូលដ្ឋានក្នុងកំព្យូទ័រ (ផ្ទៀងផ្ទាត់) និងចុះបញ្ជិកាប្រតិវេទន៍ (ផ្តល់សុពលភាព) ប្រសិនបើមិនមានកំហុស ឬ ក្រោយពេលកំហុសទាំងអស់ត្រូវបានកែសម្រួលរួច។ នៅពេលចុះបញ្ជិកាប្រព័ន្ធកំព្យូទ័រនឹងផ្តល់ដោយស្វ័យប្រវត្តិនូវ លេខ ចុះបញ្ជិកា និងកាលបរិច្ឆេទ
- បោះពុម្ពប្រតិវេទន៍គយចុះបញ្ជិការួចពីប្រព័ន្ធកំព្យូទ័រ រួមទាំងប័ណ្ណកំណត់តម្លៃ (តែករណីចាំបាច់ប៉ុណ្ណោះ) ទម្រង់ជាក្រដាស ទំហំ A4 ចំនួនពីរ (២) ច្បាប់ (ប្រតិវេទន៍គយបោះពុម្ពបានតែក្រោយពេលចុះបញ្ជិការួច)
- យកប្រតិវេទន៍គយដែលចុះបញ្ជិកាបានបោះពុម្ពភ្ជាប់ជាមួយនូវឯកសារយោងចាំបាច់នានា ទៅដាក់ជូនមន្ត្រីគយផ្នែកទទួលការដាក់ឯកសារ (ដាក់ក្នុងថាសដែលបានកំណត់ទុកសម្រាប់ដាក់ឯកសារ) និង ចុះហត្ថលេខាលើប្រតិវេទន៍គយនោះ នៅចំពោះមុខមន្ត្រីគយផ្នែកទទួលការដាក់ឯកសារ
- ប្រសិនបើមន្ត្រីគយទួលការដាក់ឯកសារមិនទទួលយកប្រតិវេទន៍គយ ត្រូវទំនាក់ទំនងទៅផ្នែកសាកសួរព័ត៌មាន
- ប្រសិនបើមានផ្នែកគ្រប់គ្រងនិវេទន៍ប័ណ្ណ យកច្បាប់ចម្លងប្រតិវេទន៍គយសម្រាប់ជើងសាគយ ឬប្រតិវេទករ ទៅដាក់ជូនមន្ត្រីគយផ្នែកនិវេទន៍ប័ណ្ណ ដើម្បីធ្វើការកាត់ស្តុកប្រតិវេទន៍ចេញពីនិវេទន៍ប័ណ្ណ
- ប្រសិនបើមានផ្នែកគ្រប់គ្រងស្កែន និងបើមានការចាំបាច់ត្រូវស្កែន យកច្បាប់ចម្លងប្រតិវេទន៍គយសម្រាប់ជើងសារ ឬ ប្រតិវេទករ ទៅកាន់កន្លែងស្កែន ដើម្បីស្កែនកុងតឺន័រ
- ប្រសិនបើប្រតិវេទន៍គយតម្រូវឱ្យមានការត្រួតពិនិត្យជារូបវន្តទំនិញ ត្រូវទំនាក់ទំនងទៅប្រធានត្រួតពិនិត្យ ដើម្បី ចាត់ចែង ធ្វើការ ត្រួតពិនិត្យទំនិញជារូបវន្ត
- ប្រសិនបើប្រតិវេទន៍គយត្រូវបានសាកសួរដោយមន្ត្រីគយ ទៅកាន់ផ្នែកសាកសួរព័ត៌មាន សម្រាប់ការសាកសួរ ព័ត៌មានចាំបាច់
- ប្រសិនបើការបង់ប្រាក់ ធ្វើឡើងតាមរយៈធនាគារ ទទួល យក សក្ខីប័ត្រ បង់ ប្រាក់ពីធនាគារ មកប្រគល់ឱ្យផ្នែកគណនេយ្យគយ ដើម្បីបញ្ជាក់ការបង់ប្រាក់ទៅក្នុងប្រព័ន្ធកុំព្យូទ័រ
- ប្រសិនបើការបង់ប្រាក់ដោយផ្ទាល់ដល់គយ យកសាច់ប្រាក់ ឬ មូលប្បទានប័ត្រមកប្រគល់ឱ្យផ្នែកគណនេយ្យគយ ដើម្បីបញ្ជាក់ការបង់ប្រាក់ទៅក្នុងប្រព័ន្ធកុំព្យូទ័រ
- ក្រោយពីការបង់ប្រាក់ពន្ធនិងអាករ ឬ ក៏ចំពោះទំនិញដែលបានប្រកាសដោយប្រើប្រាស់គណនីបង់ប្រាក់ជាមុន ទទួលយកបង្កាន់ដៃពីបេឡាករគយ និងបន្ទាប់មកទទួលយកបង្កាន់ដៃពន្ធយានយន្ត (ប្រសិនបើមាន) និងប័ណ្ណបញ្ចេញទំនិញពីប្រធានគណនេយ្យ
- យកប័ណ្ណដឹកជញ្ជូន ពីមន្ត្រីគយដែលប្រចាំការឃ្លាំង ឬទីលាន និងបន្តបញ្ចេញទំនិញពីឃ្លាំង ឬទីលាន និងនៅច្រកទ្វារចេញ
- ប្រសិនបើមានការសម្រេចនិងអនុញ្ញាតឱ្យធ្វើការបង្វិលសងវិញទាំងស្រុងឬ ភាគខ្លះនូវពន្ធនិងអាករដែលបានបង់រួចស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមាន យកឯកសារចាំបាច់នានា រួមមានសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចប្រតិវេទន៍គយ បង្កាន់ដៃពន្ធ អញ្ញត្តិប័ណ្ណ។ល។ មកប្រគល់ឱ្យផ្នែកគណនេយ្យនិងបេឡាគយ ដើម្បីបញ្ជាក់ការបង្វិលសងវិញនូវពន្ធនិងអាករដែលបានបង់ទៅក្នុងប្រព័ន្ធកំព្យូទ័រ។

## ២.១.២. ការនាំចូល

### ២.១.២.១. ផ្លូវសមុទ្រ/ផ្លូវទន្លេ

ការនាំចូលទំនិញតាមផ្លូវសមុទ្រ/ផ្លូវទន្លេត្រូវអនុវត្តតាមនីតិវិធីមួយចំនួន ដូចជាការធ្វើបែបបទនាវាចូល ការងារឃ្លាំង និងនីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**

- អនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និង ច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- ប្រកាសលេខ ៥៧២ សហវ.ប្រក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១០ ស្តីពីការរាយការណ៍អំពីទំនិញនាពេលចូលក្នុងដែនគយនៃព្រះរាជាណាចក្រកម្ពុជា
- លិខិតលេខ ០១បប ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០២ ស្តីពីបទបញ្ជាផ្ទៃក្នុងរបស់ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិកំពង់ផែស្វយ័តក្រុងព្រះសីហនុ។

#### ក. ការធ្វើបែបបទនាវាចូល

នីតិវិធីនៃការធ្វើបែបបទនាវាចូល ដូចខាងក្រោម÷

១. ពេលនាវាមកដល់ចំណុចសូន្យ ភ្នាក់ងារនាវាចរត្រូវជូនដំណឹងដល់មន្ត្រីគយទទួលបន្ទុកធ្វើបែបបទនាវាជាមុន។

២. ពេលនាវាចូលចតនៅកំពង់ផែហើយ មន្ត្រីគយទទួលបន្ទុកធ្វើបែបបទនាវា និងសមត្ថកិច្ចពាក់ព័ន្ធ រួមមានកំពង់ផែស្វយ័ត នគរបាលអន្តោប្រវេសន៍ ចត្តាឡីស័ក្ត ភ្នាក់ងារនាវាចរ និងតំណាងក្រុមហ៊ុនដឹកជញ្ជូន ឡើងធ្វើបែបបទលើនាវា។

៣. ឯកសារដែលនាវាបតីត្រូវបង្ហាញជូនសមត្ថកិច្ចពាក់ព័ន្ធដែលឡើងធ្វើបែបបទលើនាវារួមមាន÷
   - របាយការណ៍នាវា
   - និវេទន៍ប័ណ្ណទំនិញ
   - និវេទន៍ប័ណ្ណសំភារៈប្រើប្រាស់របស់នាវិក
   - បញ្ជីឈ្មោះនាវិក
   - បញ្ជីផ្ទេរទំនិញ
   - បញ្ជីឈ្មោះអ្នកដំណើរ
   - អញ្ញត្តិប័ណ្ណ
   - កិច្ចសន្យាជួលនាវា
   - វិញ្ញាបនបត្រចុះបញ្ជីនាវានិងឯកសារដទៃទៀតតាមការតម្រូវរបស់រដ្ឋបាលគយ ដើម្បីអនុវត្តវិធានការគយ។

៤. នៅពេលមន្ត្រីគយពិនិត្យរួច គ្មានភាពមិនប្រក្រតីទេ មន្ត្រីគយបញ្ចប់ការធ្វើបែបបទ ដោយការចុះថ្ងៃខែឆ្នាំចុះហត្ថលេខា និងបោះត្រាលើនិវេទន៍ប័ណ្ណ រួចបញ្ជូនទៅផ្នែកទទួលនិងគ្រប់គ្រងនិវេទន៍ប័ណ្ណទំនិញ។

#### ខ. ការងារឃ្លាំង

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**

- ប្រកាសលេខ ១០៩ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងទំនិញគ្មានការទាមទារ
- ប្រកាសលេខ ១០៦ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីសន្និធិគយបណ្តោះអាសន្ន

**នីតិវិធីការងារឃ្លាំង÷**

**១. ទំនិញរាយនិងទំនិញមិនផ្ទុកនៅក្នុងកុងតឺន័រ (ផ្ទេរចូលឃ្លាំង)÷**

- មន្ត្រីគយទទួលបន្ទុកឃ្លាំងទទួលបានពាក្យសុំផ្ទេរទំនិញចូលឃ្លាំងមួយច្បាប់ ដើម្បីកត់ត្រាក្នុងបញ្ជីតាមដានទំនិញរាយរបស់ខ្លួន។
- ពេលដើងសាគយបញ្ចប់ប្រតិវេទន៍គយនិងមកទទួលយកទំនិញ មន្ត្រីគយទទួលបន្ទុកឃ្លាំងកាត់ស្តុកទំនិញនោះចេញពីក្នុងបញ្ជីតាមដានរបស់ខ្លួន និងចេញប័ណ្ណបញ្ចេញទំនិញពីឃ្លាំងចំនួនពីរ(២)ច្បាប់។ មួយច្បាប់រក្សាទុកសម្រាប់មន្ត្រីគយទទួលបន្ទុកឃ្លាំង និងមួយច្បាប់ទៀតឱ្យដើងសាគយ សម្រាប់ទៅយកទំនិញពីឃ្លាំង។

**២. ទំនិញពេញកុងតឺន័រ÷**

- ក្រោយពេលធ្វើបែបបទនាវារួច មន្ត្រីគយទទួលបន្ទុកទីលានទទួលបាននូវនិវេទន៍ប័ណ្ណ ចំនួនមួយ(០១)ច្បាប់ ដើម្បីកត់ត្រាក្នុងបញ្ជីតាមដានកុងតឺន័រ។
- ពេលដើងសាបញ្ចប់ប្រតិវេទន៍គយនិងមកទទួលយកកុងតឺន័រទំនិញ មន្ត្រីគយទទួលបន្ទុកទីលាន កាត់ស្តុកកុងតឺន័រទំនិញនោះចេញពីក្នុងបញ្ជីតាមដានរបស់ខ្លួន និងចេញលិខិតអនុញ្ញាតដឹកជញ្ជូនទំនិញនាំចូល ក្នុងករណី ដែលទំនិញផ្ទុកច្រើនជាងមួយកុងតឺន័រ ដោយមានការបញ្ជាក់ពីកាលបរិច្ឆេទ លេខរថយន្ត គម្រោង និងរយៈពេលដល់គម្រោង។

**៣. រយៈពេលរក្សាទុកទំនិញក្នុងសន្និធិគយបណ្តោះអាសន្ន**

- មានរយៈពេលសែសិបប្រាំ (៤៥) ថ្ងៃ គិតចាប់ពីថ្ងៃចុះបញ្ជិកាទំនិញមកដល់
- ផុតរយៈពេលនេះ ទំនិញត្រូវដាក់ក្នុងនិក្ខិត្តភ័ណ្ឌគយ ហើយម្ចាស់ទំនិញត្រូវបង់កម្រៃ 0.១% លើតម្លៃគិតពន្ធគយក្នុងមួយថ្ងៃ
- ប្រសិនបើទំនិញត្រូវបានរក្សាទុកលើសពីរយៈពេលបី(៣)ខែ គិតចាប់ពីថ្ងៃកត់ត្រាចូលក្នុងបញ្ជីនៃសន្និធិគយបណ្តោះអាសន្ន ទំនិញទាំងនោះត្រូវបានចាត់ទុកថាជាទំនិញគ្មានការទាមទារ។

## គ. នីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយ

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលនាំចូលទំនិញតាមកំពង់ផែ អន្តរជាតិផ្លូវសមុទ្រ/ផ្លូវទន្លេនីមួយៗ ត្រូវបំពេញប្រតិវេទន៍គយនាំចូល អមជាមួយឯកសារភ្ជាប់ច្បាប់ដើម និង ដាក់ជូនមន្ត្រីគយមានសមត្ថកិច្ចនៅការិយាល័យបំពេញបែបបទបញ្ចេញទំនិញ។ នីតិវិធីនៃការបំពេញប្រតិវេទន៍គយ ដូចមានក្នុងចំណុច ២.១.។

## ឃ. ការងារស្កែន

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**

- លិខិតលេខ ៤៣៧ គ.រ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០២ ស្តីពី ការចាប់ផ្តើម ដាក់អោយដំណើរការជាផ្លូវការនូវស្ថានីយ៍ត្រួតពិនិត្យកុងតែនីរតាមប្រព័ន្ធ TC-SCAN
- លិខិតលេខ ៨២៣ គ.រ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីសេចក្តីណែនាំបន្ថែម និងការកែសម្រួលប្រភេទទំនិញដែលត្រូវឆ្លងស្ថានីយ៍ត្រួតពិនិត្យតាមប្រព័ន្ធ TC-SCAN
- លិខិតលេខ ១៣៥៨ អ.គ.រ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការសម្រួលពាណិជ្ជកម្មបន្ថែមទៀតដល់វិនិយោគិនក្នុងតំបន់សេដ្ឋកិច្ចពិសេស
- ប្រកាសលេខ ៣១៦ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលកម្រៃត្រួតពិនិត្យទំនិញតាមប្រព័ន្ធម៉ាស៊ីនស្កែន
- លិខិតលេខ ៧៩០ អ.គ.រ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការផ្តល់ប្រព្រឹត្តិកម្មលើកទឹកចិត្តជូនធុរជនដែលជាសមាជិកក្រុមធុរជនល្អបំផុត

- លិខិតលេខ ១៤៨៩ អ.គ.រ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីនីតិវិធីនៃការអនុវត្តយន្តការឃ្លាំមើលអនុលោមភាពសមាជិកក្រុមធុរជនល្អបំផុត
- លិខិតលេខ ១៨៦៧ អ.គ.រ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តនីតិវិធីគយតាមបណ្តាផៃស្ងួត

កុងតឺន័រដែលត្រូវឆ្លងកាត់ម៉ាស៊ីនស្កេនអនុវត្តដូចខាងក្រោម÷

**១. ចំពោះទំនិញដែលត្រូវបំពេញបែបបទនៅមាត់ច្រកចូល**

រាល់ទំនិញនាំចូលតាមកុងតឺន័រទាំងអស់ ត្រូវស្កេន លើកលែងតែ÷

- ទំនិញនាំចូលសម្រាប់អង្គទូត ឬ អង្គការមានអភ័យឯកសិទ្ធិការទូត អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលនានា ដែលត្រូវបានទទួលស្គាល់ជាផ្លូវការពីរាជរដ្ឋាភិបាល
- ទំនិញជាអំណោយមនុស្សធម៌ ជាជំនួយការនាំចូលតាមរយៈឥណទានកម្ចីរបស់រដ្ឋ ព្រមទាំងទំនិញនាំចូលរបស់អង្គភាពរដ្ឋ
- ទំនិញដែលទទួលការអនុញ្ញាតដោយឡែកឱ្យរួចពីកាតព្វកិច្ចនេះពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ទំនិញនាំចូលដោយក្រុមធុរៈជនល្អបំផុតតាមគោលការណ៍នៃការគ្រប់គ្រងហានីភ័យគយ
- កុងតឺន័រទទេ។

**២. ចំពោះទំនិញដែលត្រូវដឹកជញ្ជូនក្រោមរបបឆ្លងកាត់ជាតិ**

- ប្រតិបត្តិករផៃស្ងួតទាំងអស់ អាចជ្រើសរើសម៉ាស៊ីនស្កេននៅមាត់ច្រកចូលតាមសមុទ្រ/ទន្លេ ឬ នៅការិយាល័យគយនិងរដ្ឋាករផៃស្ងួតណាមួយដែលមានម៉ាស៊ីនស្កេន
- ទំនិញឆ្លងកាត់ទៅតំបន់សេដ្ឋកិច្ចពិសេសត្រូវបានលើកលែងការស្កេន។

**៣. កម្រៃត្រួតពិនិត្យទំនិញឆ្លងកាត់ម៉ាស៊ីនស្កេនអនុវត្តដូចខាងក្រោម**

- តម្លៃសាមសិបពីរ (៣២) ដុល្លារអាមេរិកសម្រាប់កុងតឺន័រដែលមានទំហំចាប់ពីសែសិប (៤០) ហ្វីតឡើង
- តម្លៃម្ភៃ (២០) ដុល្លាអាមេរិកសម្រាប់កុងតឺន័រដែលមានទំហំក្រោមសែសិប (៤០) ហ្វីត។

**កំណត់សម្គាល់÷** ទំនិញនាំចូលតាមកុងតឺន័រដែលជាកម្មវត្ថុនៃការលើកលែងស្កេន និងកម្រៃត្រួតពិនិត្យទំនិញឆ្លងកាត់ម៉ាស៊ីនស្កេននេះ អាចនឹងមានការកែសម្រួលប្រសិនបើមានការតម្រូវណាមួយពី អគរ។

## ២.១.២.២. ផ្លូវអាកាស

ការនាំចូលទំនិញតាមផ្លូវអាកាសត្រូវអនុវត្តតាមនីតិវិធីមួយចំនួន ដូចជានីតិវិធីនិងការធ្វើបែបបទយន្តហោះការងារឃ្លាំង និងនីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**

- ប្រកាសលេខ ១៤៤៧ សហវ.ប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីបញ្ញត្តិនិងនីតិវិធីប្រតិវេទន៍គយ
- ប្រកាសលេខ ១០៦ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីសន្និធិគយបណ្តោះអាសន្ន
- ប្រកាសលេខ ១០៩ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងទំនិញគ្មានការទាមទារ

### គ. នីតិវិធីនិងការធ្វើបែបបទយន្តហោះ

- យន្តហោះចេញចូលក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជូនដំណឹងដល់អាជ្ញាធរនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- ពេលហោះហើរក្នុងដែនអាកាសកម្ពុជា មិនអនុញ្ញាតឱ្យទម្លាក់ទំនិញខុសពីតម្រាយផ្លូវឡើយ លើកលែងតែករណីដែលបណ្ដាលឱ្យមានគ្រោះថ្នាក់ជាយថាហេតុ ដែលត្រូវរាយការណ៍ជាបន្ទាន់ដល់សមត្ថកិច្ចគយដែលនៅជិតបំផុតនៅនឹងកន្លែងចុះចត
- ការលើកដាក់ទំនិញឥវ៉ាន់អ្នកដំណើរចុះឡើងពីយន្តហោះត្រូវមានការអនុញ្ញាតនិងការត្រួតពិនិត្យពីមន្ត្រីគយ
- នៅពេលមន្ត្រីគយធ្វើការត្រួតពិនិត្យឆែកឆេរយន្តហោះ អាកាសយានិក ឬអ្នកតំណាងត្រូវបង្កលក្ខណៈងាយស្រួលក្នុងពេលបំពេញភារកិច្ច
- ក្នុងករណីយន្តហោះដែលមានគ្រោះថ្នាក់ ឬមានការចៀសវាងគ្រោះថ្នាក់ រួចមានការចុះចតនៅចំណតអាកាសយានដ្ឋានណាមួយដែលគ្មានមន្ត្រីគយ ក្នុងករណីនេះអាកាសយានិក ឬអ្នកតំណាង ត្រូវរាយការណ៍ ឱ្យរដ្ឋអំណាចមូលដ្ឋានទីនោះធ្វើការត្រួតពិនិត្យជំនួសមន្ត្រីគយ។

### ខ. ការងារឃ្លាំង

ទំនិញនាំចូលតាមផ្លូវអាកាសទាំងអស់ ត្រូវរក្សារក្នុងសន្និធិគយបណ្ដោះអាសន្នក្រោមការគ្រប់គ្រងក្រោមការគ្រប់គ្រងរបស់គយ ត្រូវរង់ចាំបំពេញបែបបទបញ្ចេញទំនិញពីគយ មុននឹងអនុញ្ញាតដាក់ឱ្យប្រើប្រាស់បានក្នុងប្រទេស ឬ ដាក់ក្រោមរបបគយមួយផ្សេងទៀតបាន។

- មានរយៈពេលសាមសិបប្រាំ (៣០) ថ្ងៃ គិតចាប់ពីថ្ងៃចុះបញ្ជិកាទំនិញមកដល់
- ផុតរយៈពេលនេះ ទំនិញត្រូវដាក់ក្នុងនិក្ខិត្តភ័ណ្ឌគយ ម្ចាស់ទំនិញត្រូវបង់កម្រៃ ០.១% លើតម្លៃគិតពន្ធគយ ក្នុងមួយថ្ងៃ
- ប្រសិនបើទំនិញត្រូវបានរក្សាទុកលើសពីរយៈពេលបី (៣) ខែ គិតចាប់ពីថ្ងៃកត់ត្រាចូលក្នុងបញ្ជីនៃសន្និធិគយបណ្ដោះអាសន្ន ទំនិញទាំងនោះត្រូវបានចាត់ទុកថាជាទំនិញគ្មានការទាមទារ។

### គ. នីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយ

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលនាំចូលទំនិញតាមអាកាសយានដ្ឋាន អន្តរជាតិ នីមួយៗ ត្រូវ បំពេញប្រតិវេទន៍គយនាំចូល អមជាមួយឯកសារភ្ជាប់ច្បាប់ដើម និងប្រគល់ជូនមន្ត្រីគយមានសមត្ថកិច្ចគយនៅមាត់ច្រកអាកាសយានដ្ឋានអន្តរជាតិនីមួយៗ។ នីតិវិធីនៃការបំពេញប្រតិវេទន៍គយ ដូចមានក្នុងចំណុច ២.១.។

## ២.១.២.៣. ផ្លូវគោក

ការនាំចូលទំនិញតាមផ្លូវគោក ត្រូវបំពេញបែបបទបញ្ចេញទំនិញពីគយតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**

- លិខិតលេខ ១៧៣៥ សហវ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៦ ស្ដីពីបែបបទនៃការគ្រប់គ្រងទំនិញនាំចូលតាមផ្លូវគោកដោយប្រើប្រាស់កំពង់ផែសមុទ្រអន្តរជាតិនៃប្រទេសជាប់ព្រំដែនកម្ពុជាតាមរបបឆ្លងកាត់ (Customs Transit) ប្រទេសទាំងនោះ ដោយផ្ទុកក្នុងកុងតឺន័រ
- ប្រកាស ៥៧២ ចុះថ្ងៃទី១៩ សីហា ២០១០ ស្ដីពីការរាយការណ៍អំពីទំនិញនាពេលចូលក្នុងដែនគយនៃព្រះរាជាណាចក្រកម្ពុជា។

### ក. ទម្រង់ការគយមុនពេលប្រកាសទំនិញ

នៅពេលដែលទំនិញមកដល់មាត់ច្រកព្រំដែនគោក នៃព្រះរាជាណាចក្រកម្ពុជា ម្ចាស់ទំនិញ ឬ តំណាង ត្រូវធ្វើការរាយការណ៍មករដ្ឋបាលគយ។

## ខ. នីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយ

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលនាំចូលទំនិញតាមមាត់ច្រកព្រំដែនគោកនីមួយៗ ត្រូវបំពេញប្រតិវេទន៍គយនាំចូល អមជាមួយឯកសារភ្ជាប់ច្បាប់ដើម និងប្រគល់ជូនមន្ត្រីគយមានសមត្ថកិច្ចគយនៅមាត់តាមមាត់ច្រកព្រំដែនគោកនីមួយ។ នីតិវិធីនៃការបំពេញប្រតិវេទន៍គយ ដូចមានក្នុងចំណុច ២.១.។

## គ. ការងារស្កេន

### ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ

- ប្រកាសលេខ ៣១៦ សហវ. ប្រក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលកម្រៃត្រួតពិនិត្យទំនិញតាមប្រព័ន្ធម៉ាសីនស្កេន
- លិខិតលេខ ៧៩០ អគរ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការផ្តល់ប្រព្រឹត្តកម្មលើកទឹកចិត្តធុរជនក្រុមហ៊ុនដែលជាសមាជិកក្រុមធុរជនល្អបំផុត។
- លិខិតលេខ ១៨៦៨ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់ម៉ាស៊ីនស្កេនន្ធូវការិយាល័យគយ និងរដ្ឋាករបាវិត

**១. ចំពោះទំនិញដែលត្រូវបំពេញបែបបទនៅមាត់ច្រកចូល÷**

- រាល់ទំនិញនាំចូលតាមកុងតឺន័រទាំងអស់ត្រូវស្កេន លើកលែងតែ÷
- ទំនិញនាំចូលសម្រាប់អង្គទូត ឬ អង្គការមានអភ័យឯកសិទ្ធិការទូត អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលនានា ដែលត្រូវបានទទួលស្គាល់ជាផ្លូវការពីរាជរដ្ឋាភិបាល
- ទំនិញជាអំណោយមនុស្សធម៌ ជាជំនួយការនាំចូលតាមរយៈឥណទានកម្ចីរបស់រដ្ឋ ព្រមទាំងទំនិញ នាំចូលរបស់អង្គភាពរដ្ឋ
- ទំនិញដែលទទួលការអនុញ្ញាតដោយឡែកឱ្យរួចពីកាតព្វកិច្ចនេះពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ទំនិញនាំចូលដោយក្រុមធុរៈជនល្អបំផុតតាមគោលការណ៍នៃការគ្រប់គ្រងហានិភ័យគយ
- កុងតឺន័រទទេ។

**២. ចំពោះទំនិញដែលត្រូវដឹកជញ្ជូនក្រោមរបបឆ្លងកាត់ជាតិ÷**

- ប្រតិបត្តិករផែស្ងួតទាំងអស់ អាចជ្រើសរើសម៉ាស៊ីនស្កេននៅមាត់ច្រកចូលតាមសមុទ្រ ទន្លេ ឬនៅការិយាល័យគយ និងរដ្ឋាករផែស្ងួតណាមួយដែលមានម៉ាស៊ីនស្កេន
- ទំនិញឆ្លងកាត់ទៅតំបន់សេដ្ឋកិច្ចពិសេស ត្រូវបានលើកលែងការស្កេន។

**៣. កម្រៃត្រួតពិនិត្យទំនិញឆ្លងកាត់ម៉ាស៊ីនស្កេនអនុវត្តដូចខាងក្រោម÷**

- តម្លៃ ៣២ (សាមសិបពីរ) ដុល្លារអាមេរិក សម្រាប់កុងតឺន័រដែលមានទំហំចាប់ពី ៤០ ហ្វីតឡើង
- តម្លៃ ២០(ម្ភៃ) ដុល្លាអាមេរិក សម្រាប់កុងតឺន័រដែលមានទំហំក្រោម ៤០ ហ្វីត។

### កំណត់សម្គាល់÷

១. ទំនិញនាំចូលតាមកុងតឺន័រដែលជាកម្មវត្ថុនៃការលើកលែងស្កេន និងកម្រៃត្រួតពិនិត្យទំនិញឆ្លងកាត់ម៉ាស៊ីនស្កេននេះ អាចនឹងមានការកែសម្រួល ប្រសិនបើមានការតម្រូវណាមួយពីអគរ។

២. ទំនិញនាំចូលតាមផ្លូវគោកដោយប្រើប្រាស់កំពង់ផែសមុទ្រអន្តរជាតិនៃប្រទេសជាប់ព្រំដែនកម្ពុជា តាមរបបឆ្លងកាត់ (Customs Transit) ត្រូវអនុវត្តដូចខាងក្រោម (លិខិតលេខ១៧៣៥សហវ)÷

- តម្រូវឲ្យទំនិញនាំចូលក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រើប្រាស់របបគយឆ្លងកាត់ (Customs Transit) ប្រទេសជាប់ព្រំដែនកម្ពុជាតាមផ្លូវគោកទាំងអស់ ត្រូវផ្ទុកក្នុងកុងតឺន័រ ដោយភ្ជាប់ជាមួយនូវអំណត្តប័ណ្ណ (Bill of lading) ផ្លូវសមុទ្រផងដែរ និងមិនអនុញ្ញាតឲ្យរើបំបែកទំនិញចេញពីកុងតឺន័រជារូបភាពតូចៗ មុនបញ្ចប់បែបបទគយនាំចូលក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ
- ចំពោះទំនិញដូចរៀបរាប់ និងមានកំណត់ដូចចែងខាងលើនេះហើយនៅតែបន្តនាំចូលតាម រូបភាពបំបែករាយក្រៅកុងតឺន័រនោះ ត្រូវមានការអនុញ្ញាតជាមុនពីអគគ ដើម្បីពិនិត្យសម្រេចតាមករណីជាក់ស្តែងនីមួយៗ។

## ២.១.៣. ការនាំចេញ

### ២.១.៣.១. ផ្លូវសមុទ្រ/ផ្លូវទន្លេ

នីតិវិធីនៃការនាំចេញទំនិញដោយបំពេញបែបបទនៅមាត់ច្រកផ្លូវសមុទ្រ/ផ្លូវទន្លេ ÷

- អ្នកនាំចេញ ឬ តំណាងត្រូវធ្វើលិខិតស្នើសុំនាំចេញទំនិញទៅប្រធានអង្គភាពគយនិងរដ្ឋាករមាត់ច្រក ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ
- ប្រធានអង្គភាពគយនិងរដ្ឋាករមាត់ច្រក ពិនិត្យលើពាក្យស្នើសុំនិងឯកសារភ្ជាប់ ព្រមទាំងចុះហត្ថលេខាអនុញ្ញាតឲ្យនាំចេញតាមសំណើ ប្រសិនបើពុំមានភាពមិនប្រក្រតី
- ក្រោយពេលទទួលបានការអនុញ្ញាតឲ្យនាំចេញ អ្នកនាំចេញ ឬ តំណាងត្រូវបំពេញនីតិវិធីនៃការបំពេញប្រតិវេទន៍គយ ដូចមានក្នុងចំណុច ២.១.។

**ការងារស្កេន**

រាល់ទំនិញនាំចេញតាមកុងតឺន័រទាំងអស់ត្រូវស្កេន លើកលែងតែ÷

- ទំនិញនាំចេញដែលជាផលិតផលសម្រេចរបស់វិនិយោគិនវិស័យកាត់ដេរ ដែលបានបំពេញបែបបទនៅសាខាគយនិងរដ្ឋាករនាំចេញ
- ទំនិញនាំចេញ ដែលត្រូវបានត្រួតពិនិត្យរូបវ័ន្តដោយមន្ត្រីគយនៃអង្គភាពគយនិងរដ្ឋាករមាត់ច្រករួច នាពេលផ្ទុកចូលកុងតឺន័រ
- ទំនិញនាំចូលសម្រាប់អង្គទូត ឬ អង្គការមានអភ័យឯកសិទ្ធិការទូត អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាលនានា ដែលត្រូវបានទទួលស្គាល់ជាផ្លូវការពីរាជរដ្ឋាភិបាល
- ទំនិញដែលទទួលការអនុញ្ញាតដោយឡែកឲ្យរួចពីកាតព្វកិច្ចនេះពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- កុងតឺន័រទទេ។

### ២.១.៣.២. ផ្លូវអាកាស

ទំនិញនាំចេញទាំងអស់ ត្រូវរាយការណ៍នៅការិយាល័យគយ ឬ ទីកន្លែងផ្សេងទៀត ទៅតាមការកំណត់របស់អគ្គនាយកគយនិងរដ្ឋាករកម្ពុជា។ ទំនិញទាំងនោះ នឹងត្រូវរក្សាទុកបណ្តោះអាសន្ននៅទីកន្លែងដែលគ្រប់គ្រងដោយរដ្ឋបាលគយ (សន្និធិគយបណ្តោះអាសន្ន) រង់ចាំបំពេញបែបបទបញ្ចេញទំនិញពីគយ មុននឹងអនុញ្ញាតយកទំនិញចេញ។

**នីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយ**

អ្នកនាំចេញទំនិញទាំងអស់ត្រូវភ្ជាប់ឯកសារពាក់ព័ន្ធ ដើម្បីបំពេញបែបបទបញ្ចេញទំនិញពីគយ។ នីតិវិធីនៃការបំពេញប្រតិវេទន៍គយ ដូចមានក្នុងចំណុច ២.១.។

### ២.១.៣.៣. ផ្លូវគោក

នីតិវិធីនៃការនាំចេញទំនិញដោយបំពេញបែបបទនៅមាត់ច្រកផ្លូវគោក ៖

- អ្នកនាំចេញ ឬ តំណាងត្រូវធ្វើលិខិតស្នើសុំនាំចេញទំនិញទៅប្រធានអង្គភាពគយនិងរដ្ឋាករមាត់ច្រក ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ
- ប្រធានអង្គភាពគយនិងរដ្ឋាករមាត់ច្រក ពិនិត្យលើពាក្យស្នើសុំ និងឯកសារភ្ជាប់ ព្រមទាំងចុះហត្ថលេខាអនុញ្ញាតឱ្យនាំចេញតាមសំណើ ប្រសិនបើពុំមានភាពមិនប្រក្រតី
- ក្រោយពេលទទួលបានការអនុញ្ញាតឱ្យនាំចេញ អ្នកនាំចេញ ឬ តំណាងត្រូវបំពេញនីតិវិធីនៃការបំពេញប្រតិវេទន៍គយ ដូចមានក្នុងចំណុច ២.១.។

## ២.១.៤. ឆ្លងកាត់

ការឆ្លងកាត់គឺជានីតិវិធីគយដែលអនុញ្ញាតឱ្យដឹកទំនិញពីការិយាល័យគយមួយទៅការិយាល័យគយមួយទៀត ក្រោមការត្រួតពិនិត្យរបស់គយដោយព្យួរពន្ធនិងអាករនាំចូល។ ការឆ្លងកាត់មានពីរ (២) ប្រភេទគឺ៖ ឆ្លងកាត់ជាតិ និងឆ្លងកាត់អន្តរជាតិ។

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**

- ប្រកាសលេខ ៥០៨ សហវ.ប្រក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៨ ស្ដីពីការឆ្លងកាត់គយ
- សេចក្ដីណែនាំលេខ ៧៩០ គរ ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០០៨ ស្ដីពីនីតិវិធីនៃការឆ្លងកាត់គយ
- ប្រកាសលេខ ៩០៧ សហវ.ប្រក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៩ ស្ដីពីការកំណត់កម្រៃឆ្លងកាត់លើមុខទំនិញមួយចំនួនដែលស្ថិតក្រោមនីតិវិធីឆ្លងកាត់គយ
- សេចក្ដីណែនាំលេខ ១០៩០ អគរ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ស្ដីពីការអនុវត្តនីតិវិធីនៃការឆ្លងកាត់គយ

### ២.១.៤.១. ឆ្លងកាត់ជាតិ

ការឆ្លងកាត់ជាតិ មានន័យថា ជាការដឹកជញ្ជូនទំនិញពី ក) ការិយាល័យគយមាត់ច្រកចូល ឆ្ពោះទៅកាន់ការិយាល័យគយមួយទៀត ខ) ការិយាល័យគយមួយ ឬ ទីកន្លែងបញ្ចេញទំនិញពីគយដែលមានការអនុញ្ញាតទៅការិយាល័យគយមួយនាមាត់ច្រកចេញ និង គ) ការិយាល័យគយមួយ ឬ ទីកន្លែងបញ្ចេញទំនិញពីគយដែលមានការអនុញ្ញាតទៅការិយាល័យគយមួយទៀត ឬ ទីកន្លែងបញ្ចេញទំនិញពីគយដែលមានការអនុញ្ញាតផ្សេងទៀតនៅក្នុងដែនគយ។

ការអនុវត្តនីតិវិធីឆ្លងកាត់ជាតិដូចខាងក្រោម៖

__ក. ទំនិញនាំចូលឆ្លងកាត់ទៅផៃស្ងួត__

- ប្រតិបត្តិករត្រូវទទួលការអនុញ្ញាតជាមុនពី អគរ ដើម្បីអនុវត្តនីតិវិធីនៃការឆ្លងកាត់គយ
- ដេីងសាគយត្រូវបំពេញប្រតិវេទន៍គយបំព្រួញនៅការិយាល័យចេញដំណើរ

- មន្ត្រីគយទទួលបន្ទុកគ្រប់គ្រងនិវេទន៍ប័ណ្ណទំនិញ កាត់កុងតឺន័រចេញពីបញ្ជីស្តុកកុងតឺន័រ
- កុងតឺន័រអាចត្រូវស្កេននៅការិយាល័យចេញដំណើរ ឬការិយាល័យគយណាមួយនៅភ្នំពេញ
- ក្នុងករណីពុំមានភាពមិនប្រក្រតី មន្ត្រីគយមានសមត្ថកិច្ចត្រូវបោះត្រានិងបញ្ជាក់នីតិវិធីគយឆ្លងកាត់ដោយកំណត់លក្ខខ័ណ្ឌមួយចំនួនដូចជាតម្រាយផ្លូវស្របច្បាប់និងរយៈពេលឆ្លងកាត់ហើយកិបសៀលគយ
- ប្រធានការិយាល័យចេញដំណើរចុះហត្ថលេខាបញ្ចប់បែបបទឆ្លងកាត់
- មន្ត្រីគយអនុញ្ញាតឲ្យកុងតឺន័រចេញទៅផៃស្ងួត។

### ខ. ទំនិញនាំចូលឆ្លងកាត់ទៅតំបន់សេដ្ឋកិច្ចពិសេស

- ប្រតិបត្តិករត្រូវធ្វើលិខិតស្នើសុំទៅការិយាល័យចេញដំណើរដើម្បីដឹកជញ្ជូនទំនិញក្រោមរបបឆ្លងកាត់ជាតិមកតំបន់សេដ្ឋកិច្ចពិសេស។ លិខិតស្នើសុំនេះ ត្រូវមានការបញ្ជាក់ពីតំណាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករប្រចាំតំបន់សេដ្ឋកិច្ចពិសេស
- ជើងសាគយត្រូវបំពេញប្រតិវេទន៍គយបំព្រួញនៅការិយាល័យចេញដំណើរ
- មន្ត្រីគយទទួលបន្ទុកគ្រប់គ្រងនិវេទន៍ប័ណ្ណទំនិញកាត់កុងតឺន័រចេញពីបញ្ជីស្តុកកុងតឺន័រ
- ក្នុងករណីពុំមានភាពមិនប្រក្រតី មន្ត្រីគយមានសមត្ថកិច្ចត្រូវបោះត្រានិងបញ្ជាក់នីតិវិធីគយឆ្លងកាត់ដោយកំណត់លក្ខខ័ណ្ឌមួយចំនួនដូចជាតម្រាយផ្លូវស្របច្បាប់និងរយៈពេលឆ្លងកាត់ហើយកិបសៀលគយ
- ប្រធានការិយាល័យចេញដំណើរចុះហត្ថលេខាបញ្ចប់បែបបទឆ្លងកាត់
- មន្ត្រីគយអនុញ្ញាតឲ្យកុងតឺន័រចេញទៅតំបន់សេដ្ឋកិច្ចពិសេស។

### គ. ទំនិញនាំចេញឆ្លងកាត់ទៅមាត់ច្រកចេញ

- មន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ចប្រចាំការមាត់ច្រកចេញ ត្រួតពិនិត្យប្រក្រតីភាពនៃសៀលគយលើមធ្យោបាយដឹកជញ្ជូន ឬកុងតឺន័រឆ្លងកាត់ ដោយផ្ទៀងផ្ទាត់ជាមួយឯកសារឆ្លងកាត់។ ក្នុងករណីយល់ថា ពុំមានភាពមិនប្រក្រតី មន្ត្រីគយកាត់សៀលគយចេញមុននឹងអនុញ្ញាតឲ្យដឹកជញ្ជូនចេញ
- មន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ចប្រចាំការមាត់ច្រក បោះត្រា "បានកាត់សៀលគយរួច" និងចុះហត្ថលេខា លើកំណត់ហេតុរួមស្តីពីការត្រួតពិនិត្យទំនិញវាយនភ័ណ្ឌនាំចេញដែលមាន ចុះហត្ថលេខារវាងមន្ត្រីគយនិងរដ្ឋាករនៃសាខាគយនិងរដ្ឋាករនាំចេញ និងមន្ត្រីកាំកុងត្រូលនៃការិយាល័យកាំកុងត្រូលផៃស្ងួត។

## ២.១.៤.២. ឆ្លងកាត់អន្តរជាតិ

ឆ្លងកាត់អន្តរជាតិគឺជាការដឹកជញ្ជូនទំនិញពីការិយាល័យគយមាត់ច្រកចូល ចូលទៅក្នុងដែនគយ ឆ្ពោះទៅកាន់ការិយាល័យគយមាត់ច្រកចេញ ចេញទៅក្រៅដែនគយ។ ប្រតិបត្តិករត្រូវទទួលការអនុញ្ញាតពីអគរ ដើម្បីអនុវត្តនីតិវិធីឆ្លងកាត់អន្តរជាតិ និងត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម÷

### ក. នៅមាត់ច្រកចូល

- ជើងសាគយត្រូវបំពេញប្រតិវេទន៍គយបំព្រួញនៅការិយាល័យចេញដំណើរ
- មន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ចត្រូវបំពេញក្នុងផ្នែក A និង C នៃប្រតិវេទន៍គយ។ ក្នុងករណីពុំមានភាពមិនប្រក្រតី មន្ត្រីគយមានសមត្ថកិច្ចត្រូវបោះត្រានិងបញ្ជាក់នីតិវិធីគយឆ្លងកាត់ដោយកំណត់លក្ខខ័ណ្ឌ មួយចំនួន ដូចជាតម្រាយផ្លូវស្របច្បាប់និងរយៈពេលឆ្លងកាត់ហើយកិបសៀលគយ

### ខ. នៅមាត់ច្រកចេញ

- ប្រតិបត្តិករនីតិវិធីនៃការឆ្លងកាត់គយ ឬ តំណាងរបស់ខ្លួន បង្ហាញប្រតិវេទន៍គយបំពេញ ជូនដល់មន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ច
- មន្ត្រីគយ និង រដ្ឋាករ មាន សមត្ថកិច្ច នា មាត់ច្រកចេញ ត្រួតពិនិត្យនូវប្រក្រតីភាពនៃត្រា ឬ សៀលគយ លើមធ្យោបាយដឹកជញ្ជូន ឬ កុងតឺន័រឆ្លងកាត់។ ក្នុងករណីយល់ថាពុំមានភាពមិនប្រក្រតី មន្ត្រីគយនិង រដ្ឋាករ បញ្ជាក់នៅក្នុងផ្នែក D នៃប្រតិវេទន៍គយ រួចកាត់ត្រា ឬ សៀលគយចេញមុនអនុញ្ញាតឱ្យដឹកជញ្ជូនឆ្លងកាត់ប្រទេសទីបី។

# ២.២. នីតិវិធីពិសេស

## ២.២.១. ធុរជនល្អបំផុត

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**

- ប្រកាសលេខ ៤៥២សហវ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣ ស្តីពីយន្តការលើកទឹកចិត្តជូនធុរជនមានអនុលោមភាពខ្ពស់
- សេចក្តីសម្រេចលេខ ២៧៨ អគរ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការផ្តល់ប្រព្រឹត្តកម្មលើកទឹកចិត្តជូនធុរជនល្អ
- សេចក្តីសម្រេចលេខ ២៧៩ អគរចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការបង្កើតអង្គភាពគ្រប់គ្រងធុរជនល្អ
- លិខិតលេខ ៧៩០ អគរ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការផ្តល់ប្រព្រឹត្តកម្មលើកទឹកចិត្តជូនធុរជនល្អបំផុត

ការអនុវត្តកម្មវិធីលើទឹកចិត្តដល់ធុរជនដែលមានអនុលោមភាពខ្ពស់ គឺជាផ្នែកមួយនៃការអនុវត្តគោលនយោបាយ កិច្ចសម្រួលពាណិជ្ជកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា។ កម្មវិធីនេះត្រូវបានអនុវត្តជាផ្លូវការចាប់ពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤ នាឱកាសពិធីប្រគល់វិញ្ញាបនបត្រសមាជិកក្រុមធុរជនល្អបំផុត នៅអគ្គនាយកដ្ឋានគយនិង រដ្ឋាករកម្ពុជា។ គិតត្រឹមខែកក្កដា ឆ្នាំ២០១៥ ក្រុមហ៊ុនចំនួន ១៣ ត្រូវបាន អគរសម្រេចផ្តល់ជាបណ្តោះអាសន្ននូវសមាជិកភាពក្រុមធុរជនល្អបំផុត។ ជាជំហានបន្ត អគរ នឹងពិនិត្យលទ្ធភាពធ្វើការជ្រើសរើសសមាជិកបន្ថែមទៀត និងឈានទៅអនុវត្តពេញលេញនូវកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាត (Authorized Economic Operator-AEO) តាមជំហាននៃយុទ្ធសាស្ត្រនិងកម្មវិធីកំណែទម្រង់និងទំនើបកម្មឆ្នាំ២០១៤-២០១៨ របស់ខ្លួន។

### ២.២.១.១.គញ្ចប់លក្ខណៈវិនិច្ឆ័យ

ដើម្បីអាចក្លាយជាធុរជនល្អបំផុតនៅកម្ពុជា ធុរជន ឬ បុគ្គលពាក់ព័ន្ធត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម÷

- ស្ថិតក្នុងបញ្ជីធុរជនចំណាត់ថ្នាក់លេខ១ (Rank 1) នៃប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន នាពេលដាក់ពាក្យស្នើសុំ
- ជានីតិបុគ្គលដែលមានដើមទុនចុះបញ្ជីមិនតិចជាង ១ពាន់លានរៀល

- មិនធ្លាប់ប្រព្រឹត្តបទល្មើសគយធ្ងន់ធ្ងរដោយចេតនាក្នុងរយៈពេល ៣ឆ្នាំចុងក្រោយនេះ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំ
- មិនធ្លាប់ជំពាក់បំណុលពន្ធអាករគយហួសកាលកំណត់ ឬ បំណុលផ្សេងទៀតដែលមិនអាចសងបាន
- អនុវត្តបានពេញលេញនូវកាតព្វកិច្ចគ្រប់គ្រងឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងការនាំចេញនាំចូលតាមបទប្បញ្ញត្តិជាធរមាន
- ត្រូវតែជាសមាជិកនៃសហគមន៍ធុរកិច្ចណាមួយដែលមានការអនុញ្ញាត និងត្រូវមានការបញ្ជាក់ពីប្រធាន សហគមន៍ធុរកិច្ចនោះពីភាពរឹងមាំនៃស្ថានភាពហិរញ្ញវត្ថុ និងអនុលោមភាពរបស់ធុរជន
- ត្រូវមានទំហំពាណិជ្ជកម្មនាំចេញនាំចូលប្រចាំឆ្នាំមិនតិចជាង ២លានដុល្លារអាមេរិក និងមានកាតព្វកិច្ចធ្វើរបាយការតាមទម្រង់នានាដែលកំណត់ដោយអង្គភាពគ្រប់គ្រងធុរជនល្អបំផុតនៃ អគរ ។

## ២.២.១.២.កញ្ចប់ប្រព្រឹត្តកម្មលើកទឹកចិត្ត

សម្រាប់ជំហានដំបូងនៃការអនុវត្តសាកល្បង (Pilot Implementation stage) ធុរជនល្អបំផុតនៅកម្ពុជា អាចទទួលបាននូវប្រព្រឹត្តកម្មអនុគ្រោះនានាដូចខាងក្រោម÷

- អាទិភាពមិនរង់ចាំតាមជួរលំដាប់លំដោយតាមគោលការណ៍មកមុនផ្តល់សេវាមុន (First-in First-out principle) ទាំងក្នុងដំណាក់កាលដាក់ឯកសារ ដំណាក់កាលត្រួតពិនិត្យទំនិញឬឯកសារ និងដំណាក់អនុញ្ញាតឱ្យយកទំនិញចេញតាមរូបភាពរហ័សនិងលទ្ធភាពដែលអាចធ្វើទៅបាន
- អាចទទួលបាននូវការអនុញ្ញាតឱ្យជំពាក់បែបបទគយ ដោយលើកលេងការតម្កល់និមុត្តិធានា
- ការលើកលែងនីតិវិធីនៃការផ្ទៀងផ្ទាត់ជាមុននូវតម្លៃគិតពន្ធគយ និងវិញ្ញាបនបត្រប្រភពដើមទំនិញ
- ការលើកលែងកាតព្វកិច្ចអមលិខិតអនុញ្ញាតដឹកជញ្ជូនកាតព្វកិច្ចត្រាពន្ធគយ និងការកាត់បន្ថយកាតព្វកិច្ចឆ្លងម៉ាស៊ីនស្កេន
- លទ្ធភាពនៃការបំពេញបែបបទគយមុនពេលទំនិញមកដល់ (Pre-arrival Clearance) និងការបំពេញបែបបទគយចុងទី (Destination Clearance) ក្រោមរបបគយឆ្លងកាត់ ជាដើម។

## ២.២.១.៣.ការដាក់ពាក្យស្នើសុំជាសមាជិក

ធុរជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីក្លាយជាសមាជិកក្រុមធុរជនល្អបំផុត ត្រូវដាក់ពាក្យស្នើសុំមកអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អមភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និងលក្ខន្តិកៈក្រុមហ៊ុន អមបញ្ជីម្ចាស់ភាគហ៊ុននាថ្ងៃស្នើសុំ
- ការប្រកាសពីស្ថានភាពហិរញ្ញវត្ថុ (Financial Statement) នាពីរឆ្នាំចុងក្រោយ (បើមានការតម្រូវ)
- លិខិតបញ្ជាក់ទទួលស្គាល់អនុលោមភាពពីសហគមន៍ធុរកិច្ចពាក់ព័ន្ធ
- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែមនិង/ឬបណ្ណប៉ាតង់ ឬ លិខិតអនុញ្ញាតប្រហាក់ប្រហែល
- ច្បាប់ចម្លងនៃអត្តសញ្ញាណបណ្ណ ឬ ឯកសារប្រហាក់ប្រហែលរបស់ថ្នាក់ដឹកនាំក្រុមហ៊ុន
- ទំហំនៃការនាំចូលការនាំចេញ និងការលក់ចូលទីផ្សារក្នុងស្រុកនាឆ្នាំចុងក្រោយ។

## ២.២.២. គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ល.គ)

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**

- ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៣ នស ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤
- លិខិតលេខ ១១០ សជណ.ផស ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៩ ស្តីពីករណីអនុវត្តអាករលើតម្លៃបន្ថែម (VAT) លើធាតុចូលដែលនាំចូលដោយរោងចក្រផលិតសំលៀកបំពាក់សម្រាប់នាំចេញ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣
- អនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- ប្រកាសលេខ ១០៥ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងទំនិញដែលត្រូវបានលើកលែងពន្ធ និងអាករ
- ប្រកាសលេខ ៣១១ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះឧស្សាហកម្មគាំទ្រ ឬ អ្នកចុះកិច្ចសន្យា ដែលធ្វើការផ្គត់ផ្គង់ទំនិញ ឬ សេវាសម្រាប់បម្រើឱ្យការ នាំចេញរបស់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរ និងការបូបដៃ និងឧស្សាហកម្មផលិតមួក
- លិខិតលេខ ៣៩៣ អគរ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ស្តីពីការអនុវត្តអាករពិសេស សម្រាប់ការនាំចូលទំនិញមួយចំនួន ដែលជាធាតុចូលផលិតកម្មវិស័យកាត់ដេរ និងឧស្សាហកម្មទ្រទ្រង់វិស័យកាត់ដេរ
- លិខិតលេខ ៧៥៨ អគរ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការអនុវត្តអាករពិសេស សម្រាប់ការនាំចូលទំនិញមួយចំនួនដែលជាធាតុចូលផលិតកម្ម និងឧស្សាហកម្ម ទ្រទ្រង់ផលិតកម្មបម្រើការនាំចេញរបស់វិនិយោគិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

អនុលោមតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា មានតែគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទេ ដែលមានសិទ្ធិទទួលបាននូវផលប្រយោជន៍ ដែលស្ថិតក្នុងក្របខ័ណ្ឌនៃច្បាប់នេះ។ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ហៅកាត់ថា គ. ល. គ មានន័យថាគម្រោងវិនិយោគដែលទទួលបានវិញ្ញាបនបត្រ ចុះបញ្ជីជាស្ថាពរ។ ដើម្បីទទួលស្គាល់ជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អ្នកវិនិយោគត្រូវដាក់សំណើវិនិយោគនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក) ឬ អនុគណៈកម្មាធិការវិនិយោគ ខេត្ត រាជធានី និងទទួលបានវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ។

គម្រោងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានបីប្រភេទ ១) គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើទីផ្សារក្នុងស្រុក ២) គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ ៣) គម្រោងវិនិយោគ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាឧស្សាហកម្មគាំទ្រ។

## ២.២.២.១. ការលើកលែងពន្ធគយ និង អាករ

### ក. ការលើកលែងពន្ធគយ

អនុលោមតាមអនុក្រឹត្យលេខ ១១១ អនក្រ.បក ស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្ម នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបានការលើកលែងពន្ធគយទាំងស្រុង ឬ ជាភាគ ផ្អែកលើប្រភេទនីមួយៗនៃគម្រោងដូចខាងក្រោម÷

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើទីផ្សារក្នុងស្រុក:** សំដៅដល់ គ.ល.គ ដែលមិនបម្រើឱ្យការនាំចេញ។ គម្រោងប្រភេទនេះ ត្រូវបានលើកលែងពន្ធគយលើការនាំចូលសម្ភារបរិក្ខារផលិតកម្ម និងសម្ភារសាងសង់តែប៉ុណ្ណោះ។ ក្នុងករណីដែលគម្រោងប្រភេទនេះមានលទ្ធភាពនាំចេញនូវផ្នែកណាមួយនៃផលិតផលដែលផលិតបានដោយផ្ទាល់ ឬ បានផ្គត់ផ្គង់ដល់ឧស្សាហកម្មនាំចេញ បរិមាណធាតុចូលផលិតកម្ម ដែលបានបង់ពន្ធនាំចូលរួចយកទៅផលិតបម្រើការនាំចេញដោយផ្ទាល់ ឬ ដោយប្រយោលនោះត្រូវបានទទួលការលើកលែងពន្ធគយក្រោយពីការត្រួតពិនិត្យរបាយការណ៍ប្រចាំត្រីមាស។

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ:** សំដៅដល់ គ.ល.គ ដែលបានលក់ ឬបានផ្ទេរសមាមាត្រណាមួយនៃផលិតផលរបស់ខ្លួនទៅឱ្យអ្នកទិញ ឬ អ្នកទទួលនៅក្រៅព្រះរាជាណាចក្រកម្ពុជា។ គម្រោងប្រភេទនេះ ត្រូវបានលើកលែងពន្ធគយលើការនាំចូលសម្ភារបរិក្ខារផលិតកម្ម សម្ភារសាងសង់ និង ធាតុចូលផលិតកម្ម។ ដោយឡែកគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឱ្យការនាំចេញ ដែលស្ថិតនៅក្រោមយន្តការភណ្ឌាគារផលិតកម្ម ក្រោមការគ្រប់គ្រងរបស់គយ ការលើកលែងពន្ធគយត្រូវអនុវត្តទៅតាមច្បាប់ និង បទប្បញ្ញត្តិជាធរមានរបស់យន្តការនោះ។ ធាតុចូលផលិតកម្មដែលកែច្នៃហើយមិនបាននាំចេញ ត្រូវបង់ពន្ធគយ និងអាករឡើងវិញលើធាតុចូលផលិតកម្មនាពេលនាំចូលក្រោយពីការត្រួតពិនិត្យរបាយការណ៍ប្រចាំត្រីមាស។

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាឧស្សាហកម្មគាំទ្រ:** សំដៅដល់ គ.ល.គ ដែលផលិតផលរបស់ខ្លួន១០០(មួយរយ) ភាគរយត្រូវផ្គត់ផ្គង់ដល់ឧស្សាហកម្មនាំចេញ ជំនួសវត្ថុធាតុដើមឬសម្ភារបន្ទាប់បន្សំដែលតែងតែនាំចូល។ គម្រោងប្រភេទនេះត្រូវបានលើកលែងពន្ធគយលើការនាំចូលសម្ភារបរិក្ខារផលិតកម្ម សម្ភារសាងសង់ និងធាតុចូលផលិតកម្ម។ ប៉ុន្តែក្នុងករណីដែលគម្រោងទាំងនេះមិនបានធ្វើការផ្គត់ផ្គង់ ១០០ (មួយរយ)ភាគរយ នៃផលិតផលដែលផលិតបានទៅដល់ឧស្សាហកម្មនាំចេញ ឬនាំចេញដោយផ្ទាល់ទេនោះ គម្រោងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទាំងនោះ ត្រូវបង់ពន្ធនិងអាករឡើងវិញ លើធាតុចូលផលិតកម្មនាពេលនាំចូលនូវបរិមាណដែលមិនបានផ្គត់ផ្គង់ឱ្យឧស្សាហកម្មនាំចេញ ឬ នាំចេញដោយផ្ទាល់ ក្រោយពីការត្រួតពិនិត្យរបាយការណ៍ប្រចាំត្រីមាស។

### ខ. ការលើកលែងអាករ

**វិស័យកាត់ដេរបម្រើឱ្យការនាំចេញ**

- អាករលើតម្លៃបន្ថែម លើធាតុចូលផលិតកម្មនាំចូល ត្រូវបានដាក់ជាបន្ទុករបស់រដ្ឋ (លិខិតលេខ ១១០ សជណ.ផស របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៩ ស្ដីពីករណីអនុវត្ត អាករលើតម្លៃបន្ថែម VAT លើធាតុចូលដែលនាំចូល ដោយរោងចក្រផលិតសំលៀកបំពាក់សម្រាប់នាំចេញ)
- អាករពិសេស លើទំនិញដែលនាំចូលជាធាតុចូលផលិតកម្មសម្រាប់ឧស្សាហកម្មផលិតសំលៀកបំពាក់ ត្រូវបានដាក់ជាបន្ទុករបស់រដ្ឋ (លិខិតលេខ ៣៩៣ អគរ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥)។

#### ឧស្សាហកម្មបម្រើឱ្យការនាំចេញ

- អាករពិសេស លើទំនិញដែលនាំចូលជាធាតុចូលផលិតកម្មសម្រាប់ឧស្សាហកម្មគាំទ្រដល់ឧស្សាហកម្ម បម្រើឱ្យការនាំចេញត្រូវបានដាក់ជាបន្ទុករបស់រដ្ឋ (លិខិតលេខ ៧៥៨ អគរ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ របស់ អគរ)។

#### ឧស្សាហកម្មគាំទ្រដល់ឧស្សាហកម្មបម្រើឱ្យការនាំចេញ

- អាករលើតម្លៃបន្ថែម លើទំនិញនាំចូលដែលជាធាតុចូលផលិតកម្មនិងសម្ភារបរិក្ខារផលិតកម្មសម្រាប់បម្រើឱ្យការផ្គត់ផ្គង់ដោយផ្ទាល់ដល់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិត ស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរ និងកាបូបដៃ និងឧស្សាហកម្មផលិតម្ជុក ត្រូវបានចាត់ទុកជាបន្ទុករបស់រដ្ឋ។
- អាករពិសេស លើទំនិញដែលនាំចូលជាធាតុចូលផលិតកម្ម សម្រាប់ ឧស្សាហកម្ម គាំទ្រ ដល់ឧស្សាហកម្ម បម្រើឱ្យការនាំចេញត្រូវបានដាក់ជាបន្ទុករបស់រដ្ឋ (លិខិតលេខ ៣៩៣ អគរ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ និងលិខិតលេខ ៧៥៨ អគរ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥)។

### ២.២.២.២. នីតិវិធីនាំចូលសម្រាប់ គ.ល.គ

ដើម្បីនាំចូលនូវសម្ភារបរិក្ខារផលិតកម្ម សម្ភារសាងសង់ ឬ ធាតុចូលផលិតកម្មសម្រាប់បម្រើដល់ផលិតកម្មរបស់ខ្លួនដោយទទួលបាននូវការលើកលែងពន្ធ ឬ អាករ គ.ល.គ ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម÷

- អ្នកវិនិយោគ ឬ តំណាងត្រូវស្នើសុំបញ្ជីមេនៃមុខទំនិញនាំចូលបម្រើឱ្យ គ.ល.គ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា “គណៈកម្មាធិការវិនិយោគកម្ពុជា” (ក.អ.ក“គ.វ.ក”)។
- បន្ទាប់ពីទទួលបានការអនុញ្ញាតពី ក.អ.ក “គ.វ.ក” បញ្ជីមេខាងលើ ត្រូវយកមកតម្កល់ទុកនៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (នាយកដ្ឋានរបបគយ)។
- នៅពេលនាំចូល ទំនិញដែលមាននៅក្នុងបញ្ជីមេ អ្នកវិនិយោគ ឬ តំណាងត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតគយ មកអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (នាយកដ្ឋានរបបគយ) ដោយភ្ជាប់មកជាមួយនូវឯកសារចាំបាច់នានារួមមាន វិក្កយបត្រទំនិញ បញ្ជីវេចខ្ចប់ ឯកសារដឹកជញ្ជូន លិខិតផ្ទេរសិទ្ធិ សម្រាប់បុគ្គលតំណាង និងឯកសារពាក់ព័ន្ធផ្សេងទៀតក្នុងករណីចាំបាច់។
- បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតគយ អ្នកវិនិយោគ ឬតំណាងត្រូវអនុវត្តនីតិវិធីនៃការបំពេញប្រតិវេទន៍គយ ដូចមានក្នុងចំណុច ២.១.។

### ២.២.២.៣. ការបំពេញបែបបទបញ្ចេញទំនិញនាំចេញនៅសាខាគយនិងរដ្ឋាករនាំចេញ

#### ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ

- សេចក្តីណែនាំលេខ ៨២២ គ.រ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែសំរួលមុខសញ្ញាប្រើប្រាស់នូវប្រភេទខ្សែចំណង SEAL គយ សំរាប់កិបចំណាំលើទ្វារកុងតឺន័រទំនិញនាំចេញ ឬ នាំចូល សម្រាប់ករណីចាំបាច់នានារបស់ការិយាល័យនាំចេញ ផែស្ងួត និងសាខាគយ និងរដ្ឋាករក្រុងព្រះសីហនុ របស់ទីចាត់ការគយនិងរដ្ឋាករ។
- សេចក្តីណែនាំលេខ ០១៦ សហវ.សជណ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៤ សេចក្តីជូនដំណឹង ស្តីពីការកែសំរួលនីតិវិធីនាំចេញលើមុខទំនិញវាយនភ័ណ្ឌ
- សេចក្តីណែនាំលេខ៤៦៨៣សហវ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការបង្កើតការិយាល័យសហព័ទ្ធរវាងអង្គភាពគយ និងរដ្ឋាករ និងកាំកុងត្រូល របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សេចក្តីណែនាំលេខ៧៤១គរ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីទំនិញសំលៀកបំពាក់

នាំចេញទៅកាន់ទីផ្សារសហគមន៍អឺរ៉ុប លក់ជូនក្រុមហ៊ុន DuPont គ្មានស្លាកសញ្ញា “Made in Cambodia” នៅលើសំបកកាតុង របស់ទីចាត់ការគយនិងរដ្ឋាករកម្ពុជា

- ប្រកាសលេខ ១៤៤៧ សហវ.ប្រកចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីបញ្ញត្តិ និងនីតិវិធីប្រតិវេទន៍គយ
- សេចក្តីណែនាំលេខ៨៣៥គរ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការដកគំរូទំនិញវាយនភ័ណ្ឌនាំចេញ របស់ទីចាត់ការគយ និងរដ្ឋាករ
- សេចក្តីណែនាំលេខ៥៤៨អគរ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការកំណត់នីតិវិធីសម្រាប់ការត្រួតពិនិត្យបែបបទគយលើទំនិញវាយនភ័ណ្ឌនាំចូលត្រឡប់មកវិញ ក្រោយពីបាននាំចេញ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- ប្រកាសលេខ ៣៨៩សហវ.ប្រកចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពមូលដ្ឋាននៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- សេចក្តីណែនាំលេខ ១១១៤ អគរ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការកែសម្រួលនីតិវិធីនិងតំរូវការឯកសារ សំរាប់ការត្រួតពិនិត្យបែបបទគយលើទំនិញវាយនភ័ណ្ឌនិងកាត់ដេរនាំចូលត្រឡប់មកវិញក្រោយពីបាននាំចេញប្រកាសលេខ ១១៥៧សហវ.ប្រកចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ក. នីតិវិធីទូទៅ សម្រាប់ការបំពេញបែបបទបញ្ចេញទំនិញនាំចេញ

សាខាគយ និងរដ្ឋាករនាំចេញមានមុខងារនិងភារកិច្ចធ្វើជាសេនាធិការឲ្យ អគរ លើការងារបំពេញបែបបទគយលើទំនិញនាំចេញស្ថិតក្រោមរូបភាពវិនិយោគ និងការងារផ្សេងទៀតដូចមានចែងក្នុងប្រការ៤ នៃប្រកាសលេខ ៣៨៩ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១០។ ការត្រួតពិនិត្យរូបវន្តទំនិញនាំចេញនៅសាខាគយនិងរដ្ឋាករនាំចេញ ត្រូវធ្វើឡើងតែម្តងរួមគ្នារវាងមន្ត្រីគយនិងរដ្ឋាករ និងមន្ត្រីកាំកុងត្រូលលើទម្រង់ឯកសារ ត្រួតពិនិត្យតែមួយរួមគ្នា គឺកំណត់ហេតុរួមស្តីពីការត្រួតពិនិត្យទំនិញវាយនភ័ណ្ឌនាំចេញ (សេចក្តីណែនាំលេខ០១៦ សហវ.សជណ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៤ សេចក្តីជូនដំណឹងស្តីពីការកែសំរួលនីតិវិធីនាំចេញលើមុខទំនិញវាយនភ័ណ្ឌ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម និងសេចក្តីណែនាំលេខ ៤៦៨៣ សហវ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការបង្កើតការិយាល័យសហព័ន្ធរវាងអង្គភាពគយនិងរដ្ឋាករនិងកាំកុងត្រូល របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)។

ទំនិញនាំចេញដែលជាកម្មវត្ថុនៃការធ្វើបែបបទគយនាំចេញនៅសាខាគយនិងរដ្ឋាករនាំចេញ គឺជាទំនិញនាំចេញស្ថិតក្រោមរូបភាពវិនិយោគ នៅតាមបណ្តាសន្និធិគយបណ្តោះអាសន្ន និង/ឬ អាជីវកម្មដ្ឋាននានារបស់វិនិយោគិន និងទំនិញនាំចេញផ្សេងទៀត តាមការកំណត់របស់ អគរ ។ ក្រោយពេលត្រួតពិនិត្យរូបវន្តទំនិញផ្ទុកក្នុងកុងតឺន័ររួចរាល់ មន្ត្រីគយនៃសាខាគយនិងរដ្ឋាករនាំចេញ និងមន្ត្រីកាំកុងត្រូលធ្វើការកិបសៀលគយ និងសៀលកាំកុងត្រូលរៀងៗខ្លួន ។ សៀលគយនាំចេញកិបនៅផ្នែកខាងស្តាំនៃទ្វារកុងតឺន័រ នឹងត្រូវកាត់ចេញវិញមុនពេលលើកឡើងមធ្យោបាយដឹកជញ្ជូននាំចេញដោយមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ចនៅមាត់ច្រកចេញក្រោយពេលពិនិត្យផ្ទៀងផ្ទាត់លេខសៀលជាក់ស្តែង និងឯកសារគយនាំចេញ (សេចក្តីណែនាំលេខ ៨២២គ.រ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៣)។

## ខ. នីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយ

អ្នកនាំចេញទំនិញទាំងអស់ត្រូវភ្ជាប់ឯកសារពាក់ព័ន្ធដើម្បីបំពេញបែបបទបញ្ចេញទំនិញពីគយ។ នីតិវិធីនៃការបំពេញប្រតិវេទន៍គយ ដូចមានក្នុងចំណុច ២.១.។

## ២.២.៣. តំបន់សេដ្ឋកិច្ចពិសេស (តសព)

### ២.២.៣.១. ការលើកទឹកចិត្តពន្ធ និងអាករដល់អ្នកវិនិយោគក្នុងតំបន់

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**

- អនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្ដីពីការអនុវត្តច្បាប់វិសោធនកម្ម នៃច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- អនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្ដីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- លិខិតលេខ៣៨៤១ សហវ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការលើកលែងអាករលើតម្លៃបន្ថែម (VAT) សម្រាប់វិនិយោគិនក្នុងតំបន់សេដ្ឋកិច្ចពិសេស (SEZ)
- លិខិតលេខ៣៧២៥ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១០ ស្ដីពីការបន្តព្យួរបណ្ដោះនូវអាករលើតម្លៃបន្ថែម (VAT) សម្រាប់វិនិយោគិនក្នុងតំបន់ពិសេសពិសេស (SEZ) រហូតដល់មានការសម្រេចជាថ្មី
- លិខិតលេខ ៧៥៨ អគរ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ ស្ដីពីការអនុវត្តអាករពិសេសសម្រាប់ការនាំចូលទំនិញមួយចំនួនដែលជាធាតុចូលផលិតកម្ម និងឧស្សាហកម្មទ្រទ្រង់ផលិតកម្មបម្រើឲ្យការនាំចេញ សម្រាប់គំរោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

ការលើកទឹកចិត្តលើការនាំចូល សម្ភារបរិក្ខារផលិតកម្ម សម្ភារសាងសង់ ធាតុចូលផលិតកម្ម ត្រូវសម្រេចផ្ដល់ជូនដល់អ្នកវិនិយោគក្នុងតំបន់តាមសំណូមពរ និងគោលការណ៍នៃច្បាប់ ដោយសាមីអ្នកវិនិយោគក្នុងតំបន់នោះ ត្រូវរៀបចំបញ្ជីសម្ភារបរិក្ខារផលិតកម្ម សម្ភារសាងសង់ ធាតុចូលផលិតកម្មដែលត្រូវនាំចូលទាំងនោះ ដាក់ជូនរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសពិនិត្យ ដែលនឹងត្រូវផ្តល់ជូននៅនឹងកន្លែង ហើយរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសគ្រាន់តែរាយការណ៍ជូនមក គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងស្ថាប័នគ្រប់គ្រង ដើម្បីជ្រាបជាព័ត៌មានប៉ុណ្ណោះ។

សិទ្ធិដែលត្រូវបានទទួលការលើកទឹកចិត្តផ្នែកសារពើពន្ធនឹងសម្រេចជូនអ្នកវិនិយោគក្នុងតំបន់ នៅក្នុងវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ ដែលនឹងត្រូវចេញជូនអ្នកវិនិយោគក្នុងតំបន់ ស្របតាមច្បាប់ និងអនុក្រឹត្យ ស្ដីពីការអនុវត្តច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជាជាធរមាន។

**ក. ការលើកលែងពន្ធគយ÷** ដូចបញ្ជាក់ក្នុងចំណុច ២.២.២.១ ស្ដីពីការលើកលែងពន្ធគយ។

**ខ. ការលើកលែងអាករ÷**

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើទីផ្សារក្នុងស្រុក:**

- អាករលើតម្លៃបន្ថែម លើសម្ភារបរិក្ខារផលិតកម្ម និង សម្ភារសាងសង់នាំចូល ត្រូវបានលើកលែង (លិខិតលេខ ៣៨៤១ សហវ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៩ និងលិខិតលេខ៣៧២៥ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បម្រើឲ្យការនាំចេញ:**

- អាករលើតម្លៃបន្ថែម លើសម្ភារបរិក្ខារផលិតកម្ម សម្ភារសាងសង់ និងវត្ថុធាតុដើមនាំចូល ត្រូវបានលើកលែង (លិខិតលេខ ៣៨៤១ សហវ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៩ និងលិខិតលេខ ៣៧២៥ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)

- អាករពិសេសលើផាតុចូលផលិតកម្ម នាំចូល ត្រូវបានលើកលែង (លិខិតលេខ ៧៥៨ អគរ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ របស់ អគរ)។

**គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលជាឧស្សាហកម្មគាំទ្រ:**

- អាករលើតម្លៃបន្ថែម លើសម្ភារបរិក្ខារផលិតកម្ម សម្ភារសាងសង់ និងវត្ថុធាតុដើមនាំចូល ត្រូវបានលើកលែង (លិខិតលេខ ៣៨៤១ សហវ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៩ និងលិខិតលេខ៣៧២៥ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)
- អាករពិសេស លើផាតុចូលផលិតកម្ម នាំចូល ត្រូវបានលើកលែង (លិខិតលេខ ៧៥៨ អគរ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា)។

## ២.២.៣.២.នីតិវិធីនាំចូល

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ÷**

- ប្រកាសលេខ៧៣៤ សហវ.ប្រក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីនីតិវិធីគយពិសេសសម្រាប់អនុវត្តក្នុងតំបន់សេដ្ឋកិច្ចពិសេស
- លិខិតលេខ១៣៥៨ អគរ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការសំរួលពាណិជ្ជកម្មបន្ថែមដល់វិនិយោគិនក្នុងតំបន់សេដ្ឋកិច្ចពិសេស

**ក. តំបន់ដែលស្ថិតនៅជិតមាត់ច្រកព្រំដែនផ្លូវការ ឬស្ថិតនៅក្នុងរង្វង់ម្ភៃ(២០) គីឡូម៉ែត្រ នៃរង្វង់អំណាចគយមណ្ឌលដីគោកជាប់ព្រំដែនគោក ឬ តំបន់ឆ្នេរសមុទ្រ (ចំណុច ៣.៤.១ នៃប្រកាសលេខ៧៣៤ សហវ.ប្រក)**

**១. នៅមាត់ច្រកផ្លូវការ**

អ្នកវិនិយោគគ្រាន់តែបង្ហាញឯកសារពាក់ព័ន្ធការដឹកជញ្ជូនឆ្លងកាត់ទៅ តសព

↓

**២. នៅ តសព**

អ្នកវិនិយោគតម្កល់ឯកសារទាក់ទងការដឹកជញ្ជូនឆ្លងកាត់ដោយអនុវត្តតាមនីតិវិធីដូចការណែនាំ

**១.នៅមាត់ច្រកផ្លូវការ**

- មន្ត្រីគយមានសមត្ថកិច្ចប្រចាំតំបន់ ត្រូវពិនិត្យ និងស្នើសុំការសម្រេចពី អគរ ដើម្បីកំណត់តម្រាយផ្លូវលំហូរទំនិញដោយសេរី (seamless route) និងកំណត់រយៈពេលសមស្រប សម្រាប់ដឹកជញ្ជូនទំនិញឆ្លងកាត់ទៅ-មករវាង តសព និងមាត់ច្រកព្រំដែនផ្លូវការ
- អ្នកនាំចូលគ្រាន់តែបង្ហាញ និងផ្តល់ជូនដល់មន្ត្រីគយមានសមត្ថកិច្ចនៅមាត់ច្រកផ្លូវការ នូវឯកសារចម្លងដែលពាក់ព័ន្ធនឹងទំនិញឆ្លងកាត់ទៅ **តសព**។ ឯកសាររួមមាន វិក្កយបត្រ ឯកសារដឹកជញ្ជូន ឬ ឯកសារផ្សេងទៀតដែលអាចបង្ហាញបាននូវទិន្នន័យទំនិញ ឬ ថាទំនិញនេះត្រូវដឹកជញ្ជូនទៅ **តសព** នៅជិតមាត់ច្រកផ្លូវការនេះ។

**២. នៅតំបន់សេដ្ឋកិច្ចពិសេស (តសព)**

- អ្នកនាំចូលត្រូវតម្កល់ឯកសារដែលអាចបង្ហាញនូវទិន្នន័យពាក់ព័ន្ធនឹងទំនិញដូចរៀបរាប់ខាងលើដល់មន្ត្រីគយមានសមត្ថកិច្ច
- មន្ត្រីគយមានសមត្ថកិច្ច គ្រាន់តែផ្ទៀងផ្ទាត់បឋមនូវអត្តសញ្ញាណបុគ្គលពាក់ព័ន្ធ មធ្យោបាយដឹកជញ្ជូន និងឯកសារពាក់ព័ន្ធរួចអនុញ្ញាតឲ្យទំនិញឆ្លងចូលទៅក្នុងអាជីវកម្មដ្ឋានរបស់អ្នកវិនិយោគ

ក្នុងតំបន់ដែលពាក់ព័ន្ធ ឬ ទីតាំងផ្សេងទៀតនៃ **តសព** ប្រសិនបើអ្នកវិនិយោគពុំមានទីតាំងសមស្របសម្រាប់ទទួលទំនិញនេះ

- អ្នកនាំចូលអាចចាត់ចែងវេទំនិញរបស់ខ្លួន ដើម្បីប្រើប្រាស់ ឬកែច្នៃតាមតម្រូវការនៃការវិនិយោគរបស់ខ្លួន ដោយពុំចាំបាច់មានវត្តមានមន្ត្រីគយមានសមត្ថកិច្ចឡើយ លើកលែងតែមានការតម្រូវជាពិសេស ពីមន្ត្រីទាំងនេះ ដើម្បីធ្វើការពិនិត្យរូបវន្តលើទំនិញ ស្របតាមគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ និងដោយមានការអនុញ្ញាតជាមុនពីតំណាង អគរ ប្រចាំតំបន់
- ក្រោយពេលវេទំនិញរួចភ្លាម អ្នកនាំចូលត្រូវតម្កល់ប្រតិវេទន៍គយលម្អិតជូនមន្ត្រីគយមានសមត្ថកិច្ច តាមនីតិវិធី ASYCUDA ដូចបញ្ជាក់ក្នុងចំណុច ២.១.១ ដោយបញ្ជាក់ច្បាស់លាស់នូវមុខទំនិញដែលមាន ឬគ្មានក្នុងបញ្ជីមេដែលមានការឯកភាពពីរដ្ឋបាល **តសព** ឬ ពីគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា
- មន្ត្រីគយមានសមត្ថកិច្ច ត្រូវគ្រប់គ្រង កាត់កងចេញពីបញ្ជីមេនូវមុខទំនិញដែលប្រកាសខាងលើ។ ចំពោះមុខទំនិញដែលគ្មានក្នុងបញ្ជីមេតែស្ថិតក្នុងមុខសញ្ញា ត្រូវលើកទឹកចិត្តស្របតាមបញ្ញត្តិនៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក នោះតំណាង អគរ ប្រចាំតំបន់ មានសិទ្ធិអនុញ្ញាតឱ្យនាំចូលដោយជំពាក់បែបបទគយនៅនឹងកន្លែង ប្រសិនបើ មានការ ស្នើសុំ ដូចគ្នា នេះ ពី អ្នកវិនិយោគក្នុងតំបន់។ ចំពោះមុខទំនិញផ្សេងទៀតដែលមិនស្ថិតក្នុងមុខសញ្ញាលើកទឹកចិត្តដូចរៀបរាប់ខាងលើ គឺជាកម្មវត្ថុនៃការអនុវត្តតាមនីតិវិធីគយជាធរមាន ជាពិសេសពាក់ព័ន្ធនឹងកាតព្វកិច្ច ពន្ធ និងអាករ និងការជាប់កម្រិតកំណត់ផ្សេង។

**ខ. ដែលមិនស្ថិតនៅជិតមាត់ច្រកព្រំដែនផ្លូវការ ឬ មិនស្ថិតនៅក្នុងរង្វង់ម្លៃ (២០) គីឡូម៉ែត្រ នៃរង្វង់អំណាចគយមណ្ឌលដីគោកជាប់ព្រំដែនគោក ឬ តំបន់ឆ្នេរសមុទ្រ (ចំណុច ៣.៤.២ នៃប្រកាសលេខ ៧៣៤ សហវ.ប្រក)**

**១. អ្នកវិនិយោគ**
ដាក់ពាក្យសុំដឹកជញ្ជូនទំនិញក្រោមរបបឆ្លងកាត់ជាតិ

↓

**២. មន្ត្រីគយប្រចាំ តសព**
បញ្ជាក់លើពាក្យសុំដឹកជញ្ជូនទំនិញក្រោមរបបឆ្លងកាត់ជាតិ (រយៈពេល ២ម៉ោងធ្វើការ)

↓

**៣. មន្ត្រីគយប្រចាំមាត់ច្រកផ្លូវការ**
ផ្ទៀងផ្ទាត់ និងអនុវត្តនីតិវិធីឆ្លងកាត់ទៅ តសព (រយៈពេល ២ម៉ោងធ្វើការ)

↓

**៤. មន្ត្រីគយប្រចាំ តសព**
អនុវត្តតាមនីតិវិធីដូចបញ្ជាក់ក្នុងចំណុច ក.២ ខាងលើ

### ១. អ្នកវិនិយោគ

- អ្នកវិនិយោគ ក្នុង តំបន់ ត្រូវ ស្នើសុំ ជាលាយលក្ខណ៍អក្សរទៅការិយាល័យគយមាត់ច្រកផ្លូវការ ដែលទំនិញរបស់ខ្លួនត្រូវបាននាំចូល ដើម្បីសុំការអនុញ្ញាតដឹកជញ្ជូនទំនិញក្រោមរបបឆ្លងកាត់ជាតិពីមាត់ច្រកផ្លូវការ មក **តសព** ដែលខ្លួនធ្វើអាជីវកម្ម
- លិខិតស្នើសុំដឹកជញ្ជូនទំនិញក្រោមរបបឆ្លងកាត់ជាតិ ត្រូវមានការបញ្ជាក់ទទួលស្គាល់ពីមន្ត្រីគយមានសមត្ថកិច្ចប្រចាំ **តសព**។

### ២. មន្ត្រីគយប្រចាំ តសព

- មន្ត្រីគយប្រចាំ តសព ត្រូវបញ្ជាក់ទទួលស្គាល់លើពាក្យសុំដឹកជញ្ជូនទំនិញក្រោមរបបឆ្លងកាត់ជាតិក្នុងរយៈពេល ពីរ (២) ម៉ោងធ្វើការ។

### ៣. មន្ត្រីគយប្រចាំមាត់ច្រកផ្លូវការ

- ដាក់ពាក្យសុំដឹកជញ្ជូនដឹកទំនិញក្រោមរបបឆ្លងកាត់ជាតិ ដោយមានការបញ្ជាក់ទទួលស្គាល់ពីមន្ត្រីគយ ប្រចាំ តសព ជូនមន្ត្រីគយប្រចាំមាត់ច្រកផ្លូវការ ដោយអមភ្ជាប់ប្រតិវេទន៍គយឆ្លងកាត់ និងឯកសារពាក់ព័ន្ធនានា
- មន្ត្រីគយប្រចាំមាត់ច្រកផ្លូវការត្រូវផ្តល់អាទិភាពក្នុងការពិនិត្យ ផ្ទៀងផ្ទាត់បែបបទគយឆ្លងកាត់តាមសំណើនេះ និងអនុញ្ញាតឱ្យដឹកទំនិញឆ្លងកាត់មក តសព ជាបន្ទាន់ ដោយគ្រាន់តែកិបសៀលគយ និងអមភ្ជាប់ដោយឯកសារពាក់ព័ន្ធ តាមនីតិវិធីឆ្លងកាត់ជាធរមាន។ មន្ត្រីគយមាត់ច្រកផ្លូវការយ៉ាងតិចបី (៣) នាក់ ត្រូវចាត់តាំងឱ្យទទួលបន្ទុកក្នុងការទំនាក់ទំនង និងត្រួតពិនិត្យបែបបទគយឆ្លងកាត់ជូនអ្នកវិនិយោគ ដោយសម្រួលការងារជូនតែមួយកន្លែង ក្នុងរយៈពេលមិនលើសពីរ (២) ម៉ោងធ្វើការ គិតចាប់ពីពេលទទួលឯកសារ តាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងការឆ្លងកាត់គយជាធរមាន។

### ៤. មន្ត្រីគយប្រចាំ តសព

- នៅពេលទំនិញឆ្លងកាត់មកដល់ **តសព** មន្ត្រីគយប្រចាំតំបន់ ត្រូវអនុវត្តតាមនីតិវិធីដូចបញ្ជាក់ក្នុងចំណុច ក.២ ខាងលើ

## ២.២.៣.៣. នីតិវិធីនាំចេញ

### ក. នាំចេញផ្ទាល់ពីតំបន់សេដ្ឋកិច្ចពិសេស

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ÷**

- ប្រកាសលេខ៧៣៤ សហវ.ប្រក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីនីតិវិធីគយពិសេសសម្រាប់អនុវត្តក្នុងតំបន់សេដ្ឋកិច្ចពិសេស
- លិខិតលេខ ១៣៥៨ អគរ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការសំរួលពាណិជ្ជកម្មបន្ថែមដល់វិនិយោគិនក្នុងតំបន់សេដ្ឋកិច្ចពិសេស

**១. អ្នកវិនិយោគ**
តម្កល់ប្រតិវេទន៍គយនាំចេញនៅការិយាល័យគយប្រចាំ **តសព**

↓

**២. មន្ត្រីគយប្រចាំ តសព**
ពិនិត្យបែបបទនាំចេញ(ក្នុងករណីពុំមានភាពមិនប្រក្រតី អនុញ្ញាតឱ្យដឹកទំនិញចេញជាបន្ទាន់)

↓

**៣. មន្ត្រីគយប្រចាំមាត់ច្រកផ្លូវការ**
ផ្ទៀងផ្ទាត់ប្រក្រតីភាព មធ្យោបាយដឹកជញ្ជូនឯកសារពាក់ព័ន្ធ (ករណីគ្មានភាពមិនប្រក្រតីអនុញ្ញាតឱ្យទំនិញចេញជាបន្ទាន់)

### ១. អ្នកវិនិយោគ

វិនិយោគតម្កល់ប្រតិវេទន៍គយនាំចេញតាមនីតិវិធី ASYCUDA ដូចបញ្ជាក់ក្នុងចំណុច ២.១.១ នៅការិយាល័យគយនិងរដ្ឋាករប្រចាំ **តសព** តាមនីតិវិធីជាធរមាន។

### ២. មន្ត្រីគយប្រចាំ តសព

- មន្ត្រីគយប្រចាំតំបន់ពិនិត្យ ផ្ទៀងផ្ទាត់បែបបទនាំចេញ
- ក្នុងករណីពុំមានភាពមិនប្រក្រតី មន្ត្រីគយមានសមត្ថកិច្ច ត្រូវអនុញ្ញាតឱ្យទំនិញបាននាំចេញជាបន្ទាន់ ដោយគ្រាន់តែកិបសៀលគយ និងអមភ្ជាប់នូវច្បាប់ចម្លងនៃឯសារនាំចេញពាក់ព័ន្ធតាមនីតិវិធីគយជាធរមានសម្រាប់បង្ហាញជូនមន្ត្រីគយមានសមត្ថកិច្ចប្រចាំមាត់ច្រកផ្លូវការ។ ចំពោះទំនិញដែលមិនផ្ទុកក្នុងកុងតឺន័រ ត្រូវកសាងយន្តការឃ្លាំមើល។

### ៣. មន្ត្រីគយប្រចាំមាត់ច្រកផ្លូវការ

- មន្ត្រីគយមានសមត្ថកិច្ចប្រចាំមាត់ច្រកផ្លូវការ ត្រូវផ្ទៀងផ្ទាត់ប្រក្រតីភាពមធ្យោបាយដឹកជញ្ជូន និងឯកសារពាក់ព័ន្ធភ្លាមដោយមិនបង្អែបង្អង់

ឬ រង់ចាំតាមលំដាប់លំដោយនោះទេ ។ ករណីពុំមានភាពមិនប្រក្រតីគួរឲ្យកត់សម្គាល់នោះទេ ត្រូវអនុញ្ញាតឲ្យទំនិញចេញជាបន្ទាន់។ ការត្រួតពិនិត្យរូបវន្តលើទំនិញអាចអនុវត្តបានតែក្នុងករណីមានភាពមិនប្រក្រតីច្បាស់លាស់ និងត្រូវមានការអនុញ្ញាតជាមុនពីប្រធានអង្គភាពពាក់ព័ន្ធជាលាយល័ក្ខណ៍អក្សរ ស្របតាមគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ។

## ខ. នាំចេញតាមរយៈផែស្ងួត

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ÷**

- លិខិតលេខ៦៥៣ អគរ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១១ ស្តីពីការសម្រួលនីតិវិធីគយសម្រាប់ការដឹកទំនិញចេញពីតំបន់សេដ្ឋកិច្ចពិសេស មកបណ្តាផែស្ងួតដើម្បី បញ្ចូលក្នុងកុងតឺន័ររួមគ្នាជាមួយនឹងទំនិញផ្សេង ដើម្បីនាំចេញទៅបរទេស

**១. អ្នកវិនិយោគ**
ស្នើសុំគយប្រចាំ **តសព** ដឹកទំនិញទៅផែស្ងួត

↓

**២. មន្ត្រីគយប្រចាំ តសព**
អនុញ្ញាតឱ្យដឹកទំនិញចេញពីតំបន់ ទៅផែស្ងួត

↓

**៣. មន្ត្រីសាខាគយនិងរដ្ឋាករនាំចេញ**
ផ្ទៀងផ្ទាត់ប្រក្រតីភាព និងបញ្ជាក់ទំនិញ
មកដល់ផែស្ងួត និងអនុញ្ញាតឱ្យធ្វើបែបបទនាំចេញ

### ១. អ្នកវិនិយោគ

- អ្នកវិនិយោគដាក់ពាក្យស្នើសុំ (៣ច្បាប់) ទៅមន្ត្រីគយប្រចាំ **តសព** ដើម្បីដឹកជញ្ជូនទំនិញចេញពីតំបន់ ទៅផែស្ងួត។

### ២. មន្ត្រីគយប្រចាំ តសព

- មន្ត្រីគយប្រចាំ តសព បញ្ជាក់ទទួលស្គាល់ និងអនុញ្ញាតឲ្យដឹកឆ្លងកាត់មកបំពេញបែបបទនៅផែស្ងួតតែម្តង ដោយទំនិញត្រូវផ្ទុកក្នុងកុងតឺន័រ កិបសៀលគយ និងអមភ្ជាប់ដោយឯកសារពាក់ព័ន្ធ តាមមធ្យោបាយដឹកជញ្ជូន។

### ៣. មន្ត្រីសាខាគយនិងរដ្ឋាករនាំចេញ

- ពេលទំនិញមកដល់ផែស្ងួត ម្ចាស់ទំនិញ ឬតំណាងស្របច្បាប់ ត្រូវរាយការណ៍ជូនមន្ត្រីគយមានសមត្ថកិច្ចនៃសាខាគយនិងរដ្ឋាករនាំចេញភ្លាម ដើម្បីផ្ទៀងផ្ទាត់ប្រក្រតីភាពនៃសៀល និងមធ្យោបាយដឹកជញ្ជូន និងបញ្ជាក់ការមកដល់គោលដៅនៃទំនិញ
- ក្នុងករណីមិនមានភាពមិនប្រក្រតី ត្រូវកាត់សៀល និងអនុញ្ញាតឲ្យបំពេញបែបបទគយនាំចេញភ្លាម ឬអនុញ្ញាតឲ្យរើទំនិញរក្សាទុកក្នុងឃ្លាំងផែស្ងួត ដើម្បីរង់ចាំបំពេញបែបបទគយតាមក្រោយ ដោយដាក់ឲ្យស្ថិតក្រោមការទទួលខុសត្រូវរបស់ប្រតិបត្តិករផែស្ងួត និងរង់ចាំការបំពេញបែបបទគយនាំចេញតាមនីតិវិធីគយជាធរមាន
- នៅពេលបញ្ចប់ការបំពេញប្រតិវេទន៍គយនាំចេញ មន្ត្រីគយធ្វើការត្រួតពិនិត្យ និងអនុញ្ញាតឲ្យរើទំនិញបញ្ចូលកុងតឺន័រ និងកិបសៀលគយ។

### ២.២.៣.៤. ការលក់ទំនិញចូលទីផ្សារក្នុងស្រុក

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**

- អនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

**ក. ស្នើសុំការអនុញ្ញាតពីរដ្ឋបាលតំបន់**

- ចំពោះការលក់ធាតុចេញផលិតកម្មដែលខូច ឬខូចគុណភាព ឬ ហួសសម័យដែលមិនអាចនាំចេញ ចូលទីផ្សារក្នុងស្រុកអ្នកវិនិយោគត្រូវស្នើសុំការអនុញ្ញាតពីរដ្ឋបាលតំបន់។

**ខ. តម្លៃប្រតិវេទន៍គយលម្អិត**

- រាល់ទំនិញដែលបញ្ចេញទៅលក់នៅទីផ្សារក្នុងស្រុក ទោះបីក្នុងស្ថានភាពណាក៏ដោយ ទំនិញនោះត្រូវបំពេញបែបបទដូចជាទំនិញដែលនាំចូលមកព្រះរាជាណាចក្រកម្ពុជា និងត្រូវរងនូវកាតព្វកិច្ចបង់ពន្ធនាំចូល និងអាករផ្សេងៗទៀតជាធរមាន ដោយតម្លៃប្រតិវេទន៍គយតាមប្រព័ន្ធ ASYCUDA ដូចមានបញ្ជាក់ ក្នុងចំណុច ២.១.។

## ២.២.៤. ការនាំចូលតាមរបបប្រវេសន៍កាលិក

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**

- ប្រកាសលេខ ៩២៨ សហវ.ប្រក ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៨ ស្តីពីការនាំចូលបណ្តោះអាសន្នតាមរបបប្រវេសន៍កាលិក

**ប្រវេសន៍កាលិក** គឺជានីតិវិធីគយ ដែលអាចអនុញ្ញាតឱ្យទំនិញនាំចូលបានក្នុងដែនគយ ក្រោមលក្ខខណ្ឌរួចផុតពីការបង់ពន្ធនិងអាករទាំងស្រុង ឬ ភាគខ្លះ។ ទំនិញទាំងនោះត្រូវបាននាំចូលក្នុងគោលបំណងច្បាស់លាស់ ហើយត្រូវនាំចេញទៅវិញក្នុងកម្រិតពេលវេលាជាក់លាក់មួយ និងមិនធ្វើការកែច្នៃ ឬ ផ្លាស់ប្តូរ លើកលែងតែការរលស់ជាធម្មតាតាមការប្រើប្រាស់ (មាត្រា ៩ នៃច្បាប់ស្តីពីគយ)។

**ការនាំចូលទំនិញក្រោមរបបប្រវេសន៍កាលិក អាចត្រូវបានអនុញ្ញាត ចំពោះករណីដូចខាងក្រោម ÷**

- ទំនិញសម្រាប់ដាក់តាំងបង្ហាញ ឬប្រើប្រាស់ក្នុងពិធីតាំងពិព័រណ៍ កិច្ចប្រជុំ ឬ ព្រឹត្តិការណ៍ប្រហាក់ប្រហែល ដែលមានបរិមាណសមស្រប
- បរិក្ខារវិជ្ជាជីវៈចាំបាច់សម្រាប់អ្នកបច្ចេកទេស ឬបុគ្គលវិជ្ជាជីវៈផ្សេងៗ ដែលចូលមកព្រះរាជាណាចក្រកម្ពុជាដើម្បីបំពេញភារកិច្ច ឬមុខរបរឯកទេស ដោយមិនរាប់បញ្ចូលនូវបណ្តាគ្រឿងម៉ាស៊ីន គ្រឿងចក្រ និងបរិក្ខារឯកទេស សម្រាប់ប្រើប្រាស់ក្នុងវិស័យកម្មន្តសាលឧស្សាហកម្ម ការវេចខ្ចប់ទំនិញ អាជីវកម្មធនធានធម្មជាតិ ការកសាង ឬ ការជួសជុលអគារ ការងារដី ឬ គម្រោងប្រហាក់ប្រហែលនានា
- កុងតឺន័រ ប៉ាឡែត កញ្ចប់ គម្រូទំនិញ និងទំនិញនាំចូលផ្សេងទៀត ដែលពាក់ព័ន្ធនឹងប្រតិបត្តិការពាណិជ្ជកម្ម តែពុំមែនជាផ្នែកនៃប្រតិបត្តិការពាណិជ្ជកម្មនៅពេលដែលត្រូវបានលក់ ឬ ទិញ
- ទំនិញនាំចូលសម្រាប់សំណូមពរនៃការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ រាប់បញ្ចូលទាំងបំណែកនៃបរិក្ខារវិទ្យាសាស្ត្រ និងសម្ភារអប់រំដែលទទួលបានការអនុញ្ញាតឱ្យនាំចូលតាមរបបប្រវេសន៍កាលិក

- ទំនិញនាំចូលសម្រាប់វិស័យកីឡាដែលប្រើប្រាស់ដោយអ្នកទេសចរ កីឡាករ អ្នកដំណើរសម្រាប់ការប្រកួតប្រជែង ការបង្ហាញ ឬ ការហ្វឹកហាត់ក្នុងដែនគយ
- សម្ភារសម្រាប់ផ្សព្វផ្សាយទេសចរ សម្រាប់ទាក់ទាញការទស្សនាប្រទេសផ្សេងៗទៀត
- ទំនិញនាំចូលដោយអ្នកដំណើរឆ្លងកាត់ព្រំដែនសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន
- ទំនិញនាំចូលសម្រាប់គោលបំណងមនុស្សធម៌ រាប់បញ្ចូលទាំងបរិក្ខារមន្ទីរពិសោធន៍ មន្ទីរវះកាត់ និងទំនិញជំនួយសង្គ្រោះជនរងគ្រោះដោយគ្រោះធម្មជាតិ និងមហន្តរាយប្រហាក់ប្រហែល
- មធ្យោបាយដឹកជញ្ជូនមនុស្ស និងទំនិញ សម្រាប់គោលបំណងពាណិជ្ជកម្ម ដូចជានាវា អាកាសយាន្ត យានយន្តផ្លូវគោក ឬ ផ្លូវដែក ដែលប្រើប្រាស់ក្នុងចរាចរដឹកជញ្ជូនជាអន្តរជាតិ រាប់បញ្ចូលទាំងគ្រឿង បន្លាស់ គ្រឿងបន្សំ និងបរិក្ខារផ្សេងៗ ទោះបីជាមិនយកកម្រៃក្តី។

**ដើម្បីនាំចូលទំនិញតាមរបបប្រវេសន៍កាលិក ត្រូវអនុវត្តតាមល័ក្ខខ័ណ្ឌដូចខាងក្រោម÷**

- ត្រូវដាក់ពាក្យសុំការអនុញ្ញាតជាមុនពីរដ្ឋបាលគយ ដោយបញ្ជាក់ឲ្យបានច្បាស់លាស់នូវប្រភេទទំនិញ បរិមាណ តម្លៃ គោលបំណងនៃការនាំទំនិញចូល អត្តសញ្ញាណរបស់ម្ចាស់ទំនិញ រយៈពេលនៃការទទួលបានរបបប្រវេសន៍កាលិក និងកាលបរិច្ឆេទនៃការនាំចេញទៅវិញ ។
- ការនាំចូលទំនិញតាមរបបប្រវេសន៍កាលិក ជាកម្មវត្ថុនៃការតម្កល់ប្រតិវេទន៍គយ និងអាចតម្រូវឲ្យតម្កល់និមុត្តិធានា។ និមុត្តិធានានេះ អាចនឹងត្រូវលប់ចោល ឬ បង្វិលសងវិញនៅពេលដែលមានការបញ្ជាក់ថាទំនិញត្រូវបាននាំចេញទៅវិញ
- ចំពោះបណ្តាគ្រឿងម៉ាស៊ីន គ្រឿងចក្រ និងបរិក្ខារឯកទេស សម្រាប់ការប្រើប្រាស់ក្នុងវិស័យកម្មន្តសាលឧស្សាហកម្ម ការវេចខ្ចប់ទំនិញ អាជីវកម្មធនធានធម្មជាតិ ការសាងសង់ ឬ ការជួសជុលអគារ ការងារដី ឬគម្រោងប្រហាក់ប្រហែលនានា អាចត្រូវបានអនុញ្ញាតដោយរដ្ឋបាលគយឲ្យនាំចូលតាមរបបប្រវេសន៍កាលិកសម្រាប់រយៈពេលកំណត់មួយ។ កាតព្វកិច្ចពន្ធ និងអាករលើទំនិញនាំចូលតាមរបបប្រវេសន៍កាលិកនេះ ត្រូវជាប់តាមអត្រាបន្ថយស្មើនឹង ២០% នៃកាតព្វកិច្ចពន្ធ និងអាករដែលត្រូវជាប់តាមតារាងពន្ធគយជាធរមាន សម្រាប់រយៈពេលមួយឆ្នាំ។ ក្នុងករណីដែលរយៈពេលកំណត់ក្នុងរបបប្រវេសន៍កាលិកតិចជាងមួយឆ្នាំកាតព្វកិច្ចពន្ធនិងអាករដែលត្រូវជាប់ ត្រូវគិតតាមខែនីមួយៗតាមអត្រាបន្ថយស្មើនឹងពីរ (២)ភាគរយនៃប្រាក់ពន្ធនិងអាករសរុបលើទំនិញទាំងនេះ
- ទំនិញនាំចូលបណ្តោះអាសន្នតាមរបបប្រវេសន៍កាលិក ត្រូវនាំចេញទៅវិញក្នុងរយៈពេលមួយឆ្នាំគិតពីថ្ងៃ ដែល ទំនិញត្រូវបាននាំចូល។ រយៈពេលកំណត់នេះ អាចត្រូវបានពន្យាដោយរដ្ឋបាលគយ ប្រសិនបើមានការស្នើសុំជាលាយល័ក្ខណ៍អក្សរមុនពេលផុតរយៈពេលកំណត់ដោយមានបញ្ជាក់ហេតុផលនៃសំណើនេះ។

## ២.២.៥. ឃ្លាំងអាគារគយមានដែនកំណត់

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**

- ប្រកាសលេខ ១១៦ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្ដីពីឃ្លាំងអាគារគយមានដែនកំណត់

**ឃ្លាំងអាគារគយមានដែនកំណត់** គឺជាអាគារ ទីកន្លែង ឬទីលាន ដែលទទួលបានការអនុញ្ញាតឱ្យធ្វើសន្និធិទំនិញក្រោមការត្រួតពិនិត្យរបស់គយ សម្រាប់រយៈពេលជាក់លាក់មួយ និងដោយមានបញ្ជាក់ពីពេលវេលាច្បាស់លាស់។ ទំនិញនាំចូល និងទំនិញក្នុងស្រុកសម្រាប់នាំចេញ អាចត្រូវបានដាក់ក្នុងឃ្លាំងអាគារគយមានដែនកំណត់។ ទំនិញក្នុងឃ្លាំងអាគារគយមានដែនកំណត់ត្រូវបានព្យួរពន្ធ និងអាករដែលត្រូវជាប់។ ការហាមឃាត់ ឬការដាក់កម្រិតកំណត់នានាលើទំនិញទាំងនេះ អាចត្រូវបានលើកលែងរហូតដល់ពេលដែលទំនិញត្រូវបានបញ្ចេញពីគយសម្រាប់ការប្រើប្រាស់ក្នុងប្រទេស ឬដើម្បីនាំចេញ។

### ២.២.៥.១. ប្រភេទឃ្លាំងអាគារគយមានដែនកំណត់

ឃ្លាំងអាគារគយមានដែនកំណត់មានបីប្រភេទ÷

**ប្រភេទ កៈ ឃ្លាំងអាគារសាធារណៈ** គឺជាឃ្លាំងអាគារគយមានដែនកំណត់ដែលទទួលបានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលអាចធ្វើប្រតិបត្តិការដោយភ្នាក់ងាររបស់រាជរដ្ឋាភិបាល ឬ ដោយបុគ្គលណាមួយ។ ឃ្លាំងអាគារនេះត្រូវបានប្រើប្រាស់សម្រាប់ផ្ដល់សេវាដល់បុគ្គលណាមួយ ដែលមានសិទ្ធិស្របច្បាប់លើទំនិញឱ្យធ្វើសន្និធិទំនិញ រាប់បញ្ចូលទាំងអ្នកនាំចូល បុគ្គលដែលទិញទំនិញក្នុងឃ្លាំងអាគារនេះ ឬ បុគ្គលណាមួយផ្សេងទៀតដែលមានសិទ្ធិស្របច្បាប់លើទំនិញទាំងនេះ

**ប្រភេទ ខៈ ឃ្លាំងអាគារឯកជន** គឺជាឃ្លាំងអាគារគយមានដែនកំណត់ដែលទទួលបានការអនុញ្ញាតពីអគ្គនាយកអគរ ត្រូវបានប្រើប្រាស់ដោយឡែកដោយបុគ្គលណាម្នាក់សម្រាប់ធ្វើសន្និធិទំនិញ ដើម្បីប្រើប្រាស់ដោយឡែក រាប់បញ្ចូលទាំងប្រតិបត្តិករអាគារលក់ទំនិញរួចពន្ធ

**ប្រភេទ គៈ ឃ្លាំងអាគារពិសេស** គឺជាឃ្លាំងអាគារគយមានដែនកំណត់ដែលទទួលបានការអនុញ្ញាតពីអគ្គនាយកអគរ សម្រាប់រក្សាប្រភេទទំនិញគ្រោះថ្នាក់ ប៉ះពាល់ដល់គុណភាពទំនិញដទៃទៀត ឬ អាចត្រូវការទីកន្លែងពិសេសសម្រាប់រក្សាទំនិញទាំងនោះ។ ឃ្លាំងអាគារគយប្រភេទនេះអាចជាឃ្លាំងអាគារសាធារណៈ ឬ ឯកជន។

### ២.២.៥.២. នីតិវិធីគ្រប់គ្រងទំនិញក្នុងឃ្លាំងអាគារគយមានដែនកំណត់

ទំនិញអាចរក្សាទុកក្នុងឃ្លាំងអាគារគយមានដែនកំណត់រហូតដល់រយៈពេលពីរ (២) ឆ្នាំគិតពីថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ។ ប្រសិនបើទំនិញស្ថិតក្នុងសភាពល្អ រយៈពេលកំណត់នេះអាចត្រូវបានពន្យាររហូតដល់ដប់ពីរ (១២) ខែដោយរដ្ឋបាលគយ តាមការស្នើសុំរបស់ប្រតិបត្តិករឃ្លាំងអាគារគយមានដែនកំណត់

- ទំនិញដែលស្ថិតក្នុងឃ្លាំងអាគារគយមានដែនកំណត់អាចត្រូវបានលក់ ឬ ផ្ទេរ។ អ្នកនាំចូល ឬ ម្ចាស់ទំនិញត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់រដ្ឋបាលគយពីការផ្ទេរកម្មសិទ្ធិនេះ។ ទំនិញដែលស្ថិតក្នុងឃ្លាំងអាគារគយមានដែនកំណត់អាចត្រូវបានផ្ទេរទៅឃ្លាំងអាគារគយមានដែនកំណត់មួយទៀតក្រោមការត្រួតពិនិត្យគយ។ សំណុំឯកសារពាក់ព័ន្ធនឹងការផ្ទេរទំនិញនេះត្រូវដាក់ជូនរដ្ឋបាលគយ

- ទំនិញដែលយកចេញពីភណ្ឌាគារគយមានដែនកំណត់សម្រាប់នាំចេញ ត្រូវជាកម្មវត្ថុនៃការតម្កល់ប្រតិវេទន៍គយនាំចេញ ហើយពុំត្រូវជាប់ពន្ធអាករនាំចូល ឬ នាំចេញទេ លើកលែងតែទំនិញក្នុងស្រុកដែលអាចជាប់អាករនាំចេញ។ ទំនិញដែលយកចេញពីភណ្ឌាគារគយមានដែនកំណត់ សម្រាប់ដាក់ឲ្យប្រើប្រាស់ក្នុងស្រុកត្រូវជាប់ពន្ធ និងអាករតាមអត្រាពន្ធ និងអាករជាធរមាននៃថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ ដើម្បីយកទំនិញចេញពីភណ្ឌាគារ
- ម្ចាស់ទំនិញក្នុងភណ្ឌាគារគយមានដែនកំណត់អាចត្រូវបានអនុញ្ញាតដោយរដ្ឋបាលគយ ដើម្បីពិនិត្យមើលទំនិញ ដកគម្រូទំនិញ និងធ្វើប្រតិបត្តិការចាំបាច់នានា ក្នុងគោលបំណងថែរក្សាទំនិញទាំងនោះដោយមិនផ្លាស់ប្តូរលក្ខណៈសំខាន់នៃទំនិញនេះ រួមមានការបាញ់ថ្នាំសម្លាប់សត្វល្អិត ការសម្ងួត ការសម្អាត ការសាកល្បង ការដេរប៉ះស្រោមសម្បករហែក ការបិទស្លាកសម្គាល់ ការសរសេរចំណាំ ការរៀបចំកញ្ចប់ទំនិញឡើងវិញ ការជ្រើសរើសឬ វេចខ្ចប់ឡើងវិញ ជាដើម។

## ២.២.៦. ទំនិញនាំចូលតាមរបបអាគារលក់ទំនិញរួចពន្ធ

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**

- លិខិតលេខ ០០៥ សហវ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០០ ស្តីពីការកែសំរួលបែបបទគ្រប់គ្រងការនាំចូលទំនិញតាមរបប អាគារលក់ទំនិញរួចពន្ធ Duty Free Shop
- លិខិតលេខ ១០០៦ គរ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីបែបបទគ្រប់គ្រងការនាំចូលទំនិញតាមរបបអាគារលក់ទំនិញរួចពន្ធ Duty Free Shop

### ២.២.៦.១. បែបបទនៃការនាំចូល

- ត្រូវមានលិខិតអនុញ្ញាតនាំចូលដែលចេញដោយ អគរ (នាយកដ្ឋានរដ្ឋាករ)រាល់ពេលនាំចូល
- ត្រូវមានឃ្លាំងសម្រាប់ស្តុក និងអាគារលក់ទំនិញរួចពន្ធដើម្បីដំណើរការអាជីវកម្មស្របតាមកិច្ចសន្យា
- ការបំពេញបែបបទនាំចូល ការបង់កម្រៃ Duty Free ត្រូវធ្វើនៅមាត់ច្រកនាំចូលតាមបណ្តាការិយាល័យសាខាគយនិងរដ្ឋាករពាក់ព័ន្ធតាមច្បាប់និងនីតិវិធីជាធរមាន។

### ២.២.៦.២. ការធ្វើចរាចរទំនិញរួចពន្ធ

រាល់ការដឹកជញ្ជូនចរាចរទំនិញរួចពន្ធ គ្រប់ប្រភេទឆ្លងកាត់ផ្ទៃក្នុងប្រទេស ត្រូវអមភ្ជាប់ជាមួយនូវលិខិតអនុញ្ញាតដឹកជញ្ជូនដែលចេញដោយ អគរ ហើយក្នុងករណីដែលអាជ្ញាធរគយមានសមត្ថកិច្ចយល់ថាចាំបាច់មន្ត្រីគយនិងរដ្ឋាករយ៉ាងតិចពីររូប អមឃ្លាំមើលទំនិញទាំងនោះ រហូតដល់គោលដៅអាជីវកម្មស្របច្បាប់នានា។

### ២.២.៦.៣. ភារកិច្ចរបស់អាជីវករ

- អាជីវករលក់ទំនិញរួចពន្ធទាំងអស់ ត្រូវគោរពនិងអនុវត្តឲ្យបានល្អ និងទាន់ពេលវេលាតាមខ្លឹមសារនៃសេចក្តីជូនដំណឹងលេខ០០៥សហវខាងលើ
- ត្រូវបង្កការងាយស្រួល និងការសហការខ្ពស់ជាប្រចាំជាមួយមន្ត្រីមានសមត្ថកិច្ចគ្រប់ផ្នែក
- ផ្ញើរបាយការណ៍ជាប្រចាំតាមគំរូដែលណែនាំដោយ អគរ ឲ្យបានទៀងទាត់មកនាយកដ្ឋានរដ្ឋាករ
- កត់ត្រាឲ្យបានច្បាស់លាស់លើវិក្កយបត្រលក់ចេញនូវយថាប្រភេទ បរិមាណទំនិញ ព្រមទាំងអត្តសញ្ញាណអតិថិជនដែលបានទិញប្រចាំថ្ងៃនីមួយ។

## ២.២.៧. ទំនិញដែលត្រូវលើកលែងពន្ធ និងអាករ

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**

- ច្បាប់ស្តីពីគយ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧
- ប្រកាសលេខ ១១៤ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពី ការកំណត់មុខទំនិញដែលត្រូវលើកលែងពន្ធ និងអាករ
- ប្រកាសលេខ ១០៥ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងទំនិញដែលត្រូវបានលើកលែងពន្ធ និងអាករ

### ២.២.៧.១. ការកំណត់មុខទំនិញដែលត្រូវលើកលែងពន្ធ និងអាករ

អនុលោមទៅតាមបញ្ញត្តិមាត្រា២៦ នៃច្បាប់ស្តីពីគយ ការលើកលែងពន្ធនិងអាករ ត្រូវបានផ្តល់ជូនចំពោះទំនិញ និង អ្នក នាំចូល ដែលមាន លក្ខណៈសម្បត្តិដូចខាងក្រោម÷

ក. ទំនិញសម្រាប់បេសកកម្មការទូត ឬ បេសកកម្មកុងស៊ុលបរទេស អង្គការអន្តរជាតិ និងភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស របស់រដ្ឋាភិបាលផ្សេងទៀត ដើម្បីប្រើប្រាស់ក្នុងការិយកិច្ចនៃមុខងារជាផ្លូវការ ដោយមានការបញ្ជាក់ពីប្រធានបេសកកម្ម និងពីក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិ

ខ. ទំនិញសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលិកផ្លូវការនៃបេសកកម្ម និងអង្គការដូចបានរៀបរាប់នៅក្នុងវាក្យខណ្ឌ ក នៃប្រការនេះ។ ការអនុវត្តនូវវាក្យខណ្ឌនេះ និងវាក្យខណ្ឌ ក នៃប្រការនេះត្រូវផ្អែកលើគោលការណ៍ច្បាប់អន្តរជាតិ និងគោលការណ៍បដិការ រវាង រដ្ឋាភិបាលពាក់ព័ន្ធ

គ. ទំនិញមានដើមកំណើតកម្ពុជា ឬ ទំនិញនាំចូលដែលបានបង់ពន្ធ និងអាកររួច ដែលចេញពីដែនគយហើយត្រូវនាំចូលត្រឡប់ ពីបរទេសមកវិញដោយពុំមានការបង្កើនតម្លៃ

ឃ. ទំនិញដែលត្រូវលើកលែងពន្ធ និងអាករក្រោមបញ្ញត្តិនៃច្បាប់ផ្សេងទៀតរបស់ព្រះរាជាណាចក្រកម្ពុជា

ង. ទំនិញជាអំណោយសម្រាប់មនុស្សធម៌ ទំនិញសម្រាប់ការស្រាវជ្រាវនិងគោលបំណងវិទ្យាសាស្ត្រ ទំនិញគំរូ និងទំនិញតាំងពិព័រណ៍ដែលគ្មានតម្លៃពាណិជ្ជកម្ម មឈូសដែលមានសាកសពមនុស្ស

ច. ទំនិញ នាំចូល ដែលមាន តម្លៃ និង បរិមាណច្បាស់លាស់មួយចំនួនតាមការកំណត់របស់អគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាដែលនាំចូលដោយអ្នកដំណើរ អ្នកបម្រើការតាមមធ្យោបាយដឹកជញ្ជូន និងជនទាំងឡាយដែលឆ្លងកាត់ព្រំដែន

ឆ. ទំនិញដែលចូលក្នុងដែនគយសម្រាប់ឆ្លងកាត់ ឬផ្ទេរមធ្យោបាយដឹកជញ្ជូន

ជ. សម្ភារប្រើប្រាស់ក្នុងផ្ទះ សម្ភារប្រើប្រាស់ផ្ទាល់ខ្លួន និងទ្រព្យសម្បត្តិផ្សេងទៀតលើកលែងតែយានយន្តដែលនាំចូលដោយ បុគ្គលដែលផ្លាស់ប្តូរលំនៅស្ថានមកកម្ពុជាក្នុងបរិមាណដែលកំណត់ដោយ អគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

ឈ. បរិក្ខារឧស្សាហកម្ម និងសម្ភារផ្សេងទៀតដែលជាតម្រូវការ សម្រាប់ ប្រតិបត្តិការ និង ការថែរក្សាបរិក្ខារ ទាំងនេះ ដែលប្រើប្រាស់នៅក្នុងសមុទ្រសម្រាប់ការរុករក និងទាញយកផលិតផលតេលសិលា និង សារធាតុខនិជនិងសរីរាង្គផ្សេង ទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ញ. ទំនិញផ្សេងទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បុគ្គលដែលនាំចូលទំនិញក្រោមបញ្ញត្តិនៃកថាខណ្ឌខាងលើត្រូវផ្តល់នូវឯកសារជាភស្តុតាងដល់រដ្ឋបាលគយថា ទំនិញមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលបានការលើកលែងពន្ធ និងអាករ។

អង្គការនានា និងបុគ្គល ដែលមានបំណងស្នើសុំការលើកលែងពន្ធ និងអាករលើទំនិញនាំចូលក្រោមបញ្ញត្តិ កថាខណ្ឌ ក និង កថាខណ្ឌ ខ ខាងលើត្រូវមានការអនុញ្ញាតជាមុនពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្របតាមនីតិវិធីជាធរមាន។

បុគ្គលដែលមានបំណងនាំចូលទំនិញក្រោមបញ្ញត្តិនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តតាមនីតិវិធី និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ការលើកលែងជាភាគនូវពន្ធ និងអាករនាំចូល ត្រូវបានផ្តល់ចំពោះមុខទំនិញ និងអ្នកនាំចូលមួយចំនួនស្របតាមបញ្ញត្តិមាត្រា ២៧ នៃច្បាប់ស្តីពីគយ។ ទំនិញដែលត្រូវបានលើកលែងជាភាគនូវពន្ធ និងអាករនាំចូលមានដូចខាងក្រោម ៖

- ទំនិញ និងសម្ភារដែលត្រូវបានលើកលែងជាភាគនូវពន្ធ និងអាករនាំចូលក្រោមបញ្ញត្តិនៃច្បាប់ណាមួយជាធរមាន
- ពូជដំណាំ និងពូជសត្វសម្រាប់កសិកម្ម
- ទំនិញដែលនឹងត្រូវទទួលការជួសជុល ការកែច្នៃ ឬ ពិសោធន៍
- ទំនិញដែលបាននាំចូលវិញតាមសភាពដើម
- ទំនិញដែលនាំចូលដោយរដ្ឋាភិបាលដើម្បីជាប្រយោជន៍សាធារណៈ និងទំនិញនាំចូលសម្រាប់របបប្រវេសកាលិក
- ទំនិញផ្សេងទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។
- បុគ្គលដែលនាំចូលទំនិញក្រោមបញ្ញត្តិនៃប្រការនេះត្រូវផ្តល់នូវឯកសារជាភស្តុតាងដល់រដ្ឋបាលគយថា ទំនិញមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលបានការលើកលែងជាភាគនូវពន្ធនិងអាករ។

## ២.២.៧.២. ការគ្រប់គ្រងទំនិញដែលបានលើកលែងពន្ធ និងអាករ

ទំនិញនាំចូលដោយលើកលែងពន្ធ និងអាករនាំចូលក្រោមបញ្ញត្តិនៃវាក្យខណ្ឌ ក កថាខណ្ឌទី ១ មាត្រា ២៦ នៃច្បាប់ស្តីពីគយ សម្រាប់បេសកកម្មការទូត ឬបេសកកម្មកុងស៊ុលបរទេស អង្គការអន្តរជាតិ និងភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលផ្សេងទៀត ដើម្បីប្រើប្រាស់ក្នុងការិយកិច្ចនៃមុខងារជាផ្លូវការរបស់ខ្លួន និងបុគ្គលិករបស់អង្គការទាំងនេះ ត្រូវនាំចេញទៅវិញបន្ទាប់ពីបញ្ចប់បេសកម្មរបស់ខ្លួន។

ទំនិញទាំងនេះព្រមទាំងទំនិញផ្សេងទៀតក្រោមបញ្ញត្តិកថាខណ្ឌទី ១ មាត្រា ២៦ នៃច្បាប់ស្តីពីគយ មិនត្រូវបានអនុញ្ញាតឲ្យលក់ ផ្ទេរ បង្វែរទៅប្រើប្រាស់អ្វីផ្សេងពីគម្រោងដែលបានអនុគ្រោះ ឬ បោះបង់ចោលដោយគ្មានការអនុញ្ញាតជាមុនពីរដ្ឋបាលគយឡើយ ។

អង្គការ ឬបុគ្គលនានាដែលមានបំណងលក់ ផ្ទេរ បង្វែរទៅប្រើប្រាស់អ្វីផ្សេងពីគម្រោងដែលបានអនុគ្រោះ ឬបោះបង់ចោលទំនិញដែលបាននាំចូលដោយលើកលែង ឬ លើកលែងជាភាគនូវពន្ធ និងអាករ នាំចូលត្រូវស្នើសុំការអនុញ្ញាតជាមុនពីរដ្ឋបាលគយ ស្របតាមនីតិវិធីដូចខាងក្រោម ៖

- ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតមករដ្ឋបាលគយ ដោយបញ្ជាក់ឲ្យបានច្បាស់លាស់ពីរបៀបនៃការប្តូរគម្រោង ឬ ការប្តូរកម្មសិទ្ធិលើទំនិញនេះ។ ច្បាប់ចម្លងនៃពាក្យស្នើសុំនេះត្រូវផ្ញើជូនក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ឬ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាសម្រាប់ទំនិញដែលនាំចូលក្រោមបញ្ញត្តិ កថាខណ្ឌទី ១ ប្រការ ១ នៃប្រកាសលេខ ១០៥ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងទំនិញដែលត្រូវបានលើកលែងពន្ធ និងអាករ

- ពាក្យស្នើសុំត្រូវអមដោយបញ្ជីទំនិញ និងឯកសារនាំចូលព្រមទាំងឯកសារផ្សេងទៀតប្រសិនបើមាន។ ទំនិញមិនត្រូវបានអនុញ្ញាតឲ្យលក់ ផ្ទេរ ឬបង្វែរ មុនពេលទទួលបានការអនុញ្ញាតពីរដ្ឋបាលគយឡើយ
- កម្មសិទ្ធិករថ្មីត្រូវទទួលខុសត្រូវលើការបង់ពន្ធ និងអាករជូនរដ្ឋបាលគយតាមនីតិវិធីគយជាធរមាន។ ទំនិញមិនត្រូវបានប្រគល់ជូនកម្មសិទ្ធិករថ្មី ដោយគ្មានការអនុញ្ញាតជាមុនពីរដ្ឋបាលគយ និងមុនពេលបង់ពន្ធ និងអាករដែលជាប់ ឬ ទទួលបានការលើកលែងពន្ធជាថ្មីពីស្ថាប័នមានសមត្ថកិច្ច
- រដ្ឋបាលគយត្រូវគិតគូរពីលក្ខខណ្ឌជាក់ស្តែង និងសភាពនៃទំនិញទាំងនោះនាពេលប្រគល់ទទួល និងអាចកែសម្រួលតម្លៃគិតពន្ធគយតាមនេះ។

ទំនិញដែលមានប្រភពក្នុងដែនគយ ឬ ដែលបាននាំចូលដោយបង់ពន្ធនិងអាកររួច ឬ ដែលនាំចូលត្រឡប់មកវិញពីបរទេសដោយពុំមានបន្ថែមតម្លៃត្រូវបានអនុញ្ញាតឲ្យលក់ ផ្ទេរ បង្វែរទៅប្រើប្រាស់ ឬ បោះបង់ចោលដោយពុំចាំបាច់មាន ការអនុញ្ញាតជាមុនពីរដ្ឋបាលគយឡើយ ។

អង្គការ ឬ បុគ្គលនានាដែលមានបំណងបោះបង់ចោលទំនិញដែលបាននាំចូលដោយលើកលែងពន្ធ និងអាករនាំចូល ត្រូវស្នើសុំការអនុញ្ញាតជាមុនពីរដ្ឋបាលគយ។ ការស្នើសុំ ត្រូវ អមដោយ បញ្ជី ទំនិញ និងឯកសារនាំចូលព្រមទាំងឯកសារពាក់ព័ន្ធផ្សេងទៀត។ ការបោះបង់ចោលទំនិញអាចធ្វើឡើងតែក្រោយពេលមានការអនុញ្ញាតពីរដ្ឋបាលគយ។ រដ្ឋបាលគយអាចឃ្លាំមើលការបោះបង់ចោល ឬ ការបំផ្លាញទំនិញទាំងនេះ។

## ២.២.៨. នីតិវិធីក្នុងការនាំចេញអង្ករ និងផលិតផលកសិកម្ម

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**

- ប្រកាសលេខ ១០៧សហវប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការរាយការណ៍ ការធ្វើចរាចរ ការធ្វើសន្និធិ និងការដឹកជញ្ជូនទំនិញនាំចេញរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ប្រកាសលេខ ១១១ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការអនុញ្ញាតឲ្យបំពេញទម្រង់ការគយនៅការិយាល័យគយ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សេចក្តីណែនាំលេខ ៥៤៦ អគរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការសម្រួលពាណិជ្ជកម្មបន្ថែមទៀតដល់វិស័យឯកជនក្នុងការបំពេញបែបបទគយ
- សេចក្តីណែនាំលេខ ៥១៦ អគរ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤ ស្តីពីការលើកលែងកម្រៃបែបបទគយ (Customs Processing Fee-CPF) លើការនាំចេញអង្ករ

- តាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគរ បានផ្តល់អាទិភាពមិនចាំបាច់រង់ចាំតាមជួរលំដាប់លំដោយ និងសម្រួលឲ្យបានជាអតិបរមាលើការបំពេញបែបបទគយនាំចេញអង្ករ តាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។ ទន្ទឹមនេះ អគរ ក៏បានសម្រេចលើកលែងកាតព្វកិច្ចបង់កម្រៃបែបបទគយផងដែរ (ដូចមានក្នុងសេចក្តីណែនាំលេខ៥១៦ អគរ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤)។
- ការនាំចេញផលិតផលកសិកម្មផ្សេងទៀត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏បានសម្រួលឲ្យអ្នកនាំចេញ ឬតំណាងធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរ រដ្ឋបាលគយអាចអនុញ្ញាតធ្វើការបំពេញ បែបបទបញ្ចេញទំនិញពីគយនៅកន្លែងផ្សេងពីការិយាល័យគយ ដែលបានកំណត់ដូចជា ទីកន្លែងដែលផលិត ឬ កែច្នៃទំនិញដើម្បីនាំចេញ។ល។ ដូចមានចែងក្នុង

ប្រកាសលេខ១០៧សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការរាយការណ៍ ការធ្វើចរាចរ ការធ្វើសន្និធិ និងការដឹកជញ្ជូនទំនិញនាំចេញរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ប្រកាសលេខ ១១១ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការអនុញ្ញាតឱ្យបំពេញទម្រង់ការគយនៅក្រៅការិយាល័យគយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**<u>នីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយ</u>**

អ្នកនាំចេញទំនិញទាំងអស់ត្រូវភ្ជាប់ឯកសារពាក់ព័ន្ធ ដើម្បីបំពេញបែបបទបញ្ចេញទំនិញពីគយ។ នីតិវិធីនៃការបំពេញប្រតិវេទន៍គយ ដូចមានក្នុងចំណុច ២.១.។

# ២.៣. នីតិវិធីមុនពេលបំពេញបែបបទបញ្ចេញទំនិញពីគយ

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**

- ប្រកាសលេខ០០២ សហវ.ប្រក.អគយ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៣ ស្តីពីវិធានបញ្ជាក់ជាមុនលើ ចំណាត់ថ្នាក់ទំនិញតាមតារាងពន្ធគយ ដើមកំណើតទំនិញ និង តម្លៃគិតពន្ធគយ
- សេចក្តីណែនាំលេខ៣៤៥ អគយ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៣ ស្តីពី ការអនុវត្តវិធានបញ្ជាក់ជាមុនលើចំណាត់ថ្នាក់ទំនិញតាមតារាងពន្ធគយ
- សេចក្តីណែនាំលេខ៣៤៦ អគយ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៣ ស្តីពី ការអនុវត្តវិធានបញ្ជាក់ជាមុនលើតម្លៃគិតពន្ធគយ
- សេចក្តីណែនាំស្តីលេខ ២១៧៥ អគយចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៤ស្តី ពី ការអនុវត្តវិធានបញ្ជាក់ជាមុនលើដើមកំណើតទំនិញ

## ២.៣.១. វិធានបញ្ជាក់ជាមុន

វិធានបញ្ជាក់ជាមុន (Advance Ruling) ត្រូវបានបង្កើត និង ដាក់អោយអនុវត្តនៅកម្ពុជានាថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៣ ក្នុង គោលបំណង ដើម្បី លើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្ម និងដើម្បីធានាថាប្រតិវេទន៍គយត្រូវបានប្រកាសត្រឹមត្រូវស្របតាមបញ្ញត្តិនៃច្បាប់ស្តីពីគយជាធរមាន។

### ២.៣.១.១. និយមន័យ

វិធានបញ្ជាក់ជាមុន គឺជាសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដែលចេញដោយ អគយ ស្តីពី (ក) ចំណាត់ថ្នាក់ទំនិញតាមតារាងពន្ធគយ (ខ)ការបកស្រាយនិងការអនុវត្តច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការកំណត់តម្លៃគិតពន្ធគយនៃទំនិញ ឬ (គ) ដើមកំណើតទំនិញ ដែលនឹងត្រូវនាំចូល ឱ្យទៅបុគ្គលណាមួយនៅពេលមានការស្នើសុំ។ វិធានបញ្ជាក់ជាមុន នឹងមានលក្ខណៈគតិយុត្តិចំពោះអាជ្ញាធរគយ ចាប់ពីថ្ងៃវិធាននេះចូលជាធរមាន។

## ២.៣.១.២. បុគ្គលដែលមានសិទ្ធិស្នើសុំវិធានបញ្ជាក់ជាមុន(អ្នកស្នើសុំ)

- អ្នកនាំចូល
- អ្នកផលិតទំនិញ
- ឬ បុគ្គលដែលបានទទួលសិទ្ធិក្នុងការនាំចូលទំនិញដែលជាកម្មវត្ថុនៃការស្នើសុំ។

## ២.៣.១.៣. ការិយាល័យទទួលបន្ទុកវិធានបញ្ជាក់ជាមុន

ការិយាល័យចំនួនពីរទទួលបន្ទុកវិធានបញ្ជាក់ជាមុនដែលស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ (ផបក) នៃអគរ÷

- **ការិយាល័យផែនការ និងគោលនយោបាយ** សម្រាប់ការចាត់ថ្នាក់ទំនិញតាមតារាងពន្ធគយ និងដើមកំណើតទំនិញ
- **ការិយាល័យបច្ចេកទេសគយ** សម្រាប់ការកំណត់តម្លៃគិតពន្ធគយ។

## ២.៣.១.៤. នីតិវិធីក្នុងការស្នើសុំវិធានបញ្ជាក់ជាមុន

ក្នុងការស្នើសុំវិធានបញ្ជាក់ជាមុន អ្នកស្នើសុំត្រូវយល់ដឹងពីខ្លឹមសារនានានៃការស្នើសុំ និងបំពេញរាល់ព័ត៌មានទាំងអស់នៃពាក្យស្នើសុំ ជាភាសាខ្មែរ ឬ អង់គ្លេស ព្រមទាំងចុះហត្ថលេខាបញ្ជាក់ផងដែរ។ ទម្រង់នៃពាក្យស្នើសុំវិធានបញ្ជាក់ជាមុន រួមមាន÷

- AR-TC Form 1 សម្រាប់ការចាត់ថ្នាក់ទំនិញតាមតារាងពន្ធគយ
- AR-CVForm1 សម្រាប់ការកំណត់តម្លៃគិតពន្ធគយ
- AR-OGForm1 សម្រាប់ការកំណត់ដើមកំណើតទំនិញ។

ពាក្យស្នើសុំវិធានបញ្ជាក់ជាមុនមួយច្បាប់ ប្រើបានសម្រាប់តែទំនិញតែមួយ ឬ សម្រាប់តែកិច្ចចម្លងការនាំចូលមួយប៉ុណ្ណោះ។ អ្នកស្នើសុំត្រូវបញ្ជូនពាក្យស្នើសុំ និងឯកសារចាំបាច់នានាដោយផ្ទាល់ទៅកាន់ការិយាល័យទទួលបន្ទុក។ ក្នុងករណីដែលអ្នកស្នើសុំជាបុគ្គលដែលបានទទួលសិទ្ធិត្រូវដាក់ភ្ជាប់លិខិតផ្ទេរសិទ្ធិមកជាមួយពាក្យស្នើសុំ។

ឯកសារចាំបាច់នានាសម្រាប់ភ្ជាប់ជាមួយពាក្យស្នើសុំ÷

- ឯកសារច្បាប់ចម្លង និងមានការបោះត្រាទទួលស្គាល់ពីក្រុមហ៊ុនស្នើសុំដែលបញ្ជាក់ពីអត្តសញ្ញាណក្រុមហ៊ុននិងអ្នកស្នើសុំ មានជាអាទិ៍ វិញ្ញាបនបត្រអាករលើតម្លៃបន្ថែម ប័ណ្ណប៉ាតង់ លិខិតផ្ទេរសិទ្ធិ អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន
- ទំនិញគំរូ ឬ ឯកសារគាំទ្រដើម្បីពិពណ៌នាជាក់លាក់ពីលក្ខណៈរបស់ទំនិញដែលត្រូវស្នើសុំ មានដូចជា កាតាឡុក វិធីផលិត វិធីប្រើ បញ្ជីធាតុផ្សំ ដំណើរការផលិតកម្ម
- ឯកសារបញ្ជាក់ការទិញលក់ និងកិច្ចចម្លងការពាក់ព័ន្ធការនាំចូល មានដូចជា លិខិតបញ្ជាទិញ កិច្ចសន្យា វិក្កយបត្រ ប័ណ្ណឥណទាននៃការទិញលក់ទំនិញជាកម្មវត្ថុនៃការស្នើសុំ។

## ២.៣.១.៥. ដំណើរការពាក្យស្នើសុំវិធានបញ្ជាក់ជាមុន

ក្រោយពីទទួលបានព័ត៌មានចាំបាច់គ្រប់គ្រាន់ អគរ នឹងផ្តល់ជូនអ្នកស្នើសុំនូវសេចក្តីសម្រេចស្តីពីវិធានបញ្ជាក់ជាមុនជាលាយលក្ខណ៍អក្សរ ព្រមទាំងផ្តល់ការពន្យល់ពីមូលហេតុ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃធ្វើការ សម្រាប់វិធានបញ្ជាក់ជាមុនលើការចាត់ថ្នាក់ទំនិញតាមតារាងពន្ធគយ និងដើមកំណើតទំនិញ និង ក្នុងរយៈពេលកៅសិប (៩០) ថ្ងៃធ្វើការ សម្រាប់វិធានបញ្ជាក់ជាមុនលើតម្លៃគិតពន្ធគយ។ ប្រសិនបើព័ត៌មានចាំបាច់នានា មិនត្រូវបានផ្តល់គ្រប់គ្រាន់ជាមួយពាក្យស្នើសុំ

អគរ នឹងចេញប្រវេសន៍ស្នើឲ្យផ្ដល់ព័ត៌មានបន្ថែម ហើយរយៈពេលកំណត់ដើម្បីចេញសេចក្ដីសម្រេចនេះ មិនរាប់បញ្ចូលរយៈពេលរង់ចាំព័ត៌មានបន្ថែមទេ។ ក្នុងន័យនេះ អ្នកស្នើសុំមានរយៈពេលសាមសិប(៣០) ថ្ងៃធ្វើការ (ឬអាចវែងជាងនេះប្រសិនបើមានចែងក្នុងប្រវេសន៍) គិតពីថ្ងៃចេញប្រវេសន៍ ដើម្បីផ្ដល់ព័ត៌មានបន្ថែម ឬ បំពេញកាតព្វកិច្ចផ្សេងទៀតតាមការតម្រូវ។ ប្រសិនបើ មិនមាន ការឆ្លើយតប នឹង ប្រវេសន៍ ក្នុងរយៈពេលនេះ ការពិនិត្យពាក្យស្នើសុំវិធានបញ្ជាក់ជាមុននឹងត្រូវបញ្ឈប់ ហើយចាត់ទុកថាពាក្យស្នើសុំនេះត្រូវបានដកហូត។

**កត្តាមួយចំនួនដែលវិធានបញ្ជាក់ជាមុនមិនអាចផ្ដល់ជូនចំពោះករណីដូចខាងក្រោម÷**

- នៅពេលដែលកម្មវត្ថុនៃការស្នើសុំមិនមានលក្ខណៈជាក់ស្ដែងឬ ជាការឧបមា
- នៅពេលដែលអ្នកស្នើសុំមិនបានផ្ដល់ព័ត៌មាន ឬ ឯកសារគ្រប់គ្រាន់ ដើម្បីឲ្យអគរ អាចធ្វើសេចក្ដីសម្រេចតាមការស្នើសុំ ចំពោះទំនិញជាកម្មវត្ថុនៃការស្នើសុំបាន
- នៅពេលទំនិញដែលជាកម្មវត្ថុនៃការស្នើសុំ ស្ថិតក្នុងការបដិសេធ ឬ ដំណើរការឧទ្ធរណ៍ ដូចមានចែងក្នុងមាត្រា២៤ នៃច្បាប់ស្ដីពីគយ
- នៅពេលដែលមានករណីវិវាទកំពុងតែកើតឡើង ឬ បម្រុងនឹងកើតឡើងរវាងភាគីនានាដែលមានការពាក់ព័ន្ធនឹងចំណាត់ថ្នាក់ទំនិញតាមតារាងពន្ធគយ កិច្ចចម្លងការនាំចូល និងដើមកំណើតទំនិញដែលជាកម្មវត្ថុនៃការស្នើសុំ
- នៅពេលដែលទំនិញជាកម្មវត្ថុនៃការស្នើសុំ ស្ថិតក្នុងដំណើរការត្រួតពិនិត្យលើឯកសាររដ្ឋបាលតែមួយ
- ឬនៅពេលដែលការស្នើសុំវិធានបញ្ជាក់ជាមុនពាក់ព័ន្ធនឹងការនាំចូលដែលបានកើតឡើងរួចហើយ
- ក្នុងករណីដែលទំនិញនៃកិច្ចចម្លងការនាំចូលជាកម្មវត្ថុនៃការលើកលែងពន្ធ ឬ អាករទាំងស្រុង
- ក្នុងករណីដែលទំនិញនៃកិច្ចចម្លងការជាកម្មវត្ថុនៃការស្នើសុំ ឬកិច្ចចម្លងការប្រហាក់ប្រហែលគ្នាស្ថិតក្នុងដំណើរការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ដូចមានចែងក្នុងមាត្រា៥៧ នៃច្បាប់ស្ដីពីគយ
- ក្នុងករណីដែលការស្នើសុំ តម្រូវឲ្យមានការបកស្រាយបញ្ញត្តិនៃច្បាប់និង/ឬបទប្បញ្ញត្តិណាផ្សេងក្រៅពីច្បាប់និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងការកំណត់តម្លៃគិតពន្ធគយ
- ក្នុងករណីដែលកិច្ចចម្លងការនាំចូលជាកម្មវត្ថុនៃការស្នើសុំ ជាប្រត្តិបត្តិការល្មើសនឹងច្បាប់ ឬ បទប្បញ្ញត្តិជាធរមាន
- ក្នុងករណីដែលកិច្ចចម្លងការនាំចូលជាកម្មវត្ថុនៃការស្នើសុំមានលក្ខណៈមិនសមហេតុផលដែលអាចចាត់ទុកជាការអនុវត្តធុរកិច្ចធម្មតា (ឧទាហរណ៍÷ កិច្ចចម្លងការនាំចូលមួយដែលតម្លៃទំនិញទាបជាងថ្លៃផលិតកម្ម)
- ក្នុងករណីដែលការស្នើសុំវិធានបញ្ជាក់ជាមុនគ្របដណ្ដប់តែមួយផ្នែកនៃកិច្ចចម្លងការនាំចូលជាកម្មវត្ថុនៃការស្នើសុំនោះ
- ក្នុងករណីដែលស្ថានភាពជាក់ស្ដែងនៃកិច្ចចម្លងការនាំចូល ត្រូវធ្វើការផ្ទៀងផ្ទាត់តាមរយៈការធ្វើសវនកម្ម និងការសាកសួរចំពោះភាគីពាក់ព័ន្ធផ្សេងទៀត។

### ២.៣.១.៦. សុពលភាពរបស់វិធានបញ្ជាក់ជាមុន

វិធានបញ្ជាក់ជាមុន មានសុពលភាពរយៈពេលបី (៣) ឆ្នាំគិតពីថ្ងៃចេញសេចក្តីសម្រេច។ ប៉ុន្តែ វិធាននេះនឹងអស់សុពលភាពមុនពេលកំណត់ ក្នុងករណី ដែលកត្តានានាពាក់ព័ន្ធនឹងទំនិញនាំចូលជាក់ស្តែង មានលក្ខណៈខុសគ្នានឹងអ្វីដែលបានបង្ហាញនៅក្នុងពាក្យស្នើសុំវិធានបញ្ជាក់ជាមុន ឬ ក្នុងករណីមានការធ្វើវិសោធនកម្មច្បាប់ឬ បទប្បញ្ញត្តិជាធរមានដែលប៉ះពាល់ដល់វិធានបញ្ជាក់ជាមុន ឬ ក្នុងករណីដែលអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាផ្តល់សេចក្តីសម្រេចលើការកែតម្រូវ ឬ ការដកហូតវិធានបញ្ជាក់ជាមុន ឬ ក្នុងករណីដែលវិធាននេះ ត្រូវបានកែតម្រូវបន្ទាប់ពីមានការពិនិត្យឡើងវិញ។

ដើម្បីទទួលបាននូវផលប្រយោជន៍ពីវិធានបញ្ជាក់ជាមុន នាពេលនាំចូល ច្បាប់ចម្លងនៃសេចក្តីសម្រេចស្តីពីវិធានបញ្ជាក់ជាមុនត្រូវដាក់ភ្ជាប់ជាមួយនឹងឯកសាររដ្ឋបាលតែមួយ (SAD) ក្នុងពេលបំពេញបែបបទគយ។

### ២.៣.១.៧. ការពិនិត្យឡើងវិញនូវវិធានបញ្ជាក់ជាមុន

ដើម្បីជំទាស់នឹងវិធានបញ្ជាក់ជាមុន អគរ តម្រូវឱ្យអ្នកស្នើសុំ ដាក់ពាក្យស្នើសុំពិនិត្យឡើងវិញនូវវិធានបញ្ជាក់ជាមុន ដោយផ្ទាល់ នៅការិយាល័យទទួលបន្ទុកក្នុងអំឡុងពេល៤៥ថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទនៃការចេញសេចក្តីសម្រេចវិធានបញ្ជាក់ជាមុន។ ទម្រង់នៃពាក្យស្នើសុំពិនិត្យឡើងវិញ រួមមាន÷

- AR-TC Form 4 សម្រាប់វិធានបញ្ជាក់ជាមុនលើការចាត់ថ្នាក់ទំនិញ
- AR-CVForm4 សម្រាប់វិធានបញ្ជាក់ជាមុនលើតម្លៃគិតពន្ធគយ
- AR-OGForm4 សម្រាប់វិធានបញ្ជាក់ជាមុនលើដើមកំណើតទំនិញ

អ្នកស្នើសុំត្រូវបំពេញនូវរាល់ព័ត៌មាននៃពាក្យស្នើសុំ ជាភាសាខ្មែរឬ អង់គ្លេស រួចចុះហត្ថលេខាបញ្ជាក់ និងភ្ជាប់ច្បាប់ចម្លងនៃវិធានបញ្ជាក់ជាមុនដែលជាកម្មវត្ថុនៃការជំទាស់ ព្រមទាំងផ្តល់ហេតុផលជាលាយលក្ខណ៍អក្សរ ដើម្បីគាំទ្រដល់ការជំទាស់នេះ។

ពាក្យស្នើសុំនឹងឆ្លងកាត់ដំណើរការនៃការពិនិត្យទៅតាមនីតិវិធីដូចមានចែងក្នុងកថាខណ្ឌទី១ នៃចំណុច“ដំណើរការពាក្យស្នើសុំវិធានបញ្ជាក់ជាមុន។ ក្រោយពីការពិនិត្យវាយតម្លៃ ការិយាល័យទទួលបន្ទុកនឹងចេញនូវសេចក្តីសម្រេចលើសំណើនេះ ហើយដែលសេចក្តីសម្រេចនេះអាចប្រើជំនួសវិធានបញ្ជាក់ជាមុនដែលជាកម្មវត្ថុនៃការជំទាស់នោះបាន។

### ២.៣.១.៨. ការផ្សព្វផ្សាយវិធានបញ្ជាក់ជាមុន

ក្នុងគោលបំណងបង្កើនតម្លាភាព វិធានបញ្ជាក់ជាមុនអាចត្រូវផ្សព្វផ្សាយជាសាធារណៈ តាមមធ្យោបាយមួយចំនួន ដូចជា តាមប្រព័ន្ធអ៊ីនធឺណេតជាដើម (គេហទំព័រ web.customs.gov.kh/advance_ruling_decisions) ជាមួយនឹងព័ត៌មានមួយចំនួនដែលមិនពាក់ព័ន្ធផ្ទាល់នឹងអត្តសញ្ញាណរបស់អ្នកស្នើសុំ។ អ្នកស្នើសុំត្រូវជូនដំណឹងដល់ អគរ អំពីព័ត៌មានសម្ងាត់ដែលមាននៅក្នុងពាក្យស្នើសុំវិធានបញ្ជាក់ជាមុន ឬ នៅក្នុងពាក្យស្នើសុំពិនិត្យឡើងវិញ លើវិធានបញ្ជាក់ជាមុនដើម្បីធានាថាព័ត៌មានទាំងនេះនឹងមិនត្រូវផ្សព្វផ្សាយជាសាធារណៈ។


ដំណើរការស្នើសុំវិធានបញ្ជាក់ជាមុនលើចំណាត់ថ្នាក់ទំនិញតាមតារាងពន្ធគយ
ពាក្យស្នើសុំវិធានបញ្ជាក់ ជាមុននិងឯកសារ ចាំបាច់នានា
ការិយាល័យផែនការនិង គោលនយោបាយនៃ នាយកដ្ឋាន ផបក នៃអគរ
វិធានបញ្ជាក់ជាមុនមាន
- ភាសាខ្មែរ និងអង់គ្លេស
- លក្ខណៈគតិយុត្តិសម្រាប់គយ
- សុពលភាពរយៈពេល៣ឆ្នាំ
AR-CV Form 1
ផ្តល់ព័ត៌មានបន្ថែម ក្នុងរយៈពេល៣០ ថ្ងៃធ្វើការ
ប្រវេសន៍
ទេ
ព័ត៌មាន គ្រប់គ្រាន់ ?
ចេញសេចក្តីសម្រេច
បាទ/ចា
AR-CV Form 2
រយៈពេល៣០ថ្ងៃធ្វើការសម្រាប់ផ្តល់ព័ត៌មានបន្ថែម
រយៈពេល៩០ថ្ងៃធ្វើការក្នុងការចេញវិធានបញ្ជាក់ជាមុន


ដំណើរការស្នើសុំវិធានបញ្ជាក់ជាមុនលើតម្លៃគិតពន្ធគយ
ពាក្យស្នើសុំវិធានបញ្ជាក់ ជាមុននិងឯកសារ ចាំបាច់នានា
ការិយាល័យបច្ចេកទេសគយនៃ នាយកដ្ឋាន ផបក នៃអគរ
វិធានបញ្ជាក់ជាមុនមាន
- ភាសាខ្មែរ និងអង់គ្លេស
- លក្ខណៈគតិយុត្តិសម្រាប់គយ
- សុពលភាពរយៈពេល៣ឆ្នាំ
AR-OG Form 1
ផ្តល់ព័ត៌មានបន្ថែម ក្នុងរយៈពេល៣០ ថ្ងៃធ្វើការ
ប្រវេសន៍
ទេ
ព័ត៌មាន គ្រប់គ្រាន់ ?
ចេញសេចក្តីសម្រេច
បាទ/ចា
AR-OG Form 2
រយៈពេល៣០ថ្ងៃធ្វើការសម្រាប់ផ្តល់ព័ត៌មានបន្ថែម
រយៈពេល៣០ថ្ងៃធ្វើការក្នុងការចេញវិធានបញ្ជាក់ជាមុន


ដំណើរការស្នើសុំវិធានបញ្ជាក់ជាមុនលើដើមកំណើតទំនិញ
ពាក្យស្នើសុំវិធានបញ្ជាក់ជាមុននិងឯកសារចាំបាច់នានា
ការិយាល័យផែនការនិងគោលនយោបាយនៃនាយកដ្ឋាន ផបក នៃអគយ
វិធានបញ្ជាក់ជាមុនមាន
- ភាសាខ្មែរ និងអង់គ្លេស
- លក្ខណៈគតិយុត្តិសម្រាប់គយ
- សុពលភាពរយៈពេល៣ឆ្នាំ
AR-OG Form 1
ផ្តល់ព័ត៌មានបន្ថែម ក្នុងរយៈពេល៣០ ថ្ងៃធ្វើការ
ប្រវេសន៍
ទេ
ព័ត៌មានគ្រប់គ្រាន់?
ចេញសេចក្តីសម្រេច
បាទ/ចាស
AR-OG Form 2
រយៈពេល៣០ថ្ងៃធ្វើការសម្រាប់ផ្តល់ព័ត៌មានបន្ថែម
រយៈពេល៣០ថ្ងៃធ្វើការក្នុងការចេញវិធានបញ្ជាក់ជាមុន


ការពិនិត្យឡើងវិញនូវវិធានបញ្ជាក់ជាមុនលើចំណាត់ថ្នាក់ទំនិញតាមពន្ធគយ
- ពាក្យស្នើសុំពិនិត្យឡើងវិញ
- ច្បាប់ចម្លងវិធានបញ្ជាក់ជាមុន ដែលជាកម្មវត្ថុនៃបណ្តឹងជំទាស់
- ព័ត៌មាន ឬឯកសារបន្ថែម
ការិយាល័យផែនការ និងគោលនយោបាយ នៃនាយកដ្ឋាន ផបក នៃ អគយ
ស្នើពិនិត្យឡើងវិញ ក្នុងរយៈពេល៤៥ថ្ងៃ ធ្វើការ
ចេញសេចក្តីសម្រេច ក្នុងរយៈពេល៣០ថ្ងៃធ្វើការ
AR-TC Form 4
AR-TC Form 4
ស្នើពិនិត្យឡើងវិញក្នុងរយៈពេល៤៥ថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទនៃវិធានបញ្ជាក់ជាមុន
ចេញសេចក្តីសម្រេចក្នុងរយៈពេល៣០ថ្ងៃធ្វើការ







## ២.៣.២. ការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ

### ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ

- ប្រកាសលេខ ៣៨៧សហវ គរ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

### ២.៣.២.១. និយមន័យតម្លៃគិតពន្ធគយ

តម្លៃគិតពន្ធគយលើទំនិញនាំចូល គឺជាតម្លៃចម្លងការមានន័យថា ជាថ្លៃដែលបានទូទាត់ ឬ នឹងត្រូវទូទាត់ពិតប្រាកដ លើទំនិញដែលបានលក់សម្រាប់នាំចេញមកកម្ពុជា។ ការប្រកាសតម្លៃគិតពន្ធគយនៃទំនិញនាំចូលត្រូវអនុលោមតាមបញ្ញត្តិមាត្រា ១៨ ចំណុច “ខ” នៃច្បាប់ស្តីពីគយនិងបញ្ញត្តិប្រកាសលេខ ៣៨៧ សហវ.គរ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូល។ តម្លៃគិតពន្ធគយនៃទំនិញនាំចូល ត្រូវប្រកាសជាប្រាក់រៀល (មាត្រា២៣ នៃច្បាប់ស្តីពីគយ)។

វិធីសាស្ត្រគណនាតម្លៃគិតពន្ធគយ មានបកស្រាយតាមរបៀបសាមញ្ញនៅក្នុង Brochure ស្តីពីការកំណត់តម្លៃគិតពន្ធគយ ដែលអាចស្វែងរកបាននៅ អគរ។

### ២.៣.២.២. ការធ្វើវិមជ្ឈការការងារតម្លៃគិតពន្ធគយ

ការធ្វើវិមជ្ឈការតម្លៃគិតពន្ធគយ មានគោលបំណងបង្កភាពងាយស្រួលបន្ថែមទៀតដល់ការនាំចេញ នាំចូល តាមរយៈការកាត់បន្ថយពេលវេលា និងការចំណាយពាក់ព័ន្ធនឹងការបំពេញបែបបទបញ្ចេញទំនិញពីគយ។ គិតត្រឹមខែកក្កដា ឆ្នាំ២០១៥ ការងារផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ត្រូវបានធ្វើវិមជ្ឈការទៅបណ្តាអង្គភាពគយនិងរដ្ឋាករមូលដ្ឋាននានានៅតាមមាត់ច្រកព្រំដែននៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែសាខាគយ និង រដ្ឋាករ កំពង់ផែ ក្រុងព្រះសីហនុ និង កំពង់ផែភ្នំពេញ។ មានន័យថា រាល់ការនាំចូលតាមមាត់ច្រកនានាក្រៅពីកំពង់ផែអន្តរជាតិទាំងពីរខាងលើ ធុរជនអាចទៅផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយនៅតាមអង្គភាពគយនិងរដ្ឋាករមូលដ្ឋានតែម្តង លើកលែងតែការនាំចូលមុខទំនិញមានហានិភ័យខ្ពស់មួយចំនួន ដូចជាមុខទំនិញប្រើរួច យានយន្តគ្រប់ប្រភេទ សម្ភារបរិក្ខារទូរគមនាគមន៍ ផលិតផលតេលសិសា និងបរិក្ខារល្បែងជាដើម ដែលជាកម្មវត្ថុនៃការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយនៅទីចាត់ការកណ្តាល(នាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ)។ អគរ បាននិងកំពុងពិនិត្យលទ្ធភាពនៃការធ្វើវិមជ្ឈការនេះ ឲ្យមានភាពគ្របដណ្តប់ពេញលេញ នៅគ្រប់អង្គភាពគយនិងរដ្ឋាករមូលដ្ឋានទូទាំងប្រទេស។

### ២.៣.២.៣. នីតិវិធីនៃការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ

**ក. ទីកន្លែង÷**

- អង្គភាពតម្លៃគិតពន្ធគយ នៅតាមសាខា និងការិយាល័យគយនិងរដ្ឋាករមូលដ្ឋាន (ក្នុងក្របខ័ណ្ឌវិមជ្ឈការ)
- នាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

**ខ. ការដាក់ឯកសារស្នើសុំផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ÷**

ដើម្បីដាក់ឯកសារនាំចេញនាំចូល ឲ្យមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ច ធ្វើការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ធុរជនពាក់ព័ន្ធត្រូវបំពេញប្រតិវេទន៍តម្លៃគិតពន្ធគយ ដោយអមភ្ជាប់ជាមួយនូវបណ្តាឯកសារគាំទ្រ ដូចជា÷

- វិក្កយបត្រពាណិជ្ជកម្ម បញ្ជីវេចខ្ចប់ និងអញ្ញត្តិប័ណ្ណចំនួន ៣ ច្បាប់
- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ប័ណ្ណប៉ាតង់ លិខិតផ្ទេរសិទ្ធិ អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនម្ចាស់ទំនិញនិងអ្នកតំណាង
- លិខិតអនុញ្ញាត (ប្រសិនបើតម្រូវ)

ក្នុងករណីខ្លះ មន្ត្រីគយមានសមត្ថកិច្ចអាចតម្រូវឲ្យធុរជនពាក់ព័ន្ធផ្តល់ឯកសារគាំទ្របន្ថែមទៀត ដូចជា÷

- កិច្ចសន្យាលក់ ប័ណ្ណបញ្ជាទិញ លិខិតបញ្ជាក់ប្រតិបត្តិការតាមធនាគារ តារាងតម្លៃសាធារណៈ និងឯកសារផ្សេងទៀតដែលពាក់ព័ន្ធនឹងកិច្ចចម្លងការ ឬការទូទាត់
- ឯកសារដែលបញ្ជាក់ពីអត្តសញ្ញាណ ឬ យថាប្រភេទលម្អិតច្បាស់លាស់នៃទំនិញ

**គ. ឯកសារត្រឹមត្រូវគឺជាឯកសារដែល÷**

- បានបំពេញដោយត្រឹមត្រូវគ្រប់ប្រឡង់ព័ត៌មាន
- ពុំមានភាពមិនប្រក្រតីឬ ការកោសលុប
- មានបោះត្រាបញ្ជាក់របស់ក្រុមហ៊ុនម្ចាស់ទំនិញចំពោះឯកសារច្បាប់ចម្លង។ល។

**ឃ. បុគ្គលដែលមាននីតិសម្បទាស្នើសុំ÷**

- ម្ចាស់ក្រុមហ៊ុនស្នើសុំនាំចូល ឬ
- បុគ្គលិករបស់ក្រុមហ៊ុនស្នើសុំនាំចូល ដែលមានទទួលសិទ្ធិតំណាងពីម្ចាស់ក្រុមហ៊ុន (ត្រូវភ្ជាប់

មកជាមួយនូវបណ្ណសំគាល់បុគ្គលិកក្រុមហ៊ុន)

- នីតិបុគ្គល ឬ បុគ្គលដែលមាននីតិសម្បទានជាជើងសាគយ

### ង. រយៈពេលនៃការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ៖

ក្នុងករណីឯកសារមានភាពត្រឹមត្រូវនិងគ្រប់គ្រាន់ ការផ្ទៀងផ្ទាត់និងការសម្រេចលើតម្លៃគិតពន្ធគយនឹងធ្វើឡើងក្នុងរង្វង់ពី ១ ទៅ ២ថ្ងៃធ្វើការ។ ក្នុងករណីមិនអាចធ្វើបានដោយប្រការណាមួយ មន្រ្តីគយនិងរដ្ឋាករមានសមត្ថកិច្ច នឹងចុះអាទិសង្កេតនៅលើឯកសារពាក់ព័ន្ធ បញ្ជាក់ ពី មូលហេតុ នៃ ការយឺតយ៉ាវ ក្នុង ការចេញសេចក្តីសម្រេចនេះ។

### ច. យន្តការឧទ្ធរណ៍នៃតម្លៃគិតពន្ធគយ៖

បុគ្គលណាដែលមិនពេញចិត្តចំពោះការសម្រេចរបស់មន្រ្តីគយមានសមត្ថកិច្ចលើតម្លៃគិតពន្ធគយ អាចធ្វើការតវ៉ាជាលាយលក្ខណ៍អក្សរ ទៅ អគរ ស្របតាមបញ្ញត្តិមាត្រា២៤ នៃច្បាប់ស្តីពីគយ។

### ឆ. មធ្យោបាយទំនាក់ទំនង៖

ក្នុងករណីមានចម្ងល់ពីវិធីសាស្រ្តគណនា ឬ នីតិវិធីនៃការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ បុគ្គលពាក់ព័ន្ធអាចសាកសួរព័ត៌មាននៅនាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ នៃ អគរ។

## ២.៣.៣. វិញ្ញាបនបត្រដើមកំណើតទំនិញ

អគរ ជាស្ថាប័នទទួលបន្ទុកត្រួតពិនិត្យ ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃវិញ្ញាបនបត្រដើមកំណើតទំនិញផ្អែកតាមនីតិវិធី ប្រតិបត្តិ វិញ្ញាបនបត្រ (Operational Certification Procedures-OCP) (ឧបសម្ព័ន្ធទី៨ នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន)

### ២.៣.៣.១. ការបង្ហាញវិញ្ញាបនបត្រដើមកំណើតទំនិញ

ក. ប្រតិវេទន៍គយ (ឯកសាររដ្ឋបាលតែមួយ)

ខ. វិញ្ញាបនបត្រដើមកំណើតទំនិញ

គ. ឯកសារពាក់ព័ន្ធដូចជា៖ វិក័យបត្រ បញ្ជីវេចខ្ចប់ និងនិវេទប័ណ្ណ

ឃ. ឯកសារផ្សេងទៀត ដែលតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិនានា

### ២.៣.៣.២. ករណី វិញ្ញាបនបត្រដើមកំណើតទំនិញត្រូវបានច្រានចោល

ក. ធ្វើសញ្ញាសម្គាល់ និងសរសេរមតិក្នុងប្រអប់ទី៤ រួចប្រគល់ជូនវិញ

ខ. មិនលើសពី ៦០ថ្ងៃ

គ. តម្រូវឲ្យមានការបញ្ជាក់ពី អាជ្ញាធរដែលចេញវិញ្ញាបនបត្រ

ឃ. បញ្ចេញទំនិញតាមអត្រា MFN

### ២.៣.៣.៣. ទម្រង់នៃវិញ្ញាបនបត្រដើមកំណើតទំនិញ

ក. វិញ្ញាបនបត្រដើមកំណើតទំនិញត្រូវជាក្រដាសដែលមានទំហំ A4

ខ. វិញ្ញាបនបត្រដើមកំណើតទំនិញ ត្រូវមានច្បាប់ដើម ១ច្បាប់ និងច្បាប់ថតចម្លងចំនួន២ច្បាប់

គ. ច្បាប់ដើមត្រូវផ្ញើមកកាន់អង្គភាពគយ ច្បាប់ចម្លង១ច្បាប់ ត្រូវទុកនូវអាជ្ញាធរដែលចេញវិញ្ញាបនបត្រ ច្បាប់ចម្លង១ច្បាប់ទៀតត្រូវប្រគល់ជូនក្រុមហ៊ុននាំចេញ

### ២.៣.៣.៤. ការត្រួតពិនិត្យវិញ្ញាបនបត្រដើមកំណើតទំនិញ

ក. វិញ្ញាបនបត្រដើមកំណើតទំនិញត្រូវចុះហត្ថលេខាត្រឹមត្រូវពីអាជ្ញាធរ

ខ. ដើមកំណើតនៃផលិតផល ត្រឹមត្រូវតាមបទប្បញ្ញត្តិនៃជំពូកទ ៣ នៃកិច្ចព្រមព្រៀង

គ. គ្រប់ផ្នែកទាំងអស់នៃវិញ្ញាបនបត្រផ្ទៀងផ្ទាត់ទៅតាមឯកសារពាក់ព័ន្ធ

## ២.៣.៤. ទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**

- អនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- អនុក្រឹត្យលេខ ២០៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១១ ស្តីពីការកែសម្រួលលើកំណត់សម្គាល់ II ឧបសម្ព័ន្ធ ២ នៃអនុក្រឹត្យលេខ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់

**ទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់** គឺជាទំនិញមានចែងក្នុងបញ្ជីឧបសម្ព័ន្ធ ១ នៃអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់។

### និយមន័យ

ទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់ គឺជាទំនិញដែលស្ថិតក្រោមល័ក្ខខ័ណ្ឌលើការនាំចេញ ឬនាំចូល ក្នុងគោលបំណងណាមួយដូចជា÷

- ការការពារសន្តិសុខជាតិ
- ការការពារសណ្តាប់ធ្នាប់សាធារណៈ និងស្តង់ដារនៃសុភាវធមិ និងសីលធមិ
- ការការពារសុខភាព និងជីវិតមនុស្ស សត្វ ឬរុក្ខជាតិ
- ការការពារបេតិកភណ្ឌជាតិ ដែលមានតម្លៃខាងសិល្បៈ ប្រវត្តិសាស្ត្រ ឬ បុរាណវត្ថុវិទ្យា
- ការអភិរក្សធនធានធម្មជាតិ
- ការតម្រូវតាមបញ្ញត្តិនានានៃច្បាប់ណាមួយជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- ការបំពេញកាតព្វកិច្ចក្រោមធម្មនុញ្ញសហប្រជាជាតិ។

### ការនាំចេញឬ នាំចូលទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់ជាកម្មវត្ថុនៃ ÷

- ការហាមឃាត់ដាច់ខាតមិនឲ្យធ្វើការនាំចេញ ឬ នាំចូល
- ការអនុញ្ញាតឲ្យនាំចេញ ឬ នាំចូលដោយតម្រូវឲ្យមានអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬ វិញ្ញាបនបត្រផ្សេងៗ ព្រមទាំងឯកសារគតិយុត្តិដែលមានទម្រង់ប្រហាក់ប្រហែលជាមុន ឬ ស្ថិតក្រោមប្រព្រឹត្តិកម្មដោយឡែកមួយចំនួនពីអាជ្ញាធរមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលរួមមាន ក្រសួង ស្ថាប័ន ឬ អង្គភាពជំនាញមានសមត្ថកិច្ចពាក់ព័ន្ធស្របតាមច្បាប់ ឬ បទប្បញ្ញត្តិនានាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

### កំណត់សម្គាល់

១- ទំនិញក្នុងបញ្ជីឧបសម្ព័ន្ធ ១ នៃអនុក្រឹត្យលេខ ២០៩ អនក្រ.បក មិនអនុវត្តចំពោះការនាំចេញ ឬ នាំចូលដែលគ្មានលក្ខណៈពាណិជ្ជកម្មតាមរូបភាពជាទំនិញគំរូ សម្ភារប្រើប្រាស់ផ្ទាល់ខ្លួនរបស់អ្នកធ្វើដំណើរ សម្ភារផ្លាស់ប្តូរលំនៅដ្ឋាន ឬ ករណីតាមរូបភាពប្រហាក់ប្រហែល ព្រមទាំងការនាំចេញមានលក្ខណៈពាណិជ្ជកម្មនូវផលិតផលផលិតពីឈើ (ឈើដាំក្នុងស្រុក) ឫស្សី ផ្តៅ ដើមត្នោត កក់ ឬ រពាក់ ជាស្នាដៃសិប្បករសម្រាប់ប្រើក្នុងលំនៅដ្ឋាន វត្ថុបតែងលម្អ និងរូបចម្លាក់ផ្សេងៗដែលមានកម្រិតខ្នាតតិចជាង៥គីឡូក្រាមក្នុងមួយឯកតា។ ការលើកលែងនេះ មិនអនុវត្តចំពោះមុខទំនិញដែលស្ថិតក្រោមមុខសញ្ញាហាមឃាត់ដាច់ខាតក្នុងការនាំចេញ នាំចូល ឬ ប្រភេទមានហានិភ័យខ្ពស់ដល់សុវត្ថិភាពសាធារណៈ (យោងអនុក្រឹត្យលេខ២០៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១១)។

២- ផលិតផលមានដើមកំណើតពីសត្វដែលស្ថិតក្នុងបញ្ជីសាយតេស ប៉ុន្តែមិនមានបញ្ជាក់ច្បាស់ក្នុងតារាងនេះដោយហេតុផលបច្ចេកទេសនោះ ត្រូវមានលិខិតអនុញ្ញាតសាយតេស។

៣- ទំនិញហាមឃាត់ និងទំនិញជាប់កម្រិតផ្សេងទៀត ក្រៅពីទំនិញក្នុងបញ្ជីឧបសម្ព័ន្ធ១ នៃអនុក្រឹត្យលេខ ២០៩ អនក្រ.បក មានដូចខាងក្រោម ÷

- រថយន្តចង្កូតស្តាំ
- ទំនិញប្រើរួចមួយចំនួនដូចជា កំព្យូទ័រ ស្បែកជើង កាបូប អាគុយ ជាដើម
- សៀវភៅសាសនា សៀវភៅនយោបាយ រូបភាពអាសអាភាស រូបភាពពាណិជ្ជកម្ម និងឯកសារបោះពុម្ពដែលច្បាប់ហាមឃាត់ផ្សេងទៀត
- ទំនិញល្មើសច្បាប់កម្មសិទ្ធិបញ្ញា (IPR Law) ឬ ទំនិញក្លែងក្លាយ និងទំនិញល្មើសសិទ្ធិផ្តាច់មុខ

៤- បរិក្ខារ ឬ ឧបករណ៍បច្ចេកទេសបម្រើឱ្យការហោះហើរ ត្រូវមានការឯកភាពជាមុនពីរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

៥- ឧបករណ៍ត្រជាក់ប្រភេទប្រើរួចគ្រប់ប្រភេទ ឬ ប្រភេទថ្មីដែលប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន ត្រូវមានការអនុញ្ញាតឱ្យនាំចូលពីក្រសួងបរិស្ថាន។

៦- ទំនិញនាំចូល ត្រូវគោរពតាមវិធានស្តង់ដារឧស្សាហកម្មកម្ពុជា និងវិធានគុណភាព និងសុវត្ថិភាព

៧- ចំពោះពូជដំណាំ ឬ គ្រាប់ពូជផ្សេងទៀតដែលពុំមានចែងក្នុងបញ្ជីនេះ ត្រូវទទួលនូវប្រព្រឹត្តកម្មដូចគ្នាជាមួយពូជដំណាំ ឬ គ្រាប់ពូជក្នុងបញ្ជីនេះដែរ ស្របតាមបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងសម្ភារកសិកម្ម។

៨- ចំពោះប្រភេទទំនិញនាំចេញណា ដែលប្រទេសនាំចូល តម្រូវឱ្យមានវិញ្ញាបនបត្របញ្ជាក់សុខភាពសត្វ វិញ្ញាបនប័ត្រភូតគាមអនាម័យ វិញ្ញាបនប័ត្របញ្ជាក់គុណភាពផ្នែករោគសាស្ត្រផលផល ឬ វិញ្ញាបនបត្រផ្សេងៗទៀត អ្នកនាំចេញត្រូវស្នើសុំវិញ្ញាបនបត្រទាំងនោះទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬ ក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត ស្របតាមការតម្រូវនៃប្រទេសនាំចូលនោះ។

៩- ចំពោះការនាំចេញធនធានរ៉ែ ត្រូវមានការអនុញ្ញាតឱ្យនាំចេញពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

១០- ចំពោះទំនិញក្នុងជំពូកទី ២៨ និងជំពូកទី ២៩ ណាដែលជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ និង/ ឬ ដែលមានចែងក្នុងបញ្ជីនៃសារធាតុផ្សំគ្រឿងញៀន បញ្ជីនៃសារធាតុប៉ះពាល់ដល់សរសៃប្រសាទ និងបញ្ជីគ្រឿងញៀន ត្រូវមានលិខិតអនុញ្ញាតពីក្រសួងសុខាភិបាល។ ដោយឡែកចំពោះទំនិញក្នុងជំពូកទី ២៨ និងជំពូកទី ២៩ ណាដែលពុំមានចែងក្នុងបញ្ជីទាំងបីនេះ ត្រូវមានលិខិតអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

១១- ចំពោះបសុឱសថដែលពុំមានចែងច្បាស់លាស់នៅក្នុងបញ្ជីនេះ ត្រូវមាន លិខិតអនុញ្ញាត ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

១២- ប្រសិនបើ មានការ អនុញ្ញាត ឱ្យ នាំចេញ ឬ នាំចូលពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ការនាំចេញ ឬនាំចូលអាចធ្វើទៅបាន ដោយពុំចាំបាច់មានការអនុញ្ញាតពីក្រសួង ឬ ស្ថាប័នមានសមត្ថកិច្ចផ្សេងទៀតឡើយ លើកលែងតែទំនិញដែលស្ថិតក្រោមកម្រិតកំណត់នៃការដឹកជញ្ជូន ដោយហេតុផលសន្តិសុខ និងសុវត្ថិភាពសាធារណៈ។

១៣- យោងតាមសំណូមពរនៃការគ្រប់គ្រង ត្រួតពិនិត្យជាក់ស្តែង ការធ្វើវិមជ្ឈការការងារ និងលទ្ធភាពនៃប្រព័ន្ធតភ្ជាប់ព័ត៌មានទំនិញក្នុងបញ្ជីនេះ ដែលទទួលបានការអនុញ្ញាតឱ្យនាំចេញ ឬ នាំចូលរួចហើយពីក្រសួង ស្ថាប័នមានសមត្ថកិច្ចតាមរូបភាពជាកញ្ចប់សម្រាប់ការនាំចេញ ឬ នាំចូលច្រើនដង និង/ ឬតាមមាត់ច្រកលើសពីមួយត្រូវស្ថិតនៅក្រោមការគ្រប់គ្រង ត្រួតពិនិត្យដោយឡែកជាបណ្តោះអាសន្នពីទីចាត់ការគយ និងរដ្ឋាករ និង/ ឬពីនាយកដ្ឋានកាំកុងត្រូល។

## ២.៣.៥. លិខិតអនុញ្ញាតគយ

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**

- ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៣ នស ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤
- សារាចរលេខ ០៣ សរ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពី បែបបទ និងនីតិវិធីនៃការស្នើសុំរួចពន្ធឧបករណ៍ សម្ភារ នាំចូល ក្នុងក្របខ័ណ្ឌជំនួយឥតសំណង ឥណទាន និងជំនួយមនុស្សធម៌
- ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/ ០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣
- អនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីពីគយ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧
- អនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- ប្រកាសលេខ ១១៤ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពី ការកំណត់មុខទំនិញដែលត្រូវលើកលែងពន្ធ និងអាករ
- អនុក្រឹត្យលេខ ២០៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១១ ស្តីពីការកែសម្រួលលើកំណត់សម្គាល់ II ឧបសម្ព័ន្ធ ២ នៃអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- ប្រកាសអន្តរក្រសួងលេខ ៥៨១ សហវ និងលេខ ១២៧៦ ក.អ.ក/គ.ជ.នា របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីបែបបទ និងនីតិវិធីនៃការស្នើសុំនាំចូលឧបករណ៍ សម្ភារ គ្រឿងចក្រ យានយន្ត និងផលិតផលគេលសិលា ដោយពន្ធនិងអាករជាបន្ទុករបស់រដ្ឋ ក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណង
- ប្រកាសលេខ ៣១១ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការអនុវត្តអាករលើតម្លៃ បន្ថែមចំពោះឧស្សាហកម្មគាំទ្រ ឬ អ្នកចុះកិច្ចសន្យា ដែលធ្វើការផ្គត់ផ្គង់ទំនិញ ឬ សេវាសម្រាប់បម្រើឲ្យការនាំ ចេញរបស់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូប យួរ និងកាបូបដៃ និងឧស្សាហកម្មផលិតមួក
- លិខិតប្រគល់សិទ្ធិលេខ ០០៥ សហវ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ ២០១៥

## ២.៣.៥.១. ទំនិញជាកម្មវត្ថុនៃការស្នើសុំលិខិតអនុញ្ញាតគយ

ទំនិញនាំចូល/នាំចេញ ដែលតម្រូវឲ្យស្នើសុំលិខិតអនុញ្ញាតគយ នៅ អគរ មានដូចខាងក្រោម÷

- ទំនិញគ្រប់ប្រភេទ ដែលនាំចូលដោយគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់(គ.ល.គ) ដែលស្ថិតនៅខាងក្រៅ តំបន់រួចពន្ធនានា និង ដែលពន្ធ និង/ឬអាករជាបន្ទុករបស់រដ្ឋ
- ទំនិញនាំចូល/នាំចេញគ្រប់ប្រភេទ ដែលមាននៅក្នុងបញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ក្នុងការនាំចូលនិងនាំចេញ នៃឧបសម្ព័ន្ធ ១ នៃអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- ទំនិញនាំចូលគ្រប់ប្រភេទ ដែលពន្ធនិងអាករជាបន្ទុករបស់រដ្ឋ ក្រោមក្របខ័ណ្ឌវិនិយោគសាធារណៈ
- ទំនិញនាំចូលគ្រប់ប្រភេទ ដែលពន្ធនិងអាករជាបន្ទុករបស់រដ្ឋ ក្រោមក្របខ័ណ្ឌជំនួយឥតសំណងឥណទាន និងជំនួយមនុស្សធម៌
- ទំនិញនាំចូលគ្រប់ប្រភេទ ដែលពន្ធនិងអាករជា បន្ទុករបស់រដ្ឋ និងដែលនាំចូលសម្រាប់បេសកកម្មការទូត ឬបេសកកម្មកុងស៊ុលបរទេស អង្គការអន្តរជាតិ និងភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលផ្សេងទៀត ដើម្បីប្រើប្រាស់ក្នុងការិយកិច្ចនៃមុខងារជាផ្លូវការ និងប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលិក
- ទំនិញនាំចូលគ្រប់ប្រភេទ ដែលពន្ធនិងអាករជាបន្ទុករបស់រដ្ឋ និងដែលជាសម្ភារប្រើប្រាស់ក្នុងផ្ទះ សម្ភារប្រើប្រាស់ផ្ទាល់ខ្លួន និងទ្រព្យសម្បត្តិផ្សេងទៀតលើកលែងយានយន្ត ដែលនាំចូលដោយបុគ្គលដែលផ្លាស់ទីលំនៅស្ថានមកកម្ពុជា
- ទំនិញផ្សេងទៀតតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ២.៣.៥.២. នីតិវិធីនៃការស្នើសុំលិខិតអនុញ្ញាតគយ

### ក. ការនាំចូលទំនិញដោយ គ.ល.គ

បុគ្គលដែលស្នើសុំលិខិតអនុញ្ញាតគយ ដើម្បីនាំចូលទំនិញបម្រើឲ្យផលិតកម្មរបស់គ.ល.គ ដែលពន្ធនិងអាករជាបន្ទុក របស់រដ្ឋ ត្រូវ÷

- មានបញ្ជីមេនៃមុខទំនិញដែលនាំចូលសម្រាប់បម្រើផលិតកម្មរបស់គ.ល.គ និងដែលបានអនុញ្ញាតដោយ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក)/គណៈកម្មាធិការវិនិយោគកម្ពុជា (គ.វ.ក)
- ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតគយ នៅ អគរ (នាយកដ្ឋានរបបគយ) ដោយភ្ជាប់មកជាមួយ នូវវិក្កយបត្រទំនិញ បញ្ជីវេចខ្ចប់ និងឯកសារដឹកជញ្ជូន លិខិតប្រគល់សិទ្ធិសម្រាប់អ្នកតំណាង និងឯកសារពាក់ព័ន្ធផ្សេងទៀតក្នុងករណីចាំបាច់។

### ខ. ការនាំចូលទំនិញ ដែលមាននៅក្នុងបញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់

ដើម្បីនាំចូលទំនិញដែលស្ថិតក្នុងបញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ ត្រូវអនុវត្តដូចខាងក្រោម÷

- ត្រូវមានអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬវិញ្ញាបនបត្រផ្សេងៗ ព្រមទាំងឯកសារគតិយុត្តិដែលមានទម្រង់ប្រហាក់ប្រហែលជាមុន ឬ ស្ថិតក្រោមប្រព្រឹត្តិកម្មដោយឡែកមួយចំនួនពីអាជ្ញាធរមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលរួមមាន ក្រសួង ស្ថាប័ន ឬអង្គភាពជំនាញមានសមត្ថកិច្ចពាក់ព័ន្ធ
- ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតគយ នៅ អគរ(នាយកដ្ឋានរបបគយ) ដោយភ្ជាប់មកជាមួយនូវវិក្កយបត្រទំនិញ បញ្ជីវេចខ្ចប់ និង ឯកសារដឹកជញ្ជូន លិខិតប្រគល់សិទ្ធិសម្រាប់អ្នកតំណាង និងឯកសារពាក់ព័ន្ធផ្សេងទៀតក្នុងករណីចាំបាច់។

## គ. ការនាំចូលទំនិញ ក្រោមក្របខ័ណ្ឌវិនិយោគសាធារណៈ

- **ក្រោមក្របខ័ណ្ឌវិនិយោគសាធារណៈ(ជំនួយឥតសំណង)**

បុគ្គលដែលស្នើសុំលិខិតអនុញ្ញាតគយ ដើម្បីនាំចូលទំនិញដែលពន្ធនិងអាករជាបន្ទុករបស់រដ្ឋក្រោមក្របខ័ណ្ឌវិនិយោគសាធារណៈ ដោយប្រើប្រាស់ជំនួយឥតសំណង ត្រូវ÷

- មានបញ្ជីមេនៃមុខទំនិញ ដែលនាំចូលសម្រាប់បម្រើផលិតកម្មរបស់គម្រោងវិនិយោគសាធារណៈ និង បានអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក)/ គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ (ក.អ.ក/គ.ជ.នា)
- ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតគយ នៅអគរ (នាយកដ្ឋានរបបគយ) ដោយភ្ជាប់មកជាមួយនូវវិក្កយបត្រទំនិញ បញ្ជីវេចខ្ចប់ និង ឯកសារដឹកជញ្ជូន លិខិតប្រគល់សិទ្ធិសម្រាប់អ្នកតំណាង និងឯកសារពាក់ព័ន្ធផ្សេងទៀតក្នុងករណីចាំបាច់។

- **ក្រោមក្របខ័ណ្ឌវិនិយោគសាធារណៈ(ឥណទាន)**

បុគ្គលដែលស្នើសុំលិខិតអនុញ្ញាតគយ ដើម្បីនាំចូលទំនិញដែលពន្ធនិងអាករជាបន្ទុករបស់រដ្ឋក្រោមក្របខ័ណ្ឌវិនិយោគសាធារណៈ ដោយប្រើប្រាស់ឥណទាន ត្រូវ÷

- មានបញ្ជីមេនៃមុខទំនិញ ដែលនាំចូលបម្រើផលិតកម្មរបស់គម្រោងវិនិយោគសាធារណៈ និង បានអនុញ្ញាតដោយក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតគយ នៅអគរ (នាយកដ្ឋានរបបគយ) ដោយភ្ជាប់មកជាមួយ នូវវិក្កយបត្រទំនិញ បញ្ជីវេចខ្ចប់ និង ឯកសារដឹកជញ្ជូន លិខិតប្រគល់សិទ្ធិសម្រាប់អ្នកតំណាង និងឯកសារពាក់ព័ន្ធផ្សេងទៀតក្នុងករណីចាំបាច់។

## ឃ. ការនាំចូលទំនិញ ក្រោមក្របខ័ណ្ឌជំនួយឥតសំណង ឥណទាន និងជំនួយមនុស្សធម៌

- **ការនាំចូលទំនិញក្រោមក្របខ័ណ្ឌជំនួយឥតសំណង (ទ្វេភាគី ពហុភាគី អង្គការមិនមែនរដ្ឋាភិបាល)**

មុនការស្នើសុំលិខិតអនុញ្ញាតគយនាំចូល ដើម្បីនាំចូលឧបករណ៍ សម្ភារ គ្រឿងចក្រ យានយន្ត និងផលិតផលតេលសិលាដោយពន្ធនិងអាករជាបន្ទុករបស់រដ្ឋ ក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងសម្រាប់អនុវត្តគម្រោង ឬ បម្រើក្នុងការិយាល័យរបស់ភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍ ភ្នាក់ងារអនុវត្តគម្រោង (រួមមានក្រសួងនិងស្ថាប័នរបស់រដ្ឋាភិបាលកម្ពុជា និង/ឬ ស្ថាប័នផ្តល់ហិរញ្ញប្បទានឥតសំណងនៃដៃគូអភិវឌ្ឍន៍ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល) អ្នកអនុវត្តគម្រោង ត្រូវស្នើសុំការអនុញ្ញាតឱ្យនាំចូលដោយពន្ធនិងអាករជាបន្ទុករបស់រដ្ឋ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍ (ក.អ.ក/គ.ជ.នា)។

បន្ទាប់ពីទទួលបានការអនុញ្ញាតឱ្យនាំចូលទំនិញដោយពន្ធនិងអាករជាបន្ទុករបស់រដ្ឋ ពីក.អ.ក/គ.ជ.នា អ្នកនាំចូលខាងលើ ត្រូវស្នើសុំលិខិតអនុញ្ញាតគយនៅអគរ (នាយកដ្ឋានរបបគយ) ដោយភ្ជាប់មកជាមួយនូវឯកសារចាំបាច់នានារួមមាន÷

- លិខិតអនុញ្ញាតឱ្យនាំចូលទំនិញដោយពន្ធនិងអាករជាបន្ទុករបស់រដ្ឋពីក.អ.ក/គ.ជ.នា
- លិខិតស្នើសុំការអនុញ្ញាតឱ្យនាំចូលដោយពន្ធនិងអាករជាបន្ទុករបស់រដ្ឋពីក.អ.ក/គ.ជ.នា
- វិក្កយបត្រទំនិញ បញ្ជីវេចខ្ចប់ និង ឯកសារដឹកជញ្ជូន លិខិតប្រគល់សិទ្ធិសម្រាប់អ្នកតំណាងនិងឯកសារពាក់ព័ន្ធផ្សេងទៀតក្នុងករណីចាំបាច់។

- **ការនាំចូលទំនិញក្រោមក្របខ័ណ្ឌឥណទាន និងជំនួយមនុស្សធម៌**

មុនការស្នើសុំលិខិតអនុញ្ញាតគយនាំចូល ដើម្បីនាំចូលឧបករណ៍ សម្ភារ ដោយពន្ធនិងអាករជាបន្ទុករបស់រដ្ឋក្នុងក្របខ័ណ្ឌឥណទាន ឬ ជំនួយមនុស្សធម៌ ភ្នាក់ងារ

អនុវត្តគម្រោង ឬ សាមីស្ថាប័នទទួលជំនួយ ត្រូវបំពេញទម្រង់បែបបទស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងសម្រេច។

បន្ទាប់ពីទទួលបានការអនុញ្ញាត ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ភ្នាក់ងារអនុវត្តគម្រោង ឬ សាមីស្ថាប័នទទួលជំនួយខាងលើ ត្រូវស្នើសុំលិខិតអនុញ្ញាតគយនៅ អគរ (នាយកដ្ឋានរបបគយ) ដោយភ្ជាប់មកជាមួយនូវឯកសារចាំបាច់នានារួមមាន÷

- លិខិតអនុញ្ញាតឱ្យនាំចូលទំនិញដោយពន្ធនិងអាករជាបន្ទុករបស់រដ្ឋពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ លិខិតស្នើសុំការអនុញ្ញាតឱ្យនាំចូលដោយពន្ធនិងអាករជាបន្ទុករបស់រដ្ឋ ដែលមានចំណារឯកភាព ពីឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ឯកសារត្រូវភ្ជាប់ជាមួយរួមមាន វិក្កយបត្រទំនិញ បញ្ជីវេចខ្ចប់ និង ឯកសារដឹកជញ្ជូន លិខិតប្រគល់សិទ្ធិសម្រាប់អ្នកតំណាង និងឯកសារពាក់ព័ន្ធផ្សេងទៀតក្នុងករណីចាំបាច់។

## ង. ការនាំចូលទំនិញ សម្រាប់បេសកកម្មការទូត ឬ បេសកកម្មកុងស៊ុលបរទេស អង្គការអន្តរជាតិ និងភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលផ្សេងទៀត

- អង្គការនានា ឬ បុគ្គលដែលមានបំណងស្នើសុំការលើកលែងពន្ធ និងអាករលើទំនិញនាំចូលសម្រាប់ បេសកកម្មការទូត ឬបេសកកម្មកុងស៊ុលបរទេស អង្គការអន្តរជាតិ និងភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស របស់រដ្ឋាភិបាលផ្សេងទៀត ដើម្បីប្រើប្រាស់ក្នុងការិយកិច្ចនៃមុខងារជាផ្លូវការ និងសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលិកផ្លូវការនៃបេសកកម្ម និងអង្គការត្រូវមានការអនុញ្ញាតជាមុនពីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- តាមសំណើខាងលើ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដាក់សំណើសុំនាំចូលទំនិញដោយពន្ធអាករជាបន្ទុករដ្ឋ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងសម្រេច (អគរ នឹងពិនិត្យ សម្រេចលើលិខិតស្នើសុំនេះក្នុងនាមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមលិខិតប្រគល់សិទ្ធិលេខ០០៥ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)
- បន្ទាប់ពីទទួលបានការឯកភាពពីថ្នាក់ដឹកនាំអគរ អ្នកស្នើសុំ ត្រូវស្នើសុំលិខិតអនុញ្ញាតគយ នៅ អគរ (នាយកដ្ឋានរបបគយ) ដោយភ្ជាប់មកជាមួយ នូវវិក្កយបត្រទំនិញ បញ្ជីវេចខ្ចប់ ឯកសារដឹកជញ្ជូន លិខិតផ្ទេរសិទ្ធិសម្រាប់បុគ្គលតំណាង និង ឯកសារ ពាក់ព័ន្ធ ផ្សេងទៀត ក្នុងករណីចាំបាច់។

## ច. ការនាំចូលទំនិញ ដែលជាសម្ភារប្រើប្រាស់ក្នុងផ្ទះ សម្ភារប្រើប្រាស់ផ្ទាល់ខ្លួន និងទ្រព្យសម្បត្តិផ្សេងទៀត លើកលែងយានយន្ត ក្នុងករណីផ្លាស់ទីលំនៅស្ថាន

- អ្នកស្នើសុំ ត្រូវដាក់លិខិតស្នើសុំនាំចូលទំនិញដោយពន្ធអាករជាបន្ទុករដ្ឋ ទៅជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- អគរ នឹងពិនិត្យ សម្រេចលើលិខិតស្នើសុំនេះក្នុងនាមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមលិខិតប្រគល់សិទ្ធិលេខ០០៥ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បន្ទាប់ពីទទួលបានការឯកភាពពីថ្នាក់ដឹកនាំ អគរ អ្នកស្នើសុំត្រូវស្នើសុំលិខិតអនុញ្ញាតគយនៅ អគរ (នាយកដ្ឋានរបបគយ) ដោយភ្ជាប់មកជាមួយរួមមាន វិក្កយបត្រទំនិញ បញ្ជីវេចខ្ចប់និង ឯកសារដឹកជញ្ជូន លិខិតប្រគល់សិទ្ធិសម្រាប់អ្នកតំណាង និងឯកសារពាក់ព័ន្ធផ្សេងទៀតក្នុងករណីចាំបាច់។

# ២.៤. នីតិវិធីផ្សេងៗ

## ២.៤.១. កញ្ចប់បញ្ញើតាមប្រៃសណីយ៍

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**

- ព្រះរាជក្រមលេខ នស/រកម/០៧០២/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០២ស្តីពីវិស័យប្រៃសណីយ៍
- ប្រកាសលេខ ១៨៣បទប្រក ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ស្តីពីការដាក់អោយប្រើប្រាស់បទដ្ឋានប្រៃសណីយ៍
- លិខិតលេខ ៩១២គ.រ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៦ របស់ទីចាត់ការគយនិងរដ្ឋាករ ស្តីពីការកំណត់ជាបណ្តោះអាសន្ន នូវបរិមាណសម្ភារប្រើប្រាស់ផ្ទាល់ខ្លួនរបស់អ្នកដំណើរ ដែលអាចយកតាមខ្លួនបាន ដោយមិនជាប់ពន្ធនិងអាករផ្សេងៗ
- ប្រកាសលេខ ១៤៤៧សហវប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីបញ្ញត្តិនិងនីតិវិធីប្រតិវេទន៍គយ
- ប្រកាសលេខ ១០៦សហវប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីសន្និធិគយបណ្តោះអាសន្ន
- ប្រកាសលេខ ៥៦៩សហវប្រក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការត្រួតពិនិត្យទំនិញនាំចេញ ទំនិញនាំចូល និងមធ្យោបាយដឹកជញ្ជូន។
- សារាចរណែនាំលេខ ០០៤សហវ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីនីតិវិធីគយលើទំនិញតម្លៃទាប
- លិខិតលេខ ៧៧៣អគរ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកំណត់បរិមាណទំនិញ ឬសម្ភារប្រើប្រាស់ផ្ទាល់ខ្លួនដែលអាចយកតាមខ្លួនបាន ដោយលើកលែងពន្ធនិងអាករផ្សេងៗរបស់អ្នកដំណើរ អ្នកបម្រើការតាមមធ្យោបាយដឹកជញ្ជូន និងជនទាំងឡាយដែលឆ្លងកាត់ព្រំដែន

### ២.៤.១.១.សន្និធិគយបណ្តោះអាសន្ន

រាល់ទំនិញនាំចេញ នាំចូលទោះជាជាប់ពន្ធនិងអាករ ឬត្រូវបានលើកលែងពន្ធ និងអាករក្តី ទំនិញទាំងនេះត្រូវតែជាកម្មវត្ថុនៃការប្រកាសគយ (មាត្រា១០ នៃច្បាប់ស្តីពី គយ)។ ទំនិញ នាំចូល ដោយ សេវាកម្ម បញ្ញើប្រៃសណីយ៍ ត្រូវបាន ថែរក្សា ទុក នៅក្នុង សន្និធិគយបណ្តោះអាសន្ន ក្រោម ការគ្រប់គ្រង ដោយ សមត្ថកិច្ចគយរង់ចាំការបំពេញបែបបទ ក្នុងគោលបំណងដើម្បីជាសម្ភារប្រើប្រាស់ផ្ទាល់ខ្លួន ឬ ក្នុងគោលបំណងផ្សេងទៀត។

### ២.៤.១.២. ការបំពេញបែបបទគយ

រាល់ទំនិញនាំចេញ នាំចូលទោះជាជាប់ពន្ធនិងអាករ ឬ ត្រូវបានលើកលែងពន្ធ និងអាករក្តី ទំនិញទាំងនេះត្រូវតែជាកម្មវត្ថុនៃការធ្វើប្រតិវេទន៍គយ (មាត្រា២៩ នៃច្បាប់ស្តីពីគយ)។

ការបំពេញបែបបទក្នុងពេលផ្ញើ ម្ចាស់ឬ តំណាងត្រូវបំពេញបែបបទនៅលើប័ណ្ណផ្ញើ និងលិខិតប្រកាសគយតាមគំរូ CP72 សម្រាប់បញ្ញើ ប្រៃសណីយ៍ភ័ណ្ឌ (បញ្ញើធម្មតា) និង CN22 សម្រាប់បញ្ញើឆាប់រហ័ស EMS ដែលនឹងត្រូវបិតភ្ជាប់នៅលើកញ្ចប់បញ្ញើ។

កញ្ចប់បញ្ញើដែលពុំមានចែងនៅក្នុងច្បាប់និងបទប្បញ្ញត្តិអំពីការលើកលែងពន្ធនិងអាករ និងមានតម្លៃលើសពីចំនួនដែលបានកំណត់នៅក្នុងបទប្បញ្ញត្តិ ត្រូវជាប់កាតព្វកិច្ចពន្ធនិងអាករ។ (សូមយោងបន្តទៅចំណុច ១.២.៥ ស្តីពីការលើកលែង ការលើកលែងជាភាគ និងការបង្វិលសងវិញនូវពន្ធនិងអាករ និងចំណុច២.៤.៥ស្តីពីនីតិវិធីគយលើទំនិញតម្លៃទាប De Minimis)។ ម្ចាស់ទំនិញ ឬតំណាងត្រូវបំពេញប្រតិវេទន៍គយ ដែលត្រូវធ្វើឡើង ជាលាយល័ក្ខណ៍អក្សរ ឬ តាមមធ្យោបាយអេឡិកត្រូនិក និង ត្រូវចុះនូវរាល់សូចនាចាំបាច់នានា។ ឯកសារភ្ជាប់ ជាមួយប្រតិវេទន៍គយ រួមមានវិក្កយបត្រទំនិញ បញ្ជីវេចខ្ចប់ និង ឯកសារដឹកជញ្ជូនក្នុងករណីចាំបាច់ និវេទន៍ប័ណ្ណអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត វិញ្ញាបនបត្រដើមកំណើតទំនិញ វិញ្ញាបនបត្រធានារ៉ាប់រង និងឯកសារពាក់ព័ន្ធផ្សេងទៀត។

### ២.៤.១.៣. ការត្រួតពិនិត្យទំនិញ

ទំនិញនាំចេញ នាំចូលទាំងអស់ ទោះបីជា ឬ មិនមែនជាកម្មវត្ថុនៃការជាប់ពន្ធ និងអាករក្តី ដែលនាំចូល ឬចេញពីដែនគយ ជាកម្មវត្ថុនៃការត្រួតពិនិត្យគយ ( មាត្រា៥៦ នៃច្បាប់ស្តីពីគយ)។ ការត្រួតពិនិត្យកញ្ចប់ប្រៃសណីយ៍ ដោយមន្ត្រីគយ ប្រព្រឹត្តទៅដោយមានវត្តមានមន្ត្រីប្រៃសណីយ៍ ឬ ម្ចាស់ទំនិញ ឬ តំណាងម្ចាស់។

ការត្រួតពិនិត្យ នឹងមិនត្រូវធ្វើលើបណ្តាកញ្ចប់ប្រៃសណីយ៍ទាំងឡាយដូចជា÷

ក. កញ្ចប់បញ្ញើដោយបេសកកម្មកុងស៊ុល ឬ ការទូតបរទេស ឬគណៈប្រតិភូផ្លូវការនៃរដ្ឋាភិបាលបរទេស

ខ. ប្រៃសណីយ៍បត្រនិងលិខិតដែលមានតែសារផ្ទាល់ខ្លួនអក្សរសាស្ត្រសម្រាប់មនុស្សពិការភ្នែក

គ. ឯកសារបោះពុម្ពដែលមិនមែនជាកម្មវត្ថុនៃការជាប់ពន្ធ

ឃ. កញ្ចប់ប្រៃសណីយ៍ដែលដឹកជញ្ជូនឆ្លងកាត់ជាអន្តរជាតិ។

## ២.៤.២. ទំនិញឬ សម្ភារប្រើប្រាស់ផ្ទាល់ខ្លួនរបស់អ្នកដំណើរ

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**

- លិខិតលេខ ៧៧៣ អគរ. ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ស្តីពីការកំណត់បរិមាណទំនិញឬ សម្ភារប្រើប្រាស់ផ្ទាល់ខ្លួន ដែលអាចយកតាមខ្លួនបានដោយលើកលែងពន្ធនិងអាករផ្សេងៗរបស់អ្នកដំណើរ អ្នកបម្រើការតាមមធ្យោបាយដឹកជញ្ជូន និង ជនទាំងឡាយដែលឆ្លងកាត់ព្រំដែន

អ្នកដំណើរ អ្នកបម្រើការតាមមធ្យោបាយដឹកជញ្ជូន និងជនទាំងឡាយដែលឆ្លងកាត់ព្រំដែន អាចយកតាមខ្លួនបានដោយលើកលែងពន្ធនិងអាករផ្សេងៗនូវបរិមាណទំនិញ និង សម្ភារប្រើប្រាស់ផ្ទាល់ខ្លួនដូចខាងក្រោម ÷

១. សុរាគ្រប់ប្រភេទមិនលើស២លីត្រ

២. បារីមិនលើស ២០០ដើម ឬ ស៊ីហ្គាមិនលើសពី ៥០ដើម ឬ ថ្នាំជក់មិនលើសពី ២៥០ក្រាម

៣. ទឹកអប់ និង គ្រឿងតុបតែងខ្លួនចំណុះមិនលើស ៣៥០ មីលីលីត្រ

៤. សម្ភារ និង ឧបករណ៍ផ្សេងទៀតក្នុងបរិមាណសមស្រប ដែលជាតម្រូវការក្នុងការធ្វើដំណើរ ហើយពុំមែនជាទំនិញប្រភេទហាមឃាត់ដាច់ខាត។

៥. ជនដែលមានអាយុតិចជាង១៨ឆ្នាំមិនទទួលបានការអនុគ្រោះលើមុខទំនិញទី១និងទី២ ខាងលើទេ។

## ២.៤.៣. ទំនិញគ្មានលក្ខណៈពាណិជ្ជកម្ម

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**

- សារាចរណែនាំ លេខ០០៩ សហវ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងទំនិញនាំចូលគ្មានលក្ខណៈពាណិជ្ជកម្ម

ទំនិញគ្មានលក្ខណៈពាណិជ្ជកម្ម គឺជាទំនិញដែលត្រូវបាននាំចូលម្តងម្កាលដោយអ្នកដំណើរ ឬ ត្រូវបាននាំចូលដោយប្រជាពលរដ្ឋដែលមានលំនៅដ្ឋានជាអចិន្ត្រៃយ៍ក្នុងតំបន់ព្រំដែន សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ឬ ប្រើប្រាស់ក្នុងតំបន់ព្រំដែន។ ការនាំចូលទំនិញគ្មានលក្ខណៈពាណិជ្ជកម្មត្រូវអនុវត្តដូចខាងក្រោម÷

- ការនាំចូលម្តងម្កាលរបស់អ្នកដំណើរ ដែលត្រូវចាត់ទុកថាគ្មានលក្ខណៈពាណិជ្ជកម្ម ត្រូវបំពេញបែបបទគយតាមច្បាប់ជាធរមាន ដោយត្រូវបង្ហាញនូវលិខិតឆ្លងដែន ដែលមានបញ្ជាក់ពីការចេញ-ចូលប្រទេសពីស្ថាប័នមានសមត្ថកិច្ចច្រកទ្វារ ហើយត្រូវប្រថាប់ត្រា ឬ សរសេរលើបង្កាន់ដៃពន្ធថា "គ្មានលក្ខណៈពាណិជ្ជកម្ម-សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន" និងពុំចាំបាច់បិទត្រាគយឡើយ។ ក្នុងករណីដែលអ្នកដំណើរម្តងម្កាលនោះនាំចូលទំនិញហើយប្រកាសថាមានលក្ខណៈពាណិជ្ជកម្មសម្រាប់ធ្វើអាជីវកម្ម ការកំណត់តម្លៃគិតពន្ធគយត្រូវបូកបន្ថែម ២០ ភាគរយ លើតម្លៃគិតពន្ធគយជាធរមាន និងត្រូវប្រថាប់ត្រា ឬ សរសេរ លើបង្កាន់ដៃពន្ធថា "មានលក្ខណៈពាណិជ្ជកម្ម" ហើយត្រូវបិទត្រាគយជូន ប្រសិនបើមុខទំនិញនោះស្ថិតក្រោមប្រព័ន្ធត្រាគយ ដើម្បី អាចចរាចរលើទីផ្សារបាន
- ចំពោះការនាំចូលរបស់ប្រជាជនដែលមានលំនៅដ្ឋាន ជា អចិន្ត្រៃយ៍ ក្នុង តំបន់ ព្រំដែន ត្រូវបំពេញបែបបទគយតាមការកំណត់ជាធរមាន ហើយត្រូវប្រថាប់ត្រា ឬ សរសេរលើបង្កាន់ដៃពន្ធថា "សម្រាប់ចរាចរក្នុងតំបន់ព្រំដែន។ ប្រជាជនតំបន់ព្រំដែន ដែលធ្វើអាជីវកម្មនាំចេញ-នាំចូលទំនិញមានលក្ខណៈពាណិជ្ជកម្ម សម្រាប់ ចរាចរ ទូទាំងប្រទេសនោះ ត្រូវតែបង្កើតជាក្រុមហ៊ុនដែលមានលេខអត្តសញ្ញាណកម្ម អាករលើតម្លៃបន្ថែម និងត្រូវមានប័ណ្ណប៉ាតង់ឆ្នាំចុងក្រោយ ដូចអ្នកនាំចេញ-នាំចូលធម្មតា ហើយក្នុងករណីចាំបាច់ត្រូវអនុវត្តតាមការណែនាំខាងលើ។

## ២.៤.៤. ទំនិញតាមរូបភាពតូច

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**

- សារាចរណែនាំ លេខ ០០៧ សហវ. ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងការនាំចេញ-នាំចូលទំនិញមួយចំនួនតាមរូបភាពតូច (សារាចរណែនាំនេះ បន្តអនុវត្តតាមសារាចរ លេខ ០០៩ សហវ.ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងទំនិញនាំចូលគ្មានលក្ខណៈពាណិជ្ជកម្ម របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)

- សេវាកម្មបំពេញបែបបទគយនាំចេញ-នាំចូលទំនិញជំនួសអ្នកដទៃ អាចធ្វើទៅបានតែដោយបុគ្គលដែលមានគុណវឌ្ឍជាជើងសារគយមួយប៉ុណ្ណោះ តាមបញ្ញត្តិជំពូក ៥ នៃច្បាប់ស្តីពីគយ។ បុគ្គលជើងសាគយ អាចប្រមូលកំរៃពីម្ចាស់ទំនិញពិត ទៅតាមការព្រមព្រៀងគ្នាជាមុន តាមករណីជាក់ស្តែង

- សម្រួលចំពោះរូបវន្តបុគ្គល ដែលធ្វើអាជីវកម្មនាំចេញ-នាំចូលតាមរូបភាពតូចតាច មានតម្លៃគិតពន្ធសមមូលត្រឹម ៣០០ ដុល្លារអាមេរិកចុះ លើមុខទំនិញរួមមាន បន្លែ ផ្លែឈើ និងកសិផលប្រហាក់ប្រហែលផ្សេងទៀត ដែលមិនស្ថិតក្នុងបញ្ជីទំនិញហាមឃាត់ និងបញ្ជីទំនិញជាប់កម្រិតកំណត់ជាធរមាន អាចបំពេញបែបបទគយដោយខ្លួនឯងបានទោះបីមាន ឬ គ្មានអត្តសញ្ញាណកម្មអាករលើតម្លៃបន្ថែមក្តី ដោយគ្រាន់តែធ្វើការប្រកាសសុំតាមទម្រង់សង្ខេប (ប្រតិវេទន៍គយសង្ខេប) និងតម្កល់នូវច្បាប់ចម្លងនៃអត្តសញ្ញាណប័ណ្ណ ឬ ឯកសារសំគាល់ខ្លួនផ្សេងៗផ្សេងទៀត ដោយមានផ្តិតមេដៃស្តាំបញ្ជាក់ ព្រមទាំងចុះហត្ថលេខាចំពោះមុខមន្ត្រីគយមានសមត្ថកិច្ចជាប់ជាមួយ។ ករណីដូចគ្នាត្រូវបានអនុវត្តសម្រាប់ការនាំចេញ-នាំចូលតាមរូបភាពតូចៗ ដើម្បីចរាចរចែកចាយក្នុងប្រទេស ទោះបីមានលក្ខណៈពាណិជ្ជកម្មក្តី ហើយតម្លៃគិតពន្ធលើមុខទំនិញទាំងនេះ ត្រូវបានកំណត់ដោយបូកបន្ថែម ១០% លើតម្លៃគិតពន្ធគយតាមបទប្បញ្ញត្តិជាធរមានដោយមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ចនាមាត់ច្រកបំពេញបែបបទគយតែម្តង។

## ២.៤.៥. ទំនិញតម្លៃទាប

### ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ

- សារាចរណែនាំលេខ ០០៤ សហវ.ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២ ស្តីពីនីតិវិធីគយចំពោះទំនិញតម្លៃទាប (សារាចរណែនាំនេះ អនុលោមតាមសារាចរណែនាំ លេខ ០០៧ សហវ. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងការនាំចេញ-នាំចូលទំនិញមួយចំនួនតាមរូបភាពតូច)

- ត្រូវបានកំណត់ថាជាទំនិញតម្លៃទាប (De Minimis) ចំពោះទំនិញនាំចេញនាំចូលទាំងឡាយណា ក្នុងទម្រង់ជាកញ្ចប់បញ្ញើរហ័ស ទំនិញនាំចូលគ្មានលក្ខណៈពាណិជ្ជកម្ម និង/ ឬ ទម្រង់ប្រហាក់ប្រហែល មានតម្លៃ FOB សមមូល៥០ ដុល្លារអាមេរិកចុះ
- ទំនិញតម្លៃទាប (De Minimis) ត្រូវបានលើកលែងពន្ធនិងអាករគយនានា
- ម្ចាស់ទំនិញ ឬតំណាងស្របច្បាប់ត្រូវធ្វើការប្រកាសតាមទម្រង់ប្រតិវេទន៍គយសង្ខេប អមដោយឯកសារទ្រទ្រង់នានា ដូចជាវិក្កយបត្រ បញ្ជីវេចខ្ចប់ វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម អញ្ញត្តិប័ណ្ណ និងឯកសារពាក់ព័ន្ធផ្សេងទៀតប្រសិនបើមាន
- មុខទំនិញមួយចំនួន ដែលមិនត្រូវបានអនុញ្ញាតជាបណ្តោះអាសន្នឱ្យស្ថិតក្រោមនីតិវិធិគយលើទំនិញតម្លៃទាប រួមមាន ÷ បណ្តាទំនិញដែលស្ថិតក្នុងបញ្ជីទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់ តាមបញ្ញត្តិនៃអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ដែលជាប់ប្រព្រឹត្តកម្មហាមឃាត់ដាច់ខាត និងទំនិញដែលមានវេទយិតភាពខ្ពស់ និងអាចប៉ះពាល់ដល់សន្តិសុខសុវត្ថិភាពសាធារណៈ ដូចជាគ្រឿងសាស្ត្រាវុធ ជាតិផ្ទុះ សម្ភារបរិក្ខារយោធា គ្រឿងញៀន សារជាតិផ្សំគ្រឿងញៀន និងសារធាតុប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត។

## ២.៤.៦. ការនាំចូល និងនាំចេញរូបិយប័ណ្ណបរទេស

### ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ

- ប្រកាសលេខ ០១៣ ប្រក.សហវ.គរ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្តីពីនីតិវិធីក្នុងការនាំចេញ-នាំចូលរូបិយប័ណ្ណបរទេស

### ២.៤.៦.១. ការនាំចូលរូបិយប័ណ្ណ

ការនាំចូលរូបិយប័ណ្ណបរទេសមកក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដោយគណៈប្រតិភូនានា ភ្ញៀវគ្រប់ប្រភេទ នីតិបុគ្គល និងរូបវន្តបុគ្គលដទៃទៀត ហៅកាត់ថា "អ្នកតំណាង" ពុំមានការកម្រិតបរិមាណទេ។ អ្នកដំណើរដែលនាំចូលនូវរូបិយប័ណ្ណបរទេស មានទឹកប្រាក់ស្មើឬលើសពី ១០.០០០ "មួយម៉ឺន" ដុល្លារអាមេរិក ចាំបាច់ត្រូវបំពេញប្រតិវេទន៍គយ តាមនីតិវិធីកំណត់ជាធរមាន ហើយត្រូវប្រគល់ឱ្យមន្ត្រីគយ សម្រាប់ពិនិត្យផ្ទៀងផ្ទាត់នៅពេលនាំចេញទៅវិញ។

### ២.៤.៦.២. ការនាំចេញរូបិយប័ណ្ណ

អ្នកដំណើរដែលនាំចេញ នូវរូបិយប័ណ្ណបរទេសពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា មានទឹកប្រាក់លើសពី ១០.០០០ "មួយម៉ឺន" ដុល្លារអាមេរិក ឬលើសពីចំនួនរូបិយប័ណ្ណបរទេសដែលសាម៉ីខ្លួនបានប្រកាសក្នុងប្រតិវេទន៍គយ នាពេលនាំចូល ត្រូវមានការអនុញ្ញាតឱ្យនាំចេញ ពីធនាគារជាតិនៃកម្ពុជា និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនានា។

### ២.៤.៦.៣. នីតិវិធីនាំចេញរូបិយប័ណ្ណ

អ្នកដំណើរដែលនាំចេញរូបិយប័ណ្ណបរទេស ត្រូវអនុវត្តដូចតទៅ÷

- បង្ហាញចំពោះមន្ត្រីគយ នូវលិខិតអនុញ្ញាតឱ្យនាំចេញដែលផ្តល់ដោយធនាគារជាតិនៃកម្ពុជា
- បំពេញប្រតិវេទន៍គយឱ្យបានត្រឹមត្រូវ គ្រប់គ្រាន់ និងច្បាស់លាស់
- ធ្វើដំណើរតាមមាត់ច្រកចូល-ចេញ ដែលបានកំណត់ដោយភ្នាក់ងារមានសមត្ថកិច្ច។ ការយករូបិយប័ណ្ណធ្វើដំណើរតាមច្រកផ្លូវផ្សេង ឬ ដោយអ្នកកាន់បញ្ញើដ៏ទៃ ក្រៅពីម្ចាស់កម្មសិទ្ធិត្រូវហាមឃាត់ជាដាច់ខាត
- បំពេញជាលាយលក្ខណ៍អក្សរឱ្យបានត្រឹមត្រូវ គ្រប់គ្រាន់ និងច្បាស់លាស់លើប្រតិវេទន៍គយ អំពីប្រភេទ និងចំនួនរូបិយប័ណ្ណ ដែលមានជាប់នឹងខ្លួន បញ្ញើជាមួយអ្នកដ៏ទៃ បញ្ញើតាមយន្តហោះ ដើម្បីបង្ហាញដល់មន្ត្រីគយដែលមានភារកិច្ចត្រួតពិនិត្យ នៅក្នុងការិយាល័យគយនិងរដ្ឋាករ។

## ២.៤.៧. ការនាំចូលនិងនាំចេញសាកសព

### ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ

- លិខិតលេខ ៦៧៣៨ កបទ.សអ/ច្ប.ក៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីការអនុញ្ញាតនាំយកសាកសពជនបរទេសចេញពីព្រះរាជាណាចក្រកម្ពុជា

- ការនាំចូលសាកសព ពីក្រៅប្រទេសចូលមកកម្ពុជា ក្រុមគ្រួសារសព ត្រូវភ្ជាប់ឯកសារពីស្ថានទូតកម្ពុជាតាំងនៅក្នុងប្រទេសនៃសពទទួលមរណៈភាព និង ភ្ជាប់ជាមួយកំណត់ហេតុ ឬមូលហេតុនៃសាកសពស្លាប់នៃប្រទេសនាំចេញ

- ការនាំយកសាកសពជនជាតិរបស់ខ្លួន ឬក្រុមគ្រួសារដែលបានទទួលមរណៈភាពនៅក្នុងប្រទេសកម្ពុជា ដោយសារជំងឺ គ្រោះថ្នាក់ចរាចរ ឬ ករណីផ្សេងទៀត ត្រូវស្នើសុំទៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ នៃប្រទេសកម្ពុជាជាមុន មុននឹងធ្វើការអនុញ្ញាតិឲ្យនាំយកសាកសពជនបរទេសចេញពីព្រះរាជាណាចក្រកម្ពុជា។

## ២.៤.៨. ការសម្រុះសម្រួលបទល្មើសគយ

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ**

- ប្រកាសលេខ ៦១៨ សហវ.ប្រក.គរ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីការសម្រុះសម្រួលបទល្មើសគយ
- ប្រកាសលេខ ៥៧០ សហវ.ប្រក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១០ ស្តីពីនីតិវិធីតវ៉ាប្រឆាំងកំណត់ហេតុគយ

រដ្ឋបាលគយមានសិទ្ធិសម្រុះសម្រួលចំពោះបទល្មើសគយ តាមបញ្ញត្តិមាត្រា ៧៧ នៃច្បាប់ស្តីពីគយ។ សិទ្ធិសម្រុះសម្រួលនេះ ប្រើប្រាស់ចំពោះតែការពិន័យជាប្រាក់តែប៉ុណ្ណោះ។

### ២.៤.៨.១. សិទ្ធិរដ្ឋបាលគយក្នុងការសម្រុះសម្រួលបទល្មើសគយ

- ប្រធានការិយាល័យគយនិងរដ្ឋាករមានសិទ្ធិសម្រុះសម្រួល បទល្មើស គយ គ្រប់ ប្រភេទពាក់ព័ន្ធនឹងទំនិញដែលមានតម្លៃមិនលើសពីមួយលានប្រាំសែន (១.៥០០.០០០) រៀល
- ប្រធានសាខា ឬប្រធាននាយកដ្ឋានគយនិងរដ្ឋាករ មានសិទ្ធិសម្រុះសម្រួលបទល្មើសគយគ្រប់ប្រភេទពាក់ព័ន្ធនឹងទំនិញដែលមានតម្លៃមិនលើសពីបួនលាន (៤.០០០.០០០) រៀល
- អគរ មានសិទ្ធិសម្រុះសម្រួលបទល្មើសគយគ្រប់ប្រភេទ។

### ២.៤.៨.២. នីតិវិធីសម្រុះសម្រួលបទល្មើសគយ

- ក្នុងរយៈពេលសាមសិបថ្ងៃ (៣០) ថ្ងៃ គិតពីកាលបរិច្ឆេទក្នុងកំណត់ហេតុបទល្មើសគយ ឬកំណត់ហេតុគយផ្សេងទៀត បុគ្គលដែលពាក់ព័ន្ធនឹងកំណត់ហេតុទាំងនេះ ត្រូវចូលខ្លួនមកសម្រុះសម្រួល ប្រសិនបើមានបំណងសម្រុះសម្រួលករណីនេះដោយមិនបាច់បញ្ជូនសំណុំរឿងទៅតុលាការមានសមត្ថកិច្ច។ សិទ្ធិសម្រុះសម្រួល និងការកំណត់ពេលវេលានេះ ត្រូវចែងនៅក្នុងកំណត់ហេតុបទល្មើសគយ ឬកំណត់ហេតុផ្សេងទៀត។ ប្រសិនបើ ក្នុងរយៈពេលកៅសិបថ្ងៃ (៩០) ថ្ងៃ គិតពីកាលបរិច្ឆេទក្នុងកំណត់ហេតុល្មើសគយ ឬកំណត់ហេតុផ្សេងទៀត សេចក្តីសម្រេចជាផ្លូវការស្តីពីការសម្រុះសម្រួលនូវបទល្មើសគយមិនអាចធ្វើទៅបាន រដ្ឋបាលគយត្រូវបញ្ជូនសំណុំរឿងទៅតុលាការមានសមត្ថកិច្ច
- បុគ្គលពាក់ព័ន្ធត្រូវអនុវត្តតាមកម្រិតកំណត់ និងល័ក្ខខ័ណ្ឌនានានៃសេចក្តីសម្រេចផ្លូវការស្តីពីការសម្រុះសម្រួលបទល្មើសគយ រាប់បញ្ចូលទាំងការបង់ប្រាក់ពិន័យ ពន្ធ និងអាករដែលត្រូវជាប់ និងកាតព្វកិច្ចផ្សេងទៀតដែលមានចែងក្នុងសេចក្តីសម្រេច ក្នុងរយៈពេលកៅសិបថ្ងៃ (៩០) ថ្ងៃគិតពីកាលបរិច្ឆេទនៃសេចក្តីសម្រេច។ ប្រសិន

បើបុគ្គលពាក់ព័ន្ធខកខានអនុវត្តតាមកម្រិតកំណត់និងល័ក្ខខ័ណ្ឌនានានៃសេចក្តីសម្រេចក្នុងរយៈពេលកំណត់នេះ ទំនិញដែលជាកម្មវត្ថុនៃសេចក្តីសម្រេចផ្លូវការនេះត្រូវចាត់ទុកជាទំនិញគ្មានការទាមទារតាមបញ្ញត្តិមាត្រា ៥៤ និងមាត្រា ៥៥ នៃច្បាប់ស្តីពីគយ។

### ២.៤.៨.៣. នីតិវិធីតវ៉ាប្រឆាំងកំណត់ហេតុគយ

- បុគ្គលដែលត្រូវរងនូវទោសទណ្ឌ ឬ ការឃាត់ទុកនូវទំនិញ មធ្យោបាយដឹកជញ្ជូន ឬវត្ថុផ្សេងទៀត អាចតវ៉ាជាលាយល័ក្ខណ៍អក្សរទៅ អគយ ក្នុងអំឡុងពេលសាមសិប (៣០) ថ្ងៃ ក្រោយពីបានទទួលសេចក្តីជូនដំណឹងពីទោសទណ្ឌ ឬ ការឃាត់ទុក ដោយបញ្ជាក់ ពីមូលហេតុនៃការតវ៉ា និងតម្កល់និមុត្តិធានាស្របតាមបញ្ញត្តិមាត្រា ៤៧ នៃច្បាប់ស្តីពីគយ
- អគយ ត្រូវចេញសេចក្តីសម្រេចជាលាយល័ក្ខណ៍អក្សរលើការតវ៉ាក្នុងអំឡុងពេលហុកសិបថ្ងៃ (៦០) ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលពាក្យតវ៉ា បើមិនដូច្នោះទេ ការតវ៉ានោះត្រូវចាត់ទុកថាបានទទួលយល់ព្រម
- ការតវ៉ាអាចត្រូវតម្កល់នៅតាមអង្គភាពគយនានាដូចជា (១)ការិយាល័យដែលគាត់តែងកំណត់ហេតុ ឬកំណត់ការពិន័យ(២)សាខាគយ និងរដ្ឋាករពាក់ព័ន្ធ (៣)ការិយាល័យកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈ ឬ (៤) លេខាធិការដ្ឋាននៃ អគយ ។ បន្ទាប់ពីបានទទួលការតវ៉ា អង្គភាពគយពាក់ព័ន្ធត្រូវបញ្ជូនលិខិតសុំតវ៉ាដោយមិនបង្អែបង្អង់ជូន អគយ
- លិខិតសុំតវ៉ាត្រូវមានព័ត៌មានដូចតទៅ (១)នាម អាសយដ្ឋាន និងហត្ថលេខារបស់បុគ្គលដែលតម្កល់ការតវ៉ា (២)សេចក្តីលម្អិតនៃកំណត់ហេតុបទល្មើសគយ ឬ កំណត់ហេតុឃាត់ទុកបណ្តោះអាសន្ន រាប់បញ្ចូលទាំងសេចក្តីថតចម្លងកំណត់ហេតុទាំងនោះ និង (៣)សេចក្តីពន្យល់អំពីមូលហេតុនៃការតវ៉ា
- ប្រសិនបើទំនិញឃាត់ទុកបណ្តោះអាសន្ន មិនជាប់អាយ័តទំនិញ មធ្យោបាយ ដឹកជញ្ជូន ឯកសារ និងវត្ថុចាប់ឃាត់ផ្សេងទៀតមិនតម្រូវសម្រាប់ជាភស្តុតាង វត្ថុឃាត់ទុកទាំងនេះអាចត្រូវបានប្រគល់ទៅម្ចាស់ ក្រោយពេលបានតម្កល់និមុត្តិធានា
- ប្រសិនបើ អគយ មិនយល់ព្រមតាមការតវ៉ាទេ បុគ្គលដែលបានដាក់ពាក្យតវ៉ា មានសិទ្ធិតវ៉ាទៅស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត រាប់បញ្ចូលទាំងតុលាការ មានសមត្ថកិច្ច ចំពោះការសម្រេចរបស់ អគយ។ ការតវ៉ានេះត្រូវធ្វើក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីសម្រេចរបស់ អគយ។

ជំពូក

# ៣ នីតិវិធីផ្សេងទៀតអនុលោមតាមច្បាប់និងបទប្បញ្ញត្តិរបស់ក្រសួងពាក់ព័ន្ធ

## ៣.១. អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងវិញ្ញាបនបត្រ

អ្នកនាំចេញ ត្រូវផ្តល់ឯកសារបន្ថែមសម្រាប់ទំនិញទាំងឡាយណាដែលរាជរដ្ឋាភិបាលកម្ពុជាកំណត់ថាជាផលិតផលរសើប ឬ ទំនិញដែលត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការឃ្លាំមើលសម្រាប់ការធ្វើពាណិជ្ជកម្ម។ តារាងខាងក្រោមបង្ហាញពីប្រភេទនៃអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬ វិញ្ញាបនបត្រ ដែលជាឯកសារចាំបាច់សម្រាប់ការនាំចេញទំនិញមួយចំនួន និងអាជ្ញាធរមានសមត្ថកិច្ចដែលទទួលបន្ទុកក្នុងការចេញលិខិតទាំងនេះ។

***សំគាល់*** ៖ សិប្បកម្មថ្មីដែលទំនិញធ្វើពីស្ពូត្រ មិនតម្រូវឲ្យមានឯកសារបន្ថែមឡើយ លើកលែងតែទំនិញទាំងនេះ ជាផ្នែកមួយនៃគ្រឿងប្រាក់ ឬ ទំនិញនោះជាវត្ថុសិល្បៈ និងបេតិកភណ្ឌជាតិ។

**អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងវិញ្ញាបនបត្រ**

| | ប្រភេទទំនិញ | ឯកសារ | អាជ្ញាធរមានសមត្ថកិច្ច |
|---|---|---|---|
| **អាជ្ញាប័ណ្ណនាំចេញ** | កៅស៊ូធម្មជាតិ | - អាជ្ញាប័ណ្ណនាំចេញ សុពលភាព÷៦០ថ្ងៃ | - ក្រសួងពាណិជ្ជកម្ម |
| | ផល និងអនុផលព្រៃឈើ | - អាជ្ញាប័ណ្ណនាំចេញ សុពលភាព÷៦០ថ្ងៃ<br>- លិខិតអនុញ្ញាត | - ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងកសិកម្ម<br>- រុក្ខាប្រមាញ់ និងនេសាទ<br>- ទីស្តីការគណៈរដ្ឋមន្ត្រី |

| | ប្រភេទទំនិញ | ឯកសារ | អាជ្ញាធរមានសមត្ថកិច្ច |
|---|---|---|---|
| **វិញ្ញាបនបត្រ** | ផ្លែឈើស្រស់ បន្លែ រុក្ខជាតិ សម្ភារធ្វើកសិកម្ម (ថ្នាំសម្លាប់សត្វល្អិត គ្រាប់ពូជ សម្ភារបណ្ដុះកូនរុក្ខជាតិ និងចំណីសត្វ) | - លិខិតអនុញ្ញាត<br>- គយនិងរដ្ឋាករ<br>- វិញ្ញាបនប័ត្រអនាម័យ និងភូតគាមអនាម័យ (SPS) | - អគរ<br>- ក្រសួងកសិកម្ម<br>- រុក្ខាប្រមាញ់ និងនេសាទ |
| | សម្លៀកបំពាក់ | វិញ្ញាបនបត្រប្រភពដើមទំនិញ សុពលភាព ÷ ៦ខែ | - ក្រសួងពាណិជ្ជកម្ម |
| | ថ្នាំពេទ្យ | វិញ្ញាបនបត្ររបស់ក្រសួងសុខាភិបាល | - ក្រសួងសុខាភិបាល |
| | សត្វរស់ | វិញ្ញាបនបត្រសុខភាពសត្វ សុពលភាព ÷ ៥ឆ្នាំ ឬ វិញ្ញាបនបត្រ CITES | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| **លិខិតអនុញ្ញាត** | ផលិតផលសិល្បៈ និងវប្បធម៌ | លិខិតអនុញ្ញាត | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| | ផល និងផលិតផលជលផល | - លិខិតអនុញ្ញាត សុពលភាព ÷ ១ឆ្នាំ<br>- វិញ្ញាបនបត្រប្រភពដើមទំនិញ<br>- លិខិតអនុញ្ញាតិគយ | - ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- អគរ |
| | គ្រឿងអលង្ការ គ្រឿងប្រាក់ និងត្បូងមានតម្លៃមិនទាន់កែច្នៃ | លិខិតអនុញ្ញាត សុពលភាព÷ ១ឆ្នាំ | ធនាគារជាតិនៃកម្ពុជា |

ប្រភពព័ត៌មាន ÷ សៀវភៅមគ្គុទេសក៍ស្ដីពីនីតិវិធីនៃការនាំចេញសម្រាប់សហគ្រាសខ្នាតតូចនិងមធ្យមនៅកម្ពុជា (ខែមករា ឆ្នាំ២០០៩)

# ៣.២. វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ

## ៣.២.១. សេចក្តីផ្តើម

វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ គឺជាឯកសារផ្លូវការមួយ ប្រើដើម្បីបញ្ជាក់ ពីប្រភពដើមទំនិញដែលបានផលិត ឬ បានទទួលទាំងស្រុង នៅក្នុងប្រទេសមួយ។ ជាទូទៅឯកសារនេះ គឺជាផ្នែកស្នូលនៃឯកសារ នាំចូលដែលប្រទេសនាំចូលបានតម្រូវ។

នៅពេលអនុវត្តទម្រង់ការទាំងឡាយ សម្រាប់នាំចេញទំនិញ ក្រោមប្រព្រឹត្តិកម្ម អនុគ្រោះ អ្នកនាំចេញ ឬតំណាងទទួលសិទ្ធិរបស់ខ្លួន ត្រូវដាក់ពាក្យ ជាលាយលក្ខណ៍អក្សរ ស្នើសុំវិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ ដោយភ្ជាប់មកជាមួយ នូវឯកសារគាំទ្រ ត្រឹមត្រូវ ដែលបង្ហាញថា ទំនិញដែលត្រូវនាំចេញ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការចេញ វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ។

វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ មានពីរប្រភេទ គឺ÷

- មិនទទួលបានភាពអនុគ្រោះពន្ធ និង
- ទទួលបានភាពអនុគ្រោះពន្ធ។

## ៣.២.២. ប្រទេសដែលតម្រូវឲ្យមានវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ

កម្ពុជាវិញ្ញាបនបត្របញ្ជាក់ ប្រភពដើមទំនិញ ទទួលបានអត្រាពន្ធអនុគ្រោះក្នុងទម្រង់ផ្សេងៗ ដូចជា÷

- អាស៊ាន-អូស្ត្រាលី-ញ៉ូវហ្ស៊ីលែន ÷ វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ ទម្រង់ AANZ
- ចិន ÷ វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ ទម្រង់ AC
- ឥណ្ឌា ÷ វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ ទម្រង់ AI
- កូរ៉េ ÷ វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ ទម្រង់ AK
- ជប៉ុន ÷ វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ ទម្រង់ AJ
- វៀតណាម ÷ វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញទម្រង់ S
- ប្រព័ន្ធអនុគ្រោះទូទៅ ផ្នែកពាណិជ្ជកម្ម (LDC និង LLDC) ÷ វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ A
- អត្រាពន្ធមិនអនុគ្រោះ អាចចេញបាន ដោយប្រើវិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ ទម្រង់ N

## ៣.២.៣. របៀបដាក់ពាក្យស្នើសុំ វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ

អ្នកនាំចេញចាំបាច់ ត្រូវដាក់ពាក្យស្នើសុំ វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ នៅនាយកដ្ឋាននាំចេញ-នាំចូល នៃក្រសួងពាណិជ្ជកម្ម។ នីតិវិធីនៃការដាក់ពាក្យស្នើសុំវិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ អាចរកបាននៅក្នុងប្រកាសលេខ១១២ MOC/SM 2013 ស្តីពីការកែប្រែនីតិវិធីចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ។ (ប្រការទី៤)

ដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញត្រូវធ្វើតាមបែបបទដូចខាងក្រោម ÷

### ១. ការនាំចេញតាមផ្លូវទឹក

**ក. ទំនិញជាសម្លៀកបំពាក់ ផលិតផលវាយនភ័ណ្ឌ ស្បែកជើង និងរបស់របរប្រើប្រាស់ផ្សេងទៀត (ប្រដាប់តុបតែងកាយ) ដូចជា កាបូប មួកជាដើម។ល។**

- ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញពីក្រុមហ៊ុន
- ច្បាប់ចម្លងប័ណ្ណបើកប្រាក់ (សែក) បញ្ជាក់ពីការទូទាត់កម្រៃរដ្ឋបាល និងកម្រៃគ្រប់គ្រងការនាំចេញ
- វិក្កយបត្រទូទាត់កម្រៃសេវាសាធារណៈ
- វិក្កយបត្រពាណិជ្ជកម្ម
- បញ្ជីវេចខ្ចប់
- អញ្ញាតប័ណ្ណដឹកជញ្ជូន (Bill of Lading)
- របាយការណ៍ត្រួតពិនិត្យរួមនៃទំនិញវាយនភ័ណ្ឌនាំចេញ ចេញដោយ អគរ និងកាំកុងត្រូល
- ប្រតិវេទន៍គយនាំចេញពីកម្ពុជា
- លិខិតបញ្ជាក់អ្នកតំណាងរបស់ក្រុមហ៊ុន

**ខ. ផលិតផលផ្សេងទៀតក្រៅពីសម្លៀកបំពាក់ វាយនភ័ណ្ឌ ស្បែកជើង និងប្រដាប់តុបតែងកាយ**

- ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញពីក្រុមហ៊ុន
- ច្បាប់ចម្លងប័ណ្ណបើកប្រាក់ (សែក) បញ្ជាក់ពីការទូទាត់កម្រៃរដ្ឋបាល និងកម្រៃគ្រប់គ្រងការនាំចេញ
- វិក្កយបត្រទូទាត់កម្រៃសេវាសាធារណៈ
- វិក្កយបត្រពាណិជ្ជកម្ម
- បញ្ជីវេចខ្ចប់
- អញ្ញាតប័ណ្ណដឹកជញ្ជូន (Bill of Lading)
- ប្រតិវេទន៍គយនាំចេញពីកម្ពុជា
- វិញ្ញាបនបត្របញ្ជាក់គុណភាពទំនិញនាំចេញ ចេញដោយកាំកុងត្រូល (CQ)
- ប្រតិវេទន៍គយ ចេញដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករនៃកម្ពុជា (CD)
- ឯកសារផ្សេងទៀតរបស់ក្រុមហ៊ុនដែលអាចបញ្ជាក់ពីប្រភពដើមនៃទំនិញ
- អាជ្ញាប័ណ្ណនាំចេញ (សម្រាប់ទំនិញដែលទាមទារឲ្យមានអាជ្ញាប័ណ្ណនាំចេញ)
- លិខិតបញ្ជាក់អ្នកតំណាងរបស់ក្រុមហ៊ុន

**គ. ទំនិញជាសិប្បកម្មតូចៗ និងកសិកម្ម**

- ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញពីក្រុមហ៊ុន
- ច្បាប់ចម្លងប័ណ្ណបើកប្រាក់(សែក) បញ្ជាក់ពីការទូទាត់កម្រៃរដ្ឋបាល និងកម្រៃគ្រប់គ្រងការនាំចេញ ប្រសិនមានការទាមទារដោយបទប្បញ្ញត្តិណាមួយ
- វិក្កយបត្រពាណិជ្ជកម្ម
- បញ្ជីវេចខ្ចប់

- អញ្ញាតប័ណ្ណដឹកជញ្ជូន (Bill of Lading)
- ប្រតិវេទន៍នាំចេញពីកម្ពុជា
- វិញ្ញាបនបត្របញ្ជាក់គុណភាពទំនិញនាំចេញ ចេញដោយកំពុងត្រួល (CQ)
- ប្រតិវេទន៍គយ ចេញដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករនៃកម្ពុជា (CD)
- ឯកសារផ្សេងទៀតរបស់ក្រុមហ៊ុនដែលអាចបញ្ជាក់ពីប្រភពដើមនៃទំនិញ (ករណីអង្ករ និងផលិតផលកសិកម្មដែលជាផលិតផលរសើប)
- អាជ្ញាប័ណ្ណនាំចេញ (សម្រាប់ទំនិញដែលទាមទារឱ្យមានអាជ្ញាប័ណ្ណនាំចេញ)
- លិខិតបញ្ជាក់អ្នកតំណាងរបស់ក្រុមហ៊ុន

### ឃ. ទំនិញជាសម្លៀកបំពាក់មានព័ណ៌ចម្រុះ ព័ណ៌បៃតង (ព័ណ៌បៃតងចាស់) និងព័ណ៌បៃតងបែបទាហាន

**បែបបទនិងឯកសារតម្រូវសម្រាប់នាំចេញ និងនាំចូលទំនិញប្រភេទនេះ ត្រូវគោរពតាមប្រកាសរបស់ក្រសួងពាណិជ្ជកម្មជាធរមាន។**

## ២. ការនាំចេញតាមផ្លូវអាកាស

### ក. ទំនិញជាសម្លៀកបំពាក់ ផលិតផលវាយនភ័ណ្ឌ ស្បែកជើង និងរបស់របរប្រើប្រាស់ផ្សេងទៀត (ប្រដាប់តុបតែងកាយ) ដូចជា កាបូប មួក ជាដើម។ល។

- ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញពីក្រុមហ៊ុន
- ច្បាប់ចម្លងប័ណ្ណបើកប្រាក់ (សែក) បញ្ជាក់ពីការទូទាត់កម្រៃរដ្ឋបាល និងកម្រៃគ្រប់គ្រងការនាំចេញ
- វិក្កយបត្រទូទាត់កម្រៃសេវាសាធារណៈ
- វិក្កយបត្រពាណិជ្ជកម្ម
- បញ្ជីវេចខ្ចប់
- លិខិតបញ្ជាក់អ្នកតំណាងរបស់ក្រុមហ៊ុន

**បន្ទាប់ពីនាំចេញទំនិញរួចហើយ ត្រូវដាក់ឯកសារបន្ថែមទៀតដូចជា ៖**

- អញ្ញត្តិប័ណ្ណដឹកជញ្ជូនតាមអាកាស
- របាយការណ៍ត្រួតពិនិត្យរួមលើទំនិញវាយនភ័ណ្ឌនាំចេញ ដោយ អគរ និងកាំកុងត្រូល
- ប្រតិវេទន៍គយនាំចេញពីកម្ពុជា

### ខ. ទំនិញជាសិប្បកម្មតូចៗ និងកសិកម្ម

- ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញពីក្រុមហ៊ុន
- ច្បាប់ចម្លងប័ណ្ណបើកប្រាក់(សែក) បញ្ជាក់ពីការទូទាត់កម្រៃរដ្ឋបាល និងកម្រៃគ្រប់គ្រងការនាំចេញ ប្រសិនមានការតម្រូវដោយបទប្បញ្ញត្តិណាមួយ
- វិក្កយបត្រពាណិជ្ជកម្ម
- បញ្ជីវេចខ្ចប់
- លិខិតបញ្ជាក់អ្នកតំណាងរបស់ក្រុមហ៊ុន

**បន្ទាប់ពីនាំចេញទំនិញរួចហើយ ត្រូវដាក់ឯកសារបន្ថែមទៀតដូចជា ៖**

- អញ្ញតប័ត្រដឹកជញ្ជូនតាមអាកាស
- របាយការណ៍ត្រួតពិនិត្យរួមលើទំនិញវាយនភ័ណ្ឌនាំចេញ ដោយ អគរ និងកាំកុងត្រូល
- ប្រតិវេទន៍គយនាំចេញពីកម្ពុជា

## ៣. ទំនិញជាសម្លៀកបំពាក់ ផលិតផលវាយនភណ្ឌ និងផលិតផលធ្វើពីស្បែក និងផលិតផលដែលដឹកជញ្ជូនតាមផ្លូវគោកឆ្លងកាត់ព្រំប្រទល់ប្រទេសកម្ពុជា ដើម្បីដឹកជញ្ជូនបន្តទៀតនៅពេលក្រោយ តាមផ្លូវអាកាសក្នុងប្រទេសជិតខាង (ផ្លូវគោក-ផ្លូវអាកាស)

- ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញពីក្រុមហ៊ុន
- ច្បាប់ចម្លងប័ណ្ណបើកប្រាក់ (សែក) បញ្ជាក់ពីការទូទាត់កម្រៃរដ្ឋបាល និងកម្រៃគ្រប់គ្រងការនាំចេញ

- វិក្កយបត្រទូទាត់កម្រៃសេវាសាធារណៈ
- វិក្កយបត្រពាណិជ្ជកម្ម
- បញ្ជីវេចខ្ចប់
- របាយការណ៍ ចេញ ដោយ មន្ត្រី ត្រួតពិនិត្យ ផលិតផល និងផលិតិផលនាំចេញតម្រូវឱ្យ ធ្វើការត្រួតពិនិត្យយ៉ាងហោចណាស់៥០%នៃ ទំនិញនាំចេញសរុប(ចំពោះការនាំចេញទំនិញ បរិមាណច្រើន) និងតម្រូវឱ្យធ្វើការត្រួតពិនិត្យ យ៉ាងហោចណាស់២០%នៃទំនិញនាំចេញសរុប ចំពោះការនាំចេញទំនិញបរិមាណតិច ដែល រោងចក្រអាចផលិតបានក្នុងរយៈពេល២ថ្ងៃ។
- លិខិតបញ្ជាក់អ្នកតំណាងរបស់ក្រុមហ៊ុន

ក្នុងអំឡុងពេល៣០ថ្ងៃ យ៉ាងយូរ បន្ទាប់ពីទទួលបាន វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ អ្នកនាំចេញ ត្រូវដាក់នូវឯកសារដូចខាងក្រោម ÷

- អញ្ញត្តិប័ណ្ណដឹកជញ្ជូនតាមអាកាស
- របាយការណ៍ត្រួតពិនិត្យរួមលើទំនិញវាយនភ័ណ្ឌ នាំចេញ ដោយ អគរ និងកាំកុងត្រូល
- ប្រតិវេទន៍គយនាំចេញពីកម្ពុជា

## ៤. ការនាំចេញតាមផ្លូវគោក

### ក. ទំនិញជាសម្លៀកបំពាក់ ផលិតផលវាយនភ័ណ្ឌ ស្បែកជើង និងរបស់របរប្រើប្រាស់ផ្សេងទៀត (ប្រដាប់តុបតែងកាយ) ដូចជា កាបូប មួក ជាដើម ÷

- ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើម ទំនិញពីក្រុមហ៊ុន
- ច្បាប់ចម្លងប័ណ្ណបើកប្រាក់ (សែក) បញ្ជាក់ពី ការទូទាត់កម្រៃរដ្ឋបាល និងកម្រៃគ្រប់គ្រងការ នាំចេញ
- វិក្កយបត្រទូទាត់កម្រៃសេវាសាធារណៈ
- វិក្កយបត្រពាណិជ្ជកម្ម
- បញ្ជីវេចខ្ចប់
- របាយការណ៍ត្រួតពិនិត្យរួមលើផលិតផលវាយនភណ្ឌនាំចេញ ដោយ អគរ និងកាំកុងត្រូល
- ប្រតិវេទន៍គយនាំចេញពីកម្ពុជា
- លិខិតបញ្ជាក់អ្នកតំណាងរបស់ក្រុមហ៊ុន

### ខ. ទំនិញជាសិប្បកម្មតូចៗ និងកសិកម្ម

- ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើម ទំនិញពីក្រុមហ៊ុន
- វិក្កយបត្រពាណិជ្ជកម្ម
- បញ្ជីវេចខ្ចប់
- អញ្ញត្តិប័ណ្ណដឹកជញ្ជូនតាមផ្លូវគោក
- ប្រតិវេទន៍នាំចេញពីកម្ពុជា

**បន្ទាប់ពីនាំចេញទំនិញរួចហើយ ត្រូវដាក់ឯកសារបន្ថែមទៀតដូចជា ÷**

- វិញ្ញាបនបត្របញ្ជាក់គុណភាពទំនិញនាំចេញ ដោយកាំកុងត្រូល (CQ)
- ប្រតិវេទន៍គយ ដោយអគ្គនាយកដ្ឋានគយ និង រដ្ឋាករនៃកម្ពុជា (CD)
- ច្បាប់ចម្លងប័ណ្ណបើកប្រាក់(សែក) បញ្ជាក់ពីការ ទូទាត់កម្រៃរដ្ឋបាល
- ឯកសារផ្សេងទៀតរបស់ក្រុមហ៊ុនដែលអាច បញ្ជាក់ពីប្រភពដើមនៃទំនិញ (ករណីអង្ករ និង ផលិតផលកសិកម្មដែលជាផលិតផលរសើប)

**(មាត្រាទី៩)**

ពេលវេលាសរុប ត្រូវបានកំណត់យ៉ាងយូរបំផុត រយៈពេល១៦ម៉ោងនៃម៉ោងធ្វើការ សម្រាប់នាយកដ្ឋាន បច្ចេកទេសនៃក្រសួងពាណិជ្ជកម្ម ការិយាល័យច្រក ចេញចូលតែមួយ នៅក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា និង ការិយាល័យតំណាងក្រសួងពាណិជ្ជកម្មតាំងនៅក្នុង រដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ហើយពេលវេលានៃ ដំណើរការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ នេះ មិនបានគិតបញ្ចូលនូវពេលវេលាសម្រាប់រៀបចំ ឯកសារ និងបែបបទរបស់ក្រុមហ៊ុន ឬ អ្នកតំណាងតាម

ផ្លូវច្បាប់របស់ក្រុមហ៊ុនឡើយ។ ពេលវេលាសរុបខាងលើគឺសម្រាប់បម្រុងបន្ថែមពីលើពេលវេលាមូលដ្ឋានរបស់មន្ត្រីរាជការ ពាក់ព័ន្ធទៅនឹងការងារផលិតផល និងអាចនឹងត្រូវកែសម្រួលជាថ្មីដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក្នុងករណីប្រព័ន្ធស្វ័យប្រព្រឹត្តិកម្មនៃការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញត្រូវបានណែនាំជាផ្លូវការ។

**(ប្រការទី៦)**

ការត្រួតពិនិត្យផលិតផល និងទំនិញនាំចេញ ត្រូវធ្វើឡើងដោយមន្ត្រីបច្ចេកទេសនៃក្រសួងពាណិជ្ជកម្ម នៅទីតាំងផលិតកម្ម នៅកន្លែងប្រមូលទំនិញ ឬ នៅឃ្លាំងទំនិញ ទៅតាមការស្នើសុំពីសំណាក់ក្រុមហ៊ុន ឬ អ្នកនាំចេញ តាមភាពចាំបាច់កំណត់ដោយនាយកដ្ឋានបច្ចេកទេស ដែលក្នុងនោះ ÷

- សម្រាប់ទំនិញកសិកម្ម និងផលិតផលកែច្នៃសម្រាប់ផលិត÷ ការត្រួតពិនិត្យត្រូវធ្វើឡើងឲ្យបានមុនការស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ។ ប្រសិនបើចាំបាច់ ក្រុមហ៊ុន ឬ អ្នកនាំចេញដែលធ្លាប់ទទួលបានការអនុញ្ញាតនាំចេញច្រើនដងពីមុនមកហើយ អាចធ្វើការស្នើសុំទៅរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មដើម្បីសុំការត្រួតពិនិត្យក្រោយការស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ។
- សម្រាប់ទំនិញជាសម្លៀកបំពាក់ ផលិតផលវាយនភណ្ឌ ដែលធ្វើអំពីស្បែក ÷ ការត្រួតពិនិត្យត្រូវធ្វើឡើង បន្ទាប់ពីការស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ តែមិនឲ្យលើសពី ៣០ថ្ងៃ រាប់ចាប់ពីថ្ងៃចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ។

**(ប្រការទី៧)**

ការប្រមូលចំណូលពីកម្រៃរដ្ឋបាល ត្រូវធ្វើឡើងដោយប័ណ្ណបើកប្រាក់ (សែក) នៅនាយកដ្ឋានគណនេយ្យនៃក្រសួងពាណិជ្ជកម្ម អនុលោមតាមប្រកាសរួមលេខ៩៨៥ ក្រ.ស.ហ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីសេវាសាធារណៈផ្តល់ដោយក្រសួងពាណិជ្ជកម្ម។

ការប្រមូលចំណូលពីកម្រៃគ្រប់គ្រងការនាំចេញ (EMF) ត្រូវធ្វើឡើងគោរពតាមប្រកាសរួមរវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាធរមាន។

**(ប្រការទី៨)**

ការទូទាត់កម្រៃសេវាសាធារណៈ ត្រូវគោរពតាមប្រកាសរួមលេខ៩៨៥ ក្រ.ស.ហ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីសេវាសាធារណៈផ្តល់ដោយក្រសួងពាណិជ្ជកម្ម។

**(ប្រការទី៩)**

អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ មានតួនាទីជាចំណុចស្នូល ដោយមាននាយកដ្ឋានអនុគ្រោះពន្ធពាណិជ្ជកម្ម (Trade Preferences Department) ជាអ្នកពិនិត្យ ស្រាវជ្រាវ និងបញ្ជាក់នូវភាពត្រឹមត្រូវនៃវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញប្រសិនបើមានសំណួរពីប្រទេសនាំចូល។ នីតិវិធីលម្អិតពាក់ព័ន្ធទៅនឹងការត្រួតពិនិត្យ និងការរៀបចំបញ្ជាក់ឯកសារ នឹងត្រូវកំណត់ដោយប្រកសាដោយឡែកនៃក្រសួងពាណិជ្ជកម្ម។

**(ប្រការទី១០)**

នីតិវិធីនៃការបន្សុីគ្នានូវស្តុករវាងវត្ថុធាតុដើមនាំចូល និងទំនិញនាំចេញ ត្រូវធ្វើឡើងនៅនាយកដ្ឋានអនុគ្រោះពន្ធពាណិជ្ជកម្ម អនុលោមតាមអនុក្រឹតលេខ៩១ អនក្រ.បក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ តាមសេចក្តីណែនាំរបស់ក្រសួងពាណិជ្ជកម្ម លេខ០០៥១ ក្រព/សម ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ និងគោលការណ៍សម្រួលពាណិជ្ជកម្ម នៃរាជរដ្ឋាភិបាល។

**(ប្រការទី១១)**

អ្នកនាំចេញត្រូវរួសរាន់ដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ និងបំពេញកាតព្វកិច្ចបង់ប្រាក់ចូលថវិកាជាតិ មិនឲ្យលើសពីសាម (៣០)ថ្ងៃ បន្ទាប់ពីទំនិញត្រូវបាននាំចេញ រាប់ចាប់ពីថ្ងៃដែលបានកត់ត្រាចូលក្នុងរបាយការណ៍ត្រួតពិនិត្យរួម ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករ នឹងអគ្គនាយកដ្ឋានកាំកុងត្រូល។

អ្នកនាំចេញដែលយឺតយ៉ាវក្នុងការបំពេញបែបបទស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ត្រូវទទួលការផាកពិន័យ ឬ ផ្អាកការនាំចេញជាបណ្ដោះអាសន្ន។ ក្រសួងពាណិជ្ជកម្មនឹងធ្វើការពិនិត្យមើលលទ្ធភាពថាអាចអនុញ្ញាតម្ដងទៀតដែរឬ ទេចំពោះការនាំចេញនៅពេលអ្នកនាំចេញបានបំពេញបែបបទស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ និងបានទូទាត់បំណុលចូលក្នុងថវិកាជាតិ ព្រមទាំងបង់ប្រាក់ពិន័យរួចរាល់។

## ៣.២.៤. តម្លៃសេវានៃការដាក់ពាក្យ ស្នើសុំវិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ

ជាទូទៅក្រុមហ៊ុនទាំងឡាយ ដែលដាក់ពាក្យស្នើសុំ វិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ ចាំបាច់ត្រូវបង់ តម្លៃសេវាសាធារណៈ និងសេវាគ្រប់គ្រងការនាំចេញ (Export Mangement Fee-EMF) ដូចមានបង្ហាញជូន ខាងក្រោមនេះ÷

| C/O | តម្លៃសេវាសាធារណៈ | តម្លៃ EMF |
|---|---|---|
| ទម្រង់N | 38 ដុល្លា | យោងឧបសម្ព័ន្ធទី១ប្រកាស១៦៤៣ សហវ.ប្រក. ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកែប្រែកម្រងសេវាសាធារណៈ |
| ទម្រង់A | 58 ដុល្លា | |
| ទម្រង់ផ្សេងៗ | 58 ដុល្លា | |

សម្រាប់ផលិតផល សម្លៀកបំពាក់ ក្រោម ចំនួន ២.០០០ ឬ គ្រឿងពាក់នៅនឹងជើង ក្រោម ២០០ គូ

| C/O | តម្លៃសេវាសាធារណៈ | តម្លៃ EMF |
|---|---|---|
| ទម្រង់N | 18 ដុល្លា | យោងឧបសម្ព័ន្ធទី១ប្រកាស១៦៤៣ សហវ.ប្រក. ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកែប្រែកម្រងសេវាសាធារណៈ |
| ទម្រង់A | 23 ដុល្លា | |
| ទម្រង់ផ្សេងៗ | 23 ដុល្លា | |

EMF ប្រែប្រួលតាមផលិតផល និងការលើកលែង ចំពោះការនាំចេញផលិតផល គិតតាមតម្លៃក្រោម ៦.០០០អឺរ៉ូ សម្រាប់បណ្ដាប្រទេសអឺរ៉ុប និងក្រោម ៨០០ដុល្លារសហរដ្ឋអាមេរិក សម្រាប់បណ្ដាប្រទេស ផ្សេងទៀត។

## ៣.២.៥. កាលវិភាគដំណើរការ ប្រព័ន្ធស្វ័យប្រវត្តិកម្ម

ក្រសួងពាណិជ្ជកម្ម បង្កើតប្រព័ន្ធស្វ័យប្រវត្តិកម្មនេះឡើង ដើម្បីសម្របសម្រួលវិស័យឯកជន។ ផ្នែកមួយសំខាន់ ក្នុងចំណោម ផ្នែកសំខាន់ៗ ជាច្រើននៃប្រព័ន្ធស្វ័យប្រវត្តិកម្ម គឺការដាក់ពាក្យ ស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ តាមអនឡាញ។ ការដាក់ពាក្យស្នើសុំ វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញតាមអនឡាញ ឋិតក្នុងដំណើរការសាកល្បង ចាប់ពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៤ សម្រាប់ក្រុមហ៊ុនទាំងឡាយដែលចុះឈ្មោះ ក្នុងគម្រោងសាកល្បងនេះ។ ប្រព័ន្ធស្វ័យប្រវត្តិកម្ម នៃវិញ្ញាបនបត្រ បញ្ជាក់ប្រភពដើមទំនិញ រំពឹងថា នឹងដាក់ឲ្យដំណើរការ ពេញលេញនាឆមាសទី២ ឆ្នាំ២០១៤។ យើងខ្ញុំសូមលើកទឹកចិត្តដល់ក្រុមហ៊ុននាំចេញ ទាំងអស់ អញ្ជើញមកចុះឈ្មោះប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ។

### ៣.២.៦. ព័ត៌មានទំនាក់ទំនង

http://www.moc.gov.kh/en-us/certificate-of-origin

# ៣.៣. វិញ្ញាបនបត្រអនាម័យ និងភូតគាមអនាម័យ

## ៣.៣.១. និយមន័យ

ការទាមទារ សំខាន់បំផុត ក្នុងការ នាំចូល ផលិតផល កសិកម្មនោះ ត្រូវតែមានសុវត្ថិភាព និងបង្កាហានិភ័យ ដល់សុខភាពមនុស្ស សត្វ និងរុក្ខជាតិ។

ដើម្បីឱ្យប្រាកដថា ពិតជាធានាសុវត្ថិភាពអាហារ និង ជៀសវាងបាននូវការឆ្លងរាលដាលជំងឺ សមាសភាពសត្វចង្រៃផ្សេងៗតាមរយៈសកម្មភាពពាណិជ្ជកម្ម រដ្ឋាភិបាលនៃគ្រប់ប្រទេស បានបង្កើតឡើងនូវលិខិតបទដ្ឋានច្បាប់ ដើម្បីការពារសុខភាពមនុស្ស និងសុបភាពសត្វ (វិធានការអនាម័យ/Sanitary Measure) និងដើម្បីការពារសុខភាពរុក្ខជាតិ (វិធានការភូតគាមអនាម័យ/Phytosanitary Measure)។

ការត្រួតពិនិត្យភូតគាមអនាម័យ មានគោលបំណង ដើម្បីទប់ស្កាត់ការរីករាលដាលឆ្លងនូវសមាសភាពចង្រៃភូតគាមអនាម័យ និងសមាសភាពចង្រៃបង្កគ្រោះថ្នាក់ពីតំបន់មួយទៀត ក្នុងព្រះរាជាណាចក្រកម្ពុជា ចូល-ចេញ ឬឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា តាមគ្រប់មធ្យោបាយ ដើម្បីការពារផលិតផលកសិកម្ម និងជីវសាស្ត្រចំរុះ។

ម្ចាស់ទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដែលនាំយក ឬ ដឹកជញ្ជូនចូល-ចេញ ឬឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា ត្រូវសុំការត្រួតពិនិត្យ និងត្រូវគោរពតាមគ្រប់វិធានភូតគាមអនាម័យ។

**បណ្តាវិធានការដែលត្រូវអនុវត្ត**

- ដើម្បីការពារសត្វ រុក្ខជាតិ ឬ សុខភាពនៅក្នុងដែនដីនៃសមាជិក ទល់នឹងហានិភ័យបង្កឡើង ដោយការឆ្លងរាលដាល រាតត្បាតនៃសមាសភាពចង្រៃ ជំងឺសារពាង្គកាយចម្លងជំងឺ ឬ សារពាង្គកាយជាភ្នាក់ងារបង្ករោគ។
- ដើម្បីការពារសុខភាព អាយុជីវិត មនុស្ស សត្វ ដែនដីសមាជិក ទល់នឹងហានិភ័យបង្កឡើង ដោយ គ្រឿងបន្ថែមក្នុងអាហារ បន្សំជាតិពុល ឬ សារពាង្គកាយបង្ករោគក្នុងអាហារ ភេសជ្ជៈ ឬ ចំណីសត្វជាដើម។

## ៣.៣.២. គោលបំណង

- ដើម្បីការពារសុខភាព អាយុជីវិតមនុស្សនៅលើ ដែនដីសមាជិក ទល់នឹងហានិភ័យបង្កឡើង ដោយជំងឺឆ្លងតាមសត្វ តាមរុក្ខជាតិ ឬ ផលិតផលផ្សេងៗ ដោយការឆ្លងរាលដាលនៃសមាសភាពសត្វចង្រៃ។
- ដើម្បីបង្កា ឬ កំណត់ការខូចខាតដទៃទៀតក្នុង ដែនដីសមាជិក ទល់នឹងការឆ្លងរាលដាល និង រាតត្បាតនៃសមាសភាពសត្វចង្រៃ។

### ៣.៣.៣. កិច្ចការពារ

វិធានការអនាម័យ និងភូតគាមអនាម័យ មាចរិតជាការដាក់កំហិតចំពោះពាណិជ្ជកម្មក្នុងកំរិតចាំបាច់មួយត្រឹមតែឲ្យប្រាកដថាពិតជាធានាបាននូវ សុវត្ថិភាពអាហារ សុខភាពសត្វ និងសុខភាពរុក្ខជាតិ។

### ៣.៣.៤. ទំនិញដែលជាកម្មវត្ថុត្រួវត្រួតពិនិត្យភូតគាមអនាម័យ

ទំនិញដែលជាកម្មវត្ថុនៃការត្រួតពិនិត្យរួមមាន ÷

- រុក្ខជាតិ បំណែករុក្ខជាតិ ផលិតផលរុក្ខជាតិ និងផលិតផលកែច្នៃពីផលិតផល
- រុក្ខជាតិដែលអាចជាជម្រក និងចម្លងសមាសភាពចង្រៃ
- សម្ភារវេចខ្ចប់ ឡាំងឈើ កំណាត់ឈើ ឬមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ និងឃ្លាំងសន្និធិ
- ដីឬ ដីដែលជាប់នឹងឫស ឬ បំណែករុក្ខជាតិ
- កត្តាចង្រៃ ឬ សរីរៈមានប្រយោជន៍ រស់ ឬ ងាប់
- ផលិតផលដែលគ្មានដើមកំណើតពីរុក្ខជាតិ តែអាចជាជម្រកនៃសមាសភាពចង្រៃ

### ៣.៣.៥. ដំណើរការស្នើសុំ វិញ្ញាបនបត្រអនាម័យ និងភូតគាមអនាម័យ

វិញ្ញាបនបត្រអនាម័យ និងភូតគាមអនាម័យ (Sanitary and Phytosanitary Certificate-SPS) ជាឯកសារចាំបាច់សម្រាប់ការនាំចេញផ្លែឈើស្រស់ បន្លែស្រស់ រុក្ខជាតិស្រស់ ត្រី សត្វរស់ និងផលិតផលផ្សេងទៀតដែលតម្រូវដោយប្រទេសនាំចូល។ វិញ្ញាបនបត្រនេះបញ្ជាក់ថា ផលិតផលនាំចេញគ្មានផ្ទុកសត្វល្អិតបង្កជំងឺ ឬសត្វល្អិតចង្រៃដែលអាចបំផ្លាញផលដំណាំ។ អ្នកនាំចូលត្រូវទទួលខុសត្រូវក្នុងការបំពេញទៅតាមលក្ខខណ្ឌអនាម័យ និងភូតគាមអនាម័យ។

ទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យមាន ÷

- រុក្ខជាតិ បំណែករុក្ខជាតិ ផលិតផលរុក្ខជាតិ និងផលិតផលកែច្នៃពីផលិតផល
- រុក្ខជាតិដែលអាចជាជម្រក និងចម្លងសមាសភាពចង្រៃ
- សម្ភារវេចខ្ចប់ ឡាំងឈើ កំណាត់ឈើ ឬមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ និងឃ្លាំងសន្និធិ
- ដីឬ ដីដែលជាប់នឹងឫស ឬ បំណែករុក្ខជាតិ
- កត្តាចង្រៃ ឬ សរីរៈមានប្រយោជន៍ រស់ ឬ ងាប់
- ផលិតផលដែលគ្មានដើមកំណើតពីរុក្ខជាតិ តែអាចជាជម្រកនៃសមាសភាពចង្រៃ

បញ្ជីមុខទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

ម្ចាស់ទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យតាមនីតិវិធីដូចខាងក្រោម ÷

- ត្រូវធ្វើប្រតិវេទន៍ទំនិញឲ្យបានត្រឹមត្រូវ
- ត្រូវមានវិញ្ញាបនបត្រភូតគាមអនាម័យ
- ត្រូវវេចខ្ចប់ទំនិញ និងធានាសុវត្ថិភាព មិនឲ្យធ្លុះធ្លាយ ឬ កំពប់រាយប៉ាយតាមផ្លូវក្នុងពេលដឹកជញ្ជូន
- ត្រូវទុកដាក់ ឬ ដឹកទំនិញតាមទិសដៅកំណត់របស់សមត្ថកិច្ចភូតគាមអនាម័យ។ ក្នុងករណីមានការដឹកជញ្ជូន រក្សាទុក ឬ ដាក់ទំនិញខុសពីទិសដៅកំណត់ ត្រូវសុំការអនុញ្ញាតិពីសមត្ថកិច្ចភូតគាមអនាម័យ។

មុនរយៈពេល១០ថ្ងៃ មុននាំទំនិញចេញ រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលជាម្ចាស់ទំនិញត្រូវដាក់ពាក្យស្នើសុំត្រួតពិនិត្យភូតគាមអនាម័យ មកសមត្ថកិច្ចភូតគាមអនាម័យដែលនៅជិតបំផុត ហើយត្រូវបង្កលក្ខណៈងាយស្រួលដល់ការត្រួតពិនិត្យភូតគាមអនាម័យ។ ក្នុងរយៈពេលនេះ សមត្ថកិច្ចភូតគាមអនាម័យត្រូវបញ្ចប់ការត្រួតពិនិត្យ និងការអនុវត្តនីតិវិធានភូតគាមអនាម័យឱ្យបានចប់សព្វគ្រប់។

ចំពោះទំនិញជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដែលមិនសមស្របតាមល័ក្ខខ័ណ្ឌភូតគាមអនាម័យ នៃប្រទេសនាំចូល ម្ចាស់ទំនិញត្រូវអនុវត្តតាមវិធានភូតគាមអនាម័យនៃប្រទេសនាំចូលនោះ។

ការចំណាយលើវិធានភូតគាមអនាម័យខាងលើ ជាបន្ទុករបស់ម្ចាស់ទំនិញ។

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបានស្នើសុំធ្វើការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញរបស់ខ្លួន ត្រូវបង់សោហ៊ុយ សេវាកម្ម ត្រួតពិនិត្យ ភូតគាម អនាម័យ។ ប្រសិនបើស្នើឱ្យធ្វើការកម្ចាត់សមាភាពចង្រៃនោះ ត្រូវបង់សោហ៊ុយសេវាកម្មកម្ចាត់សមាសភាពចង្រៃនោះ។ សោហ៊ុយ សេវាកម្ម ទាំងនេះ ត្រូវ បង់ ចូល ថវិកាជាតិ តាមរយៈសមត្ថកិច្ចភូតគាមអនាម័យ។

សោហ៊ុយសេវាកម្មត្រួតពិនិត្យភូតគាមអនាម័យ និង សោហ៊ុយ សេវាកម្ម កម្ចាត់ សមាសភាព ចង្រៃ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

Cambodia Pest Control Source ជាក្រុមហ៊ុនទទួលបានសិទ្ធិផ្តល់សេវាគ្រប់គ្រងសត្វល្អិត និងធុបទកម្ម (Fumigation) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

### ដំណើរការស្នើសុំវិញ្ញាបនបត្រអនាម័យ និងភូតគាមអនាម័យ

| | |
|---|---|
| **ជំហានទី១** | **ដាក់ពាក្យសុំ**<br>ដាក់ពាក្យស្នើសុំវិញ្ញាបនបត្រអនាម័យ និងភូតគាមអនាម័យ និងសុំឱ្យមន្ត្រីនាយកដ្ឋានក្សេត្រសាស្ត្រនិងបង្កើនគុណភាពដីកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទធ្វើការត្រួតពិនិត្យទំនិញរបស់លោកអ្នក។ លោកអ្នកត្រូវបង្ហាញបញ្ជីវេចខ្ចប់ វិក្កយបត្រ ប័ណ្ណប៉ាតង់ វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងពាក្យស្នើសុំ។ |
| **ជំហានទី២** | **គោរពតាមការណែនាំ**<br>បន្ទាប់មកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងធ្វើការវាយតម្លៃពីហានិភ័យ ដោយផ្អែកលើហានិភ័យរបស់ផលិតផលដែលរងការបំផ្លាញពីសត្វល្អិត ប្រវត្តិរបស់ក្រុមហ៊ុន ប្រភពដើមរបស់ផលិតផល។ បន្ទាប់មក ក្រសួងនឹងធ្វើការណែនាំ និងប្រាប់ពីល័ក្ខខ័ណ្ឌនាំចេញផលិតផលទាំងនេះពីប្រទេសកម្ពុជា។ |
| **ជំហានទី៣** | **កំណត់ពីការទាមទារធ្វើអធិការកិច្ច និងការធ្វើតេស្តដោយប្រទេសនាំចូល**<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងធ្វើការពិនិត្យថា តើប្រទេសនាំចូលទាមទារធ្វើតេស្ត និងអធិការកិច្ចអ្វីខ្លះ។ បន្ទាប់មក ក្រសួងនឹងរៀបចំធ្វើអធិការកិច្ច និងតេស្តទៅតាមការទាមទារទាំងនោះ។ |

| | |
|---|---|
| ជំហានទី៤ | **រៀបចំធ្វើតេស្តនៅក្នុងមន្ទីរពិសោធន៍**<br>ប្រសិនបើចាំបាច់ ក្រសួងនឹងរៀបចំធ្វើតេស្តនៅក្នុងមន្ទីរពិសោធន៍ យ៉ាងហោចណាស់ឲ្យបានមុនការនាំចេញចំនួន១៥ថ្ងៃ (គិតថ្ងៃធ្វើការប៉ុណ្ណោះ)។ ក្រសួងរៀបចំធ្វើតេស្តដែលចាំបាច់ទាំងអស់ ប៉ុន្តែលោកអ្នកគួរធ្វើការជូនដំណឹងជាមុន។ |
| ជំហានទី៥ | **ធ្វើធុបទកម្មទំនិញនាំចេញ**<br>ប្រសិនបើចាំបាច់ ក្រសួងនឹងមានរៀបចំធ្វើធូបទកម្ម យ៉ាងហោចណាស់ឲ្យបានមុនការនាំចេញចំនួន១៥ថ្ងៃ (គិតថ្ងៃធ្វើការប៉ុណ្ណោះ)។ ដំណើរការធូបទកម្មត្រូវចំណាយពេលចំនួន៩៦ម៉ោង។ ក្រសួងនឹងធ្វើការត្រួតពិនិត្យក្រោយពេលធ្វើធូបទកម្ម ដើម្បីកំណត់ថាតើចាំបាច់ត្រូវធ្វើធូបទកម្មម្តងទៀតដែរឬ ទេ។ |
| ជំហានទី៦ | **នាំចេញផលិតផល**<br>បន្ទាប់មក ក្រសួងនឹងចេញវិញ្ញាបនបត្រធូបទកម្ម (Fumigation Certificate) វិញ្ញាបនបត្រនេះបញ្ជាក់ពីប្រភេទទំនិញ ការបរិច្ឆេទ និងប្រភេទថ្នាំដែលប្រើនៅពេលធ្វើប្រព្រឹត្តកម្ម។ ក្រោយពីលោកអ្នកទទួលបានវិញ្ញាបនបត្រធូបទកម្ម មានន័យថាទំនិញរបស់លោកអ្នកបានទទួលការពិនិត្យអនាម័យ និងភូតគាមអនាម័យ និងអាចធ្វើការនាំចេញបានហើយ។ |

## ៣.៣.៦. កំណត់សម្គាល់

- ការធ្វើរោគវិនិច្ឆ័យ ត្រូវចំណាយពេលរង់ចាំ ពី១ថ្ងៃ ដល់ ៥ថ្ងៃ
- ការធ្វើធូបទកម្ម ត្រូវចំណាយពេលរង់ចាំ ពី៣ថ្ងៃ ដល់ ៧ថ្ងៃ

## ៣.៣.៧. ព័ត៌មានបន្ថែមសម្រាប់ការទារភូតគាមអនាម័យ

សូមអានការណែនាំស្តីពីនីតិវិធីសុំវិញ្ញាបនបត្រភូតគាមអនាម័យ (សម្រាប់ការនាំចេញ ឬ បន្តការនាំចេញ) ឬ សូមពិនិត្យមើលគេហទំព័រនៃអនុសញ្ញាការពារដំណាំអន្តរជាតិ ÷

http://www.ippc.int/ipp/en/default.jsp

ឬ គេហទំព័រស្តីពីវិធានការអនាម័យ និងភូតគាមអនាម័យ របស់អង្គការពាណិជ្ជកម្មពិភពលោក ÷

http://www.wto.org/english/tratpo_e/sps_tratp_e.htm

ឬ សូមទំនាក់ទំនងផ្ទាល់ អគ្គនាយកដ្ឋានកសិកម្ម (នាយកដ្ឋានការពារដំណាំអនាម័យ និងភូតគាមអនាម័យ) អាស័យដ្ឋានៈ អាគារលេខ៥៤បេ-49 អេស ផ្លូវលេខ៣៩៥ កែងផ្លូវលេខ៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៨៥ ៤៨២

ទូរសារលេខ: (៨៥៥) ២៣ ២៣៨ ៨៣២/២៦៧

សារអេឡិចត្រូនិក: ppspsdcam@online.com.kh

# ឧបសម្ព័ន្ធ

ក. ច្បាប់ និងបទប្បញ្ញត្តិ ពាក់ព័ន្ធនឹងបែបបទបញ្ចេញទំនិញពីគយ

ខ. តារាងតម្លៃ

គ. បញ្ជីទំនាក់ទំនងតាមក្រសួងពាក់ព័ន្ធ

ឃ. យោង

## ឧបសម្ព័ន្ធ ក. ច្បាប់ និងបទប្បញ្ញត្តិ ពាក់ព័ន្ធនឹងបែបបទបញ្ចេញទំនិញពីគយ

**បញ្ជីរាយអំពីច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ**

### ច្បាប់

១. ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសអោយប្រើដោយព្រះរាជក្រមលេខ០៣ នស ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤

២. ច្បាប់វិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០០៣

៣. ច្បាប់ស្តីពីគយ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧

### អនុក្រឹត្យ

៤. សារាចរលេខ០៣សរ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីបែបបទនិងនីតិវិធីនៃការស្នើសុំរួចពន្ធឧបករណ៍សម្ភារនាំចូល ក្នុងក្របខ័ណ្ឌជំនួយឥតសំណងឥណទាន និងជំនួយមនុស្សធម៌

៥. អនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់វិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

៦. អនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

៧. អនុក្រឹត្យលេខ២០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់អោយប្រើប្រាស់បញ្ជីទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់

៨. អនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ នាយកដ្ឋានពន្ធដារ និងនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៩. អនុក្រឹត្យលេខ១៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

១០. អនុក្រឹត្យលេខ២០៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១១ ស្តីពីការកែសម្រួលលើកំណត់សម្គាល់II ឧបសម្ព័ន្ធ២ នៃអនុក្រឹត្យលេខ២០៩ អនក្រ.បកចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់

១១. អនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ប្រកាស និងលិខិតរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១២. ប្រកាសលេខ០១៣ ប្រក.សហវ.គរ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្តីពីនីតិវិធីក្នុងការនាំចេញ-នាំចូលរូបិយប័ណ្ណបរទេស

១៣. លិខិតលេខ១១០ សជណ.ផស ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៩ ស្តីពីករណីអនុវត្តអាករលើតម្លៃបន្ថែម (VAT) លើធាតុចូលដែលនាំចូលដោយរោងចក្រផលិតសំលៀកបំពាក់សម្រាប់នាំចេញ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

១៤. លិខិតលេខ០០៥ សហវ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០០ ស្តីពីការកែសំរួលបែបបទគ្រប់គ្រងការនាំចូលទំនិញតាមរបបអាគារលក់ទំនិញរួចពន្ធ Duty Free Shop

១៥. លិខិតលេខ៦៧៣៨ កបទ.សអ/ច្ប.ក៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីការអនុញ្ញាតនាំយកសាកសពជនបរទេសចេញពីព្រះរាជាណាចក្រកម្ពុជា

១៦. សេចក្តីណែនាំលេខ០១៦ សហវ.សជណ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៤ សេចក្តីជូនដំណឹង ស្តីពីការកែសំរួលនីតិវិធីនាំចេញលើមុខទំនិញវាយនភ័ណ្ឌ

១៧. សេចក្តីណែនាំលេខ៨៦៨៣ សហវចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការបង្កើតការិយាល័យសហព័ទ្ធរវាងអង្គភាពគយ និងរដ្ឋាករនិងកាំកុងត្រូល របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១៨. សារាចរណែនាំលេខ០០៩ សហវ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងទំនិញនាំចូលគ្មានលក្ខណៈពាណិជ្ជកម្ម

១៩. ប្រកាសលេខ១៤៤៧ សហវ.ប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីបញ្ញត្តិនិងនីតិវិធីប្រតិវេទន៍គយ

២០. ប្រកាសលេខ១០៥ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងទំនិញដែលត្រូវបានលើកលែងពន្ធ និងអាករ

២១. ប្រកាសលេខ១០៦ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីសន្និធិគយបណ្តោះអាសន្ន

២២. ប្រកាសលេខ១០៧ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការរាយការណ៍ការធ្វើចរាចរ ការធ្វើសន្និធិ និងការដឹកជញ្ជូនទំនិញនាំចេញ

២៣. ប្រកាសលេខ១០៩ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងទំនិញគ្មានការទាមទារ

២៤. ប្រកាសលេខ១១១ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការអនុញ្ញាតឱ្យបំពេញទម្រង់ការគយនៅក្រៅការិយាល័យគយ

២៥. ប្រកាសលេខ១១៤ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការកំណត់មុខទំនិញដែលត្រូវលើកលែងពន្ធនិងអាករ

២៦. ប្រកាសលេខ១១៦ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីភណ្ឌាគារគយមានដែនកំណត់

២៧. ប្រកាសលេខ៣៨៧ សហវ គរ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការកំណត់តម្លៃគិតពន្ធគយលើទំនិញនាំចូលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

២៨. ប្រកាសលេខ៥០៨ សហវ.ប្រក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការឆ្លងកាត់គយ

២៩. ប្រកាសលេខ៧៣៤ សហវ.ប្រក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីនីតិវិធីគយពិសេសសម្រាប់អនុវត្តក្នុងតំបន់សេដ្ឋកិច្ចពិសេស

៣០. ប្រកាសលេខ៩២៨ សហវ.ប្រក ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការនាំចូលបណ្តោះអាសន្នតាមរបបប្រវេសន៍កាលិក

៣១. លិខិតលេខ៣៨៤១ សហវចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការលើកលែងអាករលើតម្លៃបន្ថែម (VAT) សម្រាប់វិនិយោគិនក្នុងតំបន់សេដ្ឋកិច្ចពិសេស (SEZ)

៣២. ប្រកាសលេខ៦១៨ សហវ.ប្រក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីការសម្រុះសម្រួលបទល្មើសគយ

៣៣. សារាចរណែនាំលេខ០០៧ សហវ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងការនាំចេញនាំចូលទំនិញមួយចំនួនតាមរូបភាពតូច

៣៤. ប្រកាស៩០៧ សហវ.ប្រក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៩ ស្តីពីការកំណត់កម្រៃឆ្លងកាត់លើមុខទំនិញមួយចំនួនដែលស្ថិតក្រោមនីតិវិធីឆ្លងកាត់

៣៥. ប្រកាសលេខ៣៨៩ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពមូលដ្ឋាននៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

៣៦. ប្រកាសលេខ៣៧២៥ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការបន្តព្យួរបណ្តោះនូវអាករលើតម្លៃបន្ថែម (VAT) សម្រាប់វិនិយោគិនក្នុងតំបន់ពិសេសពិសេស (SEZ) រហូតដល់មានការសម្រេចជាថ្មី

៣៧. ប្រកាសលេខ៥៦៩ សហវ.ប្រក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១០ ស្តីពីការត្រួតពិនិត្យទំនិញនាំចេញទំនិញនាំចូល និងមធ្យោបាយដឹកជញ្ជូន

៣៨. ប្រកាសលេខ៥៧០ សហវ.ប្រក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១០ ស្តីពីនីតិវិធីតវ៉ាប្រឆាំងកំណត់ហេតុគយ

៣៩. ប្រកាសលេខ៥៧២ សហវ.ប្រកចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១០ ស្តីពីការរាយការណ៍អំពីទំនិញនាពេលចូលក្នុងដែនគយនៃព្រះរាជាណាចក្រកម្ពុជា

៤០. លិខិតលេខ១១១៤ អគរ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការកែសំរួលនីតិវិធី និងតំរូវការឯកសារសំរាប់ការត្រួតពិនិត្យបែបបទគយ លើទំនិញវាយនភ័ណ្ឌនិងកាត់ដេរនាំចូលត្រឡប់មកវិញក្រោយពីបាននាំចេញ

៤១. សេចក្តីសំរេច០០៩ សហវ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១១ ស្តីពីការបង្កើតនិងកិច្ចដំណើរការប្រព័ន្ធទិន្នន័យគ្រប់គ្រងហានិភ័យ

៤២. សារាចរណែនាំលេខ០០៤ សហវ.ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២ ស្តីពីនីតិវិធីគយចំពោះទំនិញតម្លៃទាប

៤៣. ប្រកាសលេខ០០២ សហវ.ប្រក.អគរ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៣ ស្តីពីវិធានបញ្ជាក់ជាមុនលើចំណាត់ថ្នាក់ទំនិញតាមតារាងពន្ធគយ ដើមកំណើតទំនិញ និងតម្លៃគិតពន្ធគយ

៤៤. ប្រកាសលេខ ៤៥២សហវ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣ ស្តីពីយន្តការលើកទឹកចិត្តជូនធុរជនមានអនុលោមភាពខ្ពស់

៤៥. ប្រកាសអន្តរក្រសួងលេខ៥៨១ សហវ និងលេខ១២៧៦ ក.អ.ក/គ.ជ.នា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីបែបបទនិងនីតិវិធីនៃការស្នើសុំនាំចូលឧបករណ៍សម្ភារគ្រឿងចក្រយានយន្តនិងផលិតផលតេលសិលា ដោយពន្ធនិងអាករជាបន្ទុករបស់រដ្ឋ ក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណង

៤៦. ប្រកាសលេខ៣១១ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែមចំពោះឧស្សាហកម្មគាំទ្រ ឬអ្នកចុះកិច្ចសន្យាដែលធ្វើការផ្គត់ផ្គង់ទំនិញ ឬសេវាសម្រាប់បម្រើឱ្យការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរ និងកាបូបដៃ និងឧស្សាហកម្មផលិតមួក

៤៧. លិខិតលេខ៣១៦សហវ (១៩០៣២០១៥) ការកែសម្រួលកម្រៃត្រួតពិនិត្យដោយម៉ាស៊ីនស្កែន

៤៨. លិខិតប្រគល់សិទ្ធិលេខ០០៥សហវ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៥

## លិខិត និងសេចក្តីណែនាំរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

៤៩. សេចក្តីណែនាំលេខ ៨២២ គ.រ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែសំរួលមុខសញ្ញាប្រើប្រាស់នូវប្រភេទខ្សែចំណង SEAL គយសំរាប់កិបចំណាំលើទ្វារកុងតឺន័រទំនិញនាំចេញ ឬនាំចូល សំរាប់ករណីចាំបាច់នានារបស់ការិយាល័យនាំចេញផែស្ងួតនិងសាខាគយនិងរដ្ឋាករក្រុងព្រះសីហនុ របស់ទីចាត់ការគយនិងរដ្ឋាករ

៥០. លិខិតលេខ១០០៦គរ ចុះថ្ងៃទី២១ខែធ្នូឆ្នាំ២០០៤ ស្តីពីបែបបទគ្រប់គ្រងការនាំចូលទំនិញតាមរបបអាគារលក់ទំនិញរួចពន្ធ Duty Free Shop

៥១. សេចក្តីណែនាំលេខ៧៤១គរ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីទំនិញសំលៀកបំពាក់នាំចេញទៅកាន់ទីផ្សារសហគមន៍អឺរ៉ុប លក់ជូនក្រុមហ៊ុន DuPont គ្មានស្លាកសញ្ញា "Made in Cambodia" នៅលើសំបកកាតុងរបស់ទីចាត់ការគយនិងរដ្ឋាករកម្ពុជា

៥២. សេចក្តីណែនាំលេខ៧៩០ គរ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ របស់ទីចាត់ការគយនិងរដ្ឋាករ ស្តីពីនីតិវិធីនៃការឆ្លងកាត់គយ

៥៣. លិខិតលេខ ៨៣៥ គរ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៨ របស់ទីចាត់ការគយនិងរដ្ឋាករ ស្តីពីការដកគំរូទំនិញនាំចេញ

៥៤. សេចក្តីណែនាំលេខ ១០៩០ អគរ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ស្តីពីការអនុវត្តនីតិវិធីនៃការឆ្លងកាត់គយ

៥៥. សេចក្តីណែនាំលេខ៥៤៨អគរ ចុះថ្ងៃទី២២ខែឧសភាឆ្នាំ២០០៩ ស្តីពីការកំណត់នីតិវិធីសម្រាប់ការត្រួតពិនិត្យបែបបទគយលើទំនិញវាយនភ័ណ្ឌនាំចូលត្រឡប់មកវិញ ក្រោយពីបាននាំចេញ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

៥៦. សេចក្តីណែនាំលេខ១៣០៨អគរ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីនីតិវិធីលំអិត និងភារកិច្ចទទួលខុសត្រូវក្នុងដំណើរការប្រតិវេទន៍គយ

៥៧. លិខិតលេខ៥៤៦ អគរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ស្តីពីការសម្រួលពាណិជ្ជកម្មបន្ថែមទៀត ដល់វិស័យឯកជនក្នុងការបំពេញបែបបទគយ

៥៨. លិខិតលេខ៦៥៣ អគរ ចុះថ្ងៃទី០២ ខែ សីហា ឆ្នាំ២០១១ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ស្តីពីការសម្រួលនីតិវិធីគយសម្រាប់ការដឹកទំនិញចេញពីតំបន់សេដ្ឋកិច្ចពិសេស មកបណ្តាផែស្ងួតដើម្បីបញ្ចូលក្នុងកុងតឺន័រួមគ្នាជាមួយនឹងទំនិញផ្សេង ដើម្បីនាំចេញទៅបរទេស

៥៩. សេចក្តីណែនាំលេខ១១១៤ អគរ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការកែសំរួលនីតិវិធីនិងតំរូវការឯកសារ សំរាប់ការត្រួតពិនិត្យបែបបទគយលើទំនិញវាយនភ័ណ្ឌនិងកាត់ដេរនាំចូលត្រឡប់មកវិញក្រោយពីបាននាំចេញ

៦០. សេចក្តីណែនាំលេខ៣៤៥ អគរ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៣ស្តីពីការអនុវត្តវិធានបញ្ជាក់ជាមុនលើចំណាត់ថ្នាក់ទំនិញតាមតារាងពន្ធគយ

៦១. សេចក្តីណែនាំលេខ៣៤៦ អគរ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៣ស្តីពីការអនុវត្តវិធានបញ្ជាក់ជាមុនលើតម្លៃគិតពន្ធគយ

៦២. លិខិតលេខ១៣៥៨ អគរ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការសំរួលពាណិជ្ជកម្មបន្ថែមដល់វិនិយោគិនក្នុងតំបន់សេដ្ឋកិច្ចពិសេស

៦៣. សេចក្តីសម្រេចលេខ ២៧៨ អគរ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការផ្តល់ប្រព្រឹត្តកម្មលើកទឹកចិត្តជូនធុរជនល្អ

៦៤. សេចក្តីសម្រេចលេខ២៧៩ អគរចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការបង្កើតអង្គភាពគ្រប់គ្រងធុរជនល្អ

៦៥. លិខិតលេខ៥១៦ អគរ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤ ស្តីពីការលើកលែងកម្រៃបែបបទគយ (Customs Processing Fee-CPF) លើការនាំចេញអង្ករ

៦៦. លិខិតលេខ៧៩០ អគរ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការផ្តល់ប្រព្រឹត្តកម្មលើកទឹកចិត្តជូនធុរជនល្អបំផុត

៦៧. លិខិតលេខ១៤៨៩ អគរ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីនីតិវិធីនៃការអនុវត្តយន្តការឃ្លាំមើលអនុលោមភាពធុរជនល្អបំផុត

៦៨. លិខិតលេខ១៨៦៧ អគរ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តនីតិវិធីគយតាមបណ្តាផែស្ងួត

៦៩. លិខិតលេខ១៨៦៨ អគរ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់ម៉ាស៊ីនស្កេនកុងតែន័រនៅការិយាល័យគយនិងរដ្ឋាករបាវិត

៧០. សេចក្តីណែនាំស្តីលេខ ២១៧៥ អគរចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តវិធានបញ្ជាក់ជាមុនលើដើមកំណើតទំនិញ

៧១. លិខិតលេខ៣៩៣ អគរ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ស្តីពីការអនុវត្តអាករពិសេសសម្រាប់ការនាំចូលទំនិញមួយចំនួនដែលជាធាតុចូល ផលិតកម្មវិស័យកាត់ដេរ និងឧស្សាហកម្មទ្រទ្រង់វិស័យកាត់ដេរ

៧២. លិខិតលេខ៧៥៨ អគរ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការអនុវត្តអាករពិសេសសម្រាប់ការនាំចូលទំនិញមួយចំនួនដែលជាធាតុចូល ផលិតកម្មនិងឧស្សាហកម្មទ្រទ្រង់ ផលិតកម្មបម្រើការនាំចេញរបស់វិនិយោគិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

៧៣. លិខិតលេខ ៧៧៣ អគរ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ស្តីពីការកំណត់បរិមាណទំនិញឬ សម្ភារប្រើប្រាស់ផ្ទាល់ខ្លួន ដែលអាចយកតាមខ្លួនបាន ដោយលើកលែងពន្ធនិងអាករផ្សេងៗរបស់អ្នកដំណើរ អ្នកបម្រើការតាមមធ្យោបាយដឹកជញ្ជូន និង ជនទាំងឡាយដែលឆ្លងកាត់ព្រំដែន

# ឧបសម្ព័ន្ធ ខ. តារាងតម្លៃ

| ល.រ | បរិយាយ | តម្លៃ | កម្រៃសេវា | រយៈពេល (ថ្ងៃធ្វើការ) |
|---|---|---|---|---|
| ១ | សោហ៊ុយដំណើរការប្រតិបត្តិការគយ (CPF) | | | |
| | ១ កុងតឺន័រ (20 ហ្វីត+) | ៦0,000 រៀល | 0 | ១-២ថ្ងៃ |
| | ប្រកាសគយទំនិញផលិតផលគេលសិលា ពិតប្រាកដ | ៦0,000 រៀល | 0 | ១-២ថ្ងៃ |
| | ប្រកាសគយទំនិញក្រៅកុងតឺន័រនៃទំនិញ ក្នុងកុងតឺន័រខ្នាតតូច<20 ហ្វីត | ៤0,000 រៀល | 0 | ១-២ថ្ងៃ |
| ២ | សោហ៊ុយត្រួតពិនិត្យកុងតឺន័រតាមប្រព័ន្ធធីអេចស្កេន | | | |
| | ១ កុងតឺន័រ (<40 ហ្វីត) | ២០ដុល្លារអាមេរិច | 0 | ១-២ថ្ងៃ |
| | ១ កុងតឺន័រ (>40 ហ្វីត) | ៣២ដុល្លារអាមេរិច | 0 | ១-២ថ្ងៃ |
| ៣ | សោហ៊ុយអជ្ញាប័ណ្ណសន្និធិគយបណ្តោះអាសន្ន (មួយឆ្នាំ) | ២០,000,000 រៀល | 0 | ១-២ថ្ងៃ |
| ៤ | សោហ៊ុយសម្រាប់រក្សាទំនិញក្នុងសន្និធិគយបណ្តោះអាសន្ន បន្ទាប់ពីហួសកាលកំណត់ (មួយថ្ងៃ) | 0.១% នៃថ្លៃត្រូវគណនាពន្ធគយ | 0 | ភ្លាមៗ |
| ៥ | សោហ៊ុយឆ្លងកាត់ | | | |
| | គោ ក្របី និងសេះ (នៅរស់) | ២០,000 រៀល | 0 | ភ្លាមៗ |
| | ជ្រូក ចៀម និងពពែ (នៅរស់) | ៥,000 រៀល | 0 | ភ្លាមៗ |
| | បក្សាបក្សី (មាន់ ទា) (មួយគីឡូក្រាម) | ៥00 រៀល | 0 | ភ្លាមៗ |
| | ផលិតផលជលផល (មួយគីឡូក្រាម) | ៥00 រៀល | 0 | ភ្លាមៗ |
| ៦ | កំណត់តម្លៃទំនិញនាំចូលសម្រាប់ហាងរួចពន្ធ | ១០% នៃថ្លៃត្រូវគណនាពន្ធគយ | 0 | ភ្លាមៗ |
| ៧ | លក់ប្រកាសគយ (មួយលើក) | 0 | ១៥,000 រៀល | ភ្លាមៗ |
| ៨ | ពន្ធប្រថាប់ត្រាសម្រាប់យានយន្ត (មួយលើក) | 0 | ៣០,000 រៀល | ១-២ថ្ងៃ |
| ៩ | លក់ត្រាពន្ធគយ (មួយទំព័រ) | 0 | ៥០រៀល | ១-២ថ្ងៃ |
| ១០ | ពន្ធប្រថាប់ត្រា (បិទលើប្រអប់បារី) (មួយទំព័រ) | 0 | ៤.២រៀល | ១-២ថ្ងៃ |
| ១១ | លិខិតអនុញ្ញាតិដឹកជញ្ជូនសន្និធិ (មួយទំព័រ) | 0 | ៥០០រៀល | ភ្លាមៗ |
| ១២ | លក់ត្រាបិទលើកុងតឺន័រ (មួយ) | 0 | ៨,000 រៀល | ១-២ថ្ងៃ |

# ឧបសម្ព័ន្ធ គ. បញ្ជីទំនាក់ទំនងតាមក្រសួងពាក់ព័ន្ធ

## ក្រសួងពាណិជ្ជកម្ម
ឡូតិ៍លេខ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (ផ្លូវលេខ១១៣បេ) បត់ចូលពីមហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ&ទូរសារ : ០២៣ ៨៦៦ ៤២៥

ទូរស័ព្ទចល័ត : ០៧៧ ៦៧៧ ៥៩៩ / ០១២ ៩៣៤ ០៨៨

អ៊ីមេល : info@moc.gov.kh / moc.gov.kh@gmail.com

គេហទំព័រ : www.moc.gov.kh

## អគ្គនាយកដ្ឋានកាំកុងត្រូល
ឈ្មោះពេញជាផ្លូវការៈ អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញអាហ័រណ នីហ័រណ និងបង្ក្រាបការក្លែងបន្លំ ភូមិក្តីតាកុយ សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ&ទូរសារ : ០២៣ ៤២៦ ១៦៦

អ៊ីមេល : ccdg@camcontrol.gov.kh

គេហទំព័រ : www.camcontrol.gov.kh

## ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ដីឡូតិ៍លេខ៦០ ផ្លូវលេខ៩២ កែងផ្លូវលេខ១១៣ និងផ្លូវលេខ១០៦ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ១២២០២

ទូរស័ព្ទ : ០២៣ ៧២៤ ៦៦៤

ទូរសារ : ០២៣ ៤២៧ ៧៩៨

អ៊ីមេល : admin@mef.gov.kh

គេហទំព័រ : www.mef.gov.kh

## អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
ដីឡូតិ៍លេខ៦-៨ មហាវិថីព្រះនរោត្តម (៤១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ១២២០២

ទូរស័ព្ទ&ទូរសារ: ០២៣ ២១៤ ០៦៥

អ៊ីមេល : info-pru@customs.gov.kh

គេហទំព័រ : www.customs.gov.kh

## ក្រសួងបរិស្ថាន
អគារលេខ៤៨ មហាវិថីព្រះសីហនុ (២៧៤) ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ១២៣០១

ទូរស័ព្ទ : ០២៣ ៤២៧ ៨៩៤ / ០២៣ ២១៣ ៩០៨ / ០២៣ ២១២ ៩៩៤

ទូរសារ : ០២៣ ៤២៧ ៨៤៤ / ០២៣ ២១២ ៥៤០ / ០២៣ ២១៥ ៩២៥

អ៊ីមេល : moe-cabinet@camnet.com.kh

គេហទំព័រ : www.moe.gov.kh

## ក្រសួងសុខាភិបាល

អាគារលេខ៨០ វិថីសម្តេចប៉ែននុត សង្កាត់បឹងកក់៣ ខណ្ឌទួលគោក ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : ០២៣ ៨៨១ ៤០៨ / ០២៣ ៤២៦ ៦៧២ / ០២៣ ៨៨១ ៤០៥ / ០២៣ ៧២៥ ៨៣៣ / ០២៣ ៨៨២ ៣១៧ / ០២៣ ៨៨១ ៤០៩

ទូរសារ : ០២៣ ៤២៦ ៨៤១

អ៊ីមែល : PR@online.com.kh

អ៊ីមែល : moh_cabinet@online.com.kh

គេហទំព័រ : www.moh.gov.kh

## ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ដីឡូត៍លេខ ៤៥ មហាវិថីព្រះនរោត្តម (៤១) ១២២០៥

ទូរស័ព្ទ : ០២៣ ២២២ ៥០៤

អ៊ីមែល : industry@camnet.com.kh

គេហទំព័រ : www.mih.gov.kh

## ក្រសួងមហាផ្ទៃ

ដីឡូត៍លេខ២៧៥ មហាវិថីព្រះនរោត្តម (៤១) ១២៣០១ ភ្នំពេញ

ទូរស័ព្ទ : ០២៣ ៧២៦ ២៣៩ / ០២៣ ៧២៦ ០៥៣

ទូរស័ព្ទ&ទូរសារ: ០២៣ ៧២១ ៩០៥ / ០២៣ ២៧១ ១៩០

ទូរសារ : ០២៣ ៧២៦ ០៥២ / ០២៣ ២១៩ ៣៩០

អ៊ីមែល : moi@interior.gov.kh

អ៊ីមែល : info@interior.gov.kh

គេហទំព័រ : www.interior.gov.kh

## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ដីឡូត៍លេខ ២០០ មហាវិថីព្រះនរោត្តម (៤១) ១២៣០១ ភ្នំពេញ

ទូរស័ព្ទ : ០២៣ ៧២៦ ១២៨ / ០២៣ ៧២៦ ១២៩

ទូរសារ : ០២៣ ២១៧ ៣២០

អ៊ីមែល : info@maff.gov.kh

គេហទំព័រ : www.maff.gov.kh

## ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ដីឡូត៍លេខ៣ វិថីអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : ០២៣ ២១៤ ៤៤១ / ០២៣ ២១៦ ១២២ / ០២៣ ២២៤ ៩៧៣

ទូរសារ : ០២៣ ២១៦ ១៤៤ / ០២៣ ២១៦ ១៤១

អ៊ីមែល : mfaic@mfa.gov.kh

គេហទំព័រ : www.mfaic.gov.kh

## ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ផ្លូវលេខ១៣ កែងផ្លូវ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ភ្នំពេញ
ទូរស័ព្ទ : ០២៣៧២៤ ៨០៩/ ០២៣៤២៨ ២៤៦
អ៊ីមេល : info@mptc.gov.kh
គេហទំព័រ : www.mptc.gov.kh

## ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា - CDC

វិមានរដ្ឋាភិបាល វិថីព្រះស៊ីសុវត្ថិ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ &ទូរសារៈ ០២៣ ៤២៧ ៥៩៧ / ០២៣ ៤២៣ ៩៥៤
អ៊ីមេល : info@cambodiainvestment.gov.kh
គេហទំព័រ : www.cambodiainvestment.gov.kh

## ធនាគារជាតិនៃកម្ពុជា

ដីឡូតិ៍លេខ២២-២៤ មហាវិថីព្រះនរោត្តម (៤១) ១២២០៣ ភ្នំពេញ
ទូរស័ព្ទ : ០២៣ ៧២២ ២២១ / ០២៣ ៧២៥ ០០៥
ទូរសារ : ០២៣ ៤២៦ ១១៧
អ៊ីមេល : info@nbc.org.kh
អ៊ីមេល : nbc@online.com.kh
ប្រអប់ប្រៃសណីយ៍ : 25
គេហទំព័រ : www.nbc.org.kh

## កំពង់ផែស្វយ័តក្រុងព្រះសីហនុ

តិរៈវិថីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
ទូរស័ព្ទ : ០៣៤ ៩៣៣ ៥១១ / ០៣៤ ៩៣៣ ៤១៦
ទូរសារ : ០៣៤ ៩៣៣ ៩១៧ / ០៣៤ ៩៣៣ ៦៩៣
ទូរស័ព្ទចល័ត : ០១៦ ៣៤៥ ២២៨ / ០១២ ៨៣១ ៧៨៤
អ៊ីមេល : pasinfo@pas.gov.kh / spsez@pas.gov.kh
គេហទំព័រ : www.pas.gov.kh

## កំពង់ផែស្វយ័តភ្នំពេញ

ដីឡូតិ៍លេខ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ ១២២០១ ភ្នំពេញ
ទូរស័ព្ទ : ០២៣ ៤២៨ ៧៦២
ទូរស័ព្ទ&ទូរសារៈ ០២៣ ៤២៧ ៨០២
អ៊ីមេល : ppapmpwt@online.com.kh
គេហទំព័រ : www.ppap.com.kh

# ឧបសម្ព័ន្ធ ឃ. យោង

១. អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ដីឡូត៍លេខ៦-៨ មហាវិថីព្រះនរោត្តម (៤១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ១២២០២
ទូរស័ព្ទ : +៨៥៥ ២៣២១៤០៦៥
ទូរសារ : +៨៥៥ ២៣២១៤០៦៥
អ៊ីមែល : info-pru@customs.gov.kh
គេហទំព័រ : www.customs.gov.kh

២. ក្រសួងពាណិជ្ជកម្ម
ឡូលេខ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម(ផ្លូវលេខ១១៣បេ) ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : ០២៣ ៨៦៦ ៤២៥ / ០៧៧ ៦៧៧ ៥៩៩
អ៊ីមែល : moc.gov.kh@gmail.com
គេហទំព័រ :http://www.moc.gov.kh/en-us/certificate-of-origin
សៀវភៅមគ្គុទេសក៍នីតិវិធីនាំចេញ (លេខថ្មី)

៣. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
សៀវភៅមគ្គុទេសក៍វិនិយោគកម្ពុជា
http://www.cambodiainvestment.gov.kh/#fragment-3-tab

៤. សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC)
http://www.gmac-cambodia.org/legal/




JICA

Japan
Fund for
Poverty
Reduction

JAPAN
Official Development Assistance